**engkau** /អឹងកាវ/ *pron* អ្នក: *អ្នកគឺជាមនុស្សដែលខ្ញុំស្រលាញ់ engkau yang kucinta (អឹងកាវ យ៉ាំង គូជិនតា)*

**enteng** /អែនតិង/ *a* ស្រាល: *វ៉ាលីរបស់គាត់ស្រាល kopernya enteng (កូពើរ(r)ញ៉ា អែនតិង)*

**erat** /អេរ៉ាត់/ *a* តឹង; ណែន: *នាងកាន់កាបូបរបស់នាងយ៉ាងណែន dia memegang tasnya erat (ឌីយ៉ា មើមើហ្គាំង តាស់(ស)ញ៉ា អេរ៉ាត់)*;

**erat-erat** /អេរ៉ាត់-អេរ៉ាត់/ *a* យ៉ាងតឹង: *ក្មេងម្នាក់នោះបានចងខ្សែស្បែកជើងរបស់វាយ៉ាងតឹង anak itu mengikat tali sepatunya erat-erat (អាណាក់ អ៊ីទូ មើងីកាត់ តាលី សើប៉ាទូញ៉ា អេរ៉ាត់-អេរ៉ាត់)*;

**mempererat** /មើមពើរ(r)អេរ៉ាត់/ *v* ពង្រឹង: *គាត់ចង់ពង្រឹងទំនាក់ទំនងរបស់គាត់ជាមួយនឹងម្តាយរបស់គាត់ dia ingin mempererat hubungannya dengan ibunya (ឌីយ៉ា អ៊ីងិន មើមពើរ(r)អេរ៉ាត់ ហ៊ូប៊ូង៉ាន់ ឌើង៉ាន់ អ៊ីប៊ូញ៉ា)*

**mengerti** /មើុងើរ(r)ទី/ *v* យល់; យល់ច្បាស់: *ខ្ញុំយល់ការពន្យល់របស់គាត់ saya mengerti penjelasannya (សាយ៉ា មើងើរ(r)ទី ប៉ើនជើឡាសាន់ញ៉ា)*

**esok** /បែសុក/ *n* ថ្ងៃស្អែក: *ខ្ញុំនឹងធ្វើវានៅថ្ងៃស្អែក saya akan mengerjakannya esok (សាយ៉ា អាកាន់ មើងើរ(r)ច្យាកាន់ញ៉ា បែសុក)*

**fakir, fakir miskin** /ហ្វាគីរ(r) មីស្គិន/ *n* ជនក្រីក្រ:

*គាត់បានផ្ដល់សម្លៀកបំពាក់ដល់ជនក្រីក្រ dia memberikan pakaian kepada fakir miskin (ឌីយ៉ា មើមបើរីកាន់ ប៉ាកៃយ៉ានញ៉ា គើប៉ាដា ហ្វាគីរ(r) មីស្គិន)*

**fasih** /ហ្វាស៊ិស(s)/ *a* ស្ទាត់ជំនាញ:

*វាអាចថ្លែងសន្ទរកថាជាភាសាអង់គ្លេសបានយ៉ាងស្ទាត់ជំនាញ ia dapat berpidato dl bahasa Inggris dengan lancar dan fasih (យ៉ា ដាប៉ាត់ បើរ(r)ពីដាតូ ដាឡាម បាហាសា អ៊ិងគ្រិស(s) ឌើង៉ាន់ ឡាន់ចា្ជរ(r) ដាន់ ហ្វាស៊ិស(s))*

**firasat** /ហ្វីរ៉ាសាត់/ *n* ប្រថ្នូល: *ប្រថ្នូលមិនល្អ firasat buruk (ហ្វីរ៉ាសាត់ ប៊ូរុក)*

**fitnah** /ហ្វីណាស់(s)/ *n* បរិហារកេរ្ដិ៍; ពាក្យបង្ខូច:

*គាត់បានផ្សប់ផ្សាយពាក្យបង្ខូចអំពីមិត្តរបស់គាត់ dia menyebar fitnah tentang temannya (ឌីយ៉ា មើនញើបារ(r) ហ្វីណាស់(s) តិនតាំង ទើម៉ាន់ញ៉ា)*

**foto** /ហ្វូតូ/ *n* រូបថត: *ស៊ុមរូបថត pigura foto (ពីហ្គូរ៉ា ហ្វូតូ)*

**gading** /ហ្គាឌិង/ *n* ភ្លុក:
*គ្មានភ្លុកណាដែលមិនចេះប្រេះស្រាំនោះទេ tak ada gading yg tak retak (តាក់ អាដា ហ្គាឌិង យ៉ាំង តាក់ រ៉េតាក់)*

**gadis** /ហ្គាឌិស(s)/ *n* ស្រី:
*ស្រីដែលស្លៀកពាក់ពណ៌ក្រហម gadis berbaju merah (ហ្គាឌិស(s) ប៊ើរ(r)បាជូ មើរ៉ះ)*

**gaduh** /ហ្គាឌុះ/ *a* ក្អូកក្អាំង: *ខ្ញុំឮសម្លេងក្អូកក្អាំង saya mendengar suara gaduh (សាយ៉ា មើនឌើង៉ារ(r) ស៊ូអ៉ារ៉ា ហ្គាឌុះ)*

**gagal** /ហ្គាហ្គាល់/ *v* បរាជ័យ; ធ្លាក់:
*វាធ្លាក់ក្នុងការប្រលងនោះ dia gagal dalam ujian itu (ឌីយ៉ា ហ្គាហ្គាល់ ដាឡាម អ៊ូជីយ៉ា អ៊ីទូ)*

**gagap** /ហ្គាហ្គាប់/ *n និយាយរអាក់រអួល:*
*គាត់និយាយរអាក់រអួលនៅពេលដែលជួបនិងមនុស្សដែលទើបនឹងស្គាល់*
*dia gagap jika bertemu orang yang baru dikenal*
*(ឌីយ៉ា ហ្គាហ្គាប់ ជីកា បារូ ប៊ើរ(r)ទើមូ ឌើង៉ាន់ អូរ៉ាំង យ៉ាំង បារូ ឌិគើណាល់)*

**gaji** /ហ្គាជី/ *n* ប្រាក់ខែ/បៀវត្សរ៍: *ប្រាក់ខែខ្ពស់ gaji tinggi (ហ្គាជី ទិងហ្គី)*

**gambar** /ហ្គាំបារ(r)/ *n* រូបភាព: *រូបភាពផ្កា gambar bunga (ហ្គាំបារ(r) ប៊ូង៉ា)*;

**-- tempel** /ហ្គាំបារ(r) តែមប៉ែល/
ផ្ទាំងបិទ: *នាងលេងជាមួយផ្ទាំងបិទ dia bermain dengan gambar tempel (ឌីយ៉ា ប៊ើរ(r)ម៉ាអ៊ិន ឌើង៉ាន់ ហ្គាំបារ(r) តែមប៉ែល)*

**gandeng, bergandengan** /ប៊ើរ(r)ហ្គាន់ដែង៉ាន់/ *v* គៀកដៃគ្នា
*ពួកគេគៀកដៃគ្នា mereka bergandengan (មើរេកា ប៊ើរ(r)ហ្គាន់ដែង៉ាន់)*

**gang** /ហ្គាំង/ *n* ច្រក; ផ្លូវតូច: *ផ្លូវទាល់ gang buntu (ហ្គាំងប៊ុនទូ)*

**ganggu, mengganggu** /ម៉ឹងហ្កាំងហ្គូ/ *v* រំខាន: *កុំរំខានខ្ញុំ jangan mengganggguku (ចាំង៉ាន់ មើហ្កាំងហ្គូគូ)*

**ganjil** /ហ្កាន់ជីល/ *a* សេស: *ចំនួនសេស bilangan ganjil (ប៊ីឡាង៉ាន់ ហ្កាន់ជីល)*

**ganteng** /ហ្កាន់តឹង/ *a* សង្ហារ: *បុរសសង្ហា laki-laki ganteng (ឡាគី-ឡាគី ហ្កាន់តឹង)*

**ganti, ganti rugi** /ហ្កាន់ទី រូហ្គី/ *n* សងជំងឺចិត្ត; សំណង: *ខ្ញុំទទួលបានសំណង saya menerima ganti rugi (សាយ៉ា មើនើរីម៉ា ហ្កាន់ទី រូហ្គី)*;

**mengganti** /ម៉ឹងហ្កាន់ទី/ *v* ជំនួស; ផ្លាស់ប្តូរ: *គាត់ផ្លាស់ប្តូរគ្រឿងបន្លាស់ឡានរបស់គាត់ដែលខូច dia mengganti onderdil mobilnya yang sudah rusak (ឌីយ៉ា មឹងហ្កាន់ទី អនដើរ(r)ឌីល ម៉ូប៊ីលញ៉ាយ៉ាំង ស៊ូដះ រូសាក់)*;

**menggantikan** /មឹងហ្កាន់ទីកាន់/ *v* ជំនួស; ប្តូរជំនួស: *ខ្ញុំប្តូរជំនួសនាងក្នុងការលេងសី saya menggantikan dia bermain bulutangkis (សាយ៉ា ម៉ឹងហ្កាន់ទីកាន់ ឌីយ៉ា បើរ(r)ម៉ាអ៊ិន ប៊ូលូតាំងគីស(s))*

**gantung, bergantung kepada** /បើរ(r)ហ្កាន់ទុង គឺប៉ាដា/ *v* ពឹងផ្អែកទៅលើ; អាស្រ័យដោយ: *ខ្ញុំពឹងផ្អែកទៅលើគាត់ saya bergantung kepadanya (សាយ៉ា បើរ(r)ហ្កាន់ទុង គើប៉ាដាញ៉ា)*;

**gantungan baju** /ហ្កាន់ទូង៉ាន់ បាជូ/ ប្រដាប់ព្យួរខោអាវ: *មានប្រដាប់ព្យួរខោអាវតែពីរទេនៅក្នុងទូ hanya ada dua gantungan baju di lemari (ហាញ៉ា អាដា ឌូវ៉ា ហ្កាន់ទូង៉ាន់ បាជូ ឌិ លើម៉ារី)*

**garam** /ហ្ការ៉ាម/ *n* អំបិល: *ត្រីអណ្តែងត្រូវបានប្រលាក់អំបិលមុននឹងយកទៅចៀន ikan lele itu diberi garam sebelum digoreng (អ៊ីកាន់ ឡេឡេ អ៊ីទូ ឌីប៊ើរី ហ្គារ៉ាម សើប៊ើលុម ឌីហ្គូរ៉េង)*

**garansi** /ហ្ការ៉ាន់ស៊ី/ *n* ការធានារ៉ាប់រង; ការការពារ: *ការធានារ៉ាប់រងឡាន garansi mobil (ហ្ការ៉ាន់ស៊ី ម៉ូប៊ីល)*

**garasi** /ហ្គារ៉ាស៊ី/ *n* យានដ្ឋាន: *គ្មានឡានទៅក្នុងយានដ្ឋាន tidak ada mobil di garasi (ទីដាក់ អាដា ម៉ូប៊ិល ឌី ហ្គារ៉ាស៊ី)*

**garda, garda depan** /ហ្គារ((r)ដា ឌើប៉ាន់/ *n* ខ្សែត្រៀមជួរមុខ: *ប្អូនប្រុសរបស់គាត់មានកាតព្វកិច្ចនៅខ្សែត្រៀមជួរមុខមួយ adiknya bertugas di garda depan (អាឌិកញ៉ា បើរ(r)ទូហ្គាស់(ស) ឌិ ហ្គារដា ឌើប៉ាន់)*

**garing** /ហ្គារិង/ *a* ស្រួយ: *នំនេះស្រួយ kuenya garing (គួវញ៉ា ហ្គារិង)*

**garis** /ហ្គារីស(s)/ *n* បន្ទាត់; ជួរ: *បន្ទាត់ត្រង់ garis lurus (ហ្គារីស(s )លូរុស(s));*

**-- bawah** /ហ្គារិស(s) បាវ៉ះ/ បន្ទាត់ក្រោម: *នាងដាក់ចំណាំកន្លែងខុសដោយគូសបន្ទាត់ពីក្រោម dia menandai kesalahan dengan garis bawah (ឌីយ៉ា មើណានដៃ គើសាឡាហាន់ ឌើង៉ាន់ ហ្គារិស(s)បាវ៉ះ);*

**bergaris** /បើរ(r)ហ្គារីស(s)/ *v* ដែលមានឆ្នូត; ដែលមានជួរ: *អាវដែលមានឆ្នូត baju bergaris (បាជូ បើរ(r)ហ្គារីស(s));*

**penggaris** /ពើងហ្គារិស(s)/ *n* បន្ទាត់: *បន្ទាត់ត្រីកោណ penggaris segitiga (ពើងហ្គារិស(s) សើហ្គី ទីហ្គា)*

**garpu** /ហ្គារ(r)ពូ/ *n* សម: សមតូច *garpu kecil* (ហ្គារពូ គើជីល)

**garuk** /ហ្គារុក/ *v* អេះ: *គាត់បន្តអេះក្បាលរបស់គាត់ dia terus menggaruk kepalanya (ឌីយ៉ា តើរុស(s) ម៉ើងហ្គារុគ គើប៉ាឡាញ៉ា)*

**gatal** /ហ្គាតាល់/ *a* រមាស់: *ស្បែករមាស់ kulit gatal (គូលីត ហ្គាតាល់)*

**gaun** /ហ្គាអ៊ុន/ *n* រ៉ូប: *រ៉ូបរាត្រី gaun malam (ហ្គាអ៊ុន ម៉ាឡាម)*

**gaung** /ហ្គាអ៊ុង/ *n* សម្លេងខ្ទរ: *ខ្ញុំឮសម្លេងខ្ទររបស់វា saya mendengar gaungnya (សាយ៉ា មើនឌើង៉ារ(r) ហ្គាអ៊ុងញ៉ា)*

**gawang** /ហ្គាវ៉ាំង/ *n* ទី: *អ្នកចាំទី penjaga gawang (ពើនច្យាហ្គា ហ្គាវ៉ាំង)*

**gawat** /ហ្កាវ៉ាត់/ *a* ធ្ងន់ធ្ងរ: *ស្ថានភាពធ្ងន់ធ្ងរ keadaan gawat (កើអាដាអាន ហ្កាវ៉ាត់)*;

**-- darurat** /ហ្កាវ៉ាត់ដារូរ៉ាត់/ បន្ទាន់: *បន្ទប់សង្គ្រោះបន្ទាន់ ruang gawat darurat (រ៉ូអ៉ាន់ ហ្កាវ៉ាត់ដារូរ៉ាត់)*

**gaya** /ហ្កាយ៉ា/ *n* ម៉ូត; រចនាប័ទ្ម; បែបបទ; ស្ទាយ: *គាត់មានបែបបទផ្ទាល់ខ្លួនរបស់គាត់នៃការធ្វើការងារ dia memiliki gaya tersendiri dalam bekerja (ឌីយ៉ា មើមីលីគី ហ្កាយ៉ា តើរ(r)សិនឌីរី ដាឡាមពើគើរ(r)ចា)*

**gedung** /ហ្គើឌុង/ *n* អគារ: *អគារសាលារៀន gedung sekolah (ហ្គើឌុង សើកូឡះ)*;

**-- pertemuan** /ហ្គើឌុងពើរ(r)ទើមូអ៉ាន/ សាលប្រជុំ;

**-- teater** /ហ្គើឌុងទៀតើរ(r)/ រោងកុន; រោងមហោស្រព: *រោងមហោស្រពរបស់រាជរដ្ឋាភិបាល gedung teater milik pemerintah (ហ្គើឌុង ទៀតើរ(r) មីលិក ពើមើរិនតះ)*

**gegar, gegar budaya** /ហ្គើហ្គារ(r) ប៊ូដាយ៉ា/ *a* តំណក់ស្លុតវប្បធម៌: *គាត់ទទួលរងនូវតំណក់ស្លុតវប្បធម៌ dia mengalami gegar budaya (ឌីយ៉ា មើង៉ាឡាមី ហ្គើហ្គារ(r) ប៊ូដាយ៉ា)*;

**-- otak** /ហ្គើហ្គារ(r) អូតាក់/ ការប៉ះទង្គិចខួរក្បាល: *គាត់ទទួលរងនូវការប៉ះទង្គិចខួរក្បាលស្រាល dia mengalami gegar otak ringan (ឌីយ៉ា មើង៉ាឡាមី ហ្គើហ្គារ(r) អូតាក់ រីង៉ាន់)*

**gejala** /ហ្គើចាឡា/ *n* រោគសញ្ញា: *រោគសញ្ញានៃជំងឺ gejala penyakit (ហ្គើចាឡា ពើញ៉ាគិត)*

**gelandang, gelandangan** /ហ្គើឡាន់ដាង៉ាន់/ *n* ជនអនាថា: *នាងបានជួយជនអនាថា dia membantu para gelandangan (ឌីយ៉ា មើមបាន់ទូ ប៉ារ៉ា ហ្គើឡាន់ដាង៉ាន់)*

**gelang** /ហ្គើឡាំង/ *n* ខ្សែដៃ; កងដៃ: *ខ្សែដៃមាស gelang emas (ហ្គើឡាំង អើម៉ាស(s))*;

**pergelangan kaki** /ពើរ(r)ហ្គើឡាង៉ាន់ កាគី/ *n* កជើង: *កជើងរបស់ខ្ញុំចុក pergelangan kakiku pegal (ពើរ(r)ហ្គើឡាង៉ាន់ កាគីគូ ពើហ្គាល់)*;

**pergelangan tangan** /ពើរ(r)ហ្គើឡាង៉ាន់ តាង៉ាន់/ *n* កដៃ: *កដៃរបស់ខ្ញុំបាក់ pergelangan tanganku patah (ពើរ(r)ហ្គើឡាង៉ាន់ តាង៉ាន់គូ ប៉ាតះ)*

**gelanggang** /ហ្គើឡាំងហ្គាំង/ *n* ទីលាន: *ទីលានកីឡា gelanggang olahraga (ហ្គើឡាំងហ្គាំង អូឡះរ៉ាហ្គា)*;

**-- olahraga** /ហ្គើឡាំងហ្គាំង អូឡះរ៉ាហ្គា/ ទីលានកីឡា

**gelap** /ហ្គើឡាប់/ *a* ងងឹត; ខ្មៅ: *ស្បែកខ្មៅ kulit gelap (គូលីត ហ្គើឡាប់)*

**gelar** /ហ្គើឡារ(r)/ **1** *n* កំរិត; សញ្ញាបត្រ *កម្រិតនៃការសិក្សា gelar akademik (ហ្គើឡារ(r) អាកាឌើមិក)*; **2** *v* រីករាលដាល

**gelas** /ហ្គើឡាស់(s)/ *n* កែវ: *កែវនេះកំពុងតែលាងសម្អាត gelas itu sedang dicuci (ហ្គើឡាស់(s) អ៊ីទូ សើដាំង ឌិជូជី)*

**gelembung** /ហ្គើឡឹមប៊ុង/ *n* ពពុះ: ***ពពុះសាប៊ូ*** *gelembung sabun (ហ្គើឡឹមប៊ុង សាប៊ុន)*

**geleng, menggeleng(-gelengkan)** /មើងហ្គែឡែងកាន់/ *v* គ្រវីក្បាល: *គាត់គ្រវីក្បាលរបស់គាត់ dia menggelengkan kepala (ឌីយ៉ា មើងហ្គែឡែងកាន់ គើប៉ាឡា)*

**geli (gatal)** /ហ្គាតាល់/ *a* រមាស់: *ដៃរបស់គាត់មានអារម្មណ៍រមាស់ tangannya terasa gatal (តាំង៉ាន់ ទើរ៉ាសា ហ្គាតាល់)*

**gelincir, tergelincir** /ទើរ(r)ហ្គើលិនទីរ(r)/ *v* រអិល: *ជើងរបស់គាត់មានរបួសដោយសារតែគាត់រអិលដើងដួល kakinya terluka karena dia tergelincir (កាគីញ៉ា ទើរ(r)លូកា កាផើណា ឌីយ៉ា ទើរ(r)ហ្គើលិនទីរ(r))*

**gelinding, menggelinding** /មើងហ្គើលិនឌិង/ *v* រមៀល: *បាល់រមៀលចូលទៅលើផ្លូវ bola itu*

*menggelinding ke jalan (ប្ញូឡា អ៊ីទូ ម៉ឹងហ្គេលិនឌិង ខឺ ចា្លាឡាន់)*

**gelisah** /ហ្គើលីសះ/ *a* រសាប់រសល់; អន្ទះអន្ទែង: *មើលទៅនាងហាក់ដូចជាអន្ទះអន្ទែង dia terlihat gelisah (ឌីយ៉ា តើរ(r)លីហាត់ ហ្គើលីសះ);*

**kegelisahan** /គើហ្គើលីសាហាន់/ *n* ភាពរសាប់រសល់; ក្តីបារម្ភ: *គាត់ពោពេញទៅដោយក្តីបារម្ភ dia larut dalam kegelisahan (ឌីយ៉ា ឡារុត ដាឡាម គើហ្គើលីសាហាន់);*

**menggelisahkan** /ម៉ឹងហ្គើលីសះកាន់/ *v* គួរឱ្យភ័យខ្លាច: *ស្ថានភាពរបស់គាត់គួរឱ្យភ័យខ្លាច keadaannya menggelisahkan (គើអាដាអានញ៉ា ម៉ឹងហ្គើលីសះកាន់)*

**gelitik, menggelitik** /ម៉ឹងហ្គើលីទិក/ *v* រសើប: *ដំណឹងនោះរសើបត្រចៀកមែនទែន berita itu menggelitik telinga (បើរីតា អ៊ីទូ ម៉ឹងហ្គើលីទិក ទើលីង៉ា);*

**tergelitik** /ទើរ(r)ហ្គើលីទីគ/ *v* ត្រូវបានរសើប

**gelombang** /ហ្គើឡុមបាំង/ *n* រលកៈ *រលកសម្លេង gelombang suara (ហ្គើឡុមបាំង ស៊ូអ៊ារ៉ា);*

**bergelombang** /បើរ(r)ហ្គើឡុមបាំង/ *v* ទឹករលក: *សក់គាត់រាងទឹករលក rambutnya bergelombang (រ៉ាំប៊ុតញ៉ា បើរ(r)ហ្គើឡុមបាំង)*

**gemar** /ហ្គើម៉ារ(r)/ *a* ចូលចិត្ត: *នាងចូលចិត្តលេងកីឡា dia gemar berolahraga (ឌីយ៉ា ហ្គើម៉ារ(r) បើរ(r)អូឡះរ៉ាហ្គា);*

**kegemaran** /គើហ្គើម៉ារ៉ាន់/ *n* ចំណង់ចំណូលចិត្ត: *ចំណង់ចំណូលចិត្តរបស់គាត់គឺលេងបាល់ទាត់ kegemarannya adalah bermain sepakbola (គើហ្គើម៉ារ៉ាន់ញ៉ា អាដាឡះ បើរ(r)ម៉ាអ៊ិន សើប៉ាក់បូឡា);*

**penggemar** /ពើងហ្គើម៉ារ(r)/ *n* អ្នកគាំទ្រ: *អ្នកគាំទ្រដ៏ខ្លាំងខ្លា penggemar berat (ពើងហ្គើម៉ារ(r) បើរ៉ាត់)*

**gembala** /ហ្គឹមបាឡា/ *n* ចៀម: *គាត់មានចៀមច្រើនប្រភេទ* *dia mempunyai banyak jenis gembala* (*ឌីយ៉ា មើមពូញ៉ៃ បាញ៉ាក់ ជើនិស(s) ហ្គឹមបាឡា*);

**menggembala(kan)** /មើងហ្គឹមបាឡាកាន់/ *v* ស៊ី: *គាត់ឱ្យចៀមស៊ីស្មៅ* *dia menggembalakan kambing* (*ឌីយ៉ា មើងហ្គឹមបាឡាកាន់ កាំប៊ិង*)

**gembira** /ហ្គឹមប៊ីរ៉ា/ *a* សប្បាយរីករាយ: *ស្នាមញញឹមដោយក្តីរីករាយ* *senyum gembira* (*សើញូម ហ្គឹមប៊ីរ៉ា*);

**bergembira** /ប៊ើរ(r)ហ្គឹមប៊ីរ៉ា/ *v* សប្បាយរីករាយ: *គាត់សប្បាយរីករាយ* *dia bergembira* (*ឌីយ៉ា ប៊ើរ(r)ហ្គឹមប៊ីរ៉ា*);

**kegembiraan** /គើហ្គឹមប៊ីរ៉ាអាន/ *n* ការសប្បាយរីករាយ: *នាងទទួលការសប្បាយរីករាយយ៉ាងខ្លាំង* *dia mendapatkan kegembiraan besar* (*ឌីយ៉ា មើនដាប៉ាត់កាន់ គើហ្គឹមប៊ីរ៉ាអាន បេសារ(r)*)

**gembok** /ហ្គឹមបុក/ *n* សោ: *សោផ្ទះ* *gembok rumah* (*ហ្គឹមបុក រូម៉ះ*)

**gembur** /ហ្គឹមប៊ូរ(r)/ *a* មានជីជាតិ: *ដីមានជីជាតិ* *tanah gembur* (*តាណះ ហ្គឹមប៊ូរ(r)*)

**gemerlap** /ហ្គឹមើរ(r)ឡាប់/ *a* ពន្លឺ: *ពន្លឺតារា* *gemerlap bintang* (*ហ្គឹមើរ(r)ឡាប់ ប៊ិនតាំង*)

**gemetar** /ហ្គឹមើតារ(r)/ *a* ញ៉ាក់: *គាត់ញ័រញ៉ាក់ដោយសារតែគាត់ត្រជាក់* *dia gemetar karena kedinginan* (*ឌីយ៉ា ហ្គឹមើតារ(r) ការើណា គើឌិងីណាន់*);

**gemetaran** /ហ្គឹម៉ាតារ៉ាន់/ *n* ញ័រ: *គាត់ឡើងញ័រ* *dia gemetaran* (*ឌីយ៉ា ហ្គឹម៉ាតារ៉ាន់*)

**gempa bumi** /ហ្គឹមប៉ា ប៊ូមី/ រញ្ជួយដី

**gempar, menggemparkan** /មើងហ្គឹមប៉ារ(r)កាន់/ *v* រំជើបរំជួល: *ពត៌មានដ៏រំជើបរំជួល* *berita menggemparkan* (*បើរីតា មើងហ្គឹមប៉ារ(r)កាន់*)

**gemuk** /ហ្គឹមុក/ *a* ធាត់:

*កាលនៅវិទ្យាល័យខ្លួនរបស់ខ្ញុំធាត់ saat SMA tubuhku gemuk (សាអាត់ អេស អឹម អា ទូប៊ុះគូ ហ្គឹមុក)*

**gemulai** /ហ្គឹមូឡៃ ទូប៊ុះ/ *a* សមសួន: *ខ្លួនរបស់នាងសមសួន tubuhnya gemulai (ទូប៊ុះញ៉ា ហ្គឹមូឡៃ)*

**genap** /ហ្គឹណាប់/ *a* លេខគូ; គត់គូ: *ចំនួនគូ angka genap (អាំងកា ហ្គឹណាប់)*

**gencar** /ហ្គឹនចារ(r)/ *a* ខ្លាំងខ្លា: *គាត់ធ្វើការផ្សព្វផ្សាយពត៌មាននោះយ៉ាងខ្លាំង dia gencar menyebarkan berita itu (ឌីយ៉ា ហ្គឹនចារ(r) មើនញើបារ(r)កាន់ បើរីតា អ៊ីទូ)*

**gendang** /ហ្គឹនដាំង/ *n* ស្គរ: ***ស្គរជ្វា*** *gendang jawa (ហ្គឹនដាំង ច្វាវ៉ា)*

**gendong, menggendong** /មើងហ្គែនដុង/ *v* បី: *ស្ត្រីម្នាក់នោះកំពុងបីកូនរបស់នាង perempuan itu sedang menggendong anaknya (ពើរើមពូវ៉ាន់ អ៊ីទូ សើដាំង មើងហ្គែនដុង អាណាក់ញ៉ា)*

**generasi** /ហ្គេនើរ៉ាស៊ី/ *n* ជនាន់: *យុវជនជំនាន់ក្រោយ generasi muda (ហ្គេនើរ៉ាស៊ី មូដា)*

**genggam, menggenggam** /មើងហ្គឹងហ្គាំ/ *v* កាន់: *ស្ត្រីម្នាក់នោះកាន់ដៃកូនរបស់នាង ibu itu menggenggam tangan anaknya (អ៊ីប៊ូ អ៊ីទូ មើងហ្គឹងហ្គាំ តាង៉ាន់ អាណាក់ញ៉ា)*

**gengsi** /ហ្គែងស៊ី/ *n* រឹកធំ (ចារិក) កិត្យានុភាព: *រឹកធំ gengsi tinggi (ហ្គែងស៊ី ទិងហ្គី )*; **bergengsi** /បើរ(r)ហ្គែងស៊ី/ *v* ដែលមានកិត្យានុភាព: *សញ្ញាបត្រដ៏មានកិត្យានុភាព gelar bergengsi (ហ្គឹឡារ(r) បើរ(r)ហ្គែងស៊ី)*

**genit** /ហ្គឹនិត/ *a* ដែលចូលចិត្តម៉្ងិកម៉ូក់: *គាត់ចូលចិត្តធ្វើម៉្ងិកម៉ូក់ dia genit (ឌីយ៉ា ហ្គឹនិត)*

**genting** /ហ្គឹនទិង/ *a* តានតឹង:

*ស្ថានភាពដ៏តានតឹង situasi genting (ស៊ីទូវ៉ាស៊ី ហ្គេនទិង)*

**gerah** /ហ្គើរ៉ះ/ *a* ស្អុះស្អាប់: *អាកាសធាតុស្អុះស្អាប់ udara terasa gerah (អ៊ូដារ៉ា ទើរ៉ាសា ហ្គើរ៉ះ)*

**gerai** /ហ្គើរ៉ៃ/ *n* តុគិតលុយ; កុងទ័រ; ទូ: *ទូទូរស័ព្ទ gerai telepon (ហ្គើរ៉ៃ តែលេប៉ូន)*

**gerak, bergerak** /បើរ(r)ហ្គើរ៉ាក់/ *v* បំលាស់ទី; បោកបក់: *ខ្យល់បោកបក់ទៅខាងលិច angin bergerak ke barat (អាងិន បើរ(r)ហ្គើរ៉ាក់ គើ បារ៉ាត់);*

**gerakan** /ហ្គើរ៉ាកាន់/ *n* ចលនា: *ចលនាយឺតៗ gerakan lambat (ហ្គើរ៉ាកាន់ ឡាំបាត់);*

**menggerakkan** /មើងហ្គើរ៉ាកាន់/ *v* បំលាស់ទី: *គាត់បំលាស់ទីកូនក្តាតនោះ dia menggerakkan boneka itu (ឌីយ៉ា មើងហ្គើរ៉ាកាន់ បូឡាអ៊ីទូ)*

**gerbang** /ហ្គើរ(r)បាំង/ *n* ក្លោងទ្វារ: *ក្លោងទ្វារសាលា gerbang sekolah (ហ្គើរ(r)បាំង សើកូឡះ)*

**gerbong** /ហ្គើរ(r)បុង/ *n* ទូ(រថភ្លើង)

**gereja** /ហ្គើរេចា/ *n* ព្រះវិហារនៃសាសនាគ្រីស្ត: *គ្រីស្តសាសនិកទៅព្រះវិហាររាល់ថ្ងៃអាទិត្យ umat Kristen ke gereja setiap hari Minggu (អ៊ូម៉ាត់ គ្រីស(s)តិន គើ ហ្គើរេចា សើទីយ៉ាបហារី មិងហ្គូ)*

**gergaji** /ហ្គើរ(r)ហ្គាជី/ *n* រណា: *ម៉ាស៊ីនអារ gergaji mesin (ហ្គើរ(r)ហ្គាជី មើស៊ិន);*

**menggergaji** /មើងហ្គើរ(r)ហ្គាជី/ *v* អារ: *គាត់កំពុងអារឈើដែលរលំ dia sedang menggergaji pohon yg tumbang (ឌីយ៉ា សើដាំង មើងហ្គើរ(r)ហ្គាជី ប៉ូហុន យ៉ាំង ទុមបាំង)*

**gerhana, gerhana bulan** /ហ្គើរ(r)ហាណា ប៊ូឡាន់/ ច័ន្ទគ្រាស: *ខ្ញុំមើលឃើញច័ន្ទគ្រាស saya melihat gerhana bulan (សាយ៉ា មើលីហាត់ ហ្គើរ(r)ហាណា ប៊ូឡាន់);*

**-- matahari** /ហ្គើរ(r)ហាណា ម៉ាតាហារី/ សូរ្យគ្រាស:

*ថ្ងៃនេះនឹងមានបាតុភូតសូរ្យគ្រាសកើតឡើង hari ini akan terjadi gerhana matahari (ហារី អ៊ីនី អាកាន់ ទើរច្បាឌិ ហ្គើរ(r)ហាណា ម៉ាតាហារី)*

**gerimis** /ហ្គើរីមីស(s)/ *n* ភ្លៀងរលឹម: *រសៀលនេះមានភ្លៀងរលឹម sore ini gerimis (សូរេ អ៊ីនី ហ្គើរីមីស(s))*

**gersang** /ហ្គើរ(r)សាំង/ *a* ស្ងួត: *ដីស្ងួតបែកក្រហែង tanah gersang (តាណះ ហ្គើរ(r)សាំង)*

**gertak, gertak sambal** /ហ្គើរតាក់សាំបាល់/ *n* សម្លុតបញ្ឆោត: *គាត់គ្រាន់សម្លុតបញ្ឆោតតែប៉ុណ្ណោះ dia hanya gertak sambal (ឌីយ៉ា ហាញ៉ា ហ្គើរតាក់ សាំបាល់)*;

**gertakan** /ហ្គើរ(r)តាក់កាន់/ *n* ការគំរាមកំហែង: *វាគ្រាន់តែជាការគំរាមកំហែងរបស់គាត់តែប៉ុណ្ណោះ itu hanya gertakannya (អ៊ិទូ ហាញ៉ា ហាញ៉ា ហ្គើរ(r)តាក់កាន់ញ៉ា)*;

**menggertak** /មើងហ្គើរ(r)តាក់/ *v* គំរាមកំហែង: *ថៅកែបានគំរាមកំហែងបុគ្គលិក pimpinannya menggertak para pegawai (ពិមពីណាន់ មើងហ្គើរ(r)តាក់ ប៉ារ៉ា ពើហ្កាវ៉ៃ)*

**gerutu, menggerutu** /មើងហ្គើរូទូ/ *v* រអ៊ូរទាំ: *កូនសិស្សរអ៊ូរទាំ para murid menggerutu (ប៉ារ៉ា មូរីដ មើងហ្គើរូទូ)*

**geser, menggeser** /មើងហ្គែសែរ(r)/ *v* រំកិល: *គាត់រំកិលកៅអីរបស់គាត់ dia menggeser kursinya (ឌីយ៉ា មើងហ្គែសែរ(r) គួរ(r)ស៊ីញ៉ា)*;

**pergeseran** /ពើរ(r)ហ្គេសែរ៉ាន់/ *n* រំកិល; ផន; ផ្លាស់ប្ដូរ: *ការផ្លាស់ប្ដូរភាសា pergeseran bahasa (ពើរ(r)ហ្គេសែរ៉ាន់ បាហាសា)*

**gesit** /ហ្គើស៊ិត/ *a* រហ័សរហួន: *កូននោះរហ័សរហួន anak itu gesit (អាណាក់ អ៊ីទូ ហ្គើស៊ិត)*

**getar, bergetar** /បើរ(r)ហ្គើតារ(r)/ *v* ញ័រ: *ទូរស័ព្ទរបស់គាត់ញ័រ ponselnya bergetar (ប៉ុនសែលញ៉ា បើរ(r)ហ្គើតារ(r))*;

**getaran** /ហ្គើតារ៉ាន់/ *n* ការញ័រ:

*ការញ័រទូរស័ព្ទរបស់គាត់គឺខ្លាំង getaran ponselnya kencang (ហ្គើតារ៉ាន់ ប៉ុនសែលញ៉ា កិនចាំង)*

**giat, kegiatan** /គើក្យាតាន់/ *n* សកម្មភាព: *សកម្មភាពបោះជំរុំ kegiatan berkemah (គើក្យាតាន់ បើរ(r)កេមះ)*;

**menggiatkan** /មើងហ្គីយ៉ាតកាន់/ *v* លើកទឹកចិត្ត: *គ្រូបានលើកទឹកចិត្តសិស្សឲ្យខំសិក្សា guru itu menggiatkan para murid untuk belajar (ហ្គូរូ អ៊ីទូ មើងហ្គីយ៉ាតកាន់ ប៉ារ៉ា មូរីដ អ៊ុនទុក បើឡាចា្យរ(r))*

**gigi** /ហ្គីហ្គី/ *n* ធ្មេញ: *ធ្មេញព្រៃ, ធ្មេញទឹកដោះ gigi susu (ហ្គីហ្គី ស៊ូស៊ូ)*;

**-- geraham** /ហ្គីហ្គីហ្គើរ៉ាហាំ/ ធ្មេញថ្គាម: *ធ្មេញថ្គាមរបស់នាងត្រូវតែដកចេញ gigi gerahamnya harus dicabut (ហ្គីហ្គិ ហ្គើរ៉ាហាំញ៉ា ហារុស(s) ឌិចាប៊ុត)*;

**-- palsu** /ហ្គីហ្គី ប៉ាល់ស៊ូ/ ធ្មេញសិប្បនិមិត្ត *ធ្មេញសិប្បនិមិត្តរបស់គាត់បានជ្រុះ gigi palsunya jatuh (ហ្គីហ្គី ប៉ាល់ស៊ូញ៉ា ចា្យទុះ)*;

**-- taring** /ហ្គីហ្គី តារិង/ ធ្មេញចង្កូម: *ធ្មេញចង្កូមគាត់គឺមុត gigi taringnya tajam (ហ្គីហ្គី តារិងញ៉ា តាចា្យាំ)*

**gigih** /គីហ្គិះ/ *a* តស៊ូ: *គាត់តស៊ូ dia gigih (ឌីយ៉ា ហ្គីហ្គិះ)*

**gigil, menggigil** /មើងហ្គីហ្គីល/ *v* រងារញាក់: *ពួកយើងកំពុងរងារញាក់ kami menggigil (កាមី មើងហ្គីហ្គីល)*

**gigit** /ហ្គីហ្គិត/ *a* ខាំ; ចឹក: *ឆ្កែរខាំនាង anjing itu menggigit dia (អាន់ជ្យីង អ៊ីទូ ម៉ឺងហ្គីហ្គីត ឌីយ៉ា)*;

**menggigit** /ម៉ឺងហ្គីហ្គិត/ *v* ខាំ; ចឹក: *ឆ្កែរខាំនាង anjing itu menggigitnya (អាន់ជីងអ៊ីទូម៉ឹងហ្គីហ្គីតឌីយ៉ា)*

**gila** /ហ្គីឡា/ *a* វិកលចរិក/ឆ្កួត/ងប់ងល់: *អ្នកគាំទ្រដ៏ងប់ងល់ penggemar gila (ពើងហ្គើម៉ារ(r) ហ្គីឡា)*;

**tergila-gila** /ទើរ(r)ហ្គីឡា–ហ្គីឡា/ *v* ជក់ចិត្តជាមួយ

**giling, gilingan** /ហ្គីលីង៉ាន់/ *n* ម៉ាស៊ីន; ឧបករណ៍កិន: *ម៉ាស៊ីន ឧបករណ៍កិនសណ្ដែក gilingan kacang (ហ្គីលីង៉ាន់ កាចាំង)*;

**menggiling** /មើងហ្គីលិង/ *v* កិន: *នាងកំពុងតែកិនគ្រាប់សណ្ដែក dia sedang menggiling kacang (ឌីយ៉ា សើដាំង មើងហ្គីលិង កាចាំង)*

**gilir, bergilir(an)** /បើរ(r)ហ្គីលីរ៉ាន់/ *v* ប្ដូរវេន: *ពួកយើងត្រូវតែប្ដូរវេនប្រើកុំព្យូទ័រនោះ kita harus bergiliran memakai komputer itu (គីតា ហារុស(s) បើរ(r)ហ្គីលីរ៉ាន់ មើម៉ាកៃ កុំព្យូទ័រ(r) អ៊ីទូ)*;

**giliran** /ហ្គីលីរ៉ាន់/ *n* វេន: *ឥឡូវដល់វេនយើងហើយ sekarang giliran kita (សើការ៉ាំង ហ្គីលីរ៉ាន់ គីតា)*

**ginjal** /ហ្គិនច្បាល់/ *n* តម្រងនោម: *បរិច្ចាគតម្រងនោម donor ginjal (ដូណូរ(r) ហ្គិនច្បាល់)*

**giok** /ហ្គីយ៉ុក/ *n* ត្បូងថ្ម: *ខ្សែកត្បូងថ្ម kalung giok (កាលុង ហ្គីយ៉ុក)*

**giring, menggiring** /មើងហ្គីរិង/ *v* គៀង; ឃ្វាល: *គាត់កំពុងតែគៀងពពែឲ្យចូលទៅក្នុងទ្រុង dia sedang menggiring kambing kembali ke kandang (ឌីយ៉ា សើដាំង មើងហ្គីរិង កាំប៊ិង គើមបាលី គើ កាន់ដាំង)*

**gitar** /ហ្គីតារ(r)/ *n* ហ្គីតា: *ហ្គីតាអគ្គិសនី gitar elektrik (ហ្គីតារ(r) អែឡិកទ្រិក)*

**giur, menggiurkan** /មើងហ្គីយូរ(r)កាន់/ *v* ទាក់ទាញ: *ម្ហូបអាហារនេះពិតជាគួរឲ្យទាក់ទាញមែន makanan itu sangat menggiurkan (ម៉ាកាណាន់ អ៊ីទូ សាង៉ាត់ មើងហ្គីយូរ(r)កាន់)*;

**tergiur** /ទើរ(r)ហ្គីយូរ(r)/ *v* ត្រូវបានទាក់ទាញ; ល្បួង: *គាត់ត្រូវបានទាក់ទាញដោយរង្វាន់ដែលផ្ដល់អោយ dia tergiur dengan hadiah yg ditawarkan (ឌីយ៉ា ទើរ(r)ហ្គីយូរ(r) ដើង៉ាន់ ហាឌិយ៉ះ យ៉ាំង ឌិតាវ៉ារកាន់)*

**giwang** /ហ្គីវ៉ាំង/ *n* ក្រវិល: *ក្រវិលមាស giwang emas (ហ្គីវ៉ាំង អេម៉ាស់(s))*

**gizi** /ហ្គីស៊ី/ *n* អាហាររូបត្ថម្ភ; ជីវជាតិ:

*ទឹកក្រូចមានជីវជាតិខ្ពស់ jeruk memiliki gizi yg tinggi (ជេរុក មើមីលិគិ ហ្គីស៊ី យ៉ាំង ទិងហ្គី)*

**goda, godaan** /កូដាអាន/ *n* ការអូសទាញ; ការល្បួងលោម: *គាត់ត្រូវតែប្រឈមមុខនឹងការអូសទាញនោះ dia harus menghadapi godaan itu (ឌីយ៉ា ហារុស(s) មើងហាដាពី កូដាអាន អ៊ីទូ);*

**menggoda** /មើងហ្គូដា/ *v* អូសទាញ; ល្បួងលោម: *មិត្តភ័ក្តរបស់នាងបានព្យាយាមអូសទាញនាង temannya mencoba menggodanya (ទើម៉ាន់ញ៉ា មើនចូបា មើងហ្គូដាញ៉ា);*

**tergoda** /ទើរ(r)ហ្គូដា/ *v* ត្រូវបានអូសទាញ: *គាត់ត្រូវបានអូសទាញដោយមិត្តរបស់គាត់ dia tergoda oleh temannya (ឌីយ៉ា ទើរ(r)ហ្គូដា អូលេះ ទើម៉ាន់ញ៉ា)*

**golong, golongan darah** /ហ្គូឡូង៉ាន់ ដារ៉ះ/ *n* ប្រភេទឈាម; ក្រុមឈាម: *ពិនិត្យមើលក្រុមឈាមរបស់អ្នក periksa golongan darahmu (ពើរិកសា ហ្គូឡូង៉ាន់ ដារ៉ះមូ)*

**goncang, bergoncang** /បឺរ(r)ហ្គូនចាង/ *v* បានរញ្ជួយ; អង្រួន;

**goncangan** /ហ្គុនចាង៉ាន់/ *n* ការញ្ជួយ; អង្រួន: *ការរញ្ជួយដ៏ខ្លាំងខ្លា goncangannya sangat kencang (ហ្គុនចាង៉ាន់ ញ៉ាំង សាង៉ាត់ កិនចាំង);*

**menggoncang** /មើងហ្គុនចាំង/ *v* អង្រួន: *ពត៌មាននេះបានអង្រួនព្រលឹងរបស់នាង berita itu menggoncangnya jiwanya (បើរីតា អ៊ីទូ មើងហ្គុនចាំងញ៉ា ជីវ៉ាញ៉ា)*

**gondrong** /ហ្គុនដ្រុង/ *a* សក់ប្រេះស្នា: *សក់របស់គាត់ប្រេះស្នា rambutnya gondrong (រ៉ាំប៊ុតញ៉ា ហ្គុនដ្រុង)*

**gong** /ហ្គុង/ *n* ឃ្មោះ; គង *ឧបករណ៍តន្ត្រីជ្វាមានគងធំមួយ gamelan Jawa memiliki sebuah gong besar (ហ្គើបើឡាន់ ចា្វា មើមីលីគី សើប៊ូវ៉ះ ហ្គុង បែសារ(r))*

**goreng** /ហ្គូរ៉ែង/ *v* ចៀន; ឆា; បំពង;

**gorengan** /ហ្គូរ៉ែង៉ាន់/ *n* នំចៀន: *នាងចូលចិត្តបរិភោគនំចៀន dia suka memakan gorengan (ឌីយ៉ា ស៊ូកា មើម៉ាកាន់ ហ្គូរ៉ែង៉ាន់);*

**menggoreng** /មើងហ្គូរ៉ែង/ *v* ចៀន; ឆា; បំពង: *គាត់កំពុងតែចៀនតាហ៊ូ dia sedang menggoreng tahu (ឌីយ៉ា ស៊ើដាំង មើងហ្គូរ៉ែង តៅហ៊ូ);*

**penggorengan** /ពើងហ្គូរ៉ែង៉ាន់/ *n* ខ្ទះឆា: *ខ្ទះឆានេះធំពេក penggorengan itu terlalu besar (ពើងហ្គូរ៉ែង៉ាន់ អ៊ីទូ ទើរ(r)ឡាលូ បែសារ(r))*

**gores, goresan** /ហ្គូរ៉ែសាន់/ *n* កូត; ឆូត: *ស្នាមឆូតជញ្ជាំង goresan dinding (ហ្គូរ៉ែសាន់ ឌិនឌិង);*

**menggores** /មើងហ្គូរ៉ែស(s)/ *v* កូត; ឆូត: *កង់របស់គាត់ធ្វើឲ្យឆូតជញ្ជាំង sepedanya menggores dinding (ស៊ើពេដាញ៉ា មើងហ្គូរ៉ែស ឌិនឌិង)*

**gosok** /ហ្គូសុក/ *v* ដុះ; ជូតជម្រះ: *សូមកុំដុះដៃអ្នកខ្លាំងៗ jangan gosok tanganmu keras-keras (ចាំង៉ាន់ ហ្គូសុក តាង៉ាន់មូ គើរ៉ាស់(s)-គើរ៉ាស់(s))*

**gosong** /ហ្គូសុង/ *a* ខ្លោច: *បាយខ្លោច nasinya gosong (ណាស៊ីញ៉ា ហ្គូសុង)*

**gotong royong** /កូតុង រ៉ូយ៉ុង/ *v* សហការគ្នាទៅវិញទៅមក: *ការងារនឹងឆាប់ហើយដោយមានការសហការណ៍គ្នាទៅវិញទៅមក pekerjaan akan cepat selesai dengan gotong royong (ពើគើរ(r)ចាអាន អាកាន់ ជើប៉ាត់ ស៊ើលើសៃ ឌើង៉ាន់ កូតុង រ៉ូយ៉ុង)*

**goyah** /ហ្គូយ៉ះ/ *a* រង្គើ: *បង្គោលនេះរង្គើ tiang itu goyah (ទីយ៉ាង អ៊ីទូ ហ្គូយ៉ះ)*

**goyang, bergoyang** /បើរ(r)ហ្គូយ៉ាំង/ *v* ញ័ាក់: *ខ្លួនរបស់គាត់ញ៉ាក់ទៅតាមចង្វាក់ភ្លេង badannya bergoyang mengikuti irama musik (បាដាន់ បើរ(r)ហ្គូយ៉ាំង មើងីគូទី អ៊ីរ៉ាម៉ា មូស៊ិក)*

**gratis** /ក្រាទិស(s)/ *a* ដោយឥតគិតថ្លៃ: *ម្ហូបអាហារនេះគឺឥតគិតថ្លៃ makanan itu gratis (ម៉ាកាណាន់ អ៊ីទូ ក្រាទិស(s))*

**grogi** /ហ្ក្រោហ្គី/ *a* ជ្រួលច្រាលក្នុងចិត្ត; ភ័យ:

*គាត់ភ័យមុនពេលសម្តែង dia grogi sebelum tampil (ឌីយ៉ា ហ្គ្រោហ្គី សឺប៊ើលុម តាំពីរ(r))*

**gudang** /ហ្គូដាំង/ *n* ឃ្លាំង:
*ពួកយើងត្រូវតែសម្អាតឃ្លាំង kami harus membersihkan gudang (កាមី ហារុស(s) មើមបើរ(r)ស៊ីស(s)កាន់ ហ្គូដាំង)*

**gugat, gugatan** /ហ្គុហ្គាតាន់/
*n* ពាក្យបណ្តឹង: *គាត់បានដាក់ពាក្យបណ្តឹង dia mengajukan gugatan (ឌីយ៉ា មើង៉ាជូកាន់ ហ្គូហ្គាតាន់);*

**menggugat** /មើងហ្គូហ្គាត់/ *v* ប្តឹង:
*គាត់ប្តឹងក្រុមហ៊ុនរបស់គាត់ dia menggugat perusahaannya (ឌីយ៉ា មើងហ្គូហ្គាត់ ពើរូសាហាអានញ៉ា);*

**penggugat** /ពើងហ្គូហ្គាត់/
*n* ដើមបណ្តឹង:
*នៅក្នុងសាវនាការនោះគាត់គឺជាដើមបណ្តឹង dalam pengadilan itu, dia seorang penggugat (ដាឡាម ពើង៉ាឌិឡាន់ ឌីយ៉ា សើអូរ៉ាំង ពើងហ្គូហ្គាត់);*

**tergugat** /ទើរ(r)ហ្គូហ្គាត់/ *v* ចុងចោទ:
*នៅក្នុងសាវនាការនោះក្រុមហ៊ុនគឺជាចុងចោទ dalam pengadilan itu, perusahaannya pihak tergugat (ដាឡាម ពើង៉ាឌិឡាន់ អ៊ីទូ ពើរូសាហាអានញ៉ា ពីហាក់ ទើរ(r)ហ្គូហ្គាត់)*

**gugup** /ហ្គូហ្គុប/ *a* ភ័យ; ភ័យព្រួយ:
*នាងភ័យពេលធ្វើជាវាយគ្មិន dia gugup ketika menjadi pembicara (ឌីយ៉ា ហ្គូហ្គុប គើទីកា ម៉ើញ៉ាឌី ប៉ឹមប៊ីចារ៉ា)*

**gugur, berguguran** /បើរ(r)ហ្គូហ្គូរ៉ាន់/
*v* ជ្រុះ: *ស្លឹកឈើជ្រុះ daun berguguran (ដាអ៊ុន បើរ(r)ហ្គូហ្គូរ៉ាន់);*

**keguguran** /គើហ្គូហ្គូរ៉ាន់/ *n* រលូតកូន:
*នាងទើបតែរលូតកូន dia baru saja mengalami keguguran (ឌីយ៉ា បារូ សាច្យា មើង៉ាឡាមី គើហ្គូហ្គូរ៉ាន់);*

**menggugurkan** /មើងហ្គូហ្គូរ(r)កាន់/ *v* រំលូត:
*នាងបដិសេធមិនរំលូតកូនរបស់នាងឡើយ dia menolak menggugurkan kandungannya (ឌីយ៉ា មើណូឡាក់ មើងហ្គូហ្គូរ(r)កាន់ កាន់ឌូង៉ាន់ញ៉ា)*

**gula** /ហ្គូឡា/ *n* ស្ករ:
*គាត់តែងតែផឹកកាហ្វេជាមួយស្ករ dia selalu*

*minum kopi dengan gula (ឌីយ៉ា សើឡាលូ មីនុម កូពី ដឹង៉ាន់ ហ្គូឡា);*

**-- batu** /ហ្គូឡា បាទូ/ ស្ករផែន: *តែកាន់តែមានរសជាតិឆ្ងាញ់បើផឹកជាមួយស្ករផែន teh lebih nikmat diminum dengan gula batu (តេះ ឡេប៊ិះ និគម៉ាត់ ឌិមីនុម ឌើង៉ាន់ ហ្គូឡា បាទូ);*

**-- merah** /ហ្គូឡា មេរ៉ះ/ ស្ករក្រហម *គាត់ចូលចិត្តថែមស្ករត្នោតទៅក្នុងកាហ្វេរបស់គាត់: dia lebih suka menambahkan gula merah ke kopinya (ឌីយ៉ា ឡេប៊ិះ ស៊ូកា មើណាំបះកាន់ ហ្គូឡា មេរ៉ះ គើ កូពីញ៉ា)*

**guling, berguling-guling** /ប៊ឺរ(r)ហ្គូលីង-ហ្គូលីង/ *v* រមៀល: *កុមារនោះចូលចិត្តរមៀលខ្លួននៅលើវាលស្មៅ anak itu suka berguling-guling di rumput (អាណាក់ អ៊ីទូ ស៊ូកា ប៊ឺរ(r)ហ្គូលិង-ហ្គូលីង ឌិ រូមពុត);*

**menggulingkan** /មើងហ្គូលីងកាន់/ *v* បណ្តើរ: *កុមារនោះបណ្តើរបាល់នៅក្នុងសួនច្បារ anak itu menggulingkan bolanya di taman (អាណាក់ អ៊ីទូ មើងហ្គូលីងកាន់ បូឡាញ៉ា ឌិ តាម៉ាន់)*

**terguling** /ទើរ(r)ហ្គូលីង/ *v* ក្រឡាប់: *រថយន្តក្រឡាប់នៅលើផ្លូវជាតិ truk itu terguling di jalan raya (ទ្រូគ អ៊ីទូ ទើរ(r)ហ្គូលីង ឌិ ចាឡាន់ រ៉ាយ៉ា)*

**gulung** /ហ្គូលុង/ *n* មូល; រុំ; ដុំ: *ដុំព្រំ karpet gulung (ការ(r)ប៉ិត ហ្គូលុង)*

**guna** /ហ្គូណា/ *n* ប្រើប្រាស់;

**berguna** /ប៊ឺរ(r)ហ្គូណា/ *v* ដែលមានប្រយោជន៍: *របស់របរនោះពិតជាមានប្រយោជន៍មែន barang itu sangat berguna (បារាំង អ៊ីទូ សាង៉ាត់ ប៊ឺរ(r)ហ្គូណា);*

**menggunakan** /មើងហ្គូណាកាន់/ *v* ប្រើ: *ខ្ញុំប្រើកុំព្យូទ័រនោះដើម្បីធ្វើការ saya menggunakan komputer itu untuk bekerja (សាយ៉ា មើងហ្គូណាកាន់ កុមព្យូទើរ(r) អ៊ីទូ អ៊ុនទុក ប៊ឺគើរ(r)ចា)*

**guna-guna** /ហ្គូណា ហ្គូណា/ *n* ធ្មប់; មន្តអាគម: *គាត់ត្រូវមន្តអាគមគេ dia terkena guna-guna (ឌីយ៉ា ទើរ(r)គើណា ហ្គូណា–ហ្គូណា)*

**gundul** /ហ្គុនឌុល/ *a* ទំពែក; ឆក; វាលៈ *ព្រៃវាល hutan gundul (ហ៊ូតាន់ ហ្គុនឌុល)*

**gunjing, bergunjing** /ប៊ើរ(r)ហ្គូនជិង/ *v* និយាយដើមគេ: *ពួកគេឧស្សាហ៍និយាយដើមគេនៅក្នុងការិយាល័យ mereka sering bergunjing di kantor (មើរើកា សឺរីង ប៊ើរ(r)ហ្គូនជិង ឌិ កាន់តូរ(r));*

**gunjingan** /ហ្គូនជីង៉ាន់/ *n* ការខ្សឹបខ្សៀវ: *ការខ្សឹបខ្សៀវរបស់ពួកគេគឺមិនមែនជាការពិតឡើយ gunjingan mereka tidak benar (ហ្គូនជីង៉ាន់ មើរើកា ទីដាក់ ប៊ឺណារ(r))*

**gunting** /ហ្គូនទីង/ *n* កន្ត្រៃ: *នាងត្រូវការកន្ត្រៃនោះ dia perlu gunting itu (ឌីយ៉ា ពើរ(r)លូ ហ្គុនទីង អ៊ីទូ);*

**menggunting** /មើងហ្គូនទីង/ *v* កាត់: *គាត់កំពុងតែកាត់ក្រណាត់ខោអាវ dia sedang menggunting bahan baju itu (ឌីយ៉ា សឺដាំង មើងហ្គុនទីង បាហាន់ បាជូ អ៊ីទូ)*

**guntur** /ហ្គុនទូរ(r)/ *n* ផ្គរលាន់: *ថ្ងៃនេះគឺមានផ្គរលាន់ច្រើន hari ini sedang banyak guntur (ហារី អ៊ីនី សឺដាំង បាញ៉ាក់ ហ្គុនទូរ(r))*

**gunung** /ហ្គូនុង/ *n* ភ្នំ: *ភ្នំភ្លើង gunung Merapi (ហ្គូនុង មើរ៉ាពី);*

**pegunungan** /ពើហ្គូនូង៉ាន់/ *n* ភ្នំ: *ប្រជុំភ្នំសេវូ pegunungan Sewu (ពើហ្គូនូង៉ាន់ សេវូ)*

**gurau, bergurau** /ប៊ើរ(r)ហ្គូរ៉ៅ/ *v* និយាយកំប្លែង: *គាត់កំពុងនិយាយកំប្លែង dia senang bergurau (ឌីយ៉ា សឺណាំង ប៊ើរ(r)ហ្គូរ៉ៅ);*

**gurauan** /ហ្គូរ៉ៅវ៉ាន់/ *n* រឿងកំប្លែង: *រឿងកំប្លែងរបស់គាត់ពិតជាអស់សំណើចមែនទែន gurauannya sangat lucu (ហ្គូរ៉ៅវ៉ានញ៉ា សាង៉ាត់ លូជូ)*

**gurih** /ហ្គូរីស(ស)/ *a* ដែលមានឱជារស: *ម្ហូបអាហារនេះគឺពិតជាមានឱជារសមែន makanan itu sangat gurih (ម៉ាកាណាន់ អ៊ីទូ សាង៉ាត់ ហ្គូរីស(ស))*

**gurita** /ហ្គូរីតា/ *n* មឹក: *ប្រជាពលរដ្ឋលក់មឹកនៅក្នុងទីផ្សារបុរាណ orang-orang menjual gurita di pasar tradisional (អូរ៉ាំង-អូរ៉ាំង ម៉ើនជូវ៉ាល់ ហ្គូរីតា ឌិ ប៉ាសារ(r) ត្រាឌិស៊ីយ៉ូណាល់)*

**guru** /ហ្គូរូ/ *n* គ្រូបង្រៀន: *គ្រូគណិតវិទ្យា guru matematika (ហ្គូរូ ម៉ាទើម៉ាទិកា)*

**gurun** /ហ្គូរូន/ *n* **1** វាលរហោស្ថាន: *ទើបតែលើកនេះទេដែលគាត់បានឆ្លងកាត់វាលរហោស្ថាន baru kali ini dia melewati gurun (បារូ កាលី អ៊ីនី ឌីយ៉ា មើលើវ៉ាទី ហ្គូរូន)*; **2** វាលខ្សាច់: *វាលខ្សាច់សាហារ៉ា gurun Sahara (ហ្គូរូន សាហារ៉ា)*

**gusi** /ហ្គូស៊ី/ *n* អញ្ចាញធ្មេញ: *ហើមអញ្ចាញធ្មេញ gusi bengkak (ហ្គូស៊ី ប៊ឹងកាក់)*

**gusur, menggusur (rumah)** /ម៉ើងហ្គូស៊ូរ(r) រូម៉ះ/ *v* រុះរើ; បណ្តេញចេញ: *អាជ្ញាធរមូលដ្ឋានបានរុះរើផ្ទះប្រជាពលរដ្ឋនៅតំបន់នោះ pemerintah daerah menggusur rumah-rumah di kawasan itu (ពើម៉ើរិនតះ ដាអេរ៉ះ ម៉ើងហ្គូស៊ូរ(r) រូម៉ះ-រូម៉ះ ឌិ កាវ៉ាសាន់ អ៊ីទូ)*;

**tergusur** /ទើរ(r)ហ្គូស៊ូរ(r)/ *v* ត្រូវបានរុះរើ; ត្រូវបានបណ្តេញចេញ: *តូបនៅលើផ្លូវនោះត្រូវបានរុះរើ toko di jalan itu tergusur (តូកូ ឌិ ច្យាឡាន់ អ៊ីទូ ទើរ(r)ហ្គូស៊ូរ(r))*

**habis, kehabisan** /គើហាប៊ីសាន់/ *v* អស់:

*គាត់អស់កម្លាំង dia kehabisan tenaga (ឌីយ៉ា គើហាប៊ីសាន់ ទើណាហ្គា)*;

*ពួកគេអស់សាំង mereka kehabisan bensin (មើរេកា គើហាប៊ីសាន់ បេនស៊ីន)*;

**menghabisi** /មើងហាប៊ីស៊ី/ *v* សម្លាប់; បង្ហើយ; ផ្តួល: *គាត់បានផ្តួលគូប្រកួតរបស់គាត់ dia menghabisi lawannya (ឌីយ៉ា មើងហាប៊ីស៊ី ឡាវ៉ាន់ញ៉ា)*;

**menghabiskan** /ម៉ឹងហាប៊ីស(s)កាន់/ *v* ចំណាយ: *នាងចំណាយទាំងអស់លុយរបស់នាងសម្រាប់ទិញសំលៀលបំពាក់ dia menghabiskan semua uangnya untuk membeli baju (ឌីយ៉ា ម៉ឹងហាប៊ីស(s)កាន់ សើមូ៉អ៊ួរ៉ាំងញ៉ា អ៊ុនទុក ម៉ឹមប៊ើលី បាជូ)*

**hadap, berhadapan (dengan)** /ប៊ឺរ(r)ហាដាប៉ាន់/ *v* ទល់មុខ:

*ខ្ញុំអង្គុយទល់មុខជាមួយនិងគាត់ saya duduk berhadapan dengannya (សាយ៉ា ឌូឌុគ ប៊ឺរ(r)ហាដាប៉ាន់ ឌើង៉ាន់ញ៉ា)*;

**menghadap** /មើងហាដាប់/ *v* បែមុខទៅរក:

*សណ្ឋាគារនោះបែមុខទៅរកសមុទ្រ hotel itu menghadap ke laut (ហូតែល អ៊ីទូ មើងហាដាប់ គើ ឡាអ៊ុត)*;

**menghadapi** /មើងហាដាពី/ *v* ប្រឈមមុខ:

*គាត់ត្រូវតែប្រឈមមុខនឹងបញ្ហានេះ dia harus menghadapi masalah itu (ឌីយ៉ា ហារុស(ស) មើងហាដាពី ម៉ាសាឡះ អ៊ីទូ)*

**hadiah** /ហាឌីយ៉ះ/ *n* **1** រង្វាន់; ការជូន:

*រង្វាន់ថ្ងៃខួបកំណើត hadiah ulang tahun (ហាឌីយះ អ៊ូឡាំង តាហុន)*;

**2** អំណោយ:

*ខ្សែកនោះគឺជាអំណោយពីម្តាយរបស់ខ្ញុំ kalung itu hadiah dari ibuku (កាលុង អ៊ីទូ ហាឌិយ៉ះ ដារី អ៊ីប៊ូគូ)*;

**berhadiah** /ប៊ឺរ(r)ហាឌិយ៉ះ/ *v* មានរង្វាន់:

*សំណួរចម្លើយមានរង្វាន់ជាទឹកប្រាក់ប្រាំលានរូពីយ៉ះ kuis berhadiah uang tunai lima juta rupiah (គូវីស(ស) បឺរ(r)ហាឌិយ៉ះ អ៊ូវ៉ាំង ទូណៃ លីម៉ា ជូតា រូពីយ៉ះ);*

**menghadiahkan** /មើងហាឌិយ៉ះកាន់/ *v* ផ្តល់រង្វាន់ឱ្យ:

*អង្គការនោះបានផ្តល់អំណោយជាប្រាក់ខ្លះៗដល់ជនក្រីក្រ organisasi itu menghadiahkan sejumlah uang kepada fakir miskin (អរ(r)ហ្គានីសាស៊ី អ៊ីទូ មើងហាឌិយ៉ះកាន់ ស៊ឺជូម្លះ អ៊ូវ៉ាំង គើប៉ាដា ហ្វាគីរ(r) មីស្គិន)*

**hadir** /ហាឌីរ(r)/ *v* មានវត្តមាន:

*នាងមានវត្តមាននៅក្នុងពិធីខួបកំណើតរបស់ខ្ញុំ ia hadir di pesta ulang tahunku (អ៊ីយ៉ា ហាឌីរ(r) ឌី ប៉េស(s)តា អ៊ូឡាំង តាហ៊ុនគូ);*

**kehadiran** /គើហាឌីរ៉ាន់/ *n* វត្តមាន:

*វត្តមាននៃអភិបាលស្រុកត្រូវបានរង់ចាំដោយប្រជាពលរដ្ឋនៃទីក្រុងនេះ kehadiran bupati dinantikan oleh warga kota itu (គើហាឌីរ៉ាន់ ប៊ូប៉ាទី ឌីណាន់ទីកាន់ អូលេះ វ៉ារ(r)ហ្គា អ៊ីទូ);*

**menghadiri** /ម៉ើងហាឌីរ(r)កាន់/

*v* ចូលរួម:

*ខ្ញុំមិនអាចចូលរួមក្នុងកិច្ចប្រជុំនោះបានទេ saya tidak dapat menghadiri rapat itu (សាយ៉ា ទីដាក់ ម៉ើងហាឌីរី រ៉ាប៉ាត់ អ៊ីទូ)*

**hadirin** /ហាឌីរីន/ *n* អ្នកចូលរួម:

*អ្នកចូលរួមជាច្រើននាក់បានមកចូលរួមក្នុងកម្មវិធីនោះ banyak hadirin yg datang ke acara tersebut (បាញ៉ាក់ ហាឌីរីន យ៉ាំង ដាតាំង គើ អាចារ៉ា ទើរ(r)ស៊ឺប៊ុត)*

**hafal** /ហាហ្វាល់/ *v* **1** ទន្ទិញចាំ:

*គាត់ទន្ទិញចាំទំនុកច្រៀងបទនេះ dia hafal lirik lagu itu (ឌីយ៉ា ហាហ្វាល់ លីរីគ ឡាហ្គូ អ៊ីទូ)*; **2** ស្គាល់ច្បាស់:

*ខ្ញុំស្គាល់ចរិករបស់គាត់ច្បាស់ណាស់ saya hafal sifatnya (សាយ៉ា ហាហ្វាល់ ស៊ីហ្វាត់ញ៉ា);*

**hafalan** /ហាហ្វាឡាន់/ *n* ការសូត្រ:

*ការសូត្រគម្ពីរកូរ៉ាន hafalan Al-Qur'an (ហាហ្វាឡាន់ អាល់គួរ(r)អាន់);*

**menghafal** /មើងហាហ្វាល់/ *v* ចងចាំ: *នាងប្រាប់ខ្ញុំឱ្យចាំលេខទូរស័ព្ទនាង dia memintaku untuk menghafal nomor teleponnya (ឌីយ៉ា មើមិនតាគូ អ៊ុនទុក មើងហាហ្វាល់ ណូម៉ូរ(r) តេលែប៉ុនញ៉ា)*

**haid** /ហាអ៊ីដ/ *n* រដូវ(ស្ត្រី): *អំឡុងពេលមករដូវ masa haid (ម៉ាសា ហាអ៊ីដ)*

**hajar, menghajar** /មើងហាច្បារ(r)/ *v* វាយ: *គាត់ប្រាប់ថាឆ្មាំគុកបានវាយគាត់នៅក្នុងពន្ធនាគារ dia berkata bahwa para penjaga telah menghajarnya dalam penjara (ឌីយ៉ា ប៊ើរ(r)កាតា បះវ៉ា ប៉ារ៉ា ពើនច្យាហ្គា ទើឡះ មើងហាច្យារ(r)ញ៉ា ដាឡាំ ពើនច្យារ៉ា)*

**hajat** /ហាច្យាត់/ *n* **1** ភាពចាំបាច់; តម្រូវការ: *បញ្ហានេះគឺទាក់ទងជាមួយនិងតម្រូវការក្នុងការរស់នៅរបស់មនុស្សជាច្រើន masalah ini berhubungan dengan hajat hidup orang banyak (ម៉ាសាឡះ អ៊ីនី ប៊ើរ(r)ហ៊ូប៊ូង៉ាន់ ឌើង៉ាន់ ហាច្យាត់ ហ៊ីឌុព អូរ៉ាំង បាញ៉ាក់)*; **2** ការប្រារព្ធពិធី: *ផាវបានធ្វើឱ្យការប្រារព្ធពិធីនោះកាន់អឺកកធឹក petasan membuat hajat itu semakin meriah (ពើតាសាន់ មើមប៊ូវ៉ាត់ ហាច្យាត់ អ៊ីទូ សឺម៉ាគិន មើរីយ៉ះ)*; **3** លាមក: *តើអ្នកណាដែលមកបន្ទោបង់នៅក្នុងចំការ? siapa yang membuang hajat di kebun? (ស៊ីយ៉ាប៉ា យ៉ាំង មើមប៊ូវ៉ាំង ហាច្យាត់ ឌិ គើប៊ុន?)*

**[1]hak** /ហាក់/ *n* **1** ត្រឹមត្រូវ: *ពួកគេអាចវិនិច្ឆ័យថាមួយណាយត្រឹមត្រូវនឹងមួយណាខុសហើ mereka telah dapat menilai mana yang hak dan mana yang batil (មើរើកា ទើឡះ ដាប៉ាត់ មើនីឡៃ ម៉ាណា យ៉ាំង ហាក់ ដាន់ ម៉ាណា យ៉ាំង បាទីល)*; **2** សិទ្ធិ: *អ្នកត្រូវតែការពារសិទ្ធិរបស់អ្នក kamu harus membela hak-hakmu (កាមូ ហារុស(ស) មើមបេឡា ហាក់–ហាក់មូ)*;

**berhak** /ប៊ើរ(r)ហាក់/ *v* មានសិទ្ធិ: *មានមានសិទ្ធិដើម្បីផ្លាស់ប្តូរគំនិតរបស់គាត់ dia berhak untuk mengubah*

*pikirannya (ពីយ៉ា ប៊ឺរ(r)ហាក់ អ៊ុនទុក មើងូបះ ពីគីរ៉ាន់ញ៉ា)*

**²hak** /ហាក់/ *n* កែងជើង: *ស្បែកជើងដែលមានកែងខ្ពស់ sepatu dengan hak tinggi (សឺប៉ាទូ ដើង៉ាន់ ហាក់ ទីងហ្គី)*

**hakikat** /ហាគីកាត់/ *n* ធម្មជាតិ: *ធម្មជាតិនៃជីវិត hakikat kehidupan (ហាគីកាត់ គើហ៊ីឌូប៉ាន់)*

**hakim** /ហាគីម/ *n* ចៅក្រម: *ចៅក្រមបានសម្រេចផ្អាកសវនាការរហូតដល់ថ្ងៃអង្គារអាទិត្យក្រោយ hakim menunda sidang hingga Selasa depan (ហាគីម មើនុនដា ស៊ីដាំង ហ៊ីងហ្គា សឺឡាសា ដើប៉ាន់);*

**menghakimi** /មើងហាគីមី/ *v* កាត់ទោស: *ប្រជាពលរដ្ឋក្នុងភូមិបានកាត់ទោសចោរលួចកាបូបដោយខ្លួនឯង warga kampung menghakimi sendiri pencopet itu (វ៉ារ(r)ហ្គា កាំពុង មើងហាគីមី សឺនឌិរី ពើនចូប៉ិត អ៊ីទូ)*

**hal** /ហាល់/ *n* បញ្ហានេះ; ករណី: *ជាធម្មតាខ្ញុំនឹងមិនយល់ស្របទេប៉ុន្តែខ្ញុំនឹងធ្វើឱ្យមានការលើកលែងក្នុងករណីនេះ saya biasanya tidak akan setuju, tetapi saya akan membuat pengecualian dalam hal ini (សាយ៉ា ប៊ីយ៉ាសាញ៉ា ទីដាក់ អាកាន់ សឺទូជូ ទើតាពី សាយ៉ា អាកាន់ មើមប៊ូវ៉ាត់ ពើងើជូវ៉ាលីយ៉ាន់ ដាឡាំ ហាល់ អ៊ីនី)*

**¹halaman** /ហាឡាម៉ាន់/ *n* ទីធ្លា: *ក្មេងៗកំពុងតែលេងនៅក្នុងទីធ្លា anak-anak sedang bermain di halaman (អាណាក់–អាណាក់ សឺដាំង បឺរ(r)ម៉ាអ៊ីន ឌិ ហាឡាម៉ាន់)*

**²halaman** /ហាឡាម៉ាន់/ *n* ទំព័រ: *ទំព័រទីមួយ halaman pertama (ហាឡាម៉ាន់ ពើរ(r)តាម៉ា)*

**halang, berhalangan** /បឺរ(r)ហាឡាង៉ាន់/ *v* មានការរអាក់ខាន; អវត្តមាន: *ប្រសិនបើមានការរអាក់ខានយើងនឹងជំរាបអ្នកឱ្យដឹង jika berhalangan, kami akan memberi kabar*

*(ជីកា បឺរ(r)ហាឡាង៉ាន់ កាមី អាកាន់ មើមបឺរី កាបារ(r));*

**menghalangi** /មើងហាឡាងី/

*v* រាំងស្ទះ: *រថយន្តនោះធ្វើឲ្យរាំងស្ទះផ្លូវ truk itu menghalangi jalan (ទ្រូគ អ៊ីទូ មើងហាឡាងី ចាឡាន់);*

**terhalang** /ទើរ(r)ហាឡាំង/

*v* បាំងដោយ:

*ការមើលឃើញរបស់ខ្ញុំត្រូវបានបាំងទៅដោយបុរស់ខ្ពស់ម្នាក់នៅខាងមុខខ្ញុំ pandanganku terhalang oleh pria tinggi di depanku (ប៉ាន់ដាង៉ាន់គូ ទើរ(r)ហាឡាំង អូលេះ ព្រីយ៉ា ទីងហ្គី ឌិ ឌើប៉ាន់គូ)*

**haluan** /ហាលូវ៉ាន់/ *n* ទិសដៅ:

*ភ្លាមៗនោះយន្តហោះបានផ្លាស់ប្តូរទិសដៅ tiba-tiba pesawat terbang itu mengubah haluan (ទីបា ទីបា ពើសាវ៉ាត់ ទើរ(r)បាង អ៊ីទូ មើងូបះ ហាលូវ៉ាន់)*

**halus** /ហាលុស(s)/ *a* **1** រលោង; ម៉ត់:

*ស្បែករលោង kulit halus (គូលីតហាលូស(s));* **2** ម៉ត់: *អំបិលម៉ត់ garam halus (ហ្គារុំ ហាលុ(ស));*

**3** ដែលមិនអាចមើលឃើញ:

*វិញ្ញាណដែលមើលមិនឃើញ makhluk halus (ម៉ាក់ឃ្លុក ហាលុស(ស));*

**kehalusan** /គើហាលូសាន់/

*n* កលល្បិច: *ចរិកមានកលល្បិច kehalusan sikap (គើហាលូសាន់ ស៊ីកាប់)*

**hamba, hamba sahaya** /ហាំបារ(r) សាហាយ៉ា/ *n* ទាសករ

**hambar** /ហាំបារ(r)/ *a* **1** គ្មានរសជាតិ:

*ស៊ុបនេះគ្មានរសជាតិសោះ sup ini rasanya hambar (ស៊ុប អ៊ីនី រ៉ាសាញ៉ា ហាំបារ(r));* **2** សាប: *រស់ជាតិសាប rasanya hambar (រ៉ាសាញ៉ា ហាំបារ(r))*

**hambat, hambatan** /ហាំបាតាន់/

*n* **1** ឧបសគ្គ; បញ្ហា:

*ពួកគេបានបញ្ចប់ភារកិច្ចដោយគមានឧបសគ្គ mereka menyelesaikan tugas tanpa hambatan (មើរើកា មើញ៉ើលើសៃកាន់ ទូហ្គាស់(ស) តាន់ប៉ា ហាំបាតាន់);*

**2** ឧបសគ្គ; ចរន្ត:

*ពួកគេមិនជួបប្រទះឧបសគ្គអ្វីឡើយនៅតាមផ្លូវ mereka tidak menemukan hambatan apapun dalam perjalanan (មើរេកា ទីដាក់ មើណើមូកាន់ ហាំបាតាន់អាប៉ាពុន ដាឡាម ពើរ(រ)ចា្យឡាណាន់);*

**menghambat** /មើងហាំបាត់/

*v* **1** រាំងស្ទះ:

*អាកាសធាតុអាក្រក់បានធ្វើឲ្យរាំងស្ទះដល់ប្រតិបត្តិការជួយសង្គ្រោះ cuaca buruk menghambat operasi penyelamatan (ជូវ៉ាចា ប៊ូរុគ មើងហាំបាត់ អូពើរ៉ាស៊ី ពើញើឡាម៉ាតាន់);*

**2** រារាំង; រាំងស្ទះ; ធ្វើឲ្យស្ទះ:

*សំរាមធ្វើឲ្យរាំងស្ទះដល់ចរន្តទឹកទន្លេ sampah menghambat aliran sungai (ម៉ើងហាំបាត់);*

**penghambat** /ពើងហាំបាត់/

*n* ឧបសគ្គ; បញ្ហា: *ឧបសគ្គចម្បង penghambat utama (ពើងហាំបាត់ អ៊ូតាម៉ា);*

**terhambat** /ទើរ(r)ហាំបាត់/

*v* ត្រូវបានរាំងស្ទះ:

*ការស៊ើបអង្កេតនេះត្រូវបានរាំងស្ទះដោយសារការបាត់បង់នៃឯកសារទាំងអស់របស់ករណីនេះ penyelidikan terhambat oleh hilangnya semua dokumentasi kasus ini (ហាំបាតាន់ លីស្ទើគ, មើរេកា ទីដាក់ មើណើមូកាន់ ហាំបាតាន់អាប៉ាពុន ដាឡាម ពើរ(រ)ចា្យឡាណាន់)*

**hambur, berhamburan** /ប៊ើរ(r)ហាំប៊ូរ៉ាន់/ *v* **1** ខ្ចាត់ខ្ចាយ;

**2** រត់ខ្ចាត់ខ្ចាយ:

*នៅពេលដែលប៉ូលីសបានមកដល់ឧក្រិដ្ឋជនបានរត់ខ្ចាត់ខ្ចាយអស់ ketika polisi datang, para penjahat itu lari berhamburan (គើទីកា ប៉ូលីស៊ី ដាតាំង ប៉ារ៉ា ពើនចា្យហាត់ អ៊ីទូ ឡារី ប៊ើរ(r)ហាំប៊ូរ៉ាន់);*

**menghamburkan** /មើងហាំប៊ួរ(r)កាន់/ *v* **1** សាបព្រួះ; បាច:

*ការធ្វើចំការគឺត្រូវបានចាប់ផ្តើមដោយការសាបព្រោះគ្រាប់ពូជ berkebun dimulai dengan menghamburkan benih (ប៊ើរ(r)គើប៊ុន ឌិមូឡៃ ឌើង៉ាន់ មើងហាំប៊ួរ(r)កាន់ ប៊ើនីស(ស));*

**2** បាត់បង; ខ្ជះខ្ជាយ:

*វាបានធ្វើឲ្យខ្ជះខ្ជាយទ្រព្យសម្បត្តិមរតករបស់ឪពុក*

*ម្តាយវា ia telah menghamburkan harta warisan orang tuanya (អ៊ីយ៉ា ទើឡះ មើងហាំប៊ួរ(r)កាន់ ហារ(r)តា វ៉ារីសាន់ អូរ៉ាំង ទូវ៉ាញ៉ា )*

**hamil** /ហាមិល/ *v* មានផ្ទៃពោះ; មានគភ៌: *នាងមានផ្ទៃពោះនៅខ្ចី ឬ មានទើបតែនិងមានផ្ទៃពោះ dia hamil muda (ឌីយ៉ា ហាមិល មូដា)*

**hampir** /ហាំពីរ(r)/ *adv* ជិតតែ; ស្ទើរតែ: *គាត់ជិតតែនឹងដួល dia hampir saja jatuh (ឌីយ៉ា ហាំពីរ(r) សាច្យា ច្យាតូះ)*;

**-- saja** /ហាំពីរ(r) សាចា/ ជិតតែ; ស្ទើរតែ: *អ្នកបើកបរម្នាក់នោះជិតតែនឹងបុកមនុស្សម្នាក់ pengemudi itu hampir saja menabrak seseorang (ពើងើមូឌី ហាំពីរ(r) សាច្យា មើណាប្រាក់ ស៊ើសើអូរ៉ាំង)*;

**hampir-hampir**/ហាំពីរ(r)-ហាំពីរ(r)/ *adv* ស្ទើរតែ: *ពួកគេស្ទើរតែភ្លេចធ្វើវា mereka hampir-hampir lupa melakukannya (មើរើកា ហាំពីរ(r)-ហាំពីរ(r) លូប៉ា មើឡាគូកាន់ញ៉ា)*;

**menghampiri** /មើងហាំពីរ(r)/ *v* ទៅកៀក; ទៅជិត: *ខ្ញុំទៅជិតពួកគេស្ងាត់ៗ saya menghampiri mereka diam-diam (សាយ៉ា មើងហាំពីរ(r) មើរើកា ឌីយ៉ាម-ឌីយ៉ាម)*

**hancur** /ហាន់ជួរ(r)/ *v* ខ្ទេចខ្ទី; បែកបាក់: *កញ្ចក់ឡាននេះបានបែកខ្ទេចខ្ទី kaca mobil itu hancur berantakan (កាចា មូប៊ីល អ៊ីទូ ហាន់ជួរ(r) ប៊ើរ៉ាន់តាកាន់)*;

**kehancuran** /គើហាន់ជូរ៉ាន់/ *n* ការបែកបាក់: *អាណាចក្រនេះកំពុងតែធ្លាក់ចូលទៅក្នុងភាពបែកបាក់ kerajaan ini jatuh ke dalam kehancuran (គើរ៉ាច្យាអាន អ៊ីនី ច្យាទុះ គើ ដាឡាំ គើហាន់ជូរ៉ាន់)*;

**menghancurkan** /មើងហាន់ជួរ(r)កាន់/ *v* បំផ្លាញ; កម្ទេច: *របួសបានបំផ្លាញក្តីស្រមៃរបស់នាង cedera menghancurkan mimpinya (ចឺឌើរ៉ា មើងហាន់ជួរ(r)កាន់ មីមពីញ៉ា)*

**handuk** /ហាន់ឌុក/ *n* កន្សែង: *កន្សែងងូតទឹក handuk mandi (ហាន់ឌុក ម៉ាន់ឌិ)*

**hangat** /ហាង៉ាត់/ *a* **1** ក្តៅអ៊ុនៗ: *រំលាយអំបិលជាមួយទឹកក្តៅអ៊ុនៗ larutkan garam dalam air hangat (ឡារូតកាន់ ហ្គារ៉ាម ដាឡាំ អាយីរ(r) ហាង៉ាត់)*; **2** ក្តៅៗ; ភ្លាមៗ: *ទើបានមើលឃើញបញ្ហាក្តៅៗនៅក្នុងទស្សនាវដ្តីVogueរួចហើយនៅ? sudah lihat isu hangat di majalah Vogue? (ស៊ូដះ លីហាត់ អ៊ីស៊ូ ហាង៉ាត់ ឌិ ម៉ាចូឡាឡះ ហ្វូហ្គឺ)*;

**kehangatan** /គើហាង៉ាតាន់/ *n* ភាពកក់ក្តៅ: *ភាពកក់ក្តៅរបស់អ្នកម្តាយ kehangatan seorang ibu (គើហាង៉ាតាន់ សឺអូរ៉ាំង អ៊ីប៊ូ)*;

**menghangatkan** /មើងហាង៉ាត់កាន់/ *v* ធ្វើឲ្យកក់ក្តៅ; កម្តៅសាច់ដុំ: *វាបានដណ្តប់ភួយក្រាស់ដើម្បីធ្វើឲ្យខ្លួនរបស់វាមានភាពកក់ក្តៅ ia memakai selimut tebal untuk menghangatkan tubuhnya (អ៊ីយ៉ា មើម៉ាកាអ៊ី សឺលីមុត ទើបាល់ អ៊ុនទុក មើងហាង៉ាត់កាន់ ទូប៊ុះញ៉ា)*;

**penghangat** /ពើងហាង៉ាត់/ *n* ម៉ាស៊ីន; ឧបករណ៍កំដៅ: *ម៉ាស៊ីន ឧបករណ៍កំដៅបាយ penghangat nasi (ពើងហាង៉ាត់ ណាស៊ី)*

**hanggar** /ហាំងហ្គារ(r)/ *n* ឃ្លាំង: *យន្តហោះនោះនៅក្នុងឃ្លាំងនៅឡើយ pesawat itu masih di hanggar (ពើសាវ៉ាត់ អ៊ីទូ ម៉ាស៊ីះ ឌិ ហាំងហ្គារ(r))*

**hangus** /ហាងុស(s)/ *v* ឆេះខ្មៅខ្មី: *ផ្ទះរបស់នាងត្រូវបានឆេះខ្មៅខ្មីអស់ rumahnya hangus (រូម៉ះញ៉ា ហាងុស(ស))*;

**menghanguskan** /មើងហាងុស្កាន់/ *v* ឆាបឆេះខ្មៅខ្មី: *ភ្លើងបានឆាបឆេះខ្មៅខ្មីផ្ទះមួយចំនួន api menghanguskan beberapa rumah (អាពី មើងហាងុស្កាន់ បឺបឺរ៉ាប៉ា រូម៉ះ)*

**hantam, menghantam** /មើងហាន់តាំ/ *v* បុក: *រថយន្តនោះបានបុកកុងការន័រ mobil itu*

*menghantam truk (ម៉ឺងហាន់តាំ ទ្រុក)*; *កុងកាន័របើកបុករថយន្ត* *truk itu menghantam mobil (ទ្រុក អ៊ីទូ មឹុងហាន់តាំ ម៉ូប៊ិល)*

**hantu** /ហាន់ទូ/ *n* ខ្មោច: *ខ្មោចកូនក្មេង* *hantu anak kecil (ហាន់ទូ អាណាក់ គើជីល)*;

**berhantu** /ប៊ឺរ(r)ហាន់ទូ/ *v* ខហមោច: *ផ្ទះមានខ្មោចលង* *rumah berhantu (រូម៉ះ ប៊ឺរ(r)ហាន់ទូ)*;

**menghantui** /មើងហាន់ទុយ/ *v* លង: *របស់នោះបានលងគាត់* *makhluk itu menghantuinya (ម៉ាឃ្លុគ អ៊ីទូ មើងហាន់ទុយញ៉ា)*

**hanya** /ហាញ៉ា/ *adv* តែមួយ; គ្រាន់តែ; ត្រឹមតែ: *គ្រាន់តែមួយ* *hanya satu (ហាញ៉ា សាទូ)*

**hanyut** /ហាញុត/ *v* រសាត់: *ផ្ទះមួយចំនួនត្រូវបានរសាត់អណ្តែតដោយសារទឹកជំនន់* *beberapa rumah hanyut karena banjir (ប៊ឺប៊ឺរ៉ាប៉ា រូម៉ះ ហាញុត ការ៉ឺណា បាន់ជីរ(r))*;

**menghanyutkan** /មើងហាញុតកាន់/ *v* អូសនាំ: *ទឹកជំនន់បានអូសនាំផ្ទះរបស់ប្រជាពលរដ្ឋនៅក្នុងភូមិ* *banjir menghanyutkan rumah-rumah penduduk desa (បាន់ជីរ(r) មើងហាញុតកាន់ រូម៉ះ–រូម៉ះ ព;នឌូឌុគ ដេសា)*

**hapus, menghapus** /មើងហាពុស (s)/ *v* លុប: *គួរឱ្យសោកស្តាយមែនទែនដែលនាងបានលុបសារនោះចោល* *sayang sekali dia telah menghapus pesan itu (សាយ៉ាំង សឺកាលី ឌីយ៉ា ទើឡះ មើងហាពុស(ស) ពើសាន់ អ៊ីទូ)*; *នាងលុបឯកសាររបស់នាង* *dia menghapus berkasnya (ឌីយ៉ា មឹុងហាពុស(s) ប៊ើរ(r)កាសញ៉ា)*;

**penghapus** /ពើងហាពុស(s)/ *n* ជ័រលុប: *គាត់ភ្លេចយកជ័រលុបទៅតាមនៅពេលប្រលង* *dia lupa membawa penghapus saat ujian (ឌីយ៉ា លូប៉ា មើមបាវ៉ា ពើងហាពុស(s) សាអាត់ អ៊ូជីយ៉ាន់)*;

**terhapus** /ទើ(r)ហាពុស(s)/ *v* លុប: *សញ្ញាសម្គាល់នោះគឺងាយស្រួលក្នុងការលុប tanda itu dengan mudah terhapus (តាន់ដា អ៊ីទូ ដើង៉ាន់ មូដះ ទើរ(r)ហាពុស(s))*

**harap** /ហារ៉ាប់/ *v* សូមមេត្តា: *សូមមេត្តារង់ចាំ harap sabar menunggu (ហារ៉ាប់ សាបារ(r) មើនុងហ្គូ);*

**berharap** /ប៊ឺរ(r)ហារ៉ាប់/ *v* សង្ឃឹម: *ខ្ញុំសង្ឃឹមថានឹងទទួលបានការងារធ្វើនៅក្នុងពីរសប្តាហ៍ទៀត saya berharap mendapatkan pekerjaan dalam dua minggu ke depan (សាយ៉ា ប៊ឺរ(r)ហារ៉ាប់ មើនដាប៉ាត់កាន់ ពើគើរ(r)ចាអាន់ ដាឡាំ ឌូវ៉ា មិងហ្គូ គើ ឌើប៉ាន់);*

**harapan** /ហារ៉ាប់ប៉ាន់/ *n* ក្តីសង្ឃឹម: *ក្រុមរបស់ពួកគេនៅតែមានសង្ឃឹមឈ្នះ tim mereka masih memiliki harapan untuk menang (ទីម មើរើកា ម៉ាស៊ីស មើមីលីគី ហារ៉ាប់ប៉ាន់ អ៊ុនទុក មើណាំង);*

**harap-harap cemas** /ហារ៉ាប់ ហារ៉ាប់ ចឺម៉ាស(s)/ *adv* ភ័យអរ; អន្ទះសា: *ពួកយើងរង់ចាំការសម្រេចចិត្តនោះយ៉ាងអន្ទះសា kami menunggu keputusan itu dengan harap-harap cemas (កាមី មើនុងហ្គូ គើពើពូទូសាន់ អ៊ីទូ ដើង៉ាន់ ហារ៉ាប់-ហារ៉ាប់ ចឺម៉ាស(s));*

**mengharapkan** /មើុងហារ៉ាប់កាន់/ *v* សង្ឃឹម; ប៉ងប្រាថ្នា: *ខ្ញុំសង្ឃឹមថាថ្ងៃនេះនឹងមានភ្លៀងធ្លាក់ saya harap hari ini hujan (សាយ៉ា ហារ៉ាប់ ហារី អ៊ីនី ហ៊ូចាន់)*

**hardik, menghardik** /មើងហារ(r)ឌិគ/ *v* ស្តីបន្ទោស: *សុំទោសខ្ញុំមិនមានបំណងស្តីបន្ទោសអ្នកបែបនេះនោះទេ maaf, aku tidak bermaksud untuk menghardikmu seperti itu (ម៉ាអាហ្វ អាគូ ទីដាក់ ប៊ឺរ(r)ម៉ាក់ស៊ុត អ៊ុនទុក មើងហារ(r)ឌិគមូ សឺពើរ(r)ទី អ៊ីទូ)*

**harga** /ហារ(r)ហ្គា/ *n* តម្លៃ: *តម្លៃទិញដូរ harga komersial (ហារ(r)ហ្គា កុម៉ើរ(r)ស៊ីយ៉ាល់);*

**-- diri** /ហារ(r)ហ្កា ឌិរី/ តម្លៃខ្លួន: *អ្នកត្រូវតែការពារតម្លៃលើខ្លួនរបស់អ្នក kamu harus menjaga harga dirimu (កាមូ ហារុស(ស) ម៉េនចា្យហ្កា ហារ(r)ហ្កា ឌិរីមូ);*

**-- miring** /ហារ(r)ហ្កា មីរីង/ តម្លៃថោក: *ហាងមួយនោះលក់ទំនិញក្នុងតម្លៃថោក toko itu menjual barang dengan harga miring (តូកូ អ៊ីទូ ម៉េនជូវ៉ាល់ បារ៉ាំង ឌើង៉ាន់ ហារ(r)ហ្កា មីរីង);*

**-- pas** /ហារ(r)ហ្កា ប៉ាស/ តម្លៃថេរ; តម្លៃកំណត់; តម្លៃដាច់ថ្លៃ: *ក្រណាត់នោះត្រូវបានលក់ក្នុងតម្លៃដាច់ថ្លៃ kain itu dijual dengan harga pas (កាអ៊ីន អ៊ីទូ ឌិជូវ៉ាល់ ឌើង៉ាន់ ហារ(r)ហ្កា ប៉ាស់(ស));*

**-- pasar** /ហារ(r)ហ្កា ប៉ាសារ(r)/ តម្លៃទីផ្សារ: *តម្លៃទំនិញនៅឯតូបលក់ទំនិញតូចៗមានតម្លៃថោកជាងនៅឯទីផ្សារ harga barang di bazar itu lebih murah daripada harga pasar (ហារ(r)ហ្កា បារ៉ាង ឌិ បាហ្សារ(r) អ៊ីទូឡេប៊ិះ មូរ៉ះ ដារី ប៉ាដា ហារ(r)ហ្កា ប៉ាសារ(r));*

**berharga** /ប៊ឺរ(r)ហារ(r)ហ្កា/ *v* ដែលមានតម្លៃ: *វាគឺជាបទពិសោធន៍ដ៏មានតម្លៃ itu adalah pengalaman yang sangat berharga (អ៊ីទូ អាដាឡះ ពើង៉ាឡាម៉ាន់ យ៉ាំង សាង៉ាត់ ប៊ឺរ(r)ហារ(r)ហ្កា);*

**menghargai** /ម៉ើងហារ(r)ហ្កៃ/ *v* **1** ផ្តល់តម្លៃឱ្យ: *១ខ្ញុំពិតជាឱ្យតម្លៃនូវការជួយរបស់អ្នក aku sangat menghargai bantuanmu (សាគូ អាគូ សាង៉ាត់ ម៉ើងហារ(r)ហ្កៃ បានទូវ៉ាន់មូ ឌូវ៉ា ប៉ាវ៉ា អ) ២អ្នកជំនាញបានឱ្យតម្លៃខ្ពស់ទៅលើវត្ថុបុរាណនោះ para ahli menghargai tinggi benda antik itu (លី ម៉ើងហារ(r)ហ្កៃ ទីងហ្គី បេនដា អាន់ទីគ អ៊ីទូ);* **2** សរសើរ; ផ្តល់តម្លៃ: *ខ្ញុំសុំសរសើរការធ្វើការរបស់គាត់ saya menghargai kerjanya (សាយ៉ា ម៉ើងហារ(r)ហ្កៃ គើរ(r)ចា្យញ៉ា);*

**penghargaan** /ពើងហារ(r)ហ្កាអាន/ *n* **1** តម្លៃ; រង្វាន់: *នាងមិនសូវផ្តល់តម្លៃឱ្យតន្ត្រីសម័យដើមនោះទេ dia kurang memberikan penghargaan terhadap musik klasik (ឌីយ៉ា គូរ៉ាំង ម៉ើមប៊ឺរីកាន់ ពើងហារ(r)ហ្កាអាន ទើ(r)ហាដាប់ មូស៊ិគ ក្លាស៊ិគ);*

**2** /ប៉ឹងហារ(r)ហ្កាអាន/ រង្វាន់: *រង្វាន់សិស្សពូកែ penghargaan murid berprestasi (ប៉ឹងហារ(r)ហ្កាអាន មូរីត ប៊ើរ(r)ប្រិស(s)តាស៊ី)*

**hari** /ហារី/ *n* ថ្ងៃ: *ថ្ងៃចុងក្រោយ hari terakhir (ហារី តើរ(r)អាក់ហឺរ(r));*

**-- jadi** /ហារី ចា្យឌិ/ ថ្ងៃខួប: *ថ្ងៃខួបអាពាហ៍ពិពាហ៍ hari jadi pernikahan (ហារី ចា្យឌិ ពើរ(r)នីកាហាន់);*

**-- kerja** /ហារី គើរ(r)ចា្យ/ ថ្ងៃធ្វើការ: *ការងារនេះនឹងត្រូវបញ្ចប់ក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការ pekerjaan ini harus diselesaikan dalam waktu lima hari kerja (ពើគើរ(r)ចា្យអាន់ អ៊ីនី ហារុស(ស) ឌិសឺលើសៃកាន់ ដាឡាំ វ៉ាក់ទូ លីម៉ា ហារី គើរ(r)ចា្យ);*

**-- libur** /ហារី លីប៊ូរ(r)/ ថ្ងៃឈប់សម្រាក: *ថ្ងៃស្អែកជាថ្ងៃឈប់សម្រាករបស់ខ្ញុំ besok adalah hari liburku (បែសុក អាដាឡះ ហារី លីប៊ូរ(r)គូ);*

**-- raya** /ហារី រ៉ាយ៉ា/ ថ្ងៃបុណ្យ; ថ្ងៃឈប់សម្រាក: *បុណ្យណូអែលគឺជាថ្ងៃឈប់សម្រាករបស់ពួកគ្រីស្ទាន Natal adalah hari raya umat Kristen (ណាតាល់ អាដាឡះ ហារី រ៉ាយ៉ា អ៊ូម៉ាត់ គ្រីស្ទេន);*

**-- ulang tahun** /ហារី អ៊ូឡាំង តាហ៊ុន/ ថ្ងៃខួបកំណើត: *ម្សិលមិញគឺជាថ្ងៃខួបកំណើតរបស់ខ្ញុំ kemarin adalah hari ulang tahunku (គើម៉ារិន អាដាឡះ ហារី អ៊ូឡាំង តាហ៊ុនគូ);*

**harian** /ហារីយ៉ាន/ *n* ប្រចាំថ្ងៃ: *សកម្មភាពប្រចាំថ្ងៃ aktivitas harian (អាក់ទីវីតាស់(s) ហារីយ៉ាន);*

**seharian** /សឺហារីយ៉ាន់/ *n* មួយថ្ងៃពេញ: *មួយថ្ងៃពេញខ្ញុំបានធ្វើកិច្ចការផ្ទះ saya seharian mengerjakan pekerjaan rumah (សាយ៉ា សឺហារីយ៉ាន់ មើងើរ(r)ចា្យកាន់ ពើគើរ(r)ចា្យអាន រូម៉ះ);*

**sehari-hari** /សឺហារី–ហារី/ *n* ជារៀងរាល់ថ្ងៃ; ប្រចាំថ្ងៃ: *គាត់បានទិញកុំព្យូទ័រសាមញ្ញមួយសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ dia membeli komputer sederhana untuk keperluan sehari-hari (ឌីយ៉ា មើមបឺលី គុមព្យូទើរ(r) សឺឌើរ(r)ហាណា អ៊ុនទុក គើពើរ(r)លូវ៉ាន់ សឺហារី–ហារី)*

**harta** /ហារ(r)តា/ *n* ទ្រព្យសម្បត្តិ: *គ្រួសារគឺជាទ្រព្យសម្បត្តិដែលមិនអាចកាត់ថ្លៃបាន keluarga adalah harta yang tak ternilai (គើលូវ៉ារ(r)ហ្គា អាដាឡះ ហារ(r)តា យ៉ាំង តាក់ ទើរ(r)នីឡៃ);*

**-- karun** /ហារ(r)តា ការុន/ កំណប់: *មានពាក្យចចាមអារ៉ាមជាច្រើនអំពីកំណប់ដែលគេកប់នៅក្នុងភូមិនេះ ada banyak rumor mengenai harta karun terpendam di desa itu (អាដា បាញ៉ាក់ រូម៉ូរ(r) មើងើណៃ ហារ(r)តា ការុន ទើរ(r)ពើនដាំ ឌិ ដេសា អ៊ីទូ);*

**-- pusaka** /ហារ(r)តា ពូសាកា/ កេរ្តិ៍មរតក: *ខ្សែកនោះគឺជាកេរ្តិ៍មរតករបស់គ្រួសារនាង kalung itu adalah harta pusaka keluarganya (កាលុង អ៊ីទូ អាដាឡះ ហារ(r)តា ពូសាកា គើលូវ៉ារ(r)ហ្គាញ៉ា)*

**haru, terharu** /ទើរ(r)ហារូ/ *v* ក្តុកក្តួល: *នាងក្តុកក្តួលនៅក្នុងចិត្តដោយសារតែការទទួលដ៏កក់ក្តៅរបស់ពួកគេ dia terharu oleh sambutan hangat mereka (ឌីយ៉ា ទើរ(r)ហារូ អូលេះ សាំប៊ូតាន់ ហាង៉ាត់ មើរើកា)*

**harum** /ហារុម/ *a* ក្រអូប: *ផ្កាក្រអូប bunga-bunga yang harum (ប៊ូង៉ា–ប៊ូង៉ា យ៉ាំង ហារុម)*

**harus** /ហារុស(s)/ *adv* ត្រូវតែ: *អ្នកត្រូវតែប្រញាប់ញ៉ាំអាហារនូវពេលដែលអ្នកខ្លាន kamu harus segera makan saat lapar (កាមូ ហារុស សើហ្គើរ៉ា ម៉ាកាន់ សាអាត់ ឡាប៉ារ(r));*

**seharusnya** /សើហារ៉ូស(s)ញ៉ា/ *adv* គួរតែ: *វាគួរតែរៀន dia seharusnya belajar (ឌីយ៉ា សើហារុសញ៉ា បើឡាច្យារ(r))*

**hasil** /ហាស៊ីល/ *n* លទ្ធផល: *លទ្ធផលតេសសុខភាពរបស់គាត់គួរជាទីពេញចិត្ត*

 hasut, menghasut

*hasil tes kesehatannya sangat memuaskan (ហាស៊ីលតែស(s)); តើសេហាតាន់ញ៉ា សាងាត់ មើម្វ៉ាស់(s)កាន់);*

**-- bumi** /ហាស៊ីល ប៊ូមី/

ផលិតផលកសិកម្ម:

*តែគឺជាផលិតផលមួយនៃផលិតផលកសិកម្មដែលល្អបំផុតរបស់ឥណ្ឌូនេស៊ី teh adalah salah satu hasil bumi terbaik Indonesia (តេះ អាដាឡះ សាឡះ សាទូ ហាស៊ីល ប៊ូមី ទើរ(r)បាអ៊ីគ ឥណ្ឌូនេស៊ីយ៉ា );*

**berhasil** /បើរ(r)ហាស៊ីល/ *v* ជោគជ័យ:

*នាង ជោគជ័យយកឈ្នះទៅលើគូប្រជែងរបស់នាង dia berhasil mengalahkan lawannya (ឌីយ៉ា បើរ(r)ហាស៊ីល មើង៉ាឡះកាន់ញ៉ា);*

**keberhasilan** /គើបឺរ(r)ហាស៊ីឡាន់/

*n* ភាពជោគជ័យ:

*ការជឿជាក់លើខ្លួនឯងគឺជាគន្លឹះក្នុងការទទួលបានជោគជ័យ kepercayaan diri adalah kunci keberhasilan (គើពើរ(r)ចាយ៉ាអាន ឌិរី អាដាឡះ គុនជី គើបឺរ(r)ហាស៊ីឡាន់);*

**menghasilkan** /មើុងហាស៊ីលកាន់/

*v* **1** ផលិត: *គោផលិតទឹកដោះគោ sapi menghasilkan susu (សាពី មើុងហាស៊ីលកាន់ស៊ូស៊ូ);*

**2** ផលិត; បង្កើត:

*ទួរប៊ីនខ្យល់គេប្រើសម្រាប់ផលិតថាមពលអគ្គិសនី turbin angin itu digunakan untuk menghasilkan listrik (ទួរ(r)ប៊ីន អាង៉ីន អ៊ីទូ ឌិហ្គុណាកាន់ អ៊ុនទុក មើងហា ស៊ីលកាន់ លីស្ទ្រីគ);* **3** ផ្តល់ផល: *ដីនោះផ្តល់ផលដំណាំបានល្អ lahan itu menghasilkan tanaman yang bagus (ឡាហាន់ អ៊ីទូ មើងហាស៊ីលកាន់ តាណាំម៉ាន់ យ៉ាំង បាហ្គុស(ស));*

**penghasilan** /ពើងហាស៊ីឡាន/

*n* ប្រាក់ចំណូល:

*ប្រាក់ចំណូលរបស់គាត់គឺគ្រប់គ្រាន់សម្រាប់ទទួលទានតែប៉ុណ្ណោះ penghasilannya hanya cukup untuk makan (ពើងហាស៊ីឡានញ៉ា ហាញ៉ា ជូគុប អ៊ុនទុក ម៉ាកាន់)*

**hasut, menghasut** /មើងហាស៊ុត/

*v* ញុះញង់:

*គាត់បានញុះញង់ប្រជាពលរដ្ឋឱ្យប្រព្រឹត្តអំពើអនាធិបតេយ្យ dia menghasut warga untuk bertindak anarki (ឌីយ៉ា ម៉េងហាស៊ុត វ៉ារ(r)ហ្គា អ៊ុនទុក ប៊ើ(r)ទីនដាក់ អាណារ(r)គី);*

**penghasut** /ពើងហាស៊ុត/

*n* អ្នកញុះញង់:

*គាត់ត្រូវបានគេកំណត់មុខសញ្ញាថាគឺជាអ្នកញុះញង់ dia dicap sebagai penghasut (ឌីយ៉ា ឌិចាប់ ស៊ើបាហ្គៃ ពើងហាស៊ុត)*

**hati** /ហាទី/ *n* **1** ថ្លើម: *ថ្លើមមាន់ hati ayam (ហាទី អាយ៉ុំ);* **2** ថ្លើម; ចិត្ត:

*គាត់ទើបតែខូចចិត្ត dia baru saja patah hati (ឌីយ៉ាបារូសាចាប៉ាតាហហាទី);*

**perhatian** /ពើរ(r)ហាទីយ៉ាន/

*n* ការយកចិត្តទុកដាក់:

*ក្មេងម្នាក់នោះមិនសូវទទួលបាននូវការយកចិត្តទុកដាក់ពីឪពុកម្តាយរបស់នាងឡើយ*

*anak itu kurang mendapat perhatian dari orang tuanya (អាណាក់ អ៊ីទូ គូរ៉ាំង ម៉ើនដាប៉ាត់ ពើរ(r)ហាទីយ៉ានដារី អូរ៉ាំង ទូវ៉ាញ៉ា);*

**hati-hati** /ហាទី-ហាទី/

*adv* ប្រុងប្រយ័ត្ន:

*អ្នកត្រូវតែប្រុងប្រយ័ត្ននៅពេលបើកបររថយន្ត kamu harus hati-hati saat mengendarai mobil (កាមូ ហារុស ហាទី-ហាទី សាអាត់ មើង៉ើនដារ៉ៃម៉ូប៊ីល);*

**memperhatikan** /ម៉ើមពើរ(r)ហាទីកាន់/ *v* យកចិត្តទុកដាក់:

*វាមិនយកចិត្តទុកដាក់រៀនសូត្រនៅក្នុងថ្នាក់សោះ: dia tidak memperhatikan pelajaran di kelas (ឌីយ៉ា ទិដាក់ ម៉ើមពើរ(r)ហាទីកាន ពើឡាចារ៉ាន់ ឌីក្លាស(s))*

**haus** /ហាអ៊ុស(s)/ *a* ស្រេកទឹក: *ខ្ញុំស្រេកទឹក saya haus (សាយ៉ា ហាអុស(s))*

**hawa, hawa nafsu** /ហាវ៉ា ណាហ្វស៊ូ/

*n* តណ្ហា; ចំណង់:

*គាត់មិនអាចទប់ចំណង់របស់គាត់បាន*

*ia tidak dapat menahan hawa nafsunya (អ៊ីយ៉ា ទីដាក់ ដាប៉ាត់ ម៉ើណាហាន់ ហាវ៉ា ណាហ្វស៊ូញ៉ា)*

**hayat** /ហាយ៉ាត/ *n* ជីវិត:

*ការសិក្សាពេញមួយជីវិត pendidikan*

*sepanjang hayat (ពេនជិជិកាន់ សីប៉ាន់ច្បាំង ហាយ៉ាត);*

**menghayati** /មើងហាយ៉ាទី/ *v* យល់: *យើងទាំងអស់គ្នាត្រូវតែយល់និងអនុវត្ត នូវប៉ាញ់ចាក់សីឡា* *kita semua harus menghayati dan mengamalkan Pancasila (គីតា សឹមួរ៉ា ហារុស(ស) មើងហាយ៉ាទី ដាន់ មើង៉ាម៉ាល់កាន់ ប៉ាន់ចាស៊ីឡា)*

**hebat** /ហេបាត់/ *a* អស្ចារ្យ: *គំនិតដ៏អស្ចារ្យ* *ide yang hebat (អ៊ីដេ យ៉ាំង ហេបាត់);*

**kehebatan** /គើហេបាតាន់/ *n* ភាពអស្ចារ្យ: *គាត់មិនបានទទួលស្គាល់ភាពអស្ចារ្យរបស់កីឡាករនោះឡើយ* *dia tidak mengakui kehebatan pemain itu (ឌីយ៉ា ទីដាក់ មើង៉ាគូអ៊ី គើហេបាតាន់ ពើម៉ាអ៊ីន អ៊ីទូ)*

**hektare** /ហិកតារ(r)/ *n* ហិតា: *ដីមួយហិតា* *satu hektare tanah (សាទូ ហិកតារ(r) តាណះ)*

**hela, menghela (napas)** /មើងហេឡា ណាប៉ាស់(s)/ *v* ដកដង្ហើមឱ្យវែងៗ: *គ្រូពេទ្យបានបង្គាប់ខ្ញុំឱ្យដកដង្ហើមវែងៗ* *dokter menyuruh saya untuk menghela napas dalam-dalam (ដុកទើរ(r) មើញូរុះ សាយ៉ា អ៊ុនទុក មើងហេឡា ណាប៉ាស់(s) ដាឡាំ–ដាឡាំ)*

**helikopter** /ហេលីកុបទើរ(r)/ *n* ឧទ្ធម្ភាគចក្រ: *ខ្ញុំលឺសម្លេងឧទ្ធម្ភាគចក្រ* *aku mendengar suara helikopter (អាគូ ម៉ើនដឹងារ(r) ស៊ូវ៉ារ៉ា ហេលីកុបទើរ(r))*

**helm** /ហិលឡឹម/ *n* មួកសុវត្ថិភាព: *មួកសុវត្ថិភាពធំ* *helm besar (ហិលឡឹម បែសារ(r))*

**hemat** /ហេម៉ាត់/ *a* ដែលសន្សំសំចៃ: *ពួកគេគឺជាអ្នកទិញដែលសន្សំសំចៃបំផុត* *mereka pembeli yang hemat (មើរីកា ពើមបឺលី យ៉ាំង ហេម៉ាត់);*

*យើងខ្ញុំមានលក់នូវក្រណាត់គ្រប់ប្រភេទ dia menjual berjenis-jenis kain (កាមី ម៉ឺនជួវ៉ាល បើរ(r)ចឿនិស(s)ចឿនីស(s) កាអ៊ិន);*

**sejenis** /សឺជើនីស(s)/ **1** *a* ដូចគ្នា:

*អាចដែរអារម្មណ៍របស់អ្នកដូចគ្នាទៅនិងសេចក្តីស្រឡាញ់ mungkin saja perasaanmu itu sejenis cinta (មូងគិន សាចា្យ ពើរ៉ាសាអានមូ អ៊ីទូ សឺជើនីស(ស) ជិនតា)*; **2** *n* ប្រភេទ:

*សត្វនេះគឺជាប្រភេទសត្វល្មូន hewan ini adalah sejenis reptil (ហេវ៉ាន់ អ៊ីនី អាដាឡះ សឺជើនីស រេបទីល)*

**jenjang** /ជើនច្យាំង/ *n* កម្រិត:

*មានកម្រិតជាច្រើននៅក្នុងវគ្គសិក្សានេះ*

*ada berbagai jenjang dalam kursus itu (អាដា  បឺរ(r)បាហ្គៃ*

*ជើនច្យាំង ដាឡាំ គួរ(r)ស៊ូស(ស) អ៊ីទូ);*

**-- pendidikan** /ជើនច្យាំង ប៊ិនឌិឌិ-

កាន់/ កម្រិតក្នុងការអប់រំ;

**berjenjang** /បឹរ(r)ជើងច្យាំង/

*v* ដែលមានកម្រិត: *កម្រិតក្នុងការរកស៊ី*

*karier berjenjang (ការីយៀរ(r)*

*បឺរ(r)ជើនច្យាំង)*

**jenuh** /ជើនុះ/ *a* ឆ្អែត:

*ខ្ញុំមានអារម្មណ៍ថាឆ្អែតធ្វើការនៅក្នុងក្រុមហ៊ុននោះ*

*aku jenuh bekerja di perusahaan itu (អាគូ ជើនុះ*

*បើគើរ(r)ច្យា ឌិ ពើរូសាហាអាន អ៊ីទូ)*

**jepit, jepit rambut** /ជើពីត រ៉ាំប៊ុត/

*n* ដង្កៀបសក់: *ប្អូនស្រីរបស់ខ្ញុំចូលចិត្តប្រើដង្កៀប*

*សក់ saudara perempuan saya*

*senang mengenakan jepit rambut (សៅដារ៉ា ពើរ៉ើមពូវ៉ាន សាយ៉ា*

*សឺណាំង មើងើណាកាន់ ជើពិត រ៉ាំប៊ុត);*

**menjepit** /មើនជើពីត/ *v* គៀប:

*នាងគៀបសក់របស់នាងជាមួយនិងដង្កៀបសក់*

*dia menjepit rambutnya dengan jepit rambut (ឌីយ៉ា*

*មើនជើពិត រ៉ាំប៊ុតញ៉ា ឌើង៉ាន់ ជើពិត រ៉ាំប៊ុត);*

**penjepit** /ពើនជើពីត/ *n* ដង្កៀប:

*ពួកគេយកនុំនៅលើតុដោយប្រើដង្កៀប*

*mereka mengambil kue di meja dengan menggunakan penjepit (មើរេកា មើង៉ាំប៊ីល គូវេ ឌិ មើច្យា*

*ឌើង៉ាន់ មើងហ្គូណាកាន់ ពើនជើពិត)*

**jerami** /ជើរ៉ាមី/ *n* ស្បូវ: *ខ្ទមនោះធ្វើពីស្បូវ*

*gubuk itu terbuat dari jerami (ហ្គូប៊ុក អ៊ីទូ ទើរ(r)ប៊ូវ៉ាត់ ដារី ជើរ៉ាមី)*

**jerat** /ជើរ៉ាត់/ *n* អង្គប់; អន្ទាក់: *អន្ទាក់សត្វ*

*jerat binatang (ជើរ៉ាត់ ប៊ីណាតាំង);*

**menjerat** /មើនជើរ៉ាត់/ *v* ចាប់:

*កសិករចាប់កណ្ដុរដោយប្រើអន្ទាក់ឫស្សី*

*petani menjerat tikus dengan perangkap bambu (ពើតានី*

*មើនជើរ៉ាត់  ទីគុស(ស) ឌើង៉ាន់ ពើរ៉ាំងកាប់ បាំប៊ូ);*

**terjerat** /ទើរ(r)ជើរ៉ាត់/ *v* ជាប់:

*សត្វក្ដាន់នោះជាប់នៅក្នុងគម្ពោតព្រៃ rusa*

*itu terjerat di semak-semak (រូសា អ៊ីទូ ទើរ(r)ជើរ៉ាត់ ឌិ សឺម៉ាក់–សឺម៉ាក់)*

**jerawat** /ជើរ៉ាវ៉ាត់/ *n* មុន:

*មុខរបស់នាងពោពេញទៅដោយមុន*

*wajahnya penuh dengan jerawat (វ៉ាច្យ៉ះញ៉ា ពើនុះ ឌើង៉ាន់ ជើរ៉ាវ៉ាត់)*

**jerit, jeritan** /ចឿរីតាន់/ *n* សម្រែក: *គ្មាននរណាម្នាក់បានលឺនូវសម្រែករបស់នាងឡើយ tak seorang pun mendengar jeritannya (តាក់ សើអូរ៉ាំង ពុន ម៉ឺនដឹងារ(r) ចឿរីតាន់ញ៉ា);*

**menjerit** /ម៉ឺនចឿរីតា/ *v* ស្រែក: *នាងស្រែកដោយសារការឈឺចាប់ dia menjerit kesakitan (ឌីយ៉ា ម៉ឺនចឿរីត គើសាគីតាន់)*

**jernih** /ជើរ(r)នីះ/ *a* ភ្លឺថ្លា: *កញ្ចក់អេក្រង់ទូរទស្សន៍នោះភ្លឺថ្លា televisi itu jernih layarnya (តេឡេហ្វីស៊ី អ៊ីទូ ជើរ(r)នីស(ស) ឡាយ៉ារ(r)ញ៉ា)*

**jeruji** /ជើរូជី/ *n* ជន្លង់; ទ្រុង: *ជន្លង់ដែក jeruji besi (ជើរូជី បឺស៊ី)*

**jeruk** /ជើរុគ/ *n* ក្រូច: *ផ្លែក្រូចមានផ្ទុកទៅដោយវីតាមីន C jeruk mengandung vitamin C (ជើរុគ មើង៉ាន់ឌុង ហ្វីតាមីន ចេ);*

**-- nipis** /ជើរុក នីពីស(s)/ ក្រូចឆ្មា: *ទឹកក្រូចឆ្មាគឺល្អសម្រាប់សុខភាព air jeruk nipis baik untuk kesehatan (អាយីរ(r) ជើរុគ នីពិស(ស) បាអ៊ិគ អ៊ុនទុក គើសីហាតាន់)*

**jerumus, menjerumuskan** /មើនជើរូមូស្កាន់/ *v* ធ្វើអោយធ្លាក់ខ្លួន: *គាត់បានធ្វើឱ្យមិត្តភក្តិរបស់គាត់ធ្លាក់ខ្លួនក្លាយទៅជាអ្នកប្រើប្រាស់គ្រឿងញៀន dia telah menjerumuskan temannya untuk menjadi pengguna narkoba (ឌីយ៉ា ទើឡះ មើនជើរូមូស្កាន់ ទើម៉ាន់ញ៉ា អ៊ុនទុក មើនចាឌិ ពើងហ្គូណា ណារ(r)កូបា)*

**jewer, menjewer** /មើនជើវើរ(r)/ *v* មួរ; កិច: *ម្តាយបានមួរត្រចៀកកូនរបស់គាត់ដែលខូច ibu menjewer kuping anaknya yang nakal (អ៊ីប៊ូ មើនជើវើរ(r) គូពិង អាណាក់ញ៉ា យ៉ាំង ណាកាល់)*

**jidat** /ជីដាត់/ *n* ថ្ងាស: *ថ្ងាសរបស់វាបានហើមបន្ទាប់ពីបុកជាមួយឈើ jidatnya bengkak setelah terbentur pintu kayu itu (ជាហ៊ីញ៉ា បឹងកាក់ សឺទើឡះ ទើរ(r)បឹនទូរ(r) ពិនទូ កាយូ អ៊ីទូ)*

**jijik** /ជីជិគ/ *a* ខ្ពើម; ជិនឬក: *ខ្ញុំជិនឬកឯចរិករបស់គាត់ saya jijik dengan perilakunya (សាយ៉ា ជីជិគ ឌើង៉ាន់ ពើរីឡាគូញ៉ា);*

**menjijikkan** /មើនជីជិកាន់/

*v* គួរឱ្យស្អប់ខ្ពើម: *ចរិកដេលគួរឱ្យស្អប់ខ្ពើម*

*perilakunya menjijikkan (ពើរីឡាគូញ៉ា មើនជីជិកាន់)*

**jika** /ជ្សីកា/ *p* ប្រសិនបើ:

*ប្រសិនបើខ្ញុំមានលុយខ្ញុំចង់ទៅកំសាន្តនៅអឺរ៉ុប*

*jika saya punya uang, saya ingin berlibur ke Eropa (ជ្សីកា សាយ៉ា ពូញ៉ា អ៊ូរ៉ាំង សាយ៉ា អ៊ីងិន បើរ(r)លីប៊ូរ(r) គើអេរ៉ូប៉ា);*

*ប្រសិនបើនាងមកខ្ញុំនិងប្រាប់អ្នក jika dia datang, aku akan memberitahumu (ជ្សីកា ឌីយ៉ា ដាតាំង អាគូ អាកាន់ ម៉ឺមបើរីតាវម៉ូ)*

**jikalau** /ជីកាឡៅ/ *p* ប្រសិនបើ:

*ប្រសិនបើគ្មានភ្លៀងទេខ្ញុំនិងទៅផ្ទះរបស់អ្នក*

*jikalau hujan tidak turun, saya akan datang ke rumah Anda (ជីកាឡៅ ហ៊ូច្សាន់ ទីដាក់ ទូរុន សាយ៉ា អាកាន់ ដាតាំង គើ រូម៉ះ អានដា)*

**jilat, menjilat** /មើនជីឡាត់/ *v* លិទ្ធ:

*ក្មេងនោះលិទ្ធការ៉េមដែលតក់ទៅលើដៃរបស់វា*

*anak itu menjilat es krim yang menetes di tangannya (អាណាក់ អ៊ីទូ មើនជីឡាត់ អែស្គ្រីម យ៉ាំង មើណែតែស(ស) ឌិ តាង៉ាន់ញ៉ា);*

**penjilat** /ពើនជីឡាត់/ *n* អ្នកបញ្ចោរ:

*កុំធ្វើមិត្តជាមួយអ្នកដែលពូកែបញ្ចោរ*

*jangan berteman dengan seorang penjilat (ច្សាង៉ាន់ បឺរ(r)ទើម៉ាន់ ឌើង៉ាន់ សឺអូរ៉ាំង ពើនជីឡាត់)*

**jilid** /ជីលីត/ *n* ភាគ:

*ភាគទីមួយនៃសៀវភៅនេះគឺសប្បាយក្នុងការអាន*

*jilid pertama buku ini sangat menyenangkan untuk dibaca (ជីលីត ពើរ(r)តាម៉ា ប៊ូគូ អ៊ីនី សាង៉ាត់ មើញ៉ើណាំងកាន់ អ៊ុនទុក ឌិបាចា)*

**jinak** /ជីណាក់/ *a* ផ្សាំង: *ឆ្កែផ្សាំង anjing jinak (អាន់ជិង ជីណាក់);*

**menjinakkan** /មើនជីណាក់កាន់/

*v* ធ្វើឱ្យសាំង:

*គាត់ជោគជ័យធ្វើឱ្យសត្វព្រៃនោះសាំង dia berhasil menjinakkan binatang buas itu (ឌីយ៉ា បើរ(r)ហាស៊ីល មើនជីណាក់កាន់ ប៊ីណាតាំង ប៊ូវ៉ាស់(ស) អ៊ីទូ)*

**jiplak, menjiplak** /មើនជីប្លាក់/ *v* ចម្លង:

*ពួកយើងមិនត្រូវបានអនុញ្ញាតឱ្យលួចចម្លងសំនេររបស់អ្នកដ៏ទៃឡើយ kita tidak diperbolehkan menjiplak tulisan orang lain (គីតា ទីដាក់*

*ឌិពើរ(r)បូលេះកាន់ មើនជីផ្លាក់ ទូលីសសាន់ អ្នូរាំង ឡាអ៊ីន);*

**penjiplak** /ពើនជីប្លាក់/ *n* ម៉ាស៊ីនថតចម្លង; អ្នកថតចម្លង: *អ្នកលួចថតចម្លងនោះទីបំផុតត្រូវបានគេប្តឹងទៅតុលាការ penjiplak itu akhirnya dituntut ke pengadilan (ពើនជីផ្លាក់ អ៊ីទូ អាក់ហឺរ(r)ញ៉ា ឌិទុនទុត គើ ពើង៉ាឌីឡាន់)*

**jitu** /ជីទូ/ *a* ត្រង់: *បាញ់ត្រង់ tembakan jitu (តែមបាកាន់ ជីទូ)*

**jiwa** /ជ្វីវ៉ា/ *n* ព្រលឹង: *រូបព្រលឹង jiwa dan raga (ជ្វីវ៉ា ដាន់ រ៉ាហ្កា);*

**-- raga** /ជីវ៉ា រ៉ាហ្កា/ ខ្លួនប្រាណ: *ខ្ញុំស្រលាញ់អ្នកអស់ពីខ្លួនប្រាណ aku mencintai kamu jiwa raga (អាគូ មើនជីនតៃ កាមូ ជីកា រ៉ាហ្កា)*

**menjiwai** /មើនជីវ៉ៃ/ *v* ចម្រុញចិត្តអោយចង់: *តារាចម្រៀងរូបនេះពិតជាធ្វើឲ្យបទចម្រៀងដែលនាងយកមកច្រៀងមានភាពរស់រវើកមែន penyanyi itu sangat menjiwai lagu yang dibawakannya (ពើនញ៉ាញី អ៊ីទូ សាង៉ាត់ មើនជីវ៉ៃ ឡាគូ យ៉ាំង ឌិបាវ៉ាកាន់ញ៉ា)*

**jodoh** /ច្យូដុះ/ *n* គូរព្រេង: *បុរសម្នាក់នោះបានជួបគូព្រេងរបស់គាត់ lelaki itu sudah menemukan jodohnya (ឡឺឡាគី អ៊ីទូ ស៊ូដះ មើនើមូកាន់ ច្យូដុះញ៉ា);*

**berjodoh** /បឺរ(r)ច្យូដុះ/ *v* វាសនា; និស្ស័យ: *ប្រសិនបើមានវាសនាខ្ញុំចង់ធ្វើឲ្យនាងក្លាយទៅជាភរិយារបស់ខ្ញុំ seandainya berjodoh, saya ingin menjadikannya istriku (សេអាន់ដៃញ៉ា បឺរ(r)ច្យូដុះ សាយ៉ា អ៊ីងីន មើនច្យាឌិកាន់ញ៉ា អ៊ីស្ទ្រីគូ);*

**menjodohkan** /មើនច្យូដុះកាន់/ *v* ផ្គូផ្គង; ផ្សំផ្គុំ: *ពួកគេបានផ្សំផ្គុំនារីម្នាក់នោះជាបុរសវ័យចំណាស់ mereka menjodohkan wanita itu dengan lelaki yang lebih tua (មើរេកា មើនច្យូដុះកាន់ វ៉ានីតា អ៊ីទូ ឌើង៉ាន់ ឡឺឡាគី យ៉ាំលើប៊ិះ ទូវ៉ា)*

**joget, berjoget** /បឺរ(r)ច្យូហ្គេត/ *v* រាំ: *ក្រុមហ៊ុនបានស្នើឲ្យបុគ្គលិកគ្រប់រូបរាំរយៈពេលប្រាំនាទីមុននឹងចាប់ផ្តើមធ្វើការងារ perusahaan itu meminta*

*setiap karyawannya berjoget selama 5 menit sebelum memulai pekerjaan (ពើរ្សាហាអាន អ៊ីទូ មើមិនតា សឺទីយ៉ាប ការ(r)យ៉ាវ៉ាន់ញ៉ា បឺរ(r)ច្យហ្គិត សឺឡាម៉ា លីម៉ា មើនិត សឺបឺលុម មើមូឡៃ ពើគើរ(r)ច្យាអាន់)*

**joli, sejoli** /សឺច្យូលី/ *n* មួយគូ: *ពួកគេគឺជាគូមួយគូដែលសមគ្នា* mereka *adalah sepasang sejoli yang serasi (មើរេកា អាដាឡះ សឺប៉ាសាំង សឺច្យូលី យ៉ាំង សឺរ៉ាស៊ី)*

**jomlo** /ជុមឡូ/ *n* នៅលីវ: *បុរសម្នាក់នេះនៅលីវជាយូរមកហើយ* lelaki *itu sudah lama menjadi jomlo (ឡឺឡាគី អ៊ីទូ ស៊ូដះ ឡាម៉ា មើនច្យាឌី ចុមឡូ)*

**jompo** /ជុមប៉ូ/ *a* ចាស់ជរា: *ក្មេងប្រុសម្នាក់នោះបានជួយស្ត្រីចាស់ជរាឆ្លងផ្លូវ anak itu membantu wanita jompo itu menyeberang jalan (អាណាក់ អ៊ីទូ មើមបាន់ទូ វ៉ានីតា ចុមប៉ូ អ៊ីទូ មើញើប្រាំង ច្យាឡាន់)*

**jongkok** /ច្យុងកុក/ *v* លុតជង្គង់: *ពួកទាហានបានលុតជង្គង់នៅចំពោះមុខស្តេចរបស់ពួកគេ para prajurit itu jongkok di depan rajanya (ប៉ារ៉ា ប្រាជូរីត អ៊ីទូ ច្យុងកុក ឌិ ឌើប៉ាន់ រ៉ាច្យាញ៉ា);*

**berjongkok** /បឺរ(r)ច្យុងកុក/ *v* លុតជង្គង់: *ពួកទាហានលុតជង្គង់ថ្វាយបង្គំស្តេចរបស់គេ para prajurit itu berjongkok menyembah rajanya (ប៉ារ៉ា ប្រាជូរីត អ៊ីទូ បឺរ(r)ច្យុងកុក មើញើមបះ រ៉ាច្យាញ៉ា)*

**jorok** /ច្យូរ៉ុក/ *a* កខ្វក់

**jual** /ជូវ៉ាល/ *n* លក់: *មិនមែនសម្រាប់លក់ tidak untuk dijual (ទីដាក់ អ៊ុនទុក ឌីជូវ៉ាល);*

**-- beli** /ជូវ៉ាល់ បឺលី/ លក់ដូរ: *រដ្ឋាភិបាលហាមឃាត់មិនឲ្យលក់ដូរសត្វដែលកម្រ pemerintah melarang jual beli barang binatang langka (ពើមើរ៉េនតះ មើឡារ៉Aង ជូវ៉ាល់ បឺលី បារ៉ាំង ប៊ីណាតាំង ឡាំងកា);*

**berjualan** /បឺរ(r)ជូវ៉ាលឡាន់/ *v* លក់: *បុរសម្នាក់នេះលក់របស់ក្មេងលេងនៅមុខសាលារៀន pria itu berjualan mainan*

*anak-anak di depan sekolah (ព្រីយ៉ា អ៊ីទូ បឺរ(r)ជូវ៉ាល់ឡាន់ ម៉ាអ៊ីនណាន់ អាណាក់– អាណាក់ ឌិ ឌើប៉ាន់ សឹកូឡះ);*

**menjual** /ម៉ឺនជូវ៉ាល/ *v* លក់:

*នាងលក់បន្លែនៅក្នុងផ្សារ dia menjual sayuran di pasar (ឌីយ៉ា ម៉ឺនជូវ៉ាល សាយូរ៉ាន់ ឌី ប៉ាសារ(r));*

**penjual** /ពើនជូវ៉ាល់/ *n* អ្នកលក់:

*ទីផ្សារគឺជាកន្លែងជួបជុំរវាងអ្នកលក់និងអ្នកទិញ pasar merupakan tempat bertemunya penjual dan pembeli (ប៉ាសារ(r) ម៉ើរូប៉ាកាន់ តឹមប៉ាត់ បឺរ(r)ទើមូញ៉ា ពើនជូវ៉ាល់ ដាន់ ពើមបឺលី);*

**penjualan** /ពើនជូវ៉ាល់ឡាន់/

*n* ការលក់ដូរ:

*ការលក់ដូរផលិតផលនៅចុងឆ្នាំជាធម្មតាមានការកើនឡើង penjualan produk pada akhir tahun biasanya meningkat (ពើនជូវ៉ាល់ឡាន់ ប្រូឌុគ ប៉ាដា អាក់ហ៊ឺរ(r) តាហ៊ុន ប៊ីយ៉ាសាញ៉ា ម៉ើនិងកាត់);*

**terjual** /ទើរ(r)ជូវ៉ាល់/ *v* បានលក់; លក់ដាច់:

*រថយន្តសម័យមុនទីបំផុតត្រូវបានលក់ដាច់ mobil antik itu akhirnya terjual (ម៉ូប៊ីល អានទិគ អ៊ីទូ អាក់ហ៊ឺរ(r)ញ៉ា ទើរ(r)ជូវ៉ាល់)*

**juang, berjuang** /ប៊ើរ(r)ជូវ៉ាង/

*v* ប្រឹងប្រែង:

*ពួកគេបានខំប្រឹងប្រែងដើម្បីបានឯករាជ mereka telah berjuang untuk bebas (មើរេកា តើឡះ ប៊ើរ(r)ជូវ៉ាង អ៊ុនទុក បេបាស់(s));*

**memperjuangkan** /មើមពើរ(r)ជូវ៉ាងកាន់/ *v* តស៊ូ:

*កម្មករមិនដែលអស់សង្ឃឹមក្នុងការតស៊ូដើម្បីសិទ្ធិរបស់ពួកគេ kaum buruh tidak pernah putus asa memperjuangkan hak-hak mereka (កាអ៊ុម ប៊ូរុះ ទីដាក់ ពើរ(r)ណះ ពូទុស(ស) អាសា មើមពើរ(r)ជូវ៉ាងកាន់ ហាក់–ហាក់ មើរេកា);*

**pejuang** /ពើជូវ៉ាង/ *n* អ្នកចម្បាំង:

*អ្នកចម្បាំងពិត pejuang sejati (ពើជូវ៉ាង សើច្បាទី);*

**perjuangan** /ពើជូវ៉ាង៉ាន់/ *n* ការតស៊ូ:

*ការស៊ូគ្មានដែនកំណត់ perjuangan tiada henti (ពើជូវ៉ាង៉ាន់ ទីយ៉ាដា ហិនទី)*

**juara** /ជូវ៉ារ៉ា/ *n* ជើងឯក;

**kejuaraan** /គើជូវ៉ារ៉ាអាន/

*n* ការប្រកួតជើងឯក:

*ឥណ្ឌូនេស៊ីនឹងធ្វើជាម្ចាស់ផ្ទះក្នុងការប្រកួតជើងឯកកីឡាវាយសីតំបន់អាស៊ី Indonesia akan menyelenggarakan kejuaraan bulu tangkis tingkat Asia (ឥណ្ឌូនេស៊ីយ៉ា អាកាន់ មើញើឡឹងហ្គារ៉ាកាន់ គើជូវ៉ារ៉ាអានប៊ូលូ តាំងគិស(ស) ទិងកាត់ អាស៊ីយ៉ា);*

**menjuarai** /មើនជូវ៉ារ៉ៃ/ *v* ឈ្នះ

*កុមារនេះបានឈ្នះការប្រកួតរត់ប្រណាំងនៅក្នុងឆ្នាំនេះ anak itu menjuarai lomba lari jarak jauh tahun ini (អាណាក់ អ៊ីទូ មើនជូវ៉ារ៉ៃ ឡុមបា ឡារី ចារ៉ាក់ ចាអ៊ុះ តាហ៊ុន អ៊ីនី)*

**jubah** /ជូបះ/ *n* រ៉ូប; អាវធាយ; អាវវែង:

*រ៉ូបងូតទឹក jubah mandi (ជូបះ ម៉ាន់ឌិ)*

**judi** /ជូឌិ/ *n* ល្បែង:

*ល្បែងធ្វើឲ្យខូចសីលធម៌សង្គម judi itu merusak moral masyarakat (ជូឌី អ៊ីទូ មើរុសាក់ ម៉ូរ៉ាល់ ម៉ាស្យារ៉ាកាត់);*

**berjudi** /ប៊ឺរ(r)ជូឌិ/ *v* លេងល្បែង:

*គាត់លេងល្បែងរាល់យប់ dia berjudi setiap malam (ឌីយ៉ា ប៊ឺរ(r)ជូឌី សឺទីយ៉ាប ម៉ាឡាំ);*

**pejudi** /ពើជូឌិ/ *n* អ្នកល្បែង:

*អ្នកលេងល្បែងទីបំផុតត្រូវបានប៉ូលីសចាប់ខ្លួន pejudi itu akhirnya ditangkap polisi (ពើជូឌី អ៊ីទូ អាក់ហ៊ីរ(r)ញ៉ា ឌិតាំងកាប់ ប៉ូលីស៊ី);*

**perjudian** /ពើរ(r)ជូឌីយ៉ាន់/

*n* ល្បែងស៊ីសង:

*រដ្ឋាភិបាលបានហាមឃាត់ការលេងល្បែងស៊ីសងព្រោះវាជាអំពើល្មើសច្បាប់ pemerintah melarang perjudian karena itu ilegal (ពើមើរិនតះ មើឡារ៉ាំង ពើរ(r)ជូឌីយ៉ាន ការើណា អ៊ីទូ អ៊ីឡេហ្គាល់)*

**judul** /ជូឌុល/ *n* ចំណងជើង:

*ចំណងជើងសៀវភៅ judul buku (ជូឌុល ប៊ូគូ);*

**berjudul** /ប៊ឺរ(r)ជូឌុល/

*v* មានចំណងជើងថា:

*សៀវភៅនោះមានចំណងជើងថា*

*"The Patriot" buku itu berjudul "The Patriot" (ប៊ូគូ អ៊ីទូ បឺរ(r)ជូឌុល "ឌឺ ផាទ្រីអ៊ត")*

**juga** /ជូហ្គា/ *p* ផងដែរ: *តើអ្នកមកដែរទេ? apakah kamu juga akan datang? (អាប៉ាកះ កាមូ ជូហ្គា ដាតាំង?)*

**jujur** /ជូជូរ(r)/ *a* ស្មោះត្រង់: *ស្មោះត្រង់និងខិតខំប្រឹងប្រែងធ្វើការងារគឺជាគន្លឹះក្នុងការជោគជ័យរបស់បុគ្គលម្នាក់ៗ jujur dan kerja keras adalah kunci sukses seseorang (ជូជូរ(r) ដាន់ គើរ(r)ចា្យ គើរ៉ាស់(ស) អាដាឡះ គុនជី ស៊ុកសែស(ស) សឺសឺអូរ៉ាំង);*

**kejujuran** /គើជូជូរ៉ាន់/ *n* ភាពស្មោះត្រង់: *តាំងពីតូចពួកយើងត្រូវបានបង្រៀនឲ្យមានភាពស្មោះត្រង់ sejak kecil kami diajari kejujuran (សឺចា្យក់ គើជឹល កាមី ឌីយ៉ាចា្យរី គើជូជូរ៉ាន់)*

**Juli** /ជូលី/ *n* ខែកក្កដា: *កូនដំបូងរបស់ខ្ញុំបានកើតនៅខែកក្កដា anak pertama saya dilahirkan pada bulan Juli (អាណាក់ ពើរ(r)តាម៉ា សាយ៉ា ឌិឡាហ៊ីរ(r)កាន់ ប៉ាដា ប៊ូឡាន់ ជូលី)*

**jumlah** /ជូមឡះ/ *n* ចំនួន: *ចំនួនសរុប jumlah total (ជូឡះតូតាល់);*

**berjumlah** /ប៊ើរ (r) ជូមឡះ/

*v* មានចំនួន: *ជនរងគ្រោះដែលស្លាប់មានចំនួនបីនាក់ korban yang meninggal berjumlah tiga orang (កូរ(r)បាន់ យ៉ាំង មើនីងហ្គាល់ ប៊ើរ (r) ជូមឡះ ទីហ្គា អូរ៉ាំង);*

**penjumlahan** /ប៉ិនជូមឡាហាន់/

*n* ការបន្ថែម: *ការបន្ថែម និង ការបន្ថយ penjumlahan dan pengurangan (ប៉ិនជូឡាហាន់ ដាន់ ពើងូរ៉ាង៉ាន់);*

**sejumlah** /សឺជុមឡះ/ *n* ចំនួន: *សិស្សសាលាមួយចំនួនបានចូលមន្ទីរពិសោធន៍នៅក្នុងព្រឹកនេះ sejumlah anak sekolah memasuki ruang laboratorium pagi ini (សឺជុមឡះ អាណាក់ សឺកូឡះ មើម៉ាស៊ូគី រ្វាំងឡាបូរ៉ាតូរីយ៉ូម ប៉ាហ្គី អ៊ីនី)*

**jumpa, jumpa pers** /ជូមប៉ា ពើរ(r)ស(s)/ *n* សន្និសិទការសែត: *បន្ទាប់ពីឈ្នះជើងឯកការប្រណាំងរួចមកអ្នកប្រណាំងរូបនេះបានធ្វើសន្និសិទកាសែតមួយ*

*setelah menjuarai balapan, pebalap itu mengadakan jumpa pers (សឺទើឡះ មើនជូវ៉ារ៉ៃ បាឡាប៉ាន់ ពើបាឡាប់ អ៊ីទូ មើង៉ាដាកាន់ ជូមប៉ា ពើរ(r)ស(ស));*

**berjumpa** /បឺរ(r)ជូមប៉ា/ *v* ជួប:

*ស្ត្រីម្នាក់នោះបានបដិសេធមិនព្រមជួបជាមួយអតីតស្វាមីរបស់នាងនៅក្នុងតុលាការ wanita itu menolak untuk berjumpa dengan mantan suaminya di pengadilan (វ៉ានីតា អ៊ីទូ មើណូឡាក់ អ៊ុនទុក បឺរ(r)ជូមប៉ា ឌើង៉ាន់ ម៉ាន់តាន់ ស៊ូវ៉ាមីញ៉ា ឌិ ពើង៉ាឌីឡាន់);*

**menjumpai** /មើនជូមប៉ៃ/ *v* ជួប:

*ក្រុមអ្នកគាំទ្របានជួបតារានៅក្នុងដួងចិត្តរបស់ពួកគេនៅឯសួននោះ para penggemar menjumpai artis idolanya di taman itu (ប៉ារ៉ា ពើងហ្គើម៉ារ(r) មើនជូមប៉ៃ អារ(r)ទីស(ស) អ៊ីដូឡាញ៉ា ឌិ តាម៉ាន់ អ៊ីទូ)*

**Juni** /ជូនី/ *n* ខែមិថុនា:

*រដូវក្តៅជាធម្មតាគឺចាប់ផ្តើមពីខែមិថុនាទៅ musim panas biasanya dimulai pada bulan Juni (មូស៊ីម ប៉ាណាស់(ស) ប៊ីយ៉ាសាញ៉ា ឌិមូឡៃ ប៉ាដា ប៊ូឡាន់ ជូនី)*

**jurang** /ជូរ៉ាំង/ *n* អូរ; ជ្រោះ

*រថយន្តនោះបានធ្លាក់ចូលទៅក្នុងជ្រោះ mobil itu terjun ke jurang (ម៉ូប៊ីល អ៊ីទូ ទើរ(r)ជុន គើ ជូរ៉ាំង)*

**juri** /ជូរី/ *n* គណៈមេប្រយោគ:

*ខ្ញុំគឺជាគណៈមេប្រយោគមួយរូបនៅក្នុងការប្រកួតភាពវៃឆ្លាត saya menjadi juri di sebuah perlombaan cerdas cermat (សាយ៉ា មើនចាឌី ជូរី ឌិ សឺប៊ូវ៉ាស់(ស) ពើរ(r)ឡុមបាអាន ចឹរ(r)ដាស(ស) ចឹរ(r)ម៉ាត់)*

**juru, penjuru** /ប៉ុនជូរូ/ *n* ជ្រុង:

*ការទាត់បាល់ជ្រុង tendangan penjuru (តិនដាងាន់ ប៉ុនជូរូ)*

**jurus** /ជូរុស(s)/ *n* ក្បាច់; ស្នៀត:

*នៅទីបំផុតការប្រយុទ្ធនោះពួកគេបានបញ្ចេញនូវក្បាច់ប្រចាំត្រកូលរបស់ពួកគេ akhirnya petarung itu mengeluarkan jurus andalannya (អាក់ហឺរ(r)ញ៉ា ពើតារូង អ៊ីទូ មើងើលូវ៉ារ(r)កាន់ ជូរុស(ស) អាន់ដាឡាន់ញ៉ា);*

**jurusan** /ជូរូសាន់/ *n* ជំនាញ:

*ជំនាញភាសាអង់គ្លេស jurusan bahasa Inggris (ជូរូសាន់ បាហាសា អ៊ីងគ្រីស)*

**juta** /ជ្យូតា/ *n* លាន: *រាប់លាននាក់*

*berjuta-juta orang (ប៊ើរ (r) ជ្យូតា–ជ្យូតា អូរ៉ាំង);*

**jutaan** /ប៊ឺរ(r)ជូតា ជូតា/ *v* រាប់លាន: *ប្រជាជនប្រេស៊ីលរាប់លាននាក់បានចេញទៅតាមដងផ្លូវដើម្បីចូលរួមពិធីបុណ្យវប្បធម៌ប្រចាំឆ្នាំ* *jutaan warga Brazil turun ke jalan mengikuti festival budaya tahunan (ជូតាអាន់ វ៉ារ(r)ហ្គា ប្រាហ្ស៊ីល ទូរ៉ុន គើ ច្យាឡាន់ មើងីគុតទី ហ្វេស្ទីហ្វាល់ ប៊ូដាយ៉ា តាហ៊ូណាន់)*

**jutawan** /ជូតាវ៉ាន់/ *n* សេដ្ឋី: *ក្មេងនោះមានក្តីស្រមៃចង់ក្លាយជាសេដ្ឋី anak itu bercita-cita menjadi seorang jutawan (អាណាក់ អ៊ីទូ ប៊ឺរ(r)ជីតា–ជីតា មើនច្យាឌី សឺអូរ៉ាំង ជូតាវ៉ាន់)*

**kabut** /កាប៊ុត/ *n* អ័ព្ទ: *អ័ព្ទពេលព្រឹក kabut pagi (កាប៊ុតប៉ាហ្គី);*

**berkabut** /បើរ (r) កាប៊ុត/ *v* មានអ័ព្ទ: *អាកាសធាតុមានអ័ព្ទ cuaca berkabut (ជូវ៉ាចា បើរ (r) កាប៊ុត)*

**kaca** /កាចា/ *n* កញ្ចក់: *ចាននោះធ្វើពីកញ្ចក់ mangkuk itu terbuat dari kaca (ម៉ាំងកុក អ៊ីទូ តើរ (r)ប៊ូវ៉ាត ដារី កាចា);*

**berkaca-kaca** /បើរ(r)កាចា-កាចា/ *v* មានពន្លឺ; ភ្លឺចែងចាំង: *ភ្នែកគាត់ភ្លឺចែងចាំង matanya berkaca-kaca (ម៉ាតាញ៉ា បើរ(r)កាចា កាចា)*

**kadang, kadang-kadang** /កាដាំង កាដាំង/ *adv* កាដាំង កាដាំង: *ពេលខ្លះគាត់មក kadang-kadang dia datang (កាដាំង កាដាំង ឌីយ៉ា ដាតាំង);*

**terkadang** /តើរ(r) កាដាំង/ *adv* ពេលខ្លះ: *ពេលខ្លះពិតជាពិបាកនឹងបំភ្លេចហេតុការណ៍ដែលបានកើតឡើងនាពេលកន្លងមក terkadang sangat sukar untuk melupakan kejadian di masa lalu (តើរ(r)កាដាំង សាងាត់ ស៊ូការ(r) អ៊ុនទុក មើលូប៉ាកាន់* គើចា្យឌីយ៉ាន ឌី ម៉ាសា *ឡាលូ)*

**kaget** /កាហ្គេត/ *a* តក់ស្លុត: *គាត់តក់ស្លុតពេលលឺដំណឹងនោះ dia kaget mendengar kabar itu (ឌីយ៉ា កាហ្គេត ម៉ឺនដឹងារ(r) កាបារ(r) អ៊ីទូ);*

**mengagetkan** /មើង៉ាហ្គេតកាន់/ *v* ធ្វើឱ្យតក់ស្លុត: *ព័ត៌មាននោះធ្វើឱ្យតក់ស្លុតគ្រប់គ្នា berita itu mengagetkan semua orang (ពើរីតា អ៊ីទូ មើង៉ាហ្គេតកាន់ ស៊ើមូវ៉ា អូរ៉ាំង)*

**kagum** /កាហ្គូម/ *a* មោទនភាព: *គាត់មានមោទនភាពជាមួយនឹងការតស៊ូព្យាយាមរបស់គាត់ dia merasa kagum dengan kegigihannya (ឌីយ៉ា មើរ៉ាសា កាហ្គូម ដឹង៉ាន់ គើហ្គីហ្គីហាន់ញ៉ា)*

**kait, berkaitan dengan** /បើរ(r)កាអ៊ីតាន់ ដឹង៉ាន់/ *v* ទាក់ទងជាមួយនឹង: *ទាក់ទងជាមួយនឹងលិខិតរបស់អ្នកខ្ញុំសូមអភ័យទោស berkaitan dengan surat Saudara, saya mohon maaf*

*(ប៊ើរ(r)កាអ៊ីតាន់ ដឺង៉ាន់ ស្វ៊ាត់ សៅដារ៉ា សាយ៉ា ម៉ូហ៊ុន ម៉ាអាហ្វ);*

**mengaitkan** /មើង៉ាអ៊ីតកាន់/ *v* ចង: *ចងខ្សែនឹងដើមឈើ* *mengaitkan tali ke pohon (មើង៉ាអ៊ីតកាន់ តាលី គើ ពោហ៊ុន)*

**kaki** /កាគី/ *n* **1** ជើង: *ជើងខ្ញុំរបួសហើយ* *kakiku terluka (កាគីគូ តើរ(r)លូកា);* **2** ថ្មើជើង: *យើងខ្ញុំមកទីនេះដោយថ្មើជើង* *kami berjalan kaki kemari (កាមី ប៊ើរ(r)ជ្យាឡាន់ កាគី គើម៉ារី)*

**kalah** /កាឡះ/ *v* ចាញ់: *ពួកគេចាញ់នៅក្នុងការប្រកួតនោះ* *mereka kalah telak dalam pertandingan itu (មើរេកា កាឡះ តើឡាក់ ដាឡាម ពើរ(r)តាន់ឌីង៉ាន់ អ៊ីទូ);*

**kekalahan** /គើកាឡាហាន់/ *n* ចុះចាញ់: *គាត់ទទួលចុះចាញ់* *dia menerima kekalahannya (ឌីយ៉ា មើនើរីម៉ា គើកាឡាហាន់ញ៉ា);*

**mengalahkan** /មើង៉ាឡះកាន់/ *v* យកឈ្នះ *គាត់យកឈ្នះគូប្រកួតគាត់ដោយងាយ* *dia mengalahkan lawannya dengan mudah (ឌីយ៉ា មើង៉ាឡះកាន់ ឡាវ៉ាន់ញ៉ា ដឺង៉ាន់ មូដះ)*

**kalau** /កាឡៅ/ *adv* បើសិនជា: *បើសិនជាអ្នកចេញទៅ គាត់នឹងទៅជាមួយ* *kalau engkau pergi, dia akan ikut bersamamu (កាឡៅ អ៊ឹងកាវ ពើរ(r)ហ្គី, ឌីយ៉ា អាកាន់ អ៊ីគុត ពើរ(r)សាម៉ា)*

[1]**kali** /កាលី/ *n* លើក: *លើកទីមួយ* *kali pertama (កាលី ពើរ(r)តាម៉ា);*

**sekali** /សើកាលី/ *n* ម្តងម្កាល: *ទៅលេងម្តាយអ្នកម្តងម្កាលផង* *sekali-kali jenguklah ibumu! (សើកាលី–កាលី ជើងុកឡះ អ៊ីប៊ូមូ)*

[2]**kali** /កាលី/ *n* ទន្លេ: *មាត់ទន្លេ* *pinggir kali (ពីងហ្គៀរ(r) កាលី)*

**kalimat** /កាលីម៉ាត់/ *n* ឃ្លា; សម្តី: *គាត់ត្រូវបានខឹងសម្បារ ដោយសារតែបញ្ចេញនូវសម្តីដ៏អសុរស* *dia dimarahi karena mengeluarkan kalimat yang kasar (ឌីយ៉ា ឌីម៉ារ៉ាហ៊ី ការើណា មើងើលូអ៉ារ(r)កាន់ កាលីម៉ាត់ យ៉ាំង កាសារ(r))*

**kamar** /កាម៉ារ(r)/ *n* បន្ទប់;

*ផ្ទះនោះមានបួនបន្ទប់ rumah itu memiliki empat kamar (រូម៉ះ អ៊ីទូ មើមីលីគី អឹមប៉ាត់ កាមារ(r));*

**-- kecil** /កាម៉ារ(r) គើជីល/ បង្គន់អនាម័យ:

*ខ្ញុំទៅបង្គន់បន្តិច saya akan pergi ke kamar kecil sebentar (សាយ៉ា អាកាន់ ពើរ(r)ហ្គី គើ កាម៉ារ(r) គើជីល សេបិនតារ(r));*

**-- mandi** /កាម៉ារ(r) ម៉ាន់ឌិ/ បន្ទប់ទឹក:

*អ្នកម្តាយដុសសម្អាតកម្រាលឥដ្ឋបន្ទប់ទឹកជារៀងរាល់ថ្ងៃ ibu menyikat lantai kamar mandi setiap hari (អ៊ីប៊ូ មើញីកាត់ ឡាន់តៃ កាម៉ារ(r) ម៉ាន់ឌី សឺទីយ៉ាប ហារី);*

**-- pengantin** /កាម៉ារ(r) ពើង៉ាន់ទីន/ បន្ទប់ផ្សំដំណេក:

*បន្ទប់ផ្សំដំណេកត្រូវបានតុបតែងទៅដោយផ្កាគ្រប់ប្រភេទ kamar pengantin itu dihiasi dengan berbagai macam bunga (កាម៉ារ(r) ពើងង៉ាន់ទីន អ៊ីទូ ឌិហ៊ីយ៉ាស៊ី ឌើង៉ាន់ បឺរ(r)បាហ្គៃ ម៉ាចាំ ប៊ូង៉ា);*

**-- tidur** /កាម៉ារ(r) ទីឌូរ(r)/ បន្ទប់គេង:

*បន្ទាប់ពីដុសធ្មេញនិងលាងជើងរួចមកវាបានទៅបន្ទប់គេង setelah menyikat gigi dan mencuci kaki dia pergi ke kamar tidur (សឺទើឡះ មើញីកាត់ ហ្គីហ្គី ដាន់ មើនជូជី កាគី ឌីយ៉ា ពើរ(r)ហ្គី គើ កាម៉ារ(r) ទីឌូរ(r))*

**kambing** /កាំប៊ីង/ *n* ពពែ:

*ពពែនេះនឹងមិនត្រូវបានលក់ឡើយសូម្បីគេឲ្យថ្លៃក្នុងតម្លៃខ្ពស់ក៏ដោយ kambing itu tidak akan dijual meskipun ditawar dengan harga mahal (កាំប៊ីង អ៊ីទូ ទីដាក់ អាកាន់ ឌិជូវ៉ាល់ មែស្គីពុន ឌិតាវ៉ារ(r) ឌើង៉ាន់ ហារ(r)ហ្គា ម៉ាហាល់)*

**kambuh** /កាំប៊ុះ/ *v* លាប់:

*ជិតមួយសប្តាហ៍ហើយដែលវាមិនបានមកមើលទៅជំងឺរបស់វាប្រហែលជាលាប់មកវិញហើយ sudah hampir seminggu ia tidak datang, rupanya penyakitnya kambuh lagi (ស៊ូដះ ហាំពីរ(r) សឺមិងហ្គូ អ៊ីយ៉ា ទីដាក់ ដាតាំង រូប៉ាញ៉ា ពើនញ៉ាគិតញ៉ា កាំប៊ុះ ឡាហ្គី)*

**kamera** /កាមេរ៉ា/ *n* កាមេរ៉ា; ម៉ាស៊ីនថត:
*ម៉ាស៊ីនថតឌីជីថល kamera digital (កាមេរ៉ា ឌីហ្គីតាល់)*

**kami** /កាមី/ *n* យើង:
*យើងមិនយល់ស្របជាមួយនឹងគំនិតអ្នកទេ kami tidak setuju dengan pendapatmu (កាមី ទីដាក់ សើទូជូ ដើង៉ាន់ ប៉ិនដាប៉ាត់មូ)*

**kampanye** /កាំប៉ាញ៉េ/ *n* យុទ្ធនាការ:
*យុទ្ធនាការបោះឆ្នោតជ្រើសរើសប្រធានាធិបតី kampanye pemilihan presiden (កាំប៉ាញ៉េ ពើមីលីហាន់ ប្រេស៊ីដិន)*

**kampung** /កាំពុង/ *n* ភូមិ:
*យើងត្រូវតែចុះទៅតាមជ្រលងភ្នំដើម្បីអាចទៅដល់ភូមិនោះ kita harus menuruni lembah agar bisa sampai di kampung itu (គីតា ហារុស(ស) មើណូរុន លេមបះ អាហ្គារ(r) ប៊ីសា សាំប៉ៃ ឌិ កាំពុង អ៊ីទូ);*

**-- halaman** /កាំពុង ហាឡាម៉ាន់/ ភូមិកំណើត:
*រីករាយណាស់ដែលបានត្រឡប់មកភូមិកំណើតវិញ senangnya berada di kampung halaman kembali (សឺណាំងញ៉ា ប៊ឺរ៉ាដា ឌិ កាំពុង ហាឡាម៉ាន់ កឹមបាលី)*

**kamu** /កាមូ/ *pron* អ្នក:
*អ្នកត្រូវតែទទួលខុសត្រូវចំពោះបញ្ហានេះ kamu yang harus bertanggung jawab untuk masalah ini (កាមូ យ៉ាំង ហារូស(s) ប៊ើរ(r)តាំងហ្គុង ចាវ៉ាប់ អ៊ុនទុក មាសាឡះ អ៊ីនី)*

**kamus** /កាមុស(s)/ *n* វចនានុក្រម:
*ខ្ញុំត្រូវការវចនានុក្រមដើម្បីបកប្រែពាក្យនេះ aku perlu kamus untuk menerjemahkan kalimat ini (អាគូ ពើរ(r)លូ កាមុស(ស) អ៊ុនទុក មើណឺរ(r)ជើម៉ះកាន់ កាលីម៉ាត់ អ៊ីនី)*

**kanan** /កាណាន់/ *n* ស្តាំ: *បត់ស្តាំ belok kanan (បេឡុក កាណាន់)*

**kancing** /កាន់ជីង/ *n* ឡេវអាវឬខោ:
*ឡេវអាវគឺជាគ្រឿងបន្លាស់របស់សម្លៀកបំពាក់ kancing merupakan aksesori dari pakaian (កាន់ជិង មើរូប៉ាកាន់ អាក់សែស្សូរីស(ស) ដារី ប៉ាកៃយ៉ាន់)*

**kanda** /កាន់ដា/ *n* បងប្រុស:
*បងប្រុសទើបងនឹងចូលរួមជាមួយខ្ញុំ? kanda,*

*maukah kau menemaniku?* *(កាន់ដា ម៉ោកះ កូវ មើនើម៉ានីគូ)*

**kandang** /កាន់ដាំង/ *n* ក្រោល:
*សេះនេះមានក្រោលធំខ្លាំងណាស់ kuda itu mempunyai kandang yang sangat besar (គូដា អ៊ីទូ មើមពូញៀ៉ កាន់ដាំង យ៉ាំង សាង៉ាត់ បែសារ(r))*

**kangkung** /កាំងគុង/ *n* ត្រកួន:
*អ្នកម្ដាយទិញត្រកួននៅផ្សារ ibu membeli kangkung di pasar (អ៊ីប៊ូ មើមបើលី កាំងគុង ឌិ ប៉ាសារ(r))*

**kantin** /កាន់ទិន/ *n* អាហារដ្ឋាន:
*ពួកគេញ៉ាំអាហារថ្ងៃត្រង់នៅអាហារដ្ឋានសាលា mereka makan siang di kantin sekolah (មើរេកា ម៉ាកាន់ ស៊ីយ៉ាង ឌិ កាន់ទិន សឺកូឡះ)*

**kantong** /កាន់តុង/ *n* **1** កាន់តុង: *កាបូប kantong uang (កាន់តុង អ៊ូវ៉ាំង);*
**2** ស្បោង; ថង់:
*សំរាមត្រូវបានច្រកចូលទៅក្នុងថង់មុននឹងយកទៅចោល sampah dimasukkan ke dalam kantong sebelum dibuang (សាំប៉ះ ឌិម៉ាស៊ូកាន់ គើ ដាឡាំ កាន់តុង សឺបឺលុម ឌិប៊ូវ៉ាំង)*

**kantor**/កាន់តូរ(r)/ *n* **1** ការិយាល័យ:
*ការិយាល័យប្រៃសណីយ៍ kantor pos (កាន់តូរ(r) ប៉ុស(ស)); **2** ការិយាល័យ: ការិយាល័យប៉ូលីស kantor polisi (កាន់ត័រ(r) ប៉ូលីស៊ី); ការិយាល័យប្រៃសណីយ៍ kantor pos (កាន់ត័រ(r) ប៉ុស(s));*
**-- pos** /កាន់តូរ(r) ប៉ុស(s)/ ការិយាល័យប្រៃសណីយ៍:
*ឪពុកខ្ញុំបានប្រើខ្ញុំឲ្យទៅទិញតែមនៅការិយាល័យប្រៃសណីយ៍ ayah menyuruhku untuk membeli perangko di kantor pos (អាយ៉ះ មើញូរុះគូ អ៊ុនទុក មើមបើលី ពើរ៉ាំងកូ ឌិ កាន់តូរ(r) ប៉ុស(ស))*

**kapak** /កាប៉ាក់/ *n* ពូថៅ:
*កសិករកាប់ឈើដោយប្រើពូថៅ petani membelah kayu menggunakan kapak (ពើតានី មើមប៊ឺឡះ កាយូ មើងហ្គូណាកាន់ កាប៉ាក់); ពូថៅដែកពិតជាមុតនិងគ្រោះថ្នាក់ណាស់ kapak besi itu sangat tajam dan berbahaya (កាប៉ាក់ បើស៊ី អ៊ីទូ សាង៉ាត់ តាចាំ ដាន់ បឺរ(r)បាហាយ៉ា)*

**kapal** /កាប៉ាល់/ *n* កប៉ាល់:

*កប៉ាល់នោះបានអណ្ដែតចេញទៅហើយ kapal itu sudah berlayar (កាប៉ាល់ អ៊ីទូ ស៊ូដះ បើរ(r)ឡាយ៉ារ(r));*

*កប៉ាល់ចម្លង kapal penyeberangan (កាប៉ាល់ ពើញើបើរ៉ាង៉ាន់);*

**-- api** /កាប៉ាល់ អាពី/

កាប៉ាល់ដើរដោយថាមពលកំដៅ:

*កាប៉ាល់បានធ្វើដំណើរនៅមហាសមុទ្រប៉ាស៊ីហ្វិច kapal api itu berlayar di samudera pasifik (កាប៉ាល់ អាពី អ៊ីទូ បឺរ(r)ឡាយ៉ារ(r) ឌិ សាមូឌើរ៉ា ប៉ាស៊ីហ្វីគ);*

**-- layar** /កាប៉ាល់ ឡាយ៉ារ(r)/ ទូកក្ដោង; សំពៅ

**-- perang** /កាប៉ាល់ ពើរ៉ាំង/ នាវាចម្បាំង;

**-- pesiar** /កាប៉ាល់ ពើស៊ីយ៉ារ((r)/

នាវាទេសចរណ៍/នាវាកម្សាន្ត:

*ធ្វើការនៅលើនាវាកម្សាន្តគឺជាការងារមួយដ៏ល្អ bekerja di kapal pesiar merupakan pekerjaan yang menjanjikan (បឺគើរ(r)ចា្យ ឌិ កាប៉ាល់ ពើស៊ីយ៉ារ(r) ម៉ើរូប៉ាកាន់ ពើគើរ(r)ចា្យអាន់ យ៉ាំង មើនចា្យន់ជីកាន់);*

**-- selam** /កាប៉ាល់ សឺឡាំ/ នាវាមុជទឹក:

*នាវាមុជទឹកនោះមានពណ៌ខៀវចាស់ kapal selam itu berwarna biru tua (កាប៉ាល់ សឺឡាំ អ៊ីទូ បឺរ(r)វ៉ារ(r)ណា ប៊ីរូ ទូវ៉ា)*

**kapan** /កាប៉ាន់/ *pron* ពេលណា:

*ពេលណាបានគាត់ចាកចេញទៅ? kapan dia akan pergi? (កាប៉ាន់ ឌីយ៉ា អាកាន់ ពើរ(r)ហ្គី?);*

**kapan-kapan** /កាប៉ាន់-កាប៉ាន់/

*n* នៅថ្ងៃណាមួយ: *នៅថ្ងៃណាមួយខ្ញុំនឹងជួបអ្នក kapan-kapan saya akan menemui Anda (កាប៉ាន់-កាប៉ាន់ សាយ៉ា អាកាន់ មើនើមុយ អាន់ដា)*

**kapur** /កាពួរ(r)/ *n* ដីស:

*ដីសគេប្រើសម្រាប់សរសេរលើក្តារខៀន*

*kapur digunakan untuk menulis di papan tulis (កាពួរ(r) ឌិហ្គុណាកាន់ អ៊ុនទុក មើនូលីស ឌិ ប៉ាប៉ាន់ ទូលិស(ស))*

**karang** /ការ៉ាំង/ *n* ផ្កាថ្ម:

*យើងអាចជួបប្រទះផ្កាថ្មនៅលើឆ្នេរខ្សាច់*

*karang dapat kita jumpai di pantai (ការ៉ាង ដាប៉ាត់ គីតា ជុមប៉ៃ ឌិ ប៉ាន់តៃ)*

**karcis** /ការ(r)ជីស(s)/ *n* សំបុត្រ:

*ទស្សនិកជនគឺតម្រូវឲ្យមានសំបុត្រសម្រាប់ចូលទស្សនាការសម្តែងនេះ penonton memerlukan karcis untuk menonton pertunjukan (ពើណុនតុន មើមើរ(r)លូកាន់ ការ(r)ជិស(ស) អ៊ុនទុក មើណុនតុន ពើរ(r)ទុនជូកាន់)*

**kardus** /ការ(r)ឌូស(s)/ *n* ប្រអប់: *ប្រអប់ទទេរ kardus kosong (ការ(r)ឌូស(s) កោសុង)*

**karena** /កាអើណា/ *p* ដោយសារ: *គាត់អត់បានធ្វើការថ្ងៃនេះ ដោយសារឈឺ dia tidak bekerja hari ini karena sakit (ឌីយ៉ា ទីដាក់ ប៊ើគើរ(r)ចា្យ ហារី អ៊ីនី កាអើណា សាគីត)*

**kartu** /ការ(r)ទូ/ *n* កាត: *កាតឈ្មោះ kartu nama (ការ(r)ទូ ណាម៉ា); កាតយកទំនិញ kartu barang bawaan (ការ(r)ទូ បារ៉ាំង បាវ៉ាអាន់); កាតឥណពន្ធ, កាតដាក់លុយ kartu debit (ការ(r)ទូ ដេប៊ីត); កាតអត្តសញ្ញាណប័ណ្ណ kartu identitas (ការ(r)ទូ អ៊ីដិនទីតាស់(s)); កាតក្រេឌីត kartu kredit (ការ(r)ទូ ក្រេឌីត); កាតមឹមរី kartu memori (ការ(r)ទូ មេម៉ូរី); ការទូរស័ព្ទ kartu telepon (ការ(r)ទូ តេលេហ្វូន); លិខិតអញ្ជើញ kartu undangan (ការ(r)ទូ អ៊ុនដាង៉ាន់);*

**-- kredit** /ការ(r)ទូ ក្រេឌិត/ កាតឥណទាន; កាតក្រេឌិត: *កាតឥណទានជាធម្មតាត្រូវបានប្រើសម្រាប់ការទិញទំនិញ kartu kredit biasanya digunakan untuk berbelanja (ការ(r)ទូ ក្រេឌិត ប៊ីយ៉ាសាញ៉ា ឌិហ្គុណាកាន់ អ៊ុនទុក ប៊ើរ(r)ប៊ឡាន់ចា្យ);*

**-- nama** /ការ(r)ទូ ណាម៉ា/ កាតឈ្មោះ: *សូមទទួលយកកាតឈ្មោះរបស់ខ្ញុំដើម្បីជាសក្ខីភាពនៃការស្គាល់គ្នារបស់យើង terimalah kartu nama saya sebagai tanda perkenalan kita (ទើរីម៉ា ឡះ ការ(r)ទូ ណាម៉ា សាយ៉ា សឺបាហ្គៃ តាន់ដា ពើរ(r)គើណាល់ឡាន់ គីតា);*

**-- pos** /ការ(r)ទូ ប៉ុស(s)/ កាតប៉ុស្តិ៍: *មិត្តរបស់ខ្ញុំបានផ្ញើកាតប៉ុស្តិ៍ពីប្រទេសហូឡង់មកឲ្យខ្ញុំ temanku mengirimkan kartu pos dari Belanda (ទើម៉ាន់គូ មើងីរិមកាន់ ការ(r)ទូ ប៉ុស(ស) ដារី ប៊ឺឡាន់ដា)*

**karung** /ការុង/ *n* *ការ៉ុង: ការ៉ុងអង្ករ karung beras (ការុង ប៊ើរ៉ាស់(s))*

**karya** /ការ(r)យ៉ា/ *n* ការងារ; ស្នាដៃ: *ការងារច្នៃប្រឌិត karya kreatif (ការ(r)យ៉ា គ្រេអាទិហ្វ);*

**-- sastra** /ការ(r)យ៉ា សាស្ត្រា/ អក្សរសាស្ត្រ: *ស្នាដៃអក្សរសាស្ត្រទំនើប karya sastra modern (ការ(r)យ៉ា សាស្ត្រា ម៉ូដឺរ៉ិន)*

**karyawan** /ការ(r)យ៉ាវ៉ាន់/ *n* បុគ្គលិក: *បុគ្គលិកមួយចំនួនបានធ្វើបាតុកម្ម beberapa karyawan melakukan aksi demonstrasi (ប៊ឺប៊ើរ៉ាប៉ា ការ(r)យ៉ាវ៉ាន់ មើឡាគូកាន់ អាក់ស៊ី ដេម៉ុនស្ត្រាស៊ី)*

**kas** /កាស(s)/ *n* ប្រាក់; លុយ: *ប្រាក់របស់ពួកយើងចាប់ផ្ដើមថយចុះ uang kas kami mulai berkurang (អ៊ូវ៉ាំង កាស់(ស) កាមី មូឡៃ ប៊ឺរ(r)គូរ៉ាំង)*

**kasar** /កាសារ(r)/ *a* **1** គ្រើម: *ស្បែកគ្រើមខ្លាំង kulitnya sangat kasar (គូលីតញ៉ា សាង៉ាត់ កាសារ(r));* **2** រឹងរូស; *អាកប្បកិរិយាគាត់រឹងរូស sikapnya kasar (ស៊ីកាប់ញ៉ា កាសារ(r));* **3** គ្រើម; *ផ្ទៃគ្រើម permukaan kasar (ពើរ(r)មូកាអាន់ កាសារ(r))*

**kasih** /កាស៊ិះ/ *n* **1** អោយ; ផ្ដល់ *ផ្ដល់ក្ដីស្រឡាញ់ kasih sayang (កាសឹះ សាយ៉ាំង);* **2** ស្រឡាញ់: *អ្នកជាទីស្រឡាញ់ cinta kasih (ជិនតា កាសឹះ);*

**3** ស្រឡាញ់: *អ្នកជាទីស្រឡាញ់របស់ខ្ញុំ*

*សូមមេត្តាមក kasihku, datanglah (កាសិះគូ ដាតាំងឡះ);*

**kasihan** /កាស៊ីហាន់/ *n* អាណិត:

*អ្នកថ្មើជើងមានក្ដីអាណិតដល់ជនពិការនៅមុខបណ្ណាគារនោះ*

*para pejalan kaki merasa kasihan pada gelandangan di depan toko buku itu (ប៉ារ៉ា ពើឡាឡាន់ កាគី មើរ៉ាសា កាស៊ីហាន់ ប៉ាដា ហ្គើឡាន់ដាង៉ាន់ ឌី ឌើប៉ាន់ តូកូ ប៊ូគូ អ៊ីទូ)*

**kasir** /កាស៊ីរ(r)/ *n* កន្លែងបងប្រាក់:

*ចូរអ្នកបង់ប្រាក់នៅកន្លែងបង់ប្រាក់ដែលនៅជិតលោកអ្នកបំផុត bayarlah di kasir terdekat (បាយ៉ារ(r)ឡះ ឌី កាស៊ីរ(r) តើរ(r)ឌើកាត់)*

**kasur** /កាស៊ូរ(r)/ *n* ពូក: ពូកគេង *kasur tidur (កាស៊ូរ(r) ទីឌូរ(r))*

**kasus** /កាស៊ូស(s)/ *n* ករណី; បញ្ហា:

*ករណីមនុស្សឃាត kasus pembunuhan (កាស៊ូស ពើមប៊ូនូហាន់)*

**kata** /កាតា/ *n* ពាក្យ; ពាក្យសម្ដី:

*ពាក្យសម្ដីរបស់គាត់ធ្វើឱ្យខ្ញុំឈឺចាប់ kata-katanya mengusikku (កាតា–កាតាញ៉ា មើងូស៊ិកគូ);*

**berkata** /បើរ(r)កាតា/ *v* និយាយ:

*គាត់និយាយថាគាត់នឹងមកផ្ទះនៅល្ងាចនេះ dia berkata bahwa dia akan pulang sore ini (ឌីយ៉ា បើរ(r)កាតា បះវ៉ា ឌីយ៉ា អាកាន់ ពូឡាំង សូរ៉េ អ៊ីនី)*

**katak** /កាតាក់/ *n* កង្កែប:

*ដូចកង្កែបនៅក្នុងអណ្ដូង seperti katak di bawah tempurung (សើពើរ(r)ទី កាតាក់ ឌី បាវ៉ះ តឹមពូរុង)*

**kaus** /កាអ៊ូស(s)/ *n* អាយឺត:

*ខ្ញុំទិញអាវយឺតទុកជាអនុស្សាវរីយ៍ aku membeli kaus sebagai cendera mata (អាគូ មើមបើលី កាអ៊ូស(s) សើបាហ្គៃ ចិនឌើរ៉ា ម៉ាតា);*

**-- kaki** /កាអ៊ូស(s) កាអ៊ូស កាគី/ ស្រោមជើង:

*គាត់ពាក់ស្បែកជើងដោយគ្មានស្រោមជើង dia memakai sepatu tanpa kaus kaki (ឌីយ៉ា មើម៉ាកៃ សើប៉ាទូ តាន់ប៉ា កាអ៊ូស(s) កាគី)*

**kawin, mengawini** /មើង៉ាវីនី/ *v* រៀបការ;

*រៀបអាពាហ៍ពិពាហ៍: តើអ្នកចង់រៀបការនិងខ្ញុំទេ? maukah engkau mengawiniku? (ម៉ៅកះ អឹងកូវ មើង៉ាវីនីគូ?)*

**kaya** /កាយ៉ា/ *a* មាន: *គាត់មានមែនទែន dia kaya raya (ឌីយ៉ា កាយ៉ា រ៉ាយ៉ា)*

**kayu** /កាយូ/ *n* ឈើ: *កៅអីនោះធ្វើពីឈើ kursi itu terbuat dari kayu (គួរ(r)ស៊ី អ៊ីទូ ទើរ(r)ប៊ូវ៉ាត់ ដារី កាយូ)*

**ke** /គើ/ *p* ទៅ; ឆ្ពោះទៅ: *គាត់ធ្វើដំណើរទៅប្រទេសឥណ្ឌូនេស៊ីជាមួយគ្រួសាររបស់គាត់ dia pergi ke Indonesia bersama keluarganya (ឌីយ៉ា ពើរ(r)ហ្គី គើ ឥណ្ឌូនេស៊ីយ៉ា ប៊ើរ(r)សាម៉ា គើលូវ៉ារ(r)ហ្គាញ៉ា)*

**kebun** /គើប៊ុន/ *n* **1** សួន: *ក្មេងៗចូលចិត្តលេងនៅក្នុងសួន anak-anak gemar bermain di kebun (អាណាក់–អាណាក់ ហ្គើម៉ារ(r) ប៊ើរ(r)ម៉ាអ៊ីន ឌិ គើប៊ុន)*; **2** សួន, ចំការ: *សួន kebun bunga (គើប៊ុន);*

**-- binatang** /គើប៊ុន ប៊ីណាតាំង/ សួនសត្វ: *សួនសត្វគឺជារមណីដ្ឋានមួយក្នុងចំណោមរមណីដ្ឋានជាច្រើនដែលជាទីពេញចិត្តរបស់ភ្ញៀវទេសចរណ៍ salah satu tempat wisata favorit adalah kebun binatang (សាឡះ សាទូ តឹមប៉ាត់ វីសាតា ហ្វាហ្វូរីត អាដាឡះ គើប៊ុន ប៊ីណាតាំង);*

**berkebun** /បើរ(r)គើប៊ុន/ *v* ធ្វើចំការ: *ចំណង់ចំណូលចិត្តរបស់គាត់គឺធ្វើចំការ hobinya berkebun (ហូប៊ីញ៉ា បើរ(r)គើប៊ុន)*

**kecil** /គើជីល/ *a* **1** តូច: *ទោះបីជារូបរាងកាយរបស់គាត់តូចក៏ពិតមែនតែគាត់មាំមួនណាស់ meskipun tubuhnya kecil, dia sangat kuat (មេស្គីពុន ទូប៊ុះញ៉ា គើជីល ឌីយ៉ា សាង៉ាត់ គួវ៉ាត់);* **2** ក្មេង: *នៅក្មេង masih kecil (ម៉ាសិះ គើជីល);* **3** តូច: *ទីក្រុងតូច kota kecil (កូតា គើជីល);*

**kekecilan** /គើគើជីឡាន់/ *a* តូចពេក; ចង្អៀត: *អាវរបស់គាត់ចង្អៀត bajunya kekecilan (បាជូញ៉ា គើគើជីឡាន់)*

**kedap** /គើដាប់/ *a* ដែលជាប់; ដែលធុន; ដែលមាំ: *មិនជ្រាបទឹក kedap air (គើដាប់ អាយើរ)*

**kedelai** /គើឌើឡៃ/ *n* សណ្ដែកសៀង: *តាហ៊ូធ្វើមកពីសណ្ដែកសៀង tahu terbuat dari kedelai (តាហ៊ូ ទើរ(r)ប៊ូវ៉ាត់ ដារី គើឌើឡៃ)*

**keju** /កែជូ/ *n* ឈីស: *នំប៉័ងឈីស roti keju (រូទី កែជូ)*

**kejut, kejutan** /គើជ្យូតាន់/ *n* ការភ្ញាក់ផ្អើល: *នាងទទួលការធ្វើឲ្យភ្ញាក់ផ្អើលនៅថ្ងៃខួបកំណើតរបស់នាង dia mendapat kejutan pada hari ulang tahunnya (ឌីយ៉ា មិនដាប៉ាត់ គើជ្យូតាន់ ប៉ាដា ហារី អ៊ូឡាំង តាហ៊ុនញ៉ា);*

**mengejutkan** /មើងើជុតកាន់/ *v* ធ្វើឲ្យភ្ញាក់ផ្អើល: *ការឡើងឋានៈរបស់គាត់ធ្វើឲ្យមានការភ្ញាក់ផ្អើលដល់មនុស្សទាំងអស់ kenaikan jabatannya mengejutkan semua orang (គើណៃកាន់ ចាបាតាន់ញ៉ា មើងើជ្យុតកាន់ សើមួរ៉ា អូរ៉ាំង);*

**terkejut** /តើរ(r)គើជុត/ *v* តក់ស្លុត: *នាងតក់ស្លុតនៅពេលដែលបានលឺដំណឹងពីការស្លាប់របស់ម្ដាយនាង dia terkejut mendengar berita kematian ibunya (ឌីយ៉ា តើរ(r)គើជ្យុត ម៉ឺនឌើងារ(r) បើរីតា គើម៉ាទីយ៉ាន អ៊ីប៊ូញ៉ា)*

**kelahi, berkelahi** /បើរ(r)គើឡាហ៊ី/ *v* ជំលោះ; វាយតប់គ្នា; ប្រយុទ្ធ: *គាត់ហ៊ានប្រយុទ្ធជាមួយនិងខ្ញុំ dia menantangku berkelahi (ឌីយ៉ា មើណាន់តាំងគូ បើរ(r)គើឡាហ៊ី)*

**kelapa** /គើឡាប៉ា/ *n* ដូង: *ផ្លែដូងធ្លាក់នៅមាត់ឆ្នេរ buah kelapa berjatuhan di pinggir pantai (ប៊ូវ៉ាស់ គើឡាប៉ា បឺរ(r)ចា្យទុះហាន់ ឌិ ពិងហ្គីរ(r) ប៉ាន់តៃ)*

**kelas** /គើឡាស់(s)/ *n* ថ្នាក់: *ថ្នាក់សេដ្ឋកិច្ច kelas ekonomi (គើឡាស់(s) អេកូណូមី)*

**kelelawar** /គើលេឡាវ៉ារ(r)/ *n* ប្រចៀវ: *ម៉ោងចូលគេងផ្ទុយគ្នាដូចសត្វប្រចៀវ jam tidurnya terbalik seperti kelelawar (ចាំ ទីឌូរ(r)ញ៉ា ទើរ(r)បាលិត សឺពើរ(r)ទី គើលេឡាវ៉ារ(r))*

**keliling, mengelilingi** /មើងើលីលីងី/ *v* ព័ទ្ធជុំវិញ: *ទីក្រុងព័ទ្ធជុំវិញទៅដោយភ្នំ pegunungan mengelilingi kota itu (ពើហ្គូនូងាន់ មើងើលីលីងី កូតា អ៊ីទូ);*

**sekeliling** /សើគើលីលីង/ *p* ជុំវិញ: *បរិយាកាសនៅជុំវិញផ្ទះពិតជាស្ងប់ស្ងាត់មែន suasana di sekeliling perumahan itu sangat sunyi (ស៊ូវសាណា ឌី សើគើលីលីង ពើរ(r)រូម៉ាហាន់ អ៊ីទូ សាងាត់ ស៊ូញី)*

**kelinci** /គើលីនជី/ *n* ទន្សាយ: *ទន្សាយនោះមានរោមស*

*kelinci itu berbulu putih (គើលិនជិ អ៊ីទូ ប៊ឺរ(r)ប៊ូលូ ពូទិស(ស))*

**kelingking** /គើលីងកីង/ *n* កូនដៃ:

*កូនដៃរបស់នាងតូចម៉ែនទែន*

*kelingkingnya kecil sekali (គើលីងកីងញ៉ា គើចិល សើកាលី)*

**keliru** /គើលីរូ/ *a* ច្រឡំ; ភ័ន្តច្រឡំ; ខុស:

*ខ្ញុំជាអ្នកភ័ន្តច្រឡំក្នុងបញ្ហានោះ aku yang keliru dalam hal itu (អាគូ យ៉ាំង គើលីរូ ដាឡាំ ហាល់ អ៊ីទូ);*

**kekeliruan** /គើគើលីរូវាន់/ *n* ភ័ន្តច្រឡំ; កំហុស:

*មានការភ័ន្តច្រឡំក្នុងការកក់បន្ទប់សណ្ឋាគារ terdapat kekeliruan dalam pemesanan kamar (តើរ(r) គើគើលីរូវាន់ ដាឡាំ ពើមើសាណាន់ កាមើរ(r))*

**keluar** /គើលូអើរ(r)/ *v* ចេញ; ចេញក្រៅ; ចាកចេញ:

*ខ្ញុំចេញក្រៅជាមួយមិត្តភក្តិរបស់ខ្ញុំនៅយប់នេះ aku keluar bersama teman-temanku malam ini (អាគូ គើលូអើរ(r) ពើរ(r)សាម៉ា តើម៉ាន់ ទើម៉ាន់គូ ម៉ាឡាំ អ៊ីនី)*

**keluarga** /គើលូវ៉ារ(r)ហ្គា/ *n* គ្រួសារ:

*ផែនការគ្រួសារ (ការពន្យាកំណើត) keluarga berencana (គើលូវ៉ារ(r)ហ្គា ប៊ើរេនចាណា)*

**keluh, keluhan** /គើលូហាន់/ *n* ការត្អូញត្អែរ; ការតវ៉ា:

*មានការត្អូញត្អែរជាខ្លាំងរបស់ប្រជាពលរដ្ឋទៅចំពោះស្តង់ដារសេវារបស់មន្ទីរពេទ្យ keluhan masyarakat terhadap standar pelayanan rumah sakit sangat tinggi (គើលូហាន់ ម៉ាហ្សារ៉ាកាត់ តើរ(r)ហាដាប់ ស្តង់ដាតរ(r) ពើឡាយ៉ាណាន់ រ៉ូម៉ាស់ សាគីត សាង៉ាត់ ទីងហ្គី)*

**kemarau** /គើម៉ារ៉ាវ/ *n* ស្ងួត: *រដូវប្រាំង musim kemarau (មូស៊ីម គើម៉ារ៉ាវ)*

**kemas** /គើម៉ាស់(s)/ *a* ខ្ចប់: កុងតឺន័រ *peti kemas (ពើទី គើម៉ាស់(s));*

**kemasan** /គើម៉ាសាន់/ *n* ការវិចខ្ចប់; ប្រអប់; កញ្ចប់:

*កញ្ចប់កាបូបនោះមានភាពស្អាតល្អ kemasan tas itu sangat rapi (គើម៉ាសាន់ តាស់(s) អ៊ីទូ សាង៉ាត់ រ៉ាពី);*

**mengemas** /មើងើម៉ាស់(s)/ *v* ខ្ចប់; វិចខ្ចប់; វិចបង្វិច:

*នាងវិចបង្វិចសំលៀកបំពាក់យ៉ាងតក់ក្រហល់*

*dia mengemas terburu-buru (ឌីយ៉ា មើងើម៉ាស់(s) តើប៊ូរូ ប៊ូរូ)*

**kembali** /គឹមប៉ាលី/ *v* វិលត្រឡប់:

*ពួកគេវិលត្រឡប់មកពីភ្នំពេញវិញនៅព្រឹកនេះ*

*mereka kembali dari Phnom Penh pagi ini (មើរេកា គើមបាលី ដារី ភ្នំពេញ ប៉ាហ្គី អ៊ីនី)*

**kemudi, mengemudikan** /មើងើមូឌីកាន់/ *v* បើកបរ:

*គាត់បើកបរឡានដោយគ្មានការប្រុងប្រយ័ត្ន*

*dia mengemudikan mobil dengan ceroboh (ឌីយ៉ា មើងើមូឌីកាន់ មូបិល ទើង៉ាន់ ចើរ៉ូប៊ូស)*

**kemudian** /គើមូឌីយ៉ាន/ *n* បន្ទាប់មក; រួចមក:

*គាត់ទៅបណ្ណាគារបន្ទាប់មកគាត់ទៅហាងកាហ្វេ*

*dia pergi ke toko buku, kemudian ke kafe (ឌីយ៉ា ពើរ(r)ហ្គី គើ តូកូ ប៊ូគូ គើមូឌីយ៉ាន គើ កាហ្វេ)*

**kenal, memperkenalkan** /មឹមពើរ(r)គើណាល់កាន់/ *v* ណែនាំ:

*គាត់បានណែនាំខ្លួនឯងថាជាបងប្អូនជីដូនមួយរបស់អ្នកជិតខាងខ្ញុំ dia memperkenalkan diri sebagai sepupu tetanggaku (ឌីយ៉ា ម៉ឹមពើរ(r)គើណាល់កាន់ ឌីរី សើបាហ្គៃ សើពូពូ ទើតាំងហ្គាគូ);*

**mengenali** /មើងើណាលី/ *v* ទទួលស្គាល់: *ខ្ញុំមិនទទួលស្គាល់គាត់ទៀតទេ saya tidak mengenali dia lagi (សាយ៉ា ទីដាក់ មើងើណាលី ឌីយ៉ា ឡាហ្គី)*

**kencan** /កឹនចាន់/ *n* ការណាត់ជួប:

*ការណាត់ជួបលើកដំបូង kencan pertama (កឹនចាន់ ពើរ(r)តាម៉ា)*

**kencang** /កិនចាំង/ *a* **1** លឿន; រហ័ស:

*សេវាអ៊ីនធឺណិតគ្មានខ្សែនៅក្នុងសណ្ឋាគារនោះគឺមានល្បឿនលឿនណាស់ koneksi wi-fi di hotel itu sangat kencang (កូណិកស៊ី វ៉ាយ–ហ្វាយ ឌី ហូតែល អ៊ីទូ សាង៉ាត់ កិនចាំង)*; **2** ដែលតឹង; ដែលណែន:

*គាត់ពាក់ខ្សែក្រវ៉ាត់សុវត្ថិភាពតឹងពេក dia memasang sabuk keselamatan terlalu kencang (ឌីយ៉ា មើម៉ាស៊ាំង សាប៊ុក គើសើឡាម៉ាតាន់ តើរ(r)ឡាលូ កិនចាំង)*

**kencing** /កិនជិង/ *v* ទឹកនោម:

*លទ្ធផលតេស្តទឹកនោមរបស់គាត់គឺមានជាតិស្រា terdapat alkohol pada hasil*

*tes urinnya (តេីរ(r)ដាប៉ាត់ អាល់កូហល់ ប៉ាដា ហាស៊ីល តែស(s) អ៊ូរីនញ៉ា)*

**kendara, kendaraan** /កិនដារ៉ាអាន់/ *n* មធ្យោបាយធ្វើដំណើរ; រថយន្ត: *រថយន្តធុនធ្ងន់ kendaraan berat (កិនដារ៉ាអាន់ បើរ៉ាត់);*

**mengendarai** /មើងិនដារ៉ាអ៊ី/ *v* ជិះ *គាត់ជិះកង់ទៅការិយាល័យ dia mengendarai sepeda ke kantor (ឌីយ៉ា មើងិនដារ៉ាអ៊ី សើប៉េដា គើ កាន់ត័រ(r))*

**kentang** /កិនតាំង/ *n* ដំឡូង: *ដំឡូងជៀន kentang goreng (កិនតាំង ហ្គរ៉េង)*

**kepal, kepalan** /គើប៉ាឡាន់/ *n* កណ្ដាប់ដៃ: *កណ្ដាប់ដៃ kepalan tangan (គើប៉ាឡាន់ តាង៉ាន់)*

**kepala** /គើប៉ាឡា/ *n* **1** នាយក: *នាយកសាលា kepala sekolah (គើប៉ាឡា សើកូឡះ);* **2** ក្បាល: *ក្រអឺតក្រទម*; *វាយឫក besar kepala (ប៊ែសារ(r) គើប៉ាឡា)*

**kepiting** /គើពីតីង/ *n* ក្ដាម: *ខ្ញុំចូលចិត្តញ៉ាំក្ដាម aku suka makan kepiting (អាគូ ស៊ូកា ម៉ាកាន់ គើពីតីង)*

**kerabat** /គើរ៉ាបាត់/ *n* ញាតិសាលោហិត; សាច់ញាតិ: *សាច់ជិត kerabat dekat (គើរ៉ាបាត់ ឌើកាត់)*

**kerah** /គើរ៉ះ/ *n* កអាវ: *គាត់រៀបកអាវរបស់គាត់ឲ្យស្អាតមុនពេលថតរូប dia merapikan kerah bajunya sebelum difoto (ឌីយ៉ា មើរ៉ាពីកាន់ គើរ៉ះ បាជូញ៉ា សឺបឺលុម ឌិហ្វូតូ)*

**kerang** /គើរ៉ាំង/ *n* ខ្យង; ខ្ចៅ: *អ្នកនេសាទលក់ខ្យងដែលជាផលនេសាទរបស់ខ្លួននៅកំពង់ផែ para nelayan menjual kerang hasil tangkapan mereka di pelabuhan (ប៉ារ៉ា នើឡាយ៉ាន់ មើនជូវ៉ាល់ គើរ៉ាំង ហាស៊ីល តាំងកាប៉ាន់ មើរេកា ឌិ ពើឡាប៊ូហាន់)*

**keranjang** /គើរ៉ាំងច្យាំង/ *n* កន្ត្រក់: *កន្ត្រក់សំរាម keranjang sampah (គើរ៉ាន់ច្យាំង សាំប៉ះ)*

**keras** /គើរ៉ាស់(s)/ *a* រឹង: *រឹងក្បាល keras kepala (គើរ៉ាស់(s) គើប៉ាឡា)*

**kerbau** /គើរ(r)បៅ/ *n* ក្របី: *កសិករភ្ជួររាស់ស្រែរបស់ពួកគេជាមួយក្របី petani membajak sawah*

*dengan kerbau (ដើតានី មើមបាច្បាក់ សាវ៉ះ ខើរ៉ាន់ គើរ(r)បាវ)*

**kereta** /គើរ៉េតា/ *n* រថភ្លើង: *ស្ថានីយ៍រថភ្លើង stasiun kereta (ស្តាស៊ីយូន គើរ៉េតា)*

**kering** /គើរីង/ *a* ស្ងួត: *រដូវប្រាំងស្ងួត musim kering (មូស៊ីម គើរីង); ដីស្ងួត tanah kering (តាណះ គើរីង);*

**kekeringan** /គើគើរីង៉ាន់/ *n* ស្ងួត; រីងស្ងួត: *ភាពរីងស្ងួតបានធ្វើឱ្យខកខានការប្រមូលផល kekeringan telah menyebabkan gagal panen (គើគើរីង៉ាន់ តើឡះ មើញើបាប់កាន់ ហ្គាហ្គាល់ ប៉ាណិន);*

**mengeringkan** /មើងើរីងកាន់/ *v* ហាល; សម្ងួត: *សម្ងួតសម្លៀកបំពាក់អ្នក keringkan pakaianmu (គើរីងកាន់ ប៉ាកៃយ៉ាន់មូ)*

**keringat** /គើរីង៉ាត់/ *n* ញើស: *វាជូតញើសនៅលើមុខរបស់វា ia mengusap keringat di wajahnya (អ៊ីយ៉ា មើងូសាប់ គើរីង៉ាត់ ឌិ វ៉ាចៀះញ៉ា);*

**berkeringat 1** /បឺរ(r)គើរីង៉ាត់/ *v* មានញើស: *ក្មេងម្នាក់នោះរត់រហូតដល់ចេញញើស anak itu berlari hingga berkeringat (អាណាក់ អ៊ីទូ បឺរ(r)ឡារី ហ៊ីងហ្គា បឺរ(r)គើរីង៉ាត់);*

**2** /បើរ(r)គើរីង៉ាត់/ *v* ញើស; ដែលមានញើស: *អាកាសធាតុក្ដៅធ្វើឱ្យខ្ញុំបែកញើសច្រើន cuaca panas membuatku banyak berkeringat (ជូវ៉ាចា ប៉ាណាស់(s) មើមប៊ូវ៉ាត់គូ បាញ៉ាក់ បើរ(r)គើរីង៉ាត់)*

**kerja, bekerja** /បឺគើរ(r)ចា្យ/ *v* ធ្វើការ: *តោះធ្វើការ mari bekerja (ម៉ារី បឺគើរ(r)ចា្យ);*

**mengerjakan** /មើងងើរ(r)ចា្យកាន់/ *v* ធ្វើ: *ទើអ្នកកំពុងធ្វើអ្វី? kamu sedang mengerjakan apa? (កាមូ សឺដាំង មើងើរ(r)ចា្យកាន់ អាប៉ា?)*

**kertas** /គើរ(r)តាស់(s)/ *n* ក្រដាស: *យើងត្រូវការក្រដាសនិងប៊ិចដើម្បីសរសេរ kita perlu kertas dan pena untuk menulis (គីតា ពើរ(r)លូ*

*គើរ(r)តាស់(ស) ដាន់ ពេណា អ៊ុនទុក មើនូលិស(ស)); ក្រដាសមួយសន្លឹក selembar kertas (សើឡឹមបារ(r) គើរ(r)តាស់(s))*

**kesal** /គើសាល់/ *a* ឃ្នើសចិត្ត: *គាត់ធ្វើឲ្យខ្ញុំឃ្នើសចិត្តជាមួយនិងអត្តចរិតរបស់គាត់ dia membuatku kesal dengan tingkahnya (ឌីយ៉ា ម៉ើមប៊ូវ៉ាត់គូ គើសាល់ ដើង៉ាន់ ទីងកះញ៉ា)*

**kesan** /គើសាន់/ *n* ចំណាប់អារម្មណ៍: *មេដឹកនាំម្នាក់នោះជាមនុស្សល្អនៅក្នុងក្រសែភ្នែកកូនចៅរបស់គាត់ pimpinan itu memiliki kesan yang baik di mata anak buahnya*

*(ពីមពីណាន់ អ៊ីទូ ម៉ើមីលីគី គើសាន់ យ៉ាំង បាអ៊ីគ ឌិ ម៉ាតា អាណាក់ ប៊ូវ៉ះញ៉ា)*

**ketat** /គើតាត់/ *a* **1** តឹងរឹង: *ច្បាប់តឹងរឹង peraturan ketat (ពើរ៉ាទូរ៉ាន់ គើតាត់)*; **2** ដែលតឹង; ដែលណែន; ដែលចង្អៀត: *ខោតឹង celana ketat (ចើឡាណា គើតាត់)*

**ketela** /គើតេឡា/ *n* ក្តួច/ដំឡូង: *ដំឡូងមានផ្ទុកសរធាតុកាបូអ៊ីដ្រាតជាច្រើន ketela banyak mengandung karbohidrat (គីតេឡា បាញ៉ាក់ មើង៉ាន់ឌុគ ការ(r)បូហ៊ីដ្រាត់)*

**ketiak** /គើទីយ៉ាក/ *n* ក្លៀក: *ក្លៀករបស់វាសើម ketiaknya basah (គើទីយ៉ាកញ៉ា បាសះ)*

**ketika** /គើទីកា/ *n* នៅពេលដែល: *ខ្ញុំបានឃើញគាត់នៅពេលដែលគាត់កំពុងដើរនៅលើចិញ្ចើមផ្លូវ saya melihatnya ketika dia sedang berjalan di trotoar (សាយ៉ា មើលីហាត់ញ៉ា គើទីកា ឌីយ៉ា សឺដាំង ប៊ើរ(r)ចាឡាន់ ឌិ ត្រូតូអារ(r) )*

**ketombe** /គើតុមបេ/ *n* អង្គែ: *គាត់ទិញសាប៊ូសម្រាប់បំបាត់អង្គែនៅលើស្បែកក្បាលរបស់គាត់ dia membeli sampo untuk menghilangkan ketombe di kepalanya (ឌីយ៉ា ម៉ើមប៊ឺលី សាំប៉ូ អ៊ុនទុក មើងហ៊ីឡាន់កាន់ កេតុមបេ ឌិ គើប៉ាឡាញ៉ា)*

**ketuk, mengetuk** /មើងើទុក/ *v* គោះ: *គោះទ្វាមុននឹងចូល ketuk pintu sebelum masuk (គើទុក ពីនទូ សើប៊ើលុម ម៉ាស៊ុក)*

**khas** /ខាស់(s)/ *a* ភាពពិសេស; ប្លែក: *ចំណីអាហារប្លែក makanan khas (ម៉ាកាន់ណាន់ ខាស់(ស))*

**khawatir** /ខាវ៉ាទីរ(r)/ *a* ព្រួយបារម្ភ; ពិបាកចិត្ត:

*យើងមានការព្រួយបារម្ភដោយខ្លាចប្រឡងមិនជាប់*

*kami khawatir tidak dapat lulus ujian (កាមី ខាវ៉ាទីរ(r) ទីដាក់ ដាប៉ាត់ លូលុស អ៊ូជីយ៉ាន)*

**khusus** /ឃូស៊ូស(s)/ *a* ពិសេស:

*កម្មវិធីពិសេស acara khusus (អាចារ៉ា ឃូស៊ុស(s))*

**kilat** /គីឡាត់/ *n* រន្ទះ *រន្ទះបានបាញ់ផ្ទះនោះ*

*kilat menyambar rumah itu (គីឡាត់ មើញ៉ាំបារ(r) រូម៉ះ អ៊ីទូ)*

**kimia** /គីមីយ៉ា/ *n* គីមី:

*គីមីមានប្រយោជន៍ខ្លាំងណាស់សម្រាប់អភិវឌ្ឍបច្ចេកវិទ្យា kimia sangat berguna bagi pengembangan teknologi (គីមីយ៉ា សាង៉ាត់ បឺរ(r)ហ្គូណា បាហ្គី ពើងើមបាង៉ាន់ តិកណូឡូហ្គី)*

**kini** /គីនី/ *n* ឥឡូវ:

*ឥឡូវនេះមនុស្សគ្រប់គ្រូបបានប្រើប្រាស់ទូរស័ព្ទដៃ*

*kini setiap orang menggunakan telepon genggam (គីនី សឺទីយ៉ាប អូរ៉ាំង មើងហ្គូណាកាន់ តេឡេប៉ូន ហ្គឹងហ្គាំ)*

**kios** /គីយ៉ុស(s)/ *n* តូប; ហាង: *តូបនោះលក់បារី kios itu menjual rokok (គីយ៉ុស(s) អ៊ីទូ ម៉ើនជូវ៉ាល រ៉ូកុក)*

**kipas** /គីប៉ាស (s)/ *n* កង្ហារ:

*កង្ហារនោះស្អាតណាស់ kipas itu sangat cantik (គីប៉ាស់(ស) អ៊ីទូ សាង៉ាត់ ចាន់ទិគ)*

**kira, memperkirakan** /មឹមពើរ(r)គីរ៉ាកាន់/ *v* ប៉ាន់ស្មាន; ព្យាករណ៍:

*ពួកយើងបានធ្វើការព្យាករណ៍ថានឹងមានភ្លៀងធ្លាក់*

*kami sudah memperkirakan bahwa akan turun hujan (កាមី ស៊ូដះ ម៉ឹមពើរ(r)គីរ៉ាកាន់ បះវ៉ា អាកាន់ ទូរុន ហ៊ូចាន់);*

**mengira** /មើងីរ៉ា/ *v* គិតថា:

*ខ្ញុំមិនដែលគិតថាគាត់អាចធ្វើនូវរឿងនោះឡើយ*

*saya tidak pernah mengira dia bisa melakukan hal itu (សាយ៉ា ទីដាក់ ពើរ(r)ណាស់ មើងីរ៉ា ឌីយ៉ា ពីសា មើឡាគូកាន់ ហាល់ អ៊ីទូ);*

**kira-kira** /គីរ៉ា–គីយ៉ា/

*adv* ប្រហែល; ប្រមាណ:

*ទំងន់ក្មេងម្នាក់នោះប្រមាណជាសាមសិបគីឡូ*

*berat anak itu kira-kira 30 kg (បើរ៉ាត់ អាណាក់ អ៊ីទូ គីរ៉ា–គីរ៉ា ទីហ្កាពូលូ គីឡូក្រាម)*

**kiri** /គីរី/ *n* ឆ្វេង: *បត់ឆ្វេង belok kiri (បេឡុក គីរី); ឆ្វេងនិយម aliran kiri (អាលីរ៉ាន់ គីរី)*

**kirim** /គីរីម/ *v* ផ្ញើ; បញ្ជូន: *ផ្ញើសំបុត្រនេះភ្លាមៗ kirim surat ini segera (គីរីម ស៊ូរ៉ាត់ អ៊ីនី សើហ្គើរ៉ា);*

**kiriman** /គីរីម៉ាន់/ *n* ចែកចាយ; ដឹកជញ្ជូន: *សេវាដឹកជញ្ជូន layanan kiriman (ឡាយ៉ាណាន់ គីរីម៉ាន់)*

**kita** /គីតា/ *pron* ពួក; ពួកយើង: *យើងនឹងទៅពិធីជប់លៀងនៅយប់នេះ kita akan pergi ke pesta malam ini (គីតា អាកាន់ ពើរ(r)ហ្គី គើ ពែស្តា ម៉ាឡាំ អ៊ីនី)*

**kitab** /គីតាប់/ *n* គម្ពីរ**:** *សាសនាទាំងអស់បានបង្រៀនសាសនិករបស់ពួកគេឲ្យសូត្រនូវគម្ពីរ setiap agama mengajarkan umatnya untuk membaca kitab (សឺទីយ៉ាប អាហ្គាម៉ា មើង៉ាច្ញារ(r)កាន់ អ៊ូម៉ាត់ញ៉ា អ៊ុនទុក មើមបាចា គីតាប់)*

**kitar, sekitar** /សើគីតារ(r)/ *n* ជុំវិញ: *លេងនៅជុំវិញផ្ទះ bermain di sekitar rumah (បើរ(r)ម៉ែន ឌី សើគីតារ(r) រូម៉ះ)*

**kokoh** /កូកុះ/ *a* រឹងមាំ: *សំណង់ដ៏រឹងមាំ bangunan kokoh (បាងូណាន់ កូកុះ)*

**kolam** /កូឡាំ/ *a* អាង: *អាងត្រី kolam ikan (កូឡាំ អ៊ីកាន); អាងហែលទឹក kolam renang (កូឡាំ រើណាំង)*

**kompor** /កុំប៉ូរ(r)/ *n* ចង្ក្រាន: *ចង្ក្រានហ្គាស kompor gas (កុំប៉ូរ(r) ហ្គាស់(s)); ចង្ក្រានអគ្គីសនី kompor listrik (កុំប៉ូរ(r) លីស្ទ្រីក)*

**koper** /កូពើរ(r)/ *n* វ៉ាលី: *វ៉ាលីនោះមានសម្លៀកបំពាក់ koper itu berisi baju (កូពើរ(r) អ៊ីទូ ប៊ើរីស៊ី បាជូ)*

[1]**kopi** /កូពី/ *n* កាហ្វេ: *ពួកយើងចូលចិត្តផឹកកាហ្វេ kami suka meminum kopi (កាមី ស៊ូកា មើមីនុម កូពី)*

[2]**kopi** /កូពី/ *n* ចម្លង: *ថតចម្លង fotokopi (ហ្វូតូ កូពី)*

**koran** /កូរ៉ាន់/ *n* កាសែត: *ព័ត៌មាននៅក្នុងកាសែតភាគច្រើនអតុល្យភាព berita di koran itu seringkali*

*tidak berimbang (ទើរីតា ឌី កូរ៉ាន់ អ៊ីទូ សេរីងកាលី ទីដាក់ បើរ(r)អ៊ីមបាំង)*

**korban** /កូរ(r)បាន់/ *n* ជនរងគ្រោះ: *ជនរងគ្រោះដោយសារមនុស្សឃាត korban pembunuhan (កូរ(r)បាន់ ពើមប៊ូនូហាន់);*

**berkorban** /ប៊ឺរ(r)កូរ(r)បាន់/ *v* បូជា; លះបង់: *វីរបុរសរបស់យើងសុខចិត្តលះបង់អាយុជីវិតរបស់ពួកគេដើម្បីប្រទេសជាតិទទួលបាននូវឯករាជ pahlawan kita bersedia berkorban nyawa untuk kemerdekaan bangsa (ប៉ះឡាវ៉ាន់ គីតា ប៊ឺរ(r)សឺឌីយ៉ា ម៉ើង៉ូរ(r)បានកាន់ ញ៉ាវ៉ា អ៊ុនទុក គើមើរ(r)ដេកាអាន បាំងសា)*

**kosakata** /កូសាកាតា/ *n* វាក្យសព្ទ: *វចនានុក្រមគឺប្រមូលផ្តុំទៅដោយវាក្យស័ព្ទជាច្រើន kamus berisi kumpulan kosakata (កាមុស(ស) ប៊ើរីស៊ី គុមពូឡាន់ កូសាកាតា)*

**kosong** /កូសុង/ *a* ទទេ: *ដបទទេ botol kosong (បូតុល កូសុង);* *គំនិតគ្មានប្រយោជន៍ pikirannya kosong (ពីគីរ៉ាន់ញ៉ា កូសុង);* *ផ្ទះទទេ rumah kosong (រូម៉ះ កូសុង)*

**kota** /កូតា/ *n* ទីក្រុង: *ទីក្រុងធំ kota besar (កូតា បែសារ(r))*

**kotak** /កូតាក់/ *n* ប្រអប់: *ដាក់ចូលសៀវភៅទាំងនេះទៅក្នុងប្រអប់ masukkan buku-buku ini ke dalam kotak (ម៉ាស៊ុកកាន់ ប៊ូគូ-ប៊ូគូ អ៊ីនី គើ ដាឡាំ កូតាក់)*

**kotor** /កោត័រ(r)/ *a* កខ្វក់: *សំលៀកបំពាក់កខ្វក់ pakaian kotor (ប៉ាកៃយ៉ាន់ កោត័រ(r))*

**kritik, mengkritik** /មើងគ្រីទីគ/ *v* រិះគន់: *សកម្មជននោះតែងតែរិះគន់នូវគោលនយោបាយរបស់រដ្ឋាភិបាល aktivis itu sering mengkritik kebijakan pemerintah (អាក់ទីហ្វីស(ស) អ៊ីទូ សឺរិង មើងគ្រីទិគ កឺប៊ីច្យាកាន់ ពើមើរិនតះ)*

**kuasa, menguasai** /មើង៉ូវ៉ាសៃ/ *v* ក្តោបក្តាប់; គ្រប់គ្រង: *ប្រទេសចិនបានគ្រប់គ្រងពាណិជ្ជកម្មពិភពលោក Cina menguasai perdagangan global (ជីណា មើង៉ូវ៉ាសៃ ពើរ(r)ដាហ្គាង៉ាន់ ក្លូបាល់);*

**penguasa** /ពើង៉ូវ៉ាសា/ *n* *អ្នកគ្រប់គ្រង; អ្នកក្តោបក្តាប់: អ្នកគ្រប់គ្រងរាជាណាចក្រ penguasa kerajaan (ពើង៉ូវ៉ាសា គើរ៉ាច្យាអាន)*

**kuat 1** /គូវ៉ែត/ *a* ដែលខ្លាំង: *ទោះបីវាស្គមតែវាមានកំលាំងខ្លាំងក្លាណាស់ meskipun kurus, anak itu sangat kuat (ម៉េស្គីពុន គួរូស(s) អាណាក់ អ៊ីទូ សាង៉ាត់ គូវ៉ាត់)*; **2** /គូវ៉ាត់/ *a* ដែលមានថាមពល; អនុភាព: *ការស៊ុតបាល់ដែលពោពេញទៅដោយថាមពល sebuah tendangan yang kuat (សេីប៊ូវ៉ះ តិនដាង៉ាន់ យ៉ាំង គូវ៉ាត់)*;

**kekuatan 1** /គើគូវ៉ាតាន់/ *n* កម្លាំង; ថាមពល; អនុភាព: *កម្លាំងសេះ kekuatan kuda (គើគូវ៉ាតាន់ គូដា)*; **2** /គើកូវ៉ែតតាន់/ *n* កម្លាំង; ថាមពល; អនុភាព: *កម្លាំងរបស់គាត់កាន់តែថយចុះ kekuatannya semakin melemah (គើគូវ៉ាតាន់ញ៉ា សេីម៉ាគិន មើលើម៉ះ)*

**kubah** /គូបះ/ *n* ដោម: *ដោមវិហារអ៊ីស្លាមនោះមើលទៅស្រស់ស្អាតខ្លាំងណាស់ kubah masjid itu terlihat sangat indah (គូបះ ម៉ាស់(ស)ជិត អ៊ីទូ ទើរ(r)លីហាត់ សាង៉ាត់ អ៊ិនដះ)*

**kubik** *n* ម៉ែត្រគូប: *យើងត្រូវការទឹកបីម៉ែត្រគូបសម្រាប់ដាក់ក្នុងអាងនោះ kami memerlukan tiga kubik air untuk mengisi kolam itu (កាមី មើមើរ(r)លូកាន់ ទីហ្គា គូប៊ិក អាអៀរ(r) អ៊ុនទុក មើងីស៊ី កូឡាំ អ៊ីទូ)*

**kubis** /គូប៊ីស (s)/ *n* ស្ពៃ: *ស្ពៃត្រូវបានដាំនៅកសិដ្ឋាន kubis ditanam di ladang (គូប៊ីស(ស) ឌិតាណាំ ឌិ ឡាដាំង)*

**kubur, kuburan** /គូប៊ូរ៉ាន់/ *n* ផ្នូរ; ទីបញ្ចុះសព; ប៉ាឆា: *ផ្នូរនោះមើលទៅគួរឱ្យខ្លាចណាស់ kuburan itu tampak menyeramkan (គូប៊ូរ៉ាន អ៊ីទូ តាំប៉ាក់ មើញើរ៉ាំកាន់)*;

**menguburkan** /មើងូប៊ូរ(r) កាន់/ *v* កប់: *គាត់កប់ខ្មោចសត្វនៅកណ្តាលព្រៃ dia mengubur binatang itu di tengah hutan (ឌីយ៉ា មើងូប៊ូរ(r) ប៊ីណាតាំង អ៊ីទូ ឌិ ទើងង៉ះ ហ៊ូតាន់)*

**kubus** /គូប៊ូស(s)/ *n* គូប; បួនជ្រុង: *គាត់បត់ក្រដាសជារាងបួនជ្រុង dia melipat kertas menjadi sebuah kubus (ឌីយ៉ា មើលីប៉ាត់ គើរ(r)តាស់(ស) មើនចា្យឌី សឺប៊ូវ៉ាស់(ស)គូប៊ុស(ស))*

**kucil, mengucilkan** /មើងូជីលកាន់/ *v* រើសអើង; ដាក់ឱ្យដាច់ដោយឡែក:

*រដ្ឋាភិបាលផ្តាច់បានដាក់ក្រុមសកម្មជនឲ្យនៅដាច់ដោយឡែកនៅលើកោះតូចមួយ*

*pemerintah otoriter itu mengucilkan para aktivis di sebuah pulau kecil (ពើមើរិនតះ អូតូរីតែរ(r) អ៊ីទូ មើងូជីលកាន់ ប៉ារ៉ា អាក់ទីហ្វីស(ស) ឌិ សឺប៊ូវាស់(ស) ពូឡៅ គើជីល)*

**kucing** /គូជិង/ *n* ឆ្មា: *ឆ្មារបស់ខ្ញុំខ្លាចទឹក kucing saya takut air (គូជិង សាយ៉ា តាគុត អ៉ែយីរ(r))*

**kuda** /គូដា/ *n* សេះ:

*ពួកគេកំពុងតែទស្សនាការប្រណាំងសេះ mereka sedang menonton balapan kuda (មើរេកា សឺដាំង មើណុនតុន បាឡាប៉ាន់ គូដា)*;

**kuda-kuda** /គូដា–គូដា/ *n* ទីតាំង:

*អ្នកប្រយុទ្ធបានជ្រើសរើសទីតាំងរបស់ខ្លួនមុននឹងវ៉ៃទៅលើគូប្រកួតរបស់ខ្លួន petarung itu mengambil kuda-kuda sebelum menyerang lawannya (ពើតារុង អ៊ីទូ មើងុាំប៊ីល គូដា–គូដា សឺប៊ឺលុម មើញើរ៉ាំង ឡាវ៉ាន់ញ៉ា)*

**kue** /គូអេ/ *n* **1** នំ: *នំឈីស kue keju (គូអេ គេជូ)*;

**2** នំ; នំខេក: *នំខួបកំណើត kue ulang tahun (គូអេ អ៊ូឡាំង តាហ៊ុន)*

**kuku** /គូគូ/ *n* ក្រចក: *ការថែរក្សាក្រចក perawatan kuku (ពើរ៉ាវ៉ាតាន់ គូគូ)*

**kukuh** /គូគុះ/ *a* រឹងមាំ:

*គាត់រឹងមាំក្នុងជំហររបស់ខ្លួន dia kukuh dengan pendiriannya (ឌីយ៉ា គូគុះ ឌើង៉ាន់ ពើនឌិរីយ៉ាន់ញ៉ា)*;

**memperkukuh** /មើមពើរ(r)គូគុះ/ *v* ពង្រឹង:

*រដ្ឋាភិបាលបានព្យាយាមពង្រឹងនូវសន្តិសុខជាតិ*

*pemerintah berusaha memperkukuh keamanan nasional (ពើមើរិនតះ ប៊ឺរូសាហា មើមពើរ(r)គូគុះ គើអាម៉ាណាន់ ណាស៊ីយ៉ូណាល់)*;

**pengukuhan** /ពើង៉ូគូហាន់/ *n* សម្ពោធ; ប្រគល់តំណែង; តែងតាំង:

*សប្តាហ៍ក្រោយយើងនឹងទៅកម្មវិធីការតែងតាំងសាស្ត្រាចារ្យមហាបរិញ្ញា minggu depan kami akan hadir dalam acara pengukuhan profesor itu (មិងហ្គូ ឌើប៉ាន់ កាមី អាកាន់ ហាឌីរ(r) ដាឡាំ អាចារ៉ា ពើង៉ូគូហាន់ ប្រូហ្វេសើរ(r) អ៊ីទូ)*

**kukus** /គូគូស(s)/ *n* ចំហុយ; កម្ដៅ:

*បន្លែចំហុយ sayuran kukus (សាយូរ៉ាន់ គូគុស(ស));*

**mengukus** /មើងូគូស(s)/ *v* ចំហុយ; កម្ដៅ: *អ្នកម្ដាយកម្ដៅម្ហូបនៅឯចង្ក្រានបាយ ibu mengukus makanan di dapur (អ៊ីប៊ូ មើងូគុស(ស) ម៉ាកាណាន់ ឌិ ដាពួរ(r))*

**kuliah** /គូលីយ៉ះ/ *n* រៀន:

*ក្មេងនោះមិនសូវចូលរៀននោះទេ anak itu jarang mengikuti kuliah (អាណាក់ អ៊ីទូ ច្យារ៉ាំង មើងីគូទី គូលីយ៉ះ)*

**kulit** /គូលីត/ *n* ស្បែក;

*ស្បែកកខ្ញុំក្រហមដោយសារប្រតិកម្ម/អាឡែហ្ស៊ី kulitku merah karena alergi (គូលីត មេរ៉ះ ការើណា អាលើរ(r)ហ្គី);*

*កាបូបរបស់នាងធ្វើពីស្បែក tasnya terbuat dari kulit (តាស់(s)ញ៉ា តើរ(r)ប៊ូអ៉ាត ដារី គូលីត)*

**kulkas** /គុលកាស់(s)/ *n* ទូទឹកកក:

*កំទុកចេកនៅក្នុងទូទឹកកក jangan simpan pisang dalam kulkas (ច្យាង៉ាន់ ស៊ីមប៉ាន់ ពីសាំង ដាឡាំ គុលកាស់(s))*

**kumal** /គូម៉ាល់/ *a* រយាក:

*អ្នកសុំទានម្នាក់នោះពាក់ខោអាវរយាក gelandangan itu mengenakan baju kumal (ហ្គើឡាន់ដាង៉ាន់ អ៊ីទូ មើងើណាកាន់ បាជូ គូម៉ាល)*

**kuman** /គូម៉ាន់/ *n* ពពួកផ្សិត; មេរោគ:

*គាត់សម្អាតពពួកផ្សិតដែលនៅជាប់និងដៃរបស់គាត់ dia membersihkan kuman yang menempel di tangan (ឌីយ៉ា មើមបឺរ(r)ស៊ីះកាន់ គូម៉ាន់ យ៉ាំង មើណែមប៉ែល ឌិ តាង៉ាន់)*

**kumbang** /គូមបាំង/ *n* ឌឹម៉ាល់:

*ឌឹម៉ាល់កំពុងតែក្រេបជញ្ជក់លម្អងផ្កា kumbang itu sedang menghisap sari bunga (គុមបាំង អ៊ីទូ សឺដាំង មើងហ៊ីសាប់ សារី ប៊ូង៉ា)*

**kumis** /គូមីស(s)ញ៉ា/ *n* ពុកមាត់:

*គាត់កាត់ពុកមាត់របស់គាត់ដែលក្រាស dia merapikan kumisnya yang tebal (ឌីយ៉ា មើរ៉ាពីកាន់ គូមីស(ស)ញ៉ា យ៉ាំង ទើបាល់)*

**kumpul, berkumpul** /បឺរ(r)គុមពុល/ *v* ប្រមូលផ្ដុំ:

*យើងបានប្រមូលផ្ដុំគ្នានៅទីធ្លាជារៀងរាល់ព្រឹក*

*kami berkumpul di halaman setiap pagi hari (កាមី ប៊ឺ(r)គូមពុល ឌិហាឡាម៉ាន់ សឺទីយ៉ាប ប៉ាហ្គី ហារី);*

**mengumpulkan** /មើងុមពុលកាន់/ *v* ប្រមូល: *អ្នកគិតលុយប្រមូលវិក័យប័ត្រការលក់របស់គាត់ kasir itu mengumpulkan bon penjualannya (កាស៊ីរ(r) អ៊ីទូ មើងុមពុលកាន់ បោន ពើនជូវ៉ាល់ឡាន់ញ៉ា);*

**perkumpulan** /ពើរ(r)គុមពូឡាន់/ *n* សមាគម: *សមាគមយុវជន perkumpulan remaja (ពើរ(r)គូមពូឡាន់ រ៉េម៉ាចា)*

**kumuh** /គូមុះ/ *a* កខ្វក់; អនាធិបតេយ្យ: *តំបន់អនាធិបតេយ្យ perkampungan kumuh (ពើរ(r)កាំពូង៉ាន់ គូមុះ)*

**kunang-kunang** /គូណាំង–គូណាំង/ *n* សត្វអំពិលអំពែក: *សត្វអំពិលអំពែកភ្លឺភ្លឹបភ្លែតៗនៅកន្លែងងងឹត kunang-kunang berkelap-kelip di kegelapan (គូណាំង–គូណាំង ប៊ឺ(r)គើឡាប់ គើលីប ឌិ គើហ្គើឡាប៉ាន់)*

**kunci** /គុនជី/ *n* សោ; កូនសោ; គន្លឹះ: *សោផ្ទះ kunci rumah (គុនជី រូម៉ះ);*

**mengunci** /មើងុនជី/ *v* ចាក់សោ: *កំភ្លេចចាក់សោទ្វា jangan lupa mengunci pintu (ចាង៉ាន់ លូប៉ា មើងុនជី ពិនទូ)*

**kuning** /គូនីង/ *n* ពណ៌លឿង: *ត្រីនោះពណ៌លឿង ikan itu berwarna kuning (អ៊ីកាន់ អ៊ីទូ ប៊ឺ(r)វ៉ារ(r)ណា គូនិង);*

**-- telur** /គូនីង ទើលូរ(r)/ ស៊ុត; ពង(លឿង): *ខ្ញុំចូលចិត្តញ៉ាំពង(លឿង)សម្រាប់អាហារពេលព្រឹក saya suka makan kuning telur untuk sarapan (សាយ៉ា ស៊ូកា ម៉ាកាន់ គូនិងទើលូរ(r) អ៊ុនទុក សារ៉ាប៉ាន់);*

*tampan (ត្ស៊ីឡាគី អ៊ីទូ សាង៉ាត់ ហ្គាហ្គះ ដាន់ តាំប៉ាន់)*

**lelang** /ឡេឡាំង/ *n* ការដេញថ្លៃ: *ផ្ទះចំណាស់នោះត្រូវបានដាក់ឲ្យដេញថ្លៃ rumah tua itu dilelang (រូម៉ះ ទូវ៉ា អ៊ីទូ ឌិឡេឡាំង);*

**melelang** /មើឡេឡាំង/ *v* ដេញថ្លៃ: *គាត់ចូលចិត្តចូលរួមដេញថ្លៃវត្ថុបុរាណ dia senang mengikuti lelang barang antik (ឌីយ៉ា សឺណាំង មើងីគូទី ឡេឡាំង បារ៉ាង អានទីគ);*

**pelelangan** /ពើឡេឡាង៉ាន់/ *n* ការដាក់ឲ្យដេញថ្លៃ: *ការដាក់ឲ្យដេញថ្លៃផ្ទះប្រណីតនឹងត្រូវធ្វើឡើងនៅសប្តាហ៍ក្រោយ pelelangan rumah mewah itu akan diadakan minggu depan (ពើឡេឡាង៉ាន់ រូម៉ះ មើវ៉ះ អ៊ីទូ អាកាន់ ឌីយ៉ាដាកាន់ មីងហ្គូ ឌើប៉ាន់);*

**lelap** /លើឡាប់/ *v* គេងលុងលក់: *គាត់បានគេងលុងលក់នៅលើកៅអី dia tertidur lelap di kursi (ឌីយ៉ា ទើរ(r)ទីឌូរ(r) លើឡាប់ ឌិ គួរ(r)ស៊ី);*

**terlelap** /ទើរ(r)លើឡាប់/ *v* គេងលក់: *ព្រះអាទិត្យរះកាន់តែខ្ពស់ទៅហើយប៉ុន្តែវានៅតែគេងលុងលក់នៅឡើយ matahari sudah tinggi, tapi dia masih terlelap tidur (ម៉ាតាហារី ស៊ូដះ ទីងហ្គី, តាពី ឌីយ៉ា ម៉ាស៊ីស ទើរ(r)ឡេឡាប់ ទីឌូរ(r))*

**leleh, meleleh** /មើឡេឡេះ/ *v* រលាយ: *ការ៉េមរលាយដោយសារតែត្រូវកំដៅព្រះអាទិត្យ es krimnya meleleh terkena sinar matahari (អ៊ែស្គ្រីមញ៉ា មើឡេឡេះ ទើរ(r)គើណា ស៊ីណារ(r) ម៉ាតាហារី);*

**melelehkan** /មើឡេឡេះកាន់/ *v* ធ្វើឲ្យរលាយ: *វាកំពុងធ្វើឲ្យសូកូឡារលាយ dia sedang melelehkan coklat batangan (ឌីយ៉ា សឺដាំង មើឡេឡេះកាន់ ចូក្លាត់ បាតាង៉ាន់)*

**leluasa** /ឡឺលូវ៉ាសា/ *a* ទូលំទូលាយ; តាមចិត្ត: *គាត់កាន់តែទូលំទូលាយក្នុងការរៀបរាប់ប្រាប់ដល់គ្រូពេទចិត្តសាស្រ្ត dia lebih leluasa untuk bercerita pada psikiater (ឌីយ៉ា លើប៊ិះ ឡឺលូវ៉ាសា អ៊ុនទុក បឺរ(r)ចឺរីតា ប៉ាដា ព្សីគីយ៉ាទើរ(r))*

**lelucon** /ឡឺលូចុន/ *n* កំប្លែង: *ការកំប្លែងរបស់គាត់ពិតជាគួរឲ្យអស់សំណើចណាស់ leluconnya sangat lucu (ឡឺលូចុនញ៉ា សាង៉ាត់ លូជូ)*

**leluhur** /លើលូហ៊ូរ(r)/ *n* ជីដូនជីតា; បុព្វបុរសៈ

*យើងត្រូវតែគោរពបុព្វបុរសរបស់យើង kita harus menghormati leluhur kita (គីតា ហារុស(ស) មើងហូរ(r)ម៉ាទី ឡេលូហ៊ូរ(r) គីតា)*

**lem** /ឡែម/ *n* កាវៈ

*ការស្អិតជាប់ខ្លាំងទៅលើវត្ថុអ្វីក៏ដោយ lem itu merekat kuat pada benda apa pun (ឡែម អ៊ីទូ មើរើកាត់ គូវ៉ាត់ ប៉ាដា បេនដា អាប៉ា ពុន)*

**lemah** /លើម៉ះ/ *a* ខ្សោយ; គ្មានកម្លាំងៈ

*សេវាខ្សោយ sinyal lemah (ស៊ីញ៉ាល់ លើម៉ះ);*

**-- lembut** /លើម៉ះ ឡឹមប៊ុត/ ទន់ភ្លន់ៈ

*សម្ដីសម្ដោរបស់គាត់ពិតជាទន់ភ្លន់ណាស់ tutur katanya sangat lemah lembut (ទូទូរ(r) កាតាញ៉ា សាង៉ាត់ លើម៉ះ ឡឹមប៊ុត);*

**kelemahan** /គើលើម៉ាហាន់/

*n* ចំណុចខ្សោយៈ

*មនុស្សគ្រប់រូបតែងមានចំណុចខ្សោយនិងចំណុចខ្លាំងរបស់ខ្លួន setiap orang memiliki kelemahan dan kelebihan (សើទីយ៉ាប អូរ៉ាំង មើមីលីគី គើលើម៉ាហាន់ ដាន់ គើលើប៊ីហាន់);*

**melemahkan** /មើលើម៉ះកាន់/

*v* ចុះខ្សោយៈ

*គាត់ជោគជ័យធ្វើឱ្យគូប្រជែងរបស់គាត់ចុះខ្សោយ dia berhasil melemahkan lawannya (ឌីយ៉ា បឺរ(r)ហាស៊ីល មើលើម៉ះកាន់ ឡាវ៉ាន់ញ៉ា)*

**lemak** /ឡឹម៉ាក់/ *n* ខ្លាញ់ៈ

*ការលើសជាតិខ្លាញ់គឺមិនល្អសម្រាប់រាងកាយរបស់យើង kelebihan lemak tidak baik bagi tubuh kita (គើលើប៊ីហាន់ លើម៉ាក់ ទីដាក់ បាអ៊ីគ បាហ្គី ទូប៊ុះ គីតា);*

**-- hewani** /ឡឹម៉ាក់ ហេវ៉ានី/ ខ្លាញ់សត្វៈ

*ប្រេងធ្វើឡើងពីខ្លាញ់សត្វ minyak itu terbuat dari lemak hewani (មីញ៉ាក់ អ៊ីទូ ទើរ(r)ប៊ូវាត់ ដារី ឡឹម៉ាក់ ហេវ៉ានី);*

**-- nabati** /ឡឺម៉ាក់ ណាបាទី/ ប្រេងធញ្ញជាតិ: *ប្រេងធញ្ញជាតិជាធម្មតាគេប្រើសម្រាប់គ្រឿងសម្អាង lemak nabati biasanya digunakan untuk alat kecantikan (ឡឺម៉ាក់ ណាបាទី ប៊ីយ៉ាសាញ៉ា ឌិហ្គូណាកាន់ អ៊ុនទុក អាឡាត់ កើចាន់ទីកាន់);*

**berlemak** /ប៊ឺរ(r)ឡឺម៉ាក់/ *v* ដែលមានខ្លាញ់: *សាច់នោះមានខ្លាញ់ច្រើនណាស់ daging itu sangat berlemak (ដាហ្គិង អ៊ីទូ សាង៉ាត់ ប៊ឺរ(r)ឡឺម៉ាក់)*

**lemari** /លើម៉ារី/ *n* ទូ: *ទូតាំង lemari pajangan (លើម៉ារី ប៉ាចាង៉ាន់); ទូសំលៀកបំពាក់ lemari pakaian (លើម៉ារី ប៉ាកៃយ៉ាន់);*

**-- es** /ឡឺម៉ារី អែស(s)/ ទូរទឹកកក: *វាទុកការម៉ែមនៅក្នុងទូរទឹកកក ia menyim-pan makannya di lemari es (អ៊ីយ៉ា មើញីមប៉ាន់ ម៉ាកាន់ញ៉ា ឌិ ឡឺម៉ារី អែស(ស));*

**lemas** /លើម៉ាស់(s)/ *a* ហេវហត់អស់កម្លាំងខ្លាំង: *ភាពហេវហត់អស់កម្លាំងខ្លាំងគឺជារោគសញ្ញាមួយក្នុងចំណោមរោគសញ្ញាជាច្រើនរបស់ជម្ងឺស្លេកស្លាំង lemas adalah salah satu gejala kurang darah (លើម៉ាស់(s) អាដាឡះ សាឡះ សាទូ ហ្គើច្បាឡា គូរ៉ាំង ដារ៉ះ)*

**lembaga** /ឡឺមបាហ្គា/ *n* ស្ថាប័ន: *ស្ថាប័នរដ្ឋ lembaga pemerintah (ឡឹមបាហ្គា ពើមើរិនតះ)*

**lembah** /ឡឹមបះ/ *n* ជ្រលងភ្នំ: *ជ្រលងភ្នំនេះពិតជាស្រស់ស្អាតសម្រាប់ដើរកម្សាន្ត lembah itu sangat indah untuk dikunjungi (ឡឹមបះ អ៊ីទូ សាង៉ាត់ អ៊ីនដះ អ៊ុនទុក ឌិគុនជុងិ)*

**lembap** /ឡឹមបាប់/ *a* សើម: *បន្ទប់នេះគឺសើមខ្លាំងណាស់ដូច្នេះគឺងាយស្រួលធ្វើឲ្យមានមេរោគ ruangan itu sangat lembap sehingga mudah berjamur (រ៉ាង៉ាន់ អ៊ីទូ សាង៉ាត់ ឡឹមបាប់ សឺហ៊ីងហ្គា មូដះ ប៊ឺរ(r)ចាមូរ(r));*

**pelembap** /ពើឡឹមបាប់/ *n* ក្រែមការពារស្បែកស្ងួត: *គាត់តែងប្រើក្រែមមុខ dia selalu menggunakan pelembap wajah (ឌីយ៉ា សឺឡាលូ មើងហ្គូណាកាន់ ពើឡឹមបាប់ វ៉ាច្ប៉ះ)*

**lembar** /ឡឹមបារ((r)/ *n* ក្រដាស់; សន្លឹក: *សន្លឹកការងារ lembar kerja (ឡឹមបារ(r) គើរ(r)ច្បា)*

**lembek** /ឡឹមបិក/ *a* ជោរ: *ចេកនេះជោរពេកបើយកទៅចម្អិន pisang itu terlalu lembek untuk dimasak (ពីសាំង អ៊ីទូ ទើរ(r)ឡាលូ ឡឹមបិគ អ៊ុនទុក ឌិម៉ាសាក់)*

**lembu** /ឡឹមប៊ូ/ *n* គោ: *សាច់គោឆ្ងាញ់ណាស់សម្រាប់ញ៉ាំ daging lembu sangat enak untuk dimakan (ដាហ្គិង ឡឹមប៊ូ សាង៉ាត់ អ៊ែណាក់ អ៊ុនទុក ឌិម៉ាកាន់)*

**lembur** /ឡឹមប៊ូរ((r)/ *n* ថែមម៉ោង: *គាត់ធ្វើការថែមម៉ោង dia bekerja lembur (ឌីយ៉ា បឹគើរ(r)ចា្យ ឡឹមប៊ូរ(r))*

**lembut** /ឡឹមប៊ុត/ *a* ទន់; ទន់ល្មើយ; ស្រទន់: *ចូរនិយាយដោយពាក្យសម្តីស្រទន់ berkatalah dengan lembut (បើរ(r)កាតាឡះ ដឹង៉ាន់ ឡឹមប៊ុត);*

**kelembutan** /គើឡឹមប៊ូតាន់/ *n* ភាពទន់ភ្លន់: *ភាពទន់របស់នាងបានធ្វើឱ្យបេះដូងរបស់គាត់បាក់ស្រលាញ់ kelembutan wanita itu telah meluluhkan hatinya (គើឡឹមប៊ូតាន់ វ៉ានីតា អ៊ីទូ ទើឡះ មើលូលុះកាន់ ហាទីញ៉ា);*

**melembutkan** /មើឡឹមប៊ុតកាន់/ *v* ធ្វើឱ្យទន់: *គាត់ធ្វើឱ្យស្បែកកាបូបរបស់គាត់ទន់ជាមួយនិងទឹកពិសេស dia melembutkan tas kulitnya dengan cairan khusus (ឌីយ៉ា មើឡឹមប៊ុតកាន់ តាស់(ស) គូលីតញ៉ា ឌើង៉ាន់ ចាអ៊ីរ៉ាន់ ឃូស៊ុស(ស));*

**pelembut** /ពើឡឹមប៊ុត/ *n* ទឹកបន្ទន់; ទឹកក្រអូប: *ទឹកបន្ទន់សម្លៀកបំពាក់ធ្វើឱ្យសម្លៀកបំពាក់ទន់នឹងក្រអូប pelembut pakaian itu membuat pakaian menjadi lembut dan wangi (ពើឡឹមប៊ុត ប៉ាកៃយ៉ាន់ អ៊ីទូ មើមប៊ូអ៉ាត់ ប៉ាកៃយ៉ាន់ មើនចា្យឌិ ឡឹមប៊ុត ដាន់ វ៉ាងី)*

**lempar, lempar lembing** /ឡែមប៉ារ((r) ឡឹមប៊ិង/ ចោលលំពែង: *ការប្រកួតប្រជែងចោលលំពែងត្រូវបានប្រារព្ធធ្វើឡើងនៅក្នុងទីក្រុង lomba lempar lembing sedang diadakan di kotanya (ឡុមបា ឡែមប៉ារ(r) ឡឹមប៊ិង សឹដាំង ឌិអាដាកាន់ ឌិ កូតាញ៉ា);*

**lemparan** /ឡែមប៉ារ៉ាន់/ *n* បោះ; គប់; ចោល: *ការចោលរបស់គាត់គឺចំគោលដៅ lemparannya tepat mengenai*

*sasaran (ឡែមប៉ាក៉ាន់ញ៉ា ទើប៉ាត់ មើងើណៃ សាសារ៉ាន់);*

**melempar** /ឡឹមប៉ារ(r); មើឡឹមប៉ារ(r)/ *v* គប់; បោះ; បោះចោល: *បោះសន្ទូចចូលទៅក្នុងទន្លេ melempar kail ke dalam sungai (មើឡឹមប៉ារ(r) កាអ៊ីល គើ ដាឡាំ ស៊ូង៉ៃ)*

**lengan** /លើង៉ាន់/ *n* ដៃ: *ដៃរបស់មនុស្សពេញវ័យ lengan orang dewasa (លើង៉ាន់ អូរ៉ាង ដេវ៉ាសា)*

**lengkap** /ឡឹងកាប់/ *a* ពេញលេញ; គ្រប់: *កងកម្លាំងប្រដាប់អាវុធ pasukan lengkap (ប៉ាស៊ូកាន់ ឡឹងកាប់);*

**melengkapi** /មើឡឹងកាពី/ *v* បំពាក់ទៅដោយ: *គាត់បំពាក់ទៅដោយឧបករណ៍សង្គ្រាមជាមួយអាវុធទំនើប dia melengkapi peralatan perangnya dengan senjata mutakhir (ឌីយ៉ា មើឡឹងកាពី ពើរ៉ាឡាតាន់ ពើរ៉ាំងញ៉ា ឌើង៉ាន់ សិនច្យាតា មូតាក់ហ៊ីរ(r));*

**perlengkapan** /ពើរ((r)ឡឹងកាប៉ាន់/ *n* ឧបករណ៍/សំភារៈ: *សំភារៈការិយាល័យ perlengkapan kantor (ពើរ(r)ឡឹងកាប៉ាន់ កាន់តូរ(r))*

**lengkung, melengkung** /មើឡឹងគុង/ *v* កាច់; ពត់: *គាត់ពត់ដែកយ៉ាងខ្លាំងជាមួយនឹងដៃទាំងពីររបស់គាត់ dia melengkungkan besi itu dengan kedua tangannya yang kuat (ឌីយ៉ា មើឡឹងគុងកាន់ បឺស៊ី អ៊ីទូ ឌើង៉ាន់ គើឌូវ៉ា តាង៉ាន់ញ៉ា យ៉ាំង គូវ៉ាត់)*

**lentik** /ឡិនទីគ/ *a* ស្ទើង: *រោមភ្នែកនាងស្ទើងណាស់ bulu matanya sangat lentik (ប៊ូលូ ម៉ាតាញ៉ា សាង៉ាត់ ឡិនទីគ)*

**lentur** /ឡិនទូរ(r)/ *a* ទន់: *ខ្លួនរបស់គាត់ពិតជាទន់ណាស់ក្នុងការធ្វើចលនា badannya sangat lentur digerakkan (បាដាន់ញ៉ា សាង៉ាត់ ឡិនទូរ(r) ឌិហ្គើរ៉ាកាន់ );*

**kelenturan** /គើឡិនទូរ៉ាន់/ *n* ភាពអាចពត់បាន: *អ្នករាំរបាំបាឡេគ្រប់រូបត្រូវតែមានភាពអាចពត់បាននៃរាងកាយខ្ពស់ setiap penari balet harus memiliki kelenturan tubuh yang tinggi (សឺទីយ៉ាប ពើនណារី បាឡិត ហារុស(ស) មើមមីលីគី គើឡិនទូរ៉ាន់ ទូប៊ុះ យ៉ាំង ទិងហ្គី)*

**lenyap** /ឡឺនញ៉ាប់/ *a* រសាត់បាត់: *អ័ព្ទបានរសាត់បាត់លែងឃើញ kabut itu telah lenyap pandangan (កាប៊ុត អ៊ីទូ ទើឡះ ឡឺនញ៉ាប់ ប៉ាន់ដាង៉ាន់)*

**lepas** /លើប៉ាស់(s)/ *a* ដោះចេញ; ស្រាយចេញ: *ស្រាយខ្សែរស្បែកជើងរបស់អ្នកចេញ lepas tali sepatumu (លើប៉ាស់(s) តាលី សើប៉ាទូមូ);*

**-- landas** /លើប៉ាស់(s) ឡាន់ដាស់(s)/ ហោះឡើង: *យន្តហោះបានហោះចាកចេញទៅនៅវេលាម៉ោងប្រាំពីរព្រឹក pesawat lepas landas pukul 07.00 pagi (ពើសាវ៉ាត់ លើប៉ាស់(s) ឡាន់ដាស់(s) ប៉ូកុល ទូជុស ប៉ាហ្គី);*

**-- tangan** /លើប៉ាស់(s) តាំង៉ាន់/ ដោះដៃ: *គាត់ដោះដៃពីការទទួលខុសត្រូវរបស់គាត់ dia lepas tangan dari tanggung jawabnya (ឌីយ៉ា លើប៉ាស់(ស) តាង៉ាន់ ដារី តាំងហ្គុង ច្យាវ៉ាប់ញ៉ា);*

**melepas** /មើលើប៉ាស់/ *v* ព្រមឲ្យទៅ; ដោះលែង: *ខ្ញុំពិបាកធ្វើចិត្តខ្លាំងណាស់ដែលព្រមឲ្យនាងចាកចេញពីខ្ញុំ hatiku berat melepas dia pergi (ហាទីគូ ពើរ៉ាត់ មើលើប៉ាស់ ឌីយ៉ា ពើរ(r)ហ្គី);*

**melepaskan** /មើលើប៉ាស់(s)កាន់/ *v* ដោះលែង: *ដោះលែងត្រីដែលស្ទូចបាន melepaskan ikan hasil mengail (មើលើប៉ាស់(s)កាន់ អ៊ីកាន ហាស៊ីល មើង៉ាអ៊ីល)*

**lereng** /ឡែរ៉ែង/ *n* ជម្រាល: *ជម្រាលភ្នំភ្លើង lereng gunung Merapi (ឡែរ៉ែង ហ្គូនុង មើរ៉ាពី)*

**les** /លែស(s)/ *n* វគ្គសិក្សា: *ខ្ញុំរៀនវគ្គសិក្សាភាសាឥណ្ឌូនេស៊ីរយៈពេលប្រាំមួយខែនៅស្ថានទូតឥណ្ឌូនេស៊ី saya mengambil les bahasa Indonesia selama enam bulan di KBRI (សាយ៉ា មើងដុំប៊ីល លែស(ស) បាហាសា ឥណ្ឌូនេស៊ីយ៉ា ស៊ឺឡាម៉ា អឺណាំ ប៊ូឡាន់ ឌិ  កាបេអែរ(r)អ៊ី)*

**lestari** /លែស្តារី/ *a* និរន្តភាព; ថែរក្សា; អភិរក្ស;

**melestarikan** /មើលែសតារីកាន់/ *v* ថែរក្សា; ការពារ; អភិរក្ស: *ពួកយើងត្រូវតែថែរក្សាវប្បធម៌របស់យើង kita harus melestarikan budaya (គីតា ហារ៉ូស(s) មើលែសតារីកាន់ ប៊ូដាយ៉ា);*

**pelestarian** /ពើលែស្តារីយ៉ាន/

*n* និរន្តភាព; ថែរក្សា; អភិរក្ស:

*ការគ្រប់គ្រងព្រៃឈើត្រូវតែភ្ជាប់ជាមួយនូវការអភិរក្សធម្មជាតិ pengelolaan hutan harus diikuti dengan pelestarian alam (ពើងើឡូឡាអាន ហ៊ូតាន់ ហារុស(ស) ឌិអ៊ីគូទី ឌើង៉ាន់ ពើលែស្តារីយ៉ាន អាឡាំ)*

**letak** /ឡឺតាក់/ *n* ទីតាំង:

*ទីតាំងការិយាល័យអន្តោប្រវេសន៍ letak kantor imigrasi (ឡឺតាក់ កាន់តូរ(r) អ៊ីមីហ្គ្រាស៊ី);*

**meletakkan** /មើលើតាក់កាន់/ *v* ដាក់:

*ខ្ញុំដាក់វ៉ែនតានៅលើតុ saya meletakkan kacamata di atas meja (សាយ៉ា មើលើតាក់កាន់ កាចា ម៉ាតា ឌី អាតាស(s) មើចា);*

**terletak** /តើរ(r)លើតាក់/ *v* តាំងនៅ; ស្ថិតនៅ: *ផ្ទះរបស់នាងស្ថិតនៅមិនឆ្ងាយពីផ្សារទេ rumahnya terletak tidak jauh dari pasar (រូម៉ាស់ញ៉ា តើរ(r)លើតាក់ ទីដាក់ ចាវ ដារី ប៉ាសើរ(r))*

**letih** /ឡឺទិះ/ *a* អស់កម្លាំង; ហត់នឿយ:

*ពួកគេមិនអាចផ្តោតអារម្មណ៍ទៅលើកិច្ចប្រជុំដោយសារតែអស់កម្លាំង mereka tidak dapat berkonsentrasi dalam rapat itu karena lelah (មើរេកា ទីដាក់ ដាប៉ាត់ បឺរ(r)កុនសិនត្រាស៊ី ដាឡាំ រ៉ាប៉ាត់ អ៊ីទូ ការើណា ឡឺឡះ)*

**letus, letusan (gunung)** /ឡឺទូសាន់ ហ្គូនុង/ *n* ការផ្ទុះ

*ការផ្ទុះភ្នំភ្លើងកាន់តែបង្កគ្រោះថ្នាក់ដូច្នេះប្រជាពលរដ្ឋបានចាប់ផ្តើមជម្លៀសខ្លួនទៅកកន្លែងដែលសុវត្ថិភាព letusan gunung berapi semakin membahayakan sehingga warga mulai diungsikan ke tempat yang lebih aman (លើទូសាន់ ហ្គូនុង បឺរ៉ាពី សឺម៉ាគិន មើមបាហាយ៉ាកាន់ សឺហ៊ិងហ្គា វ៉ារ(r)ហ្គា មូឡៃ ឌិអ៊ុងស៊ីកាន់ គើ ទើមប៉ាត់ យ៉ាំង លើប៊ិះ អាម៉ាន់);*

**meletus** /មើលើទូស(s)/ *v* ផ្ទុះ:

*ផ្ទុះភ្នំភ្លើង gunung meletus (ហ្គូនុង មើលើទូស(s));*

**meletus (gunung)** /មើលើទុស(s) ហ្គូនុង/ *v* ផ្ទុះ:

*ផ្ទុះភ្នំភ្លើងតាំបូរ៉ានៅឆ្នាំ១៨១៥ត្រូវបានគេកត់ត្រាទុកថាជាការផ្ទុះដ៏ធំជាងគេបំផុតនៅក្នុងប្រវត្តិសាស្ត្រ letusan gunung Tambora*

*tahun 1815 tercatat sebagai letusan terbesar dalam sejarah (ឈើទូសាន់ ហ្គូនុង តាំបូរ៉ា តាហ៊ុន សឺរីប៊ូ ឌើឡាប៉ាន់ រ៉ាទុស(ស) លីម៉ា ប៊ឺឡាស់(ស) ទើរ(r)ចាតាត់ សឺបាហ្គៃ លើទូសាន់ ទើរ(r)បែសារ(r) ដាឡាំ សឺចារ៉ះ)*

**lewat** /លេវ៉ាត់/ *v* ឆ្លងកាត់:

*ឆ្លងកាត់មុខផ្ទះរបស់គាត់ lewat di depan rumahnya (លេវ៉ាត់ ឌី ដើប៉ាន់ រូម៉ាស់ញ៉ា)*

**lezat** /លើហ្សាត់/ *a*ឆ្ងាញ់:

*អាហារនៅក្នុងភោជនីយដ្ឋានោះឆ្ងាញ់ណាស់ makanan di restoran itu sangat lezat (ម៉ាកាណាន់ ឌិ រ៉េស្តូរ៉ាន់ អ៊ីទូ សាង៉ាត់ លើហ្សាត់);*

**pelezat** /ពើលេហ្សាត/

*n* គ្រឿងផ្សំឱ្យមានរស់ជាតិ:

*ស្ករអាចប្រើជាគ្រឿងផ្សំធម្មជាតិឱ្យមានរស់ជាតិនៅក្នុងការចម្អិនអាហារ gula dapat digunakan sebagai pelezat alami dalam masakan (ហ្គូឡា ដាប៉ាត់ ឌិហ្គូណាកាន់ សឺបាហ្គៃ ពើលើហ្សាត់ អាឡាំមី ដាឡាំ ម៉ាសាកាន់)*

**liang** /លីយ៉ាង/ *n* រូង:

*ក្មេងៗបានរកឃើញរូងរបស់ទន្សាយនៅក្នុងចំការ anak-anak menemukan sebuah liang kelinci di kebun itu (អាណាក់-អាណាក់ មើនើមូកាន់ សឺប៊ូវ៉ាស់(ស) លីយ៉ាង គើលីនជី ឌិ គើប៊ុន អ៊ីទូ)*

**liar** /លីយ៉ារ(r)/ *a* ព្រៃ: *សត្វព្រៃ binatang liar (ប៊ីណាតាំង លីយ៉ារ(r));*

*នៅសួនសាហ្វារីប្រទេសឥណ្ឌូនេស៊ីភ្ញៀវទេសចរអាចមើលឃើញសត្វព្រៃរាប់ពាន់ក្បាលដែលរស់នៅក្នុងជម្រកធម្មជាតិរបស់ពួកគេ di Taman Safari, Indonesia, wisatawan dapat melihat ribuan satwa liar hidup di habitat alami mereka (ឌិ តាម៉ាន់ សាហ្វារី ឥណ្ឌូនេស៊ីយ៉ា វីសាតាវ៉ាន់ ដាប៉ាត់ មើលីហាត់ រីប៊ូវ៉ាន សត្វា លីយ៉ារ(r) ហ៊ីឌុប ឌិ ហាប៊ីតាត់ អាឡាមី មើរេកា)*

**libat, keterlibatan**

/គើទើរ(r)លីបាតាន់/ *n* ការជាប់ទាក់ទង:

*ការការជាប់ទាក់ទងរបស់សិល្បករនៅក្នុងករណីសំណូកសូកប៉ាន់នោះគឺស្ថិតនៅក្រោមការស៊ើបអង្កេតនៅឡើយ keterlibatan seorang artis dalam perkara suap itu masih dalam penyelidikan (គើទើរ(r)លីបាតាន់ សឺអូរ៉ាំង អារ(r)ទិស(ស) ដាឡាំ ពើរ(r)ការ៉ា ស៊ូវ៉ាប់ អ៊ីទូ ម៉ាស៊ិះ ដាឡាំ ពើញ៉េលីឌិកាន់);*

**melibatkan** /មើលីបាត់កាន់/

*v* ធ្វើអោយជាប់ទាក់ទង; ធ្វើឱ្យចូលរួម: *រដ្ឋាភិបាលបានធ្វើឱ្យមេដឹកនាំសហគមន៍ចូលរួមក្នុងការផ្សព្វផ្សាយការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ pemerintah melibatkan tokoh-tokoh masyarakat dalam sosialisasi mengenai penyalahgunaan narkoba (ពើមើរិនតះ មើលីបាត់កាន់ តូកុះ តូកុះ ម៉ាស្យារ៉ាកាត់ ដាឡាំ សូស៊ីយ៉ាលីសាស៊ី មើងើណៃ ពើញ៉ាឡះហ្គូណាអាន ណារ(r)កូបា)*

**libur** /លីប៊ូរ(r)/ *n* ថ្ងៃឈប់សម្រាក: *ពួកយើងទទួលបានថ្ងៃឈប់សម្រាក់ពីរថ្ងៃក្នុងមួយខែ kami mendapat dua kali libur dalam sebulan (កាមី មើនដាប៉ាត់ ឌូវ៉ា កាលី លីប៊ូរ(r) ដាឡាំ សឺប៊ូឡាន់);*

**berlibur** /បឺរ(r)លីប៊ូរ(r)/

*v* សម្រាក់លំហែរកាយ: *ឆ្នាំមុនខ្ញុំបានសម្រាក់លំហែរកាយនៅក្រៅប្រទេសជាមួយមិត្តភ័ក្តរបស់ខ្ញុំ tahun lalu saya berlibur ke luar negeri bersama teman-teman (តាហ៊ុន ឡាលូ សាយ៉ា បឺរ(r)លីប៊ូរ(r) គើ លូវ៉ារ(r) ណឺហ្គើរី បឺរ(r)សាម៉ា ទើម៉ាន់ ទើម៉ាន់);*

**liburan** /លីប៊ូរ៉ាន់/ *n* ថ្ងៃឈប់សម្រាក់

**licik** /លីជិគ/ *a* ល្បិចកល; ឧបាយកល: *យុទ្ធសាស្រ្តទីផ្សារដែលមានល្បិចកល strategi pemasaran yang licik (ស្ត្រាតេហ្គី ពើម៉ាសារ៉ាន់ យ៉ាំង លីជីគ)*

**licin** /លីជិន/ *a* រអិល: *វាដួលដោយសារតែផ្លូវរអិល ia jatuh karena jalannya licin (អ៊ីយ៉ា ចាតួះ ការើណា ច្បាឡាន់ញ៉ា លីជិន)*

**lidah** /លីដះ/ *n* អណ្តាត: *អណ្តាតសម្រាប់ភ្លក់រស់ជាតិ lidah untuk merasa (លីដះ អ៊ុនទុ មើរ៉ាសា);*

**-- buaya** /លីដះ ប៊ូវ៉ាយ៉ា/

ប្រទាលកន្ទុយក្រពើ: *ញ៉ាំទឹកប្រទាលកន្ទុយក្រពើគឺល្អខ្លាំងណាស់សម្រាប់ថែរក្សារសម្រស់របស់ស្បែក konsumsi jus lidah buaya sangat bagus untuk memelihara kecantikan kulit (កុនស៊ូមស៊ី ជូស លីដះ ប៊ូវ៉ាយ៉ា សាង៉ាត់ បាហ្គុស(ស) អ៊ុនទុក មើមើលីហារ៉ា គើចាន់ទីកាន់ គូលីត)*

**lidi** /លីឌិ/ *n* ដំបង; ដង: *ដងអំបោស sapu lidi (សាពូ លីឌី)*

**lihat** /លីហាត់/ *n* មើល: មើលន,

*ទេសភាពស្អាតណាស់ តើមែនទេ? lihat,*

*pemandangan itu indah, bukan? (លីហាត់ ពើម៉ាន់ដាង៉ាន់ អ៊ីទូ អ៊ីនដាស់ ពូកាន់?);*

**kelihatannya** /គើលីហាតាន់ញ៉ា/ *adv* មើលទៅ: *មើលទៅបញ្ហានេះគឺកាន់តែមានភាពស្មុគស្មាញ់ kelihatannya masalah ini semakin rumit (គើលីហាតាន់ញ៉ា ម៉ាសាឡះ អ៊ីនី សឺម៉ាគិន រូមីត);*

**melihat** /មើលីហាត់/ *v* ឃើញ; មើល: *មើលឲ្យច្បាស់ melihat dengan jelas (មើលីហាត់ ទើង៉ាន់ ជើឡាស់(s));*

**melihat-lihat** /មើលីហាត់-លីហាត់/ *v* មើលជុំវិញ: *ខ្ញុំបានទៅចេញទៅមើលស្ថានភាពនៅជិតកន្លែងកើតហេតុ saya keluar untuk melihat-lihat situasi di dekat tempat kejadian perkara (សាយ៉ា គើលូវ៉ារ(r) អ៊ុនទុក មើលីហាត់-លីហាត់ ស៊ីទូវ៉ាស៊ី ឌិ ឌើកាត់ តឹមប៉ាត់ គើឌ្យាឌីយ៉ាន់ ពើរ(r)កាវ៉ា);*

**memperlihatkan** /មឹមពើរ(r)លីហាត់កាន់/ *v* បង្ហាញ: *គាត់បង្ហាញស្នាដៃរបស់គាត់ដោយមានមោទនភាព dengan bangganya dia memperlihatkan karyanya (ឌើង៉ាន់ បាំងហ្គាញ៉ា ឌីយ៉ា មើ្មពើរ(r)លីហាត់កាន់ការីយ៉ាញ៉ា);*

**penglihatan** /ពឹងលីហាតាន់/ *n* ការមើលឃើញ: *ការមើលឃើញរបស់គាត់គឺមិនសូវច្បាស់ penglihatannya kurang jelas (ពឹងលីហាតាន់ញ៉ា គូរ៉ាង ជើឡាស់(s));*

**terlihat** /ទើរ(r)លីហាត់/ *v* ដែលអាចមើលឃើញ: *ផលប៉ះពាល់ដែលអាចមើលឃើញនៃឱសថនេះគឺកន្ទួលលើស្បែក efek samping yang terlihat dari pemakaian obat ini adalah ruam kulit (អ៊ែហ្វែត សាំពិង យ៉ាំង ទើរ(r)លីហាត់ ដារី ពើម៉ាកៃយ៉ាន់ អូបាត់ អ៊ីនី អាដាឡះ រូវ៉ាម គូលីត)*

**liku** /លីគូ/ *n* បត់បែន: *ផ្លូវដែលទៅដល់តំបន់នោះគឺបត់បែនច្រើនណាស់ jalan untuk mencapai lokasi itu banyak likunya (ច្យាឡាន់ អ៊ុនទុក មើនចាប៉ៃ ឡូកាស៊ី អ៊ីទូ បាញ៉ាក់ លីគូញ៉ា);*

**berliku-liku** /បឺរ(r)លីគូ-លីគូ/ *v* បត់ចុះបត់ឡើង: *ផ្លូវបត់ចុះបត់ឡើង jalan berliku-liku (ច្យាឡាន់ បឺរ(r)លីគូ-លីគូ)*

**lilin** /លីលិន/ *n* ទៀន:

*ភ្លៀវទេសចរណ៍បានអុជទៀនដើម្បីរំលឹកដល់វិញ្ញាណខ័ន្ធជនរងគ្រោះ pengunjung menyalakan lilin untuk mengenang para korban (ពើងុនជួង មើញ៉ាឡាកាន់ លីលិន អ៊ុនទុក មើងេណាំង ប៉ារ៉ា កូរ(r)បាន់)*

**lilit, lilitan** /លីលីតាន់/ *n* ចំណង:

*ចូរសាក់បន្ធូរខ្សែរចំណងនោះបន្តិច coba longgarkan lilitan tali itu (ចូបា ឡុងហ្គារ(r)កាន់ លីលីតាន់ តាលី អ៊ីទូ);*

**melilitkan** /មើលីលីតកាន់/ *v* រិត; រុំ:

*ពស់រិតចំណីរបស់វាយ៉ាងខ្លាំង ular melilit mangsanya dengan kuat (អ៊ូឡារ មើលីលិត ម៉ាំងសាញ៉ា ឌើង៉ាន់ គូវ៉ាត់);*

**terlilit** /ទើរ(r)លីលីត/ *v* ជាប់; ទាក់:

*ជើងរបស់សត្វនោះជាប់នឹងឬសឈើ kaki binatang itu terlilit akar pohon (កាគី ប៊ីណាតាំង អ៊ីទូ ទើរ(r)លីលីត អាការ(r) ប៉ូហុន)*

**limbah** /លិមបះ/ *n* សំណល់:

*ទន្លេត្រូវបានបំពុលដោយកាកសំណល់ឧស្សាហកម្ម sungai-sungai tercemar oleh limbah industri (ស៊ូងង៉ៃ-ស៊ូងង៉ៃ ទើរ(r)ចឺម៉ារ(r) អូលែះ លីមបះ អ៊ីនឌុស្ទ្រី)*

**lincah** /លិនចះ/ *a* រហ័សរហួន:

*ក្មេងស្រីនោះរហស័រហួនណាស់ anak perempuan itu sangat lincah (អាណាក់ ពើរើមពូវ៉ាន់ អ៊ីទូ សាង៉ាត់ លិនចះ)*

**lindung, berlindung** /ប៊ឺរ(r)លិនឌុង/ *v* ជ្រក:

*ប្រសិនបើមានរញ្ជួយដីកើតឡើងសូមជ្រកនៅក្រោមតុ jika terjadi gempa, berlindunglah di bawah meja (ជីកា ទើរ(r)ចាឌិ ហ្គើមប៉ា ប៊ឺរ(r)លីនឌុងឡះ ឌិ បាវ៉ះ មេចា);*

**melindungi** /លីនឌុង, មើលីនឌូងី/ *v* ការពារ; គាំពារ:

*ឪពុកម្តាយត្រូវតែការពារដល់កូនចៅរបស់ពួកគេ orang tua harus melindungi anaknya (អូរ៉ាំង ទូវ៉ា ហារ៉ូស(s) មើលីនឌូងី អាណាក់ញ៉ា);*

**pelindung** /ពើលិនឌុង/ *n* ការពារ:

*ការពារពីពន្លឺព្រះអាទិត្យ pelindung sinar matahari (ពើលិនឌុង ស៊ីណារ(r) ម៉ាតាហារី);*

**perlindungan** /ពើរ(r)លីនឌូង៉ាន់/ *n* **1** ការការពារ:

*ជនភៀសខ្លួនស្វែងរកការការពារពីរដ្ឋាភិបាលក្នុងតំបន់ para pengungsi mencari perlindungan kepada pemda setempat (ប៉ារ៉ា ពើង៉ុងស៊ី ម៉ើនចារី ពើរ(r)លិនឌូង៉ាន់ គើប៉ាដា ពើមដា សឺតឹមប៉ាត់)*; **2** ការការពារ; ការគាំពារ: *ការការពារកុមារ* perlindungan anak *(ពើរ(r)លីនឌូង៉ាន់ អាណាក់)*

**lingkar** /លិងការ(r)/ *n* រង្វង់: *រង្វង់ផែនដី lingkar bumi (លីងការ(r) ប៊ូមមី)*;

**lingkaran** /លីងកាវ៉ាន់/ *n* រង្វង់: *តោះប្រមូលគ្នានៅក្នុងរង្វង់ ayo berkumpul dalam lingkaran! (អាយ៉ូ បឺរ(r)គុមពុល ដាឡាំ លីងកាវ៉ាន់)*;

**~ setan** /លីងកាវ៉ាន់ សេតាន់/ រង្វង់កាចសាហា: *ប្រទេសកំពុងអភិវឌ្ឍនៅតែប្រឈមនឹងបញ្ហារង្វង់កាចសាហាវនៃភាពក្រីក្រ negara-negara berkembang masih menghadapi isu lingkaran setan kemiskinan (នើហ្គារ៉ា–នើហ្គារ៉ា បឺរ(r)ក៏មបាំង ម៉ាស៊ិះ មើងហាដាពី អ៊ីស៊ូ លិងការ៉ាន់ សេតាន់ គើមីស្គីណាន់)*;

**melingkar** /មើលីងការ( r)/ *v* ព័ទ្ធជុំវិញ: *ខ្សែកមាសព័ទ្ធជុំវិញករបស់គាត់ kalung emas melingkari lehernya (កាលូង អេម៉ាស មើលីងការី លេហេរ(r)ញ៉ា)*

**lingkung, lingkungan** /លីងគូង៉ាន់/ *n* បរិស្ថាន; បរិយាកាស: *វាលំបាកក្នុងការសម្របខ្លួនទៅនិងបរិយាកាសថ្មី ia sulit beradaptasi dengan lingkungan yang baru (អ៊ីយ៉ា ស៊ូលីត បឺរ៉ាដាប់តាស៊ី ឌើង៉ាន់ លីងគូង៉ាន់ យ៉ាំង បារូ)*;

**~ hidup** /លីងគូង៉ាន់ ហ៊ីឌុព/ បរិស្ថានរស់នៅ: *ការរក្សានូវបរិស្ថានរស់នៅ pelestarian lingkungan hidup (ពើលេស្តារីយ៉ាន លីងគូង៉ាន់ ហ៊ីឌុព)*;

**melingkupi** /មើលីងគូពី/ *v* គ្របដណ្ដប់: *ជំនួយដែលបានផ្ដល់ដោយរដ្ឋាភិបាលគ្របដណ្ដប់លើការចំណាយផ្នែកសុខភាពនិងការអប់រំ bantuan yang diserahkan pemerintah melingkupi biaya kesehatan dan pendidikan (បានទូវ៉ាន់ យ៉ាំង ឌិសឺរ៉ះកាន់ ពើមើរិនតះ មើលិងគូពី ប៊ីយ៉ាយ៉ា គើសីហាតាន់ ដាន់ ពើនឌិឌិកាន់)*

**lintas, lintas alam** /លីនតាស់(s) អាឡាម/ *n* ទូទាំងប្រទេស: *ដើម្បីបង្កើតឲ្យមានសាមគ្គីក្រុមថ្នាក់គ្រប់គ្រងនឹងរៀ*

*បច់ព្រឹត្តិការណ៍ទូទាំងប្រទេស untuk membangun solidaritas tim, pihak manajemen akan mengadakan kegiatan lintas alam (អ៊ុនទុក មើមបាងុន សូលីដារីតាស់(ស) ទីម ពីហាក់ ម៉ាណាជើម៉ើន អាកាន់ មើង៉ាដាកាន់ គើហ្គីយ៉ាតាន់ លិនតាស់(ស) អាឡាំ);*

**-- batas** /លិនតាស់(s) បាតាស់(s)/ ឆ្លងដែន: *វប្បធម៌ឆ្លងដែន lintas batas budaya (លិនតាស់(ស) បាតាស់(ស) ប៊ូដាយ៉ា);*

**lintasan** /លីនតាស់(s), លីនតាសាន់/ *n* ផ្លូវ: *ផ្លូវរថភ្លើង lintasan kereta api (លីនតាសាន់ គើរេតា អាពី);*

**melintas** /មើលីនតាស់(s)/ *v* ឆ្លងកាត់: *រថយន្តឆ្លងកាត់នៅលើផ្លូវជាតិ mobil melintas di jalan raya (មូប៊ីល មើលីនតាស់(s) ឌី ចា្យឡាន់ រ៉ាយ៉ា);*

**selintas** /សឺលិនតាស់(s)/ *n* មួយភ្លែត: *មួយភ្លែតគាត់បានឃើញស្រមោលមនុស្សម្នាក់នៅពីក្រោយទ្វា selintas ia melihat bayangan seseorang di balik pintu (សឺលិនតាស់(ស) អ៊ីយ៉ា មើលីហាត់ បាយ៉ាង៉ាន់ សឺសឺអូរ៉ាំង ឌិ បាលិគ ពិនទូ);*

**terlintas** /ទើរ(r)លិនតាស់(s)/ *v* ជិតដាម: *ឧប្បត្តិហេតុនោះបានជិតដាមនៅក្នុងចិត្តរបស់ខ្ញុំ insiden itu kembali terlintas di pikiranku (អ៊ីនស៊ីដិន អ៊ីទូ គើមបាលី ទើរ(r)លិនតាស់(ស) ឌិ ពីគីរ៉ាន់គូ)*

**lipat** /លីប៉ាត់ឡះ/ *v* បត់: *ចូរបត់សម្លៀកបំពាក់របស់អ្នកហើយទុកវានៅក្នុងទូ lipatlah bajumu dan simpan di dalam lemari (លីប៉ាត់ឡះ បាជូមូ ដាន់ ស៊ិមប៉ាន់ ឌិ ដាឡាំ ឡឺម៉ារី);*

**berlipat-lipat** /ប៊ឺរ(r)លីប៉ាត់-លីប៉ាត់/ *v* ពហុគុណ; ច្រើន: *ចំណូលច្រើន pendapatan yang berlipat-lipat (ពើនដាប៉ាតាន់ យ៉ាំង ប៊ឺរ(r)លីប៉ាត់-ប៉ាត់);*

**kelipatan** /គើលីប៉ាតាន់/ *n* ពហុគុណ: *៣៥គឺជាពហុគុណនៃ៧ 35 adalah bilangan kelipatan 7 (ទីហ្គា ពូលុះ លីម៉ា អាដាឡះ ប៊ីឡាង៉ាន់ គើលីប៉ាត់តាន់ ទូជុះ)*

**lipatan** /លីប៉ាតាន់/ *n* ផ្នត់: *ផ្នត់ពោះ lipatan perut (លីប៉ាតាន់ ពើរូត);*

**melipat** /មើលីប៉ាត់/ *v* បត់: *វាបត់សំបុត្រជាមួយនិងអារម្មណ៍ក្តុកក្តួល ia melipat surat itu dengan*

*perasaan haru (លើយ៉ា មើលីប៉ាត់ ស៊្រាត់ អ៊ីទូ ឌើង៉ាន់ ពើរ៉ាសាអាន ហារូ)*

**lipat ganda, berlipat ganda** /ប៊ើរ(r)លីប៉ាត់ ហ្កាន់ដា/ *v* គុណនិងពី; ទ្វេដង: *ការប្រមូលផលទ្វេដង panen yang berlipat ganda (ប៉ាន់ណឹន យ៉ាំង ប៊ើរ(r)លីប៉ាត់ ហ្កានដា)*

**liput, liputan** /លីពូតាន់/ *n* ការរាយការណ៍: *ការរាយការណ៍ប្រព័ន្ធផ្សព្វផ្សាយ liputan media (លីពូតាន់ មេឌីយ៉ា);*

**meliputi** /មើលីពូទី/ *v* រួមមាន; ដូចជា: *របៀបវារៈនៃកិច្ចប្រជុំនៅថ្ងៃនេះរួមមានការពិភាក្សាអំពីផែនការអភិវឌ្ឍន៍អាជីវកម្ម agenda rapat hari ini meliputi pembahasan rencana pengembangan bisnis (អាហ្គេនដា រ៉ាប៉ាត់ ហារី អ៊ីនី មើលីពូទី ពើមបាហាសាន់ រេនចាណា ពើងើមបាង៉ាន់ ប៊ីស្និស(ស))*

**lirik, lirikan** /លីរិកាន់/ *n* ការសម្លឹងមើល: *ការសម្លឹងមើលរបស់បុរសនោះធ្វើឲ្យនាងខ្លាច lirikan laki-laki itu membuatnya takut (លីរីកាន់ ឡាគី-ឡាគី អ៊ីទូ មើមប៊្វាត់ញ៉ា តាគុត);*

**melirik** /មើលីរិក/ *v* សម្លឹងមើល: *ខ្ញុំបានសម្លឹងមើលសារដែលចូលមកទូរស័ព្ទរបស់ខ្ញុំ saya melirik pesan masuk di ponsel saya (សាយ៉ា មើលីរីក ពើសាន់ ម៉ាស៊ុក ឌិ ប៉ុនសែល សាយ៉ា)*

**lisan** /លីសាន់/ *a* ផ្ទាល់មាត់; និយាយ: *ភាសានិយាយ bahasa lisan (បាហាសា លីសាន់)*

**listrik** /លីស្ទ្រិក/ *n* អគ្គិសនី: *គ្រោះមហន្តរាយដោយធម្មជាតិបានធ្វើឲ្យទីក្រុងដាច់ភ្លើងនឹងបណ្ដាញទំនាក់ទំនងគ្មានសល់ bencana alam membuat kota itu lumpuh tanpa listrik dan jaringan komunikasi (ប៊ិនចាណា អាឡាំ មើមប៊្វាត់ កូតា អ៊ីទូ លុមពុះ តាន់ប៉ា លីស្ទ្រីក ដាន់ ច្យារីង៉ាន់ កូមូនីកាស៊ី)*

**lobi** /ឡូប៊ី/ *n* **1** កន្លែងទទួលភ្ញៀវ; បន្ទប់រង់ចាំ: *បន្ទប់រង់ចាំរបស់សណ្ឋាគារ lobi hotel (ឡូប៊ី ហូតែល)*; **2** បញ្ចុះបញ្ចូល: *គាត់ពូកែធ្វើការបញ្ចុះបញ្ចូលគេ dia pandai melakukan lobi (ឌីយ៉ា ប៉ាន់ដៃ មើឡាគូកាន់ ឡូប៊ី)*

**logam** /ឡូហ្កាំ/ *n* ដែក; លោហៈ: *សិប្បកម្មដែក kerajinan logam (គើរ៉ាជីណាន់ ឡូហ្កាំ)*;

**-- mulia** /ឡូហ្កាំ មូលីយ៉ា/ មាស: *ការវិនិយោគមាស investasi logam mulia (អ៊ីនវេស្តាស៊ី ឡូហ្កាំ មូលីយ៉ា)*

**logat** /ឡូហ្កាត់/ *n* ក្រាមភាសា

**loket** /ឡូកិត/ *n* ស្តង់; តុគិតលុយ: *ស្តង់លក់សំបុត្រ loket penjualan karcis (ឡូកិត ពិនជួលឡាន់ ការ(r)ជីស(s))*

**lolos** /ឡូឡូស(s)/ *v* រួចផុត: *រួចផុតពីការស្លាប់ lolos dari maut (ឡូឡូស(ស) ដារី ម៉ាអ៊ុទ);*

**meloloskan** /មើឡូឡូស្កាន់/ *v* ធ្វើឱ្យរួច: *អាជ្ញាធរអន្តោប្រវេសន៍ត្រូវបានគេរិះគន់ចំពោះការធ្វើឱ្យរួចនូវជនសង្ស័យជួញដូរថ្នាំញៀនពីការត្រួតពិនិត្យសន្តិសុខ pihak imigrasi dikecam karena meloloskan seorang terduga pengedar narkotika dari pengecekan keamanan (ពីហាក់ អ៊ីមីហ្គ្រាស៊ី ឌិគើចាំ ការើណា មើឡូឡូសកាន់ សឺអូរ៉ាំង ទើរ(r)ឌូហ្គា ពើងង៉េដារ(r) ណារ(r)កូទីកា ដារី ពើងង៉េចឹកាន់ កែអាម៉ាណាន់);*

**~ diri** /មើឡូឡូស្កាន់ ឌិរី/ រត់គេចខ្លួន: *ឧក្រិដ្ឋជនបានរត់គេចខ្លួនពីការដេញចាប់របស់ប៉ូលីស penjahat itu berhasil meloloskan diri dari kejaran polisi (ពើនចាហាត់ អ៊ីទូ បឺរ(r)ហ៊ុល មើឡូឡូសកាន់ ឌិរី ដារី កេចា្យរ៉ាន់ ប៉ូលីស៊ី)*

**lomba** /ឡុមបា/ *n* ការប្រកួត: *ការប្រកួតរត់ប្រណាំង lomba lari (ឡុមបា ឡារី); ការប្រកួតចំអិនអាហារ lomba masak (ឡុមបា ម៉ាសាក់);*

**berlomba** /បើរ(r)ឡុមបា/ *v* ប្រលងប្រជែង; ប្រណាំងប្រជែង; ប្រកួតប្រជែង: *ពួកគេប្រកួតប្រជែងគ្នាដើម្បីទទួលបានពានរង្វាន់ mereka berlomba untuk mendapatkan piala (មើរេកា បើរ(r)ឡុមបា អ៊ុនទុ ម៉ឺនដាប៉ាត់កាន់ ពីយ៉ាឡា);*

**perlombaan** /ពើរ(r)លុំបាអាន់/ *n* ការប្រលងប្រជែង; ការប្រណាំងប្រជែង; ការប្រកួតប្រជែង: *ការប្រកួតប្រជែងក្នុងការចំអិនអាហារ perlombaan memasak (ពើរ(r)ឡុមបាអាន មើម៉ាសាក់);*

**lompat** /ឡុមប៉ាត់/ *v* លោត: *លោតចម្ងាយ lompat jauh (ឡុមប៉ាត់ ចូវ)*

**longgar** /ឡុងហ្គារ(r)/ *a* រលុង: *អាវយឺតនេះរលុងបន្តិច kaus ini sedikit longgar (កាអ៊ូស អ៊ីនី សឺឌិគីត ឡុងហ្គារ(r))*;

**kelonggaran** /គើឡុងហ្គារ៉ាន់/ *n* ធំ: *អាវយឺតនេះរាងធំបន្តិច kaus ini sedikit kelonggaran (អាអ៊ូស អ៊ីនី សឺឌិគីត គើឡុងហ្គារ៉ាន់)*

**longsor** /ឡុងសួរ(r)/ *v* **1** ច្រោះបាក់; រអិលបាក់: *ភ្លៀងធ្លាក់ខ្លាំងរាប់សប្តាហ៍បានបង្កឲ្យមានការរអិលបាក់ដីទួលនៅពីក្រោយផ្ទះរបស់ខ្ញុំ hujan deras selama berminggu-minggu menyebabkan bukit di belakang rumahku longsor (ហ៊ូចាន់ ដេរ៉ាស សឺឡាម៉ា បឺរ(r)មីងហ្គូ មីងហ្គូ មើញ៉េបាប់កាន់ ប៊ូគីត ឌិ បឺឡាកាំង រូម៉ះគូ ឡុងសរ(r))*; **2** ច្រោះបាក់ដី; រអិលបាក់ដី: *ផ្លូវធំទៅទីក្រុងត្រូវបានបិទរយៈពេលពីរថ្ងៃដោយសារការរអិលបាក់ដី jalan utama menuju kota itu ditutup selama dua hari karena longsor (ចាឡាន់ អ៊ូតាម៉ា មើនូជូ កូតា អ៊ីទូ ឌិទូទុប់ សឺឡាម៉ា ឌូវ៉ា ហារី ការើណា ឡុងសូរ(r))*

**lonjak, lonjakan** /ឡុនចាកាន់/ *n* ការកើនឡើង: *ការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមនៅប៉ុន្មានឆ្នាំចុងក្រោយនេះគឺមានការកើនឡើងគួរឲ្យកត់សម្គាល់ lonjakan angka penggunaan media sosial beberapa tahun terakhir ini sangat signifikan (ឡុនចាកាន់ អាំងកា ពើងហ្គូណាអាន មេឌីយ៉ា សូស៊ីយ៉ាល បឺបឺរ៉ាប៉ា តាហ៊ុន ទើរ(r)អាក់ហឺរ(r)អ៊ីនី សាង៉ាត់ ស៊ីគនីហ្វីកាន់)*;

**melonjak** /មើឡុងចាក់/ *v* កើនឡើង: *នៅមុនថ្ងៃអ៊ីដុលហ្វិតទ្រីមកដល់តម្លៃទំនិញចាំបាច់ប្រចាំថ្ងៃមានការកើនឡើងនៅតំបន់មួយចំនួននៅក្នុងប្រទេសឥណ្ឌូនេស៊ី menjelang hari raya Idul Fitri, harga kebutuhan pokok di beberapa daerah di Indonesia melonjak (មើនជើឡាំង ហារី រ៉ាយ៉ា អ៊ីឌុល ហ្វីទ្រី ហារ(r)ហ្គា គើប៊ូទូហាន់ ប៉ូកុក ឌិ បឺបឺរ៉ាប៉ា ដាអេរ៉ះ ឌិ ឥណ្ឌូនេស៊ីយ៉ា មើឡុនចាក់)*

**lonjong** /ឡុនចុង/ *a* រាងពងក្រពើ; រាងមូលទ្រវែង: *ពងនោះរាងរបស់វាពងក្រពើ*

*telur bentuknya lonjong (តើលូរ(r) ប៊ិនទុកញ៉ា ឡុនចុង)*

**loreng** /ឡូរ៉ែង/ *a*ឆ្នូត: *ឯកសណ្ឋានឆ្នូត seragam loreng (សឺរ៉ាហ្គាំ ឡូរ៉ែង)*

**lorong** /ឡូរ៉ុង/ *n* ច្រក: *ផលិតផលអាហារសរីរាង្គមាននៅច្រកទីប្រាំ produk makanan organik ada di lorong lima (ប្រូឌុគ ម៉ាកាណាន់ អូរ(r)ហ្គានិគ អាដា ឌិ ឡូរ៉ុង លីម៉ា)*

**luang** /លូវ៉ាង/ *a* ទំនេរ: *ពេលទំនេរ waktu luang (វ៉ាក់ទូ លូវ៉ាង)*

**luap, luapan** /លូវ៉ាប៉ាន់/ *n* ពុះ; លើសលប់: *កំហឹងដ៏លើសលប់ luapan kemarahan (លូវ៉ាប៉ាន់ កឹម៉ារ៉ាហាន់);*

**meluap** /មើលូវ៉ាប់/ *v* ជោ; ឡើង: *ទឹកទន្លេឡើងខ្លាំងបានធ្វើឲ្យខូចខាតដល់ស្រែរបស់ប្រជាពលរដ្ឋ air sungai meluap dan merusak persawahan penduduk (អាយើរ(r) ស៊ូង៉ៃ មើលូវ៉ាប់ ដាន់ មើរូសាក់ ពើរ(r)សាវ៉ាហាន់ ពើនឌូឌុគ)*

**luar** /លូអើរ (r)/ *n* ខាងក្រៅ: *កុំនៅតែខាងក្រៅ jangan diam di luar (ចាងាន់ ឌីយៀម ឌី លូអើរ (r));*

**-- biasa** /លូវ៉ារ(r) ប៊ីយ៉ាសា/ **1** ខ្លាំងណាស់: *គាត់ពិតជាឆ្លាតខ្លាំងណាស់ luar biasa cerdasnya (លូវ៉ារ(r) ប៊ីយ៉ាសា ចើរ(r)ដាស់(s)ញ៉ា)*; **2** អស្ចារ្យ: *ឃាតកម្មដ៏សាហាវអស្ចារ្យ kejahatan luar biasa (កើចូាហាតាន់ លូវ៉ារ(r) ប៊ីយ៉ាសា);*

**-- dalam** /លូវ៉ារ(r) ដាឡាំ/ ទាំងក្នុងទាំងក្រៅ: *ខ្ញុំពិតជាស្គាល់នាងច្បាស់ទាំងក្នុងទាំងក្រៅ saya sangat memahami dirinya luar dalam (សាយ៉ា សាង៉ាត់ មើម៉ាហាមី ឌិរីញ៉ា លូវ៉ារ(r) ដាឡាំ);*

**-- negeri** /លូវ៉ារ (r) នើគ្រី/ បរទេស: *ទៅបរទេស pergi ke luar negeri (ពើរ(r)ហ្គី គើ លូវ៉ារ(r) នើគ្រី);*

**-- ruang** /លូវ៉ារ(r) រូវ៉ាំង/ កណ្ដាលវាល; ក្រៅអគារ: *កីឡាលេងនៅកណ្ដាលវាល olahraga luar ruang (អូឡះរ៉ាហ្គា លូវ៉ារ(r) រូវ៉ាំង)*

**luas** /លូវ៉ាស់ (s)/ *a* ធំទូលាយ; ខ្ពង់ខ្ពស់: *ទីធ្លាផ្ទះធំទូលាយ, គាត់មានចំណេះដឹងខ្ពង់ខ្ពស់ halaman rumahnya luas; pengetahuannya luas (ហាឡាម៉ាន់*

*រូម៉ះញ៉ា លូវ៉ាស់ (s); ពើងើតាហូវ៉ាន់ញ៉ា លូវ៉ាស់ (s));*

**memperluas** /មើមពើរ(r)លូវ៉ាស់(s)/ *v* ធ្វើឲ្យធំ: *ធ្វើឲ្យមុខជំនួញកាន់តែធំ memperluas usaha (មើមពើរ(r)លូវ៉ាស់(ស) អ៊ូសាហា);*

**perluasan** /ពើរ(r)លូវាសាន់/ *n* ពង្រីក: *គម្រោងពង្រីកផ្លូវធំនឹងចំណាយទឹកប្រាក់មួយពាន់កោដិរូពីយ: proyek perluasan jalan tol memakan biaya 10 triliun rupiah (ប្រូយេគ ពើរ(r)លូវាសាន់ ច្យាឡាន់ តុល មើម៉ាកាន់ ប៊ីយ៉ាយ៉ា សីពូលុះ ទ្រីលីយ៉ុន រូពីយ៉ះ)*

**lubang** /លូបាំង/ *n* ប្រហោង: *ប្រហោងសោ lubang kunci (លូបាំង គុនជី);*

**berlubang** /ប៊ើរ(r)លូបាំង/ *v* ដែលមានប្រហោង; ធ្លាយ: *កញ្ជើធ្លាយ keranjang itu berlubang (គើរ៉ាន់ច្យាំង អ៊ីទូ ប៊ើរ(r)លូបាំង);*

**melubangi** /មើលូបាងី/ *v* ចុះប្រហោង: *ដើម្បីរក្សាទុកបន្លែកំឲ្យឆាប់រលួយអ្នកត្រូវចុះថង់បន្លែឲ្យមានប្រហោងតូចៗ agar sayuran yang disimpan tidak cepat busuk, Anda harus melubangi sedikit plastik pembungkus sayuran (អាហ្គារ(r) សាយូរ៉ាន់ យ៉ាំង ឌិស៊ីមប៉ាន់ ទីដាក់ ចឺប៉ាត់ ប៊ូស៊ុគ អានដា ហារុស(ស) មើលូបាងី សឺឌិគីត ផ្លាស្ទីគ ពើមប៊ុងគុស(ស) សាយូរ៉ាន់)*

**lubuk** /លូប៊ុគ/ *n* រណ្តៅ: *ត្រីតូចៗរស់នៅក្នុងរណ្តៅនោះ ikan-ikan kecil hidup di dalam lubuk itu (អ៊ីកាន់–អ៊ីកាន់ គើជីល ហ៊ីឌុព ឌិ ដាឡាំ លូប៊ុគ អ៊ីទូ);*

**-- hati** /លូប៊ុគ ហាទី/ ពីបេះដូង: *ភាពស្មោះត្រង់ចេញពីបេះដូង keikhlasan dari lubuk hati (គើអ៊ីខ្លាសាន់ ដារី លូប៊ុគ ហាទី);*

**lucu** /លូជូ/ *a* កំប្លែង: *រឿងកំប្លែង cerita lucu (ជើរីតា លូជូ);*

**melucu** /មើលូជូ/ *v* ធ្វើកំប្លែង: *វាធ្វើកំប្លែងដើម្បីឲ្យភាពតានតឹងនៅក្នុងបន្ទប់នេះបានធូរស្បើយមកវិញ ia melucu untuk mencairkan ketegangan di ruangan itu (អ៊ីយ៉ា មើលូជូ អ៊ុនទុក មើនចាយីរ(r)កាន់ គើទើហ្គាង៉ាន់ ឌិ រូវ៉ាង៉ាន់ អ៊ីទូ)*

**lucut, melucuti (pakaian)** /មើលូជូទី ប៉ាកៃយ៉ាន់/ *v* ដោះ;

**melucuti (senjata)** /មើលូជូទី សឺនច្យាតា/ *v* ដកហូត: *កងទ័ពមានភារកិច្ចដកហូតអាវុធពីពួកឧទ្ទាមនិងរំដោះចំណាប់ខ្មាំង pasukan itu bertugas melucuti senjata pemberontak dan membebaskan para sandera (ប៉ាស៊ូកាន់ អ៊ីទូ ប៊ើ(r)ទូហ្គាស់(ស) មើលូជូទី សិនច្យាតា ពើមបឺរ៉ុនតាក់ ដាន់ មើមបេបាស្កាន់ ប៉ារ៉ា សាន់ឌើរ៉ា)*

**ludah** /លូដះ/ *n* ទឹកមាត់: *ទឹកមាត់ air ludah (អ៉ៃយើរ(r) លូដះ);*

**meludah** /មើលូដាស់/ *v* ខាកស្ដោះ: *ហាមខាកស្ដោះ dilarang meludah (ឌីឡារ៉ាំង មើលូដះ)*

**lugas** /លូហ្គាស់(s)/ *a* ចំៗ: *សុន្ទរកថាចំៗរបស់បេក្ខជនប្រធានាធិបតីបានធ្វើឲ្យទស្សនិកជនមានការកោតសរសើរជាខ្លាំង pidato lugas calon presiden itu sangat diapresiasi oleh para pemirsa (ពីដាតូ លូហ្គាស់ ចាឡុន ប្រេស៊ីដិន អ៊ីទូ សាង៉ាត់ ឌិអាប្រេស៊ីយ៉ាស៊ី អូលេះ ប៉ារ៉ា ពើមីរ(r)សា)*

**lugu** /លូហ្គូ/ *a* ដែលសាមញ្ញ: *យុវជនត្រូវបានគេស្គាល់ថាមានវិធីសស្ត្រក្នុងការគិតដែលសាមញ្ញ remaja dikenal memiliki cara berpikir yang lugu (រឺម៉ាច្យា ឌិគើណាល់ មើមីលីគី ចារ៉ា ប៊ើ(r)ពីគីរ(r) យ៉ាំង លូហ្គូ)*

**luhur** /លូហ៊ួរ(r)/ *a* ដ៏ឧត្ដុងឧត្ដម: *គោលបំណងដ៏ឧត្ដុងឧត្ដម tujuan yang luhur (ទូជួរ៉ាន់ យ៉ាំង លូហ៊ួរ(r))*

**luka** /លូកា/ *n* ដំបៅ: *ដំបៅស្ងួតហើយ lukanya sudah kering (លូកាញ៉ា ស៊ូដះ គើរីង);*

**terluka** /តើរ(r) លូកា/ *v* **1** របួស: *ជើងគាត់របួសដោយសារអំបែងកញ្ចក់ kakinya terluka kena pecahan kaca (កាគីញ៉ា តើរ(r)លូកា គើណា ពើចាហាន់ កាចា)*; **2** ឈឺ: *ខ្ញុំឈឺបេះដូង hatiku terluka (ហាទីគូ តើរ(r) លូកា)*

**lukis, lukisan** /លូគីសាន់/ *n* គំនូរ: *គំនូរអរូបី lukisan abstrak (លូគីសាន់ អាប់ស្ត្រាក់);*

**melukis** /មើលូគិស(s)/ *v* គូសគំនូរ: *ពួកយើងគូសគំនូរទេសភាពធម្មជាតិស្រុកស្រែ*

*kami melukis pemandangan alam pedesaan (កាមី មើលូគីស(ស) ពើម៉ាន់ដាង៉ាន់ អាឡាំ ពើដេសាអាន);*

**pelukis** /ពើលូគិស(s)/ *n* វិចិត្រករ

**luluh** /លូលុះ/ *v* រំលាយ; កម្ទិច:

*បន្ទាប់ពីជជែកគ្នាអស់រយៈពេលយ៉ាងយូរទីបំផុតវាត្រូវបានកម្ទិចផងដែរ setelah berdebat cukup panjang, akhirnya ia luluh juga (សឺទើឡះ បឺរ(r)ឌើបាត់ ជូគុប ប៉ាន់ចាំង អាក់ហឺរ(r)ញ៉ា អ៊ីយ៉ា លូលុះ ជូហ្គា);*

**meluluhkan** /មើលូលុះកាន់/ *v* រំសាយ:

*អ្នកត្រូវតែព្យាយាមឲ្យខ្លាំងដើម្បីរំសាយចិត្តចៅហ្វាយរបស់អ្នក Anda harus berusaha lebih keras untuk meluluhkan hati bos Anda (អានដា ហារុស(ស) ប៊ឺរូសាហា លើប៊ិះ គើរ៉ាស់(ស) អ៊ុនទុក មើលូលុះកាន់ ហាទី បុស(ស) អានដា)*

**lulus** /លូលុស/ *v* ជាប់:

*ឆ្នាំនេះជាង៩០%នៃសិស្សវិទ្យាល័យបានប្រឡងជាប់ថ្នាក់ជាតិ tahun ini, lebih dari 90% murid sekolah menengah atas lulus ujian nasional (តាហ៊ុន អ៊ីនី លើប៊ិះ ដារី សឹមប៊ឺឡាន់ ពូលុះ ពើរ(r)សិន មូរីត សឹកូឡះ*

*មើនើង៉ះ អាតាស់(ស) លូលុស(ស) អ៊ូជីយ៉ាន់ ណាស៊ីយ៉ូណាល);*

**kelulusan** /គើលូលូសាន់/

*n* ការបញ្ចប់ការសិក្សា:

*ស្តង់ដារនៃការបញ្ចប់ការសិក្សា standar kelulusan (ស្តានដារ(r) គើលូលូសាន់);*

**lulusan** /លូលូសាន់/ *n* បញ្ចប់ការសិក្សា:

*និស្សិតបញ្ចប់ការសិក្សាដែលទទួលចំណាត់ថ្នាក់ល្អ lulusan terbaik (លូលូសាន់ ទើរ(r)បាអ៊ីគ);*

**meluluskan** /មើលូលូសកាន់/

*v* បញ្ចប់ការសិក្សា:

*ចាប់តាំងពីឆ្នាំមុនសាលាបានបញ្ចប់ការសិក្សាសិស្សជាង១០០នាក់ sejak tahun lalu, sekolah itu telah meluluskan lebih dari 100 siswa berprestasi (សឺចាក់ តាហ៊ុន ឡាលូ សឹកូឡះ អ៊ីទូ ទើឡះ មើលូលូស្កាន់លើប៊ិះ ដារី សឺរ៉ាទុស(ស) ស៊ីស្វា បឺរ(r)ព្រេស្តាស៊ី)*

**lumas, melumasi** /មើលូម៉ាស៊ី/

*v* ដាក់ប្រេង:

*លោកឪពុកគាត់បានដាក់ប្រេងត្រចៀកទ្វាកំឲ្យច្រេះចាប់ ayah melumasi engsel*

*pintu supaya tidak berkarat (អាយ៉ះ មើលូម៉ាស៊ី ផែងសែល ពិនទូ ស៊ូប៉ាយ៉ា ទីដាក់ បឺរ(r)ការ៉ាត់);*

**pelumas** /ពើលូម៉ាស់(s)/ *n* ប្រេងរំអិល: *ប្រេងរំអិលរថយន្ត pelumas mobil (ពើលូម៉ាស់ មូប៊ីល)*

**lumayan** /លូម៉ាយ៉ាន់/ *a* ល្អគួរសម; គ្រាន់បើ: *សម្រាប់អ្នកទើបនឹងចាប់ផ្តើមការងារការងាររបស់អ្នកគឺល្អគួរសម untuk seorang pemula, pekerjaan Anda lumayan (អ៊ុនទុក សឺអូរ៉ាំង ពើមូឡា ពើគើរ(r)ចា្ចអាន អានដា លូម៉ាយ៉ាន់)*

**lumba-lumba** /លុមបា–លុមបា/ *n* ផ្សោត: *ការសម្តែងផ្សោត pertunjukan lumba-lumba (ពើរ(r)ទុនជូកាន់ លុមបា–លុមបា)*

**lumpuh** /លុមពុះ/ *a* ពិការ: *វាមានអារម្មណ៍ថាដៃរបស់វាពិការបន្ទាប់ពីពស់ខាំរួចមក ia merasa lengan kanannya lumpuh setelah digigit ular (អ៊ីយ៉ា មើរ៉ាសា ឡឹង៉ាន់ កាណាន់ញ៉ា លូមពុះ សឺទើឡះ ឌិហ្គីហ្គិត អ៊ូឡារ(r));*

**melumpuhkan** /មើលុមពុះកាន់/ *v* ធ្វើឲ្យខ្ទេចខ្ទី: *ការវាយប្រហារដោយគ្រាប់បែកបានធ្វើឲ្យកន្លែងសាធារណៈមួយចំនួនត្រូវបានខ្ទេចខ្ទី serangan bom melumpuhkan beberapa fasilitas umum (សឺរ៉ាង៉ាន់ បុម មើលុមពុះកាន់ បឺបឺរ៉ាប៉ា ហ្វាស៊ីលីតាស់(ស) អ៊ូមុម)*

**lumpur** /លុមពួរ(r)/ *n* ភក់: *ភក់ស្ងួត lumpur kering (លុមពួរ(r) គើរិង);*

**berlumpur** /បឺរ(r)លុមពួរ(r)/ *v* ដែលមានភក់: *ផ្លូវដែលមានភក់ jalanan berlumpur (ចាឡាន់ បឺរ(r)លុមពួរ(r))*

**lumrah** /លុមរ៉ះ/ *a* សាមញ្ញ; ធម្មតា: *បរិភោគជាមួយនិងដៃគឺជារឿងធម្មតាសម្រាប់ប្រជាជនឥណ្ឌូនេស៊ី makan menggunakan tangan lumrah bagi masyarakat Indonesia (ម៉ាកាន់ មើងហ្គុណាកាន់ តាង៉ាន់ លុមរ៉ះ បាហ្គី ម៉ាស្យារ៉ាកាត់ ឥណ្ឌូនេស៊ីយ៉ា)*

**lumur, berlumuran** /បឺរ(r)លូមូរ៉ាន់/ *v* សាច: *អាវធំត្រូវភក់សាចត្រូវ jas itu berlumuran lumpur (ចាស់ អ៊ីទូ បឺរ(r)លូមូរ៉ាន់ លុមពួរ(r))*

**lumut** /លូមុត/ *n* ស្លែ: *ស្លែដុះនៅលើជញ្ជាំងដែលសើម lumut tumbuh di dinding yang lembab (លូមុត ទុមប៊ុះ ឌិ ឌិនឌិង យ៉ាំង ឡឹមបាប់);*

**berlumut** /ប៊ឺរ(r)លូមុត/ *v* ដែលមានស្លែ: *ដីដែលមានស្លែ tanah berlumut (តាណះ ប៊ឺរ(r)លូមុត)*

**lunak** /លូណាក់/ *a* ទន់: *ផ្នែកទន់ perangkat lunak (ពើរ៉ាំងកាត់ លូណាក់)*

**lunas** /លូណាស់(s)/ *v* ដែលបានបង់ប្រាក់; សង: *បំណុលរបស់គាត់ត្រូវបានសងរួចរាល់បន្ទាប់ពីគាត់លក់រថយន្តរបស់គាត់ utangnya lunas setelah ia menjual mobilnya (ហ៊ូតាំងញ៉ា លូណាស់ សឺទើឡះ អ៊ីយ៉ា មើនជូវាល់ ម៉ូប៊ីលញ៉ា)*

**luncur, meluncur** /មើលុនជូរ(r)/ *v* អូស; រុញ; ទេរ: *ឡានក្រុងទេរចូលទៅរកជ្រោះ bus itu meluncur ke jurang (ប៊ើស អ៊ីទូ មើលុនជូរ(r) គើ ជូរ៉ាំង);*

**meluncurkan** /មើលលុនជូរ(r)កាន់/ *v* បើកដំណើរការ; ចាប់ផ្តើម; សម្ពោធ: *គាត់បានសម្ពោធសៀវភៅដំបូងរបស់គាត់ជាផ្លូវការ ia resmi meluncurkan buku perdananya (អ៊ីយ៉ា រេស្មី មើលុនជូរ(r)កាន់ ប៊ូគូ ពើរ(r)ដាណាញ៉ា)*

**lunta, terlunta-lunta** /ទើរ(r)លុនតា-លុនតា/ *v* ជាប់គាំង: *ពួកយើងបានយកឆ្មាដែលជាប់គាំងតាមផ្លូវមកចិញ្ចឹម kami memungut kucing yang terlunta-lunta itu dari jalanan (កាមីz មើមូងុត គូជិង ទើរ(r)លុនតា–លុនតា អ៊ីទូ ដារី ចា ឡាណាន់)*

**luntur** /លុនទូរ(r)/ *a* ហើរពណ៌: *ត្រូវប្រយ័ត្នក្រណាត់នេះនឹងហើរពណ៌នៅពេលដែលបោក hati-hati, kain ini akan luntur bila dicuci! (ហាទី–ហាទី កាអ៊ីន អ៊ីនី អាកាន់ លុនទូរ(r) ប៊ីឡា ឌិជូជី)*

**lupa** /លូប៉ា/ *v* ភ្លេច: *សុំទោសខ្ញុំភ្លេចយកឯកសារដែលអ្នកត្រូវការយកមកជាមួយ maaf, saya lupa membawa fail yang Anda minta (ម៉ាអាហ្វ សាយ៉ា លូប៉ា មើមបាវ៉ា ហ្វាអ៊ីល យ៉ាំង អានដា មីនតា);*

-- **daratan** /លូប៉ា ដារ៉ាតាន់/ មមើមមាយ: *គាត់បានមមើមមាយដោយសារតែគាត់មានអារម្មណ៍ថាមានទូនាទីនៅក្នុងការិយាល័យ ia menjadi lupa daratan karena merasa memiliki jabatan di kantor (អ៊ីយ៉ា មើនច្យាឌី លូប៉ា ដារ៉ាតាន់ ការ៉េណា មើរ៉ាសា មើមីលីគី ច្យាបាតាន់ ឌិ កាន់តូរ(r));*

-- **diri** /លូប៉ា ឌីរី/ ភ្លេចខ្លួន:

**melupakan** /មើលូប៉ាកាន់/ *v* បំភ្លេច: *ខ្ញុំត្រូវការពេលវេលាជាច្រើនខែដើម្បីបំភ្លេចហេតុការណ៍ដ៏គួរឱ្យអាម៉ាស់នេះ saya butuh waktu berbulan-bulan untuk melupakan kejadian memalukan itu (សាយ៉ា ប៊ូទុះ វ៉ាក់ទូ ប៊ើរ(r)ប៊ូឡាន់–ប៊ូឡាន់ អ៊ុនទុក មើលូប៉ាកាន់ គើច្យាឌីយ៉ាន មើម៉ាលូកាន់ អ៊ីទូ);*

**pelupa** /ពើលូប៉ា/ *n* ដែលភ្លេចច្រើន: *បើទោះបីជានៅវ័យក្មេងម្ដាយរបស់ខ្ញុំគាត់ភ្លេចច្រើនណាស់ meski masih muda, ibu saya benar-benar pelupa (ម៉េស្គី ម៉ាស៊ិះ មូដា អ៊ីប៊ូ សាយ៉ា ប៊ើណារ(r)-ប៊ើណារ(r) ពើលូប៉ា)*

**lurus** /លូរុស(s)/ *a* ត្រង់: *បន្ទាត់ត្រង់ garis lurus (ការីស(s) លូរុស(s))*

**lusa** /លូសា/ *n* ខានស្អែក: *ខានស្អែកពួកយើងនឹងជួបគ្នាទៀតនៅទីនេះ lusa, kita akan bertemu lagi di sini (លូសា គីតា អាកាន់ ប៊ើរ(r)ទើមូ ឡាហ្គី ឌិ ស៊ីនី)*

**lusin** /លូស៊ីន/ *n* រាប់សិប: *រាប់សិបកែវ selusin cangkir (សើលូស៊ីន ចាំងគៀរ(r))*

**lutut** /លូទុត/ *n* ជង្គង់: *ជង្គង់គាត់របួសដោយសារដួល lututnya luka karena jatuh (លូទុតញ៉ា លូកា ការ៉េណា ច្យាតូះ);*

**berlutut** /ប៊ើរ(r)លូទុត/ *v* លុតជង្គង់

**maaf** /ម៉ាអាហ្វ/ *n* **1** សូមអភ័យទោស: *សូមភ័យទោស កាលពីម្សិលមិញខ្ញុំមិនអាចចូលរួមជប់លៀងអ្នក maaf, saya kemarin tidak dapat datang ke pestamu (ម៉ាអាហ្វ សាយ៉ា កើម៉ារីន ទីដាក់ ដាប៉ាត់ ដាតាំង កើ ពេស្តាមូ)*; **2** ការសុំទោស: *សូមទទួលយកការសុំទោសរបស់ខ្ញុំ terimalah permintaan maafku (តើរីម៉ាឡះ ពើរ(r)មីនតាអាន់ ម៉ាអាហ្វគូ)*;

**memaafkan** /មើម៉ាអាហ្វកាន់/ *v* អភ័យទោស; អត់ទោស; *មិនងាយស្រួលឡើយក្នុងការអភ័យទោសហើយនិងបំភ្លេច tidak pernah mudah untuk memaafkan dan melupakan (ទីដាក់ ពើរ(r)ណះ មូដះ អ៊ុនទុក មើម៉ាអាហ្វកាន់ ដាន់ មើលូប៉ាកាន់)*; *សូមអភ័យទោសឲ្យខ្ញុំសម្រាប់ការដែលមិនបានមកមុន maafkan saya tidak datang lebih awal (ម៉ាអាហ្វកាន់ សាយ៉ា ទីដាក់ ដាតាំង លើបិះ អាវ៉ាល់)*

**mabuk** /ម៉ាប៊ុក/ *a* **1** ពុល: *គាត់ពុលទឹករលក mabuk laut (ម៉ាប៊ុក ឡាអ៊ុត)*; **2** ស្រវឹង: *កុំផឹកច្រើនពេក ប្រយ័ត្នស្រវឹង jangan terlalu banyak minum, nanti mabuk! (ចាងាន់ តើ(r)ឡាលូ បាញ៉ាក់ មីនុម ណាន់ទី ម៉ាប៊ុក)*;

**-- darat** /ម៉ាប៊ុក ដារ៉ាត់/ ពុលឡាន: *គាត់ពុលឡានយ៉ាងខ្លាំង dia mengalami mabuk darat yang parah (ឌីយ៉ា មើង៉ាឡាមី ម៉ាប៊ុក ដារ៉ាត់ យ៉ាំង ប៉ារ៉ះ)*;

**-- laut** /ម៉ាប៊ុក ឡាអ៊ុត/ ពុលសមុទ្រ: *ព្យុះបានធ្វើឲ្យគាត់ពុលសមុទ្រ badai membuat dia mabuk laut (បាដៃ មើមប៊្វ៉ាត ឌីយ៉ា ម៉ាប៊ុក ឡាអ៊ុត)*

**macam** /ម៉ាចាំ/ *n* ប្រភេទ: *ទើការងារប្រភេទអ្វីដែលអ្នកកំពុងតែស្វែងរក? pekerjaaan macam apa yang Anda cari? (ពើគើចាអាន ម៉ាចាំ អាប៉ា យ៉ាំង អានដា ចារី?)*;

**bermacam-macam** /ប៊ឺរ(r)ម៉ាចាំ-ម៉ាចាំ/ *a* ច្រើនប្រភេទ: *មានផ្លែឈើជាច្រើនប្រភេទដែលមានផ្ទុកសារធាតុវីតាមីនស៊ី (C) ada bermacam buah-buahan yang*

*mengandung vitamin C (អាងា បឺរ(r)ម៉ាចាំ ប៊ូវ៉ះ ប៊ូវ៉ាហាន់ យ៉ាំង មើង៉ាន់ឌុង ហ្វីតាមីន ចេ);*

**macam-macam** /ម៉ាចាំ–ម៉ាចាំ/ *adv* ប្រភេទៗ: *ទើអ្នកអាចបង្ហាញខ្ញុំពីប្រភេទៗនៃក្រណាត់ដែលលក់នៅក្នុងហាងនេះទេ? bisa Anda perlihatkan macam-macam kain yang dijual di toko ini? (ប៊ីសា អាន់ដា ពើរ(r)លីហាត់កាន់ ម៉ាចាំ–ម៉ាចាំ កាអ៊ីន យ៉ាំង ឌិជូវ៉ាល់ ឌិ តូកូ អ៊ីនី);*

**semacam** /សឺម៉ាចាំ/ *a* ដូចជា: *មានអារម្មណ៍ដូចជាចម្លែកដែលជួបនឹងគាត់ទៀត rasanya aneh berjumpa lagi dengannya (រ៉ាសាញ៉ា អាណេះ បឺរ(r)ជុមប៉ា ឡាហ្គី ឌើង៉ាន់ញ៉ា)*

**macet** /ម៉ាចិត/ *a* ស្ទះ: ចរាចរណ៍នៅទីក្រុងហ្សាកាតាឧស្សាហ៍ស្ទះ *lalu lintas di Jakarta sering kali macet (ឡាលូ លីនតាស់(s) ឌី ច្យាការ(r)តា សើរីង កាលី ម៉ាចិត)*

**madu** /ម៉ាឌូ/ *n* ទឹកឃ្មុំ: *នាងចូលចិត្តដាក់ទឹកឃ្មុំចូលក្នុងតែរបស់នាង ia menyukai madu di dalam tehnya (អ៊ីយ៉ា មើញូកៃ ម៉ាឌូ ឌិ ដាឡាំ តេះញ៉ា)*

**magnet** /ម៉ាកណេត/ *n* មេដែក; ប្រភពទាក់ទាញ: *អ្នករាំម្នាក់នេះគឺជាប្រភពដែលទាក់ទាញចំណាប់អារម្មណ៍របស់ទស្សនិកជន penari itu menjadi magnet yang menarik perhatian penonton (ពើណារី អ៊ីទូ មើនច្យាឌិ ម៉ាកណែ យ៉ាំង មើណារីគ ពើរ(r)ហាតីយ៉ាន ពើណុនតុន)*

**mahal** /ម៉ាហាល់/ *a* ថ្លៃ: *តម្លៃនាឡិកានេះថ្លៃណាស់ harga jam ini sangat mahal (ហារ(r)ហ្គា ច្យាំ អ៊ីនី សាងាត់ ម៉ាហាល់)*

**mahasiswa** /ម៉ាហាស៊ីស្វា/ *n* និស្សិត: *កូនស្រីរបស់គាត់គឺជានិស្សិតដែលឆ្លាត putranya adalah mahasiswa yang pintar (ពូត្រាញ៉ា អាដាឡះ ម៉ាហាស៊ីស្វា យ៉ាំង ពិនតារ(r))*

**mahir** /ម៉ាហ៊ីរ(r)/ *a* ដែលមានជំនាញ: *អ្នកបច្ចេកទេសដែលមានជំនាញ teknisi yang mahir (តិគនីស៊ី យ៉ាំង ម៉ាហ៊ីរ(r))*

**mahkota** /ម៉ះកូតា/ *n* មកុដ: *អ្នកឈ្នះការប្រកួតបវរកញ្ញាបានពាក់មកុដដែលចាំ*

*ងផ្តេកៗ pemenang kontes kecantikan mengenakan mahkota yang berkilau (ពើមើណាំង កុនតែស(ស) គើចាន់ទីកាន់ មើងើណាកាន់ ម៉ះកូតា យ៉ាំង បឺរ(r)គីឡៅ)*

**main, bermain** /ពើរ(r) ម៉ែន/ *v* លេង:

*ក្មេងៗលេងបាល់ទាត់ដោយរីករាយ anak-anak bermain sepak bola dengan gembira (អាណាក់ អាណាក់ បើរ(r) ម៉ែន សើប៉ាក់ បូឡា ឌើង៉ាន់ ហ្គើមប៊ីរ៉ា);*

**mainan** /ម៉ាអ៊ីណាន់/ *n* ប្រដាប់ក្មេងលេង:

*ក្មេងប្រុសនេះបានរក្សាប្រដាប់ក្មេងលេងរបស់គាត់នៅក្នុងប្រអប់ដ៏ធំ anak itu meyimpan mainan-mainannya di dalam kotak besar (អាណាក់ អ៊ីទូ មើញិមប៉ាន់ ម៉ាអ៊ីណាន់–ម៉ាអ៊ីណាន់ញ៉ា ឌិ ដាឡាំ កូតាក់ បែសារ(r));*

**main-main** /ម៉ាអ៊ីន–ម៉ាអ៊ីន/ *v* លេងៗ:

*កុំខ្វល់ការនិយាយរបស់គាត់ៗគ្រាន់តែនិយាយលេងទេ jangan pedulikan ucapannya, dia hanya main-main (ចាង៉ាន់ ពើឌូលីកាន់ អ៊ូចាប៉ាន់ញ៉ា ឌីយ៉ា ហាញ៉ា ម៉ាអ៊ីន– ម៉ាអ៊ីន);*

**mempermainkan** /មើមពើរ(r)ម៉ាអ៊ីនកាន់/ *v* លេងសើច; បោកប្រាស់:

*មិនល្អឡើយលេងសើចចំពោះនរណាម្នាក់ដែលគេកំពុងតែមានបញ្ហា tidak baik mempermainkan seseorang yang sedang dalam kesulitan (ទីដាក់ បាអ៊ិត មើមពើរ(r)ម៉ាអ៊ីនកាន់ សឺសឺអូរ៉ាំង យ៉ាំង សឺដាំង ដាឡាំ គើស៊ូលីតាន់);*

**pemain** /ពើម៉ាអ៊ីន/ *n* កីឡាករ:

*បងប្រុសរបស់ខ្ញុំគឺជាកីឡាករបាល់បោះម្នាក់ kakakku adalah seorang pemain basket (កាកាក់គូ អាដាឡះ សឺអូរ៉ាំង ពើម៉ាអ៊ីន បាស្កិត);*

**permainan** /ពើរ(r)ម៉ាអ៊ីណាន់/ *n* ល្បែង; កីឡា; ហ្គេម:

*ពួកយើងចូលចិត្តលេងហ្គេមម៉ោនូប៉ូលីណាស់ kami senang sekali permainan monopoli (កាមី សឺណាំង សឺកាលី ពើរ(r)ម៉ាអ៊ីណាន់ ម៉ូណូប៉ូលី)*

**majalah** /ម៉ាចាឡាះ/ *n* ទស្សនាវដ្តី:

*ខ្ញុំបានសរសេរអត្ថបទទស្សនាវដ្តីមួយចំនួនសម្រាប់ស្ត្រី saya telah menulis beberapa artikel untuk*

*majalah wanita (សាយ៉ា ទើឡុះ មើនូលិស(ស) ប៊ីប៊ីរ៉ាប៉ា អារ(r)ទីគើល អ៊ុនទុក ម៉ាចា្យឡះ);*

**-- dinding** /ម៉ាចា្យឡះ ឌិនឌិង/ ព្រឹត្តិបត្រព័ត៌មាន: *ព្រឹត្តិបត្រព័ត៌មានសាលា majalah dinding sekolah (ម៉ាចា្យឡះ ឌិនឌិង សឺកូឡះ);*

**-- ilmiah** /ម៉ាចា្យឡះ អ៊ីលមីយ៉ះ/ ទស្សនាវដ្ដីវិទ្យាសាស្ត្រ: *ទើនៅកន្លែងណាដែលខ្ញុំអាចរកបាននូវទស្សនាវដ្ដីវិទ្យាសាស្ត្រ? dimana saya bisa mendapatkan majalah ilmiah? (ឌិម៉ាណា សាយ៉ា ប៊ីសា មើនដាប៉ាត់កាន់ ម៉ាចា្យឡះ អ៊ីលមីយ៉ះ?)*

**majemuk** /ម៉ាជើមុគ/ *a* លាយគ្នា

**majikan** /ម៉ាជីកាន់/ *n* ថៅកែ: *ថៅកែរបស់ខ្ញុំមានអតចរិក្សសរាយរាក់ទាក់ណាស់ majikanku mempunyai sifat yang sangat ramah (ម៉ាជីកាន់គូ មើមពូញ៉ៃ ស៊ីហ្វាត់ យ៉ាំង សាង៉ាត់ រ៉ាម៉ះ)*

**maju** /ម៉ាជូ/ **1** *v* ឆ្ពោះទៅមុខ: *គាត់ឆ្ពោះទៅមុខថ្នាក់ dia maju ke depan kelas (ឌីយ៉ា ម៉ាជូ គឺ ឌើប៉ាន់ គើឡាស់ (s));* **2** *v* ទៅមុខ: *ទៅមុខមួយជំហ៊ាន maju satu langkah (ម៉ាជូ សាទូ ឡាំងកះ);* **3** *a* អភិវឌ្ឍន៍: *ប្រទេសអភិវឌ្ឍន៍ negara maju (នើហ្គារ៉ា ម៉ាជូ)*

**maju, kemajuan** /គើម៉ាជូវ៉ាន/ *n* **1** ការរីកចម្រើន: *ការរីកចម្រើននៃបច្ចេកវិទ្យាកំពុងមានការអភិវឌ្ឍយ៉ាងឆាប់រហ័សប៉ុន្មានឆ្នាំកន្លងមក kemajuan teknologi berkembang sangat pesat beberapa tahun terakhir (គើម៉ាជូវ៉ាន់ តិគណូឡូហ្គី ប៊ើរ(r)គើមបាំង សាង៉ាត់ ពើសាត់ប៊ីប៊ីរ៉ាប៉ា តាហ៊ុន ទើរ(r)អាក់ហ៊ីរ(r));* **2** ការអភិវឌ្ឍ: *ការអភិវឌ្ឍលឿន kemajuan pesat (គើម៉ាជូវ៉ាន់ ពើសាត់);*

**memajukan** /មើម៉ាជូកាន់/ *v* ធ្វើឲ្យរីកចម្រើន: *ការសាងសង់សាលារៀនដោយឥតគិតថ្លៃនឹងធ្វើឲ្យរីកចម្រើនដល់ការអប់រំនៅឥណ្ឌូនេស៊ី pembangunan sekolah-sekolah gratis dapat memajukan pendidikan di Indonesia (ពើមបាងូណាន់ សឺកូឡះ*

*សឹកូឡះ ហ្ការិស(ស) ដាប៉ាត់ មើម៉ាជូកាន់ ពើនឌិឌិកាន់ ឌិ ឥណ្ឌូនេស៊ីយ៉ា)*

**maka** /ម៉ាកា/ *p* ដូច្នេះ; ហេតុនេះហើយ: *ខ្ញុំមិនអាចវាយកំព្យូទ័របានល្អហេតុដូចនេះហើយលិខិតអញ្ជើញនេះខ្ញុំសរសេរវាដោយដៃ saya tidak dapat mengetik dengan baik, maka surat undangan itu saya tulis saja (សាយ៉ា ទីដាក់ ដាប៉ាត់ មើងើទិក ឌើង៉ាន់ បាអ៊ីត ម៉ាកា ស៊ូរ៉ាត់ អ៊ុនដាង៉ាន់ អ៊ីទូ សាយ៉ា ទូលិស(ស) សាច្បា)*

**makalah** /ម៉ាកាឡះ/ *n* ក្រដាស់; សន្លឹក: *វានឹងបង្ហាញក្រដាសកិច្ចការវានៅថ្ងៃស្អែក ia akan menampilkan makalahnya besok (អ៊ីយ៉ា អាកាន់ មើណាំពីលកាន់ ម៉ាកាឡះញ៉ា បេសុក);*

**pemakalah** /ពើម៉ាកាឡះ/ *n វាយគ្មិន: វាយគ្មិនសំខាន់ pemakalah utama (ពើម៉ាកាឡះ អ៊ូតាម៉ា)*

**makam** /ម៉ាកាំ/ *n* ផ្នូរ; ទីបញ្ចុះសព: *នៅលើទួលនោះមានផ្នូរនៃក្រុមគ្រួសាររបស់យើង di bukit itu terletak makam keluarga kami (ឌិ ប៊ូគិត អ៊ីទូ ទើរ(r)លើតាក់ ម៉ាកាំ គើលូវ៉ារ(r)ហ្គា កាមី);*

**memakamkan** /មើម៉ាកាំកាន់/ *v* កប់; បូជា; បញ្ចុះសព: *ខ្ញុំមានទុក្ខសោកយ៉ាងខ្លាំងនៅពេលដែលពួកគេចាប់ផ្តើមបញ្ចុះសពជីដូនរបស់ខ្ញុំ saya sangat berduka saat mereka mulai memakamkan nenek (សាយ៉ា សាង៉ាត់ បឺរ(r)ឌូកា សាអាត់ មើរេកា មូឡៃ មើម៉ាកាំកាន់ នែណេក);*

**pemakaman** /ពើម៉ាកាម៉ាន់/ *n* ការបូជា; ការបញ្ចុះសព: *អ្នកភូមិបានទៅចូលរួមក្នុងពិធីបញ្ចុះសពរបស់មេដឹកនាំសាសនា warga mendatangi acara pemakaman tokoh agama itu (វ៉ារ(r)ហ្គា មើនដាតាងី អាចារ៉ា ពើម៉ាកាម៉ាន់ តូកុះ អាហ្កាម៉ា អ៊ីទូ)*

**makan** /ម៉ាកាន់/ *v* ញ៉ាំ: *ខ្ញុំចូលចិត្តញ៉ាំបាយឆា; ញ៉ាំអាហារពេលយប់; ញ៉ាំអាហារពេលថ្ងៃ; ញ៉ាំអាហារពេលព្រឹក saya suka makan nasi goreng; (សាយ៉ា ស៊ូកា ម៉ាកាន់ ណាស៊ី ហ្គូរ៉េង); ញ៉ាំអាហារពេលយប់ makan malam (ម៉ាកាន់ ម៉ាឡាំ); ញ៉ាំអាហារថ្ងៃត្រង់ makan siang (ម៉ាកាន់ ស៊ីយ៉ាង); ញ៉ាំអាហារពេលព្រឹក makan pagi (ម៉ាកាន់ ប៉ាហ្គី)*

**-- angin** /ម៉ាកាន់ អាង៊ីន/

ស្រូបយកខ្យល់បរិសុទ្ធ:

*ខ្ញុំចេញក្រៅបន្តិចដើម្បីស្រូបយកខ្យល់បរិសុទ្ធ saya akan keluar sebentar untuk makan angin (សាយ៉ា អាកាន់ គើលូវ៉ារ(r) សឺបិនតារ(r) អ៊ុនទុក ម៉ាកាន់ អាង៊ិន);*

**-- asam garam** /ម៉ាកាន់ អាសាំ ហ្គារ៉ាម/ ដែល់មានពិសោធន៍:

*ឪពុករបស់ខ្ញុំគឺជាអ្នកជនដែលមានបទពិសោធន៍ច្រើន ayah saya seorang perantau yang banyak makan asam garam (អាយ៉ះ សាយ៉ា ស៊ឺអូរ៉ាំង ពើរ៉ាន់តៅ យ៉ាំង បាញ៉ាក់ ម៉ាកាន់ អាសាំ ហ្គារ៉ាម);*

**-- besar** /ម៉ាកាន់ បែសារ(r)/

ញ៉ាំអាហារជុំគ្នា:

*ក្រុមគ្រួសាររបស់ខ្ញុំបានគ្រោងទុកកម្មវិធីញ៉ាំអាហារជុំគ្នានៅឯផ្ទះយប់នេះ keluarga saya merencanakan acara makan besar di rumah malam ini (គើលូវ៉ារ(r)ហ្គា សាយ៉ា មើរេនចាណាកាន់ អាចារ៉ា ម៉ាកាន់ បែសារ(r)ឌិ រូម៉ះ ម៉ាឡាំ អ៊ីនី);*

**makanan** /ម៉ាកាណាន់/ *n* **1** ម្ហូបអាហារ:

*ម្ហូបអាហាររហ័ស makanan cepat saji (ម៉ាកាណាន់ ចើប៉ាត់ សាជ្សី);*

**2** អាហារ: *អាហារដែលញ៉ាំភ្លាមៗ makanan cepat saji (ម៉ាកាណាន់ ចឹប៉ាត់ សាជី);*

**~ cepat saji** /ម៉ាកាណាន់ ចឹប៉ាត់ សាជី/ អាហារដែលញ៉ាំភ្លាមៗ:

*ល្អគួរជៀសវាងការបរិភោគអាហារញ៉ាំភ្លាមៗ ព្រោះវាមិនល្អសម្រាប់សុខភាពរបស់អ្នកឡើយ sebaiknya hindari mengonsumsi makanan cepat saji karena tidak bagus bagi kesehatan Anda (សឺបាអ៊ីគញ៉ា ហ៊ីនដារី មើង៉ុនស៊ុមស៊ី ម៉ាកាណាន់ ជើប៉ាត់ សាជី ការើណា ទីដាក់ បាហ្គុស(ស) បាហ្គី គើសឺហាតាន់ អានដា);*

**~ empuk** /ម៉ាកាណាន់ អើមពូគ គឺយ៉ាសាន់/ ជាមុខសញ្ញា:

*សម្តីដ៏ចម្រូងចម្រាសរបស់លោកអភិបាលក្រុងបានក្លាយជាទៅមុខសញ្ញារបស់ប្រព័ន្ធផ្សព្វផ្សាយដើម្បីធ្វើឱ្យរង្គូសរង្គើតំណែងរបស់គាត់ pernyataan kontroversial wali kota itu menjadi makanan empuk media massa untuk menggoyang kedudukannya (ពើរ(r)ញ៉ាតាអាន កុនត្រូហ្វែរ(r)ស៊ីយ៉ាល វ៉ាលីកុតា អ៊ីទូ មើនចាឌិ ម៉ាកាណាន់ អើមពុគ មេឌីយ៉ា ម៉ាស់សា អ៊ុនទុក មើងហ្គូយ៉ាំង គើឌូឌូកាន់ញ៉ា);*

**memakan** /មើម៉ាកាន់/ *v* ញុំា; បរិភោគ; ស៊ី: *ខ្ញុំចង់ញុំាបាយឆា saya ingin makan nasi goreng (សាយ៉ា អ៊ីងីន ម៉ាកាន់ ណាស៊ី ហ្គូរ៉េង)*

**makhluk** /ម៉ាក់លុគ/ *n* សត្វលោក: *មនុស្សគឺជាសត្វលោកដែលអាចគិតជាលក្ខណៈតក្ក manusia adalah makhluk yang mampu berpikir secara logis (ម៉ានូស៊ីយ៉ា អាដាឡះ ម៉ាក់ឃ្លុគ យ៉ាំង ម៉ាំពូ បឺរ(r)ពីគីរ(r) សឺចារ៉ា ឡូហ្គិស(ស))*

**maki** /ម៉ាគី/ *v* ជេប្រមាថ; ស្តីបន្ទោស: *ចូរកុំជេប្រមាថកូននៅទីសាធារណៈ jangan maki anakmu di depan umum! (ចា្យង៉ាន់ ម៉ាគី អាណាក់មូ ឌិ ឌើប៉ាន់ អ៊ូមុម);*

**makian** /ម៉ាគីយ៉ាន់/ *n* ការជេប្រមាថ; ការស្តីបន្ទោស;

**memaki** /មើម៉ាគី/ *v* ជេប្រមាថ; ស្តីបន្ទោស: *បុរសម្នាក់នោះបានស្តីបន្ទោសដល់ភាពចង្រៃនៅថ្ងៃនេះ lelaki itu memaki kesialannya hari ini (ឡឺឡាគី អ៊ីទូ មើម៉ាគី គើស៊ីយ៉ាឡាន់ញ៉ា ហារី អ៊ីនី);*

**memaki-maki** /មើម៉ាគី-ម៉ាគី/ *v* ជេប្រមាថ; ស្តីបន្ទោស: *អ្នកសុំទានបានជេប្រមាថម្ចាស់ផ្ទះដែលមិនបានផ្តល់ប្រាក់ដល់គេ seorang pengemis memaki pemilik rumah yang tidak mau memberinya uang (សឺអូរ៉ាំង ពើង៉េមិស(ស) មើម៉ាគី ពើមីលីគ រូម៉ះ យ៉ាំង ទីដាក់ ម៉ាវ មើមបឺរីញ៉ា អ៊ូរ៉ាំង)*

**makin** /ម៉ាគិន/ *adv* កាន់តែ: *អ្នកមើលទៅកាន់តែស្រស់ស្អាត Anda terlihat makin cantik (អានដា ទើរ(r)លីហាត់ ម៉ាគីន ចាន់ទីគ);*

**semakin** /សឺម៉ាគិន/ *adv* កាន់តែ: *ក្មេងនោះយំកាន់តែខ្លាំង anak itu menangis semakin keras (អាណាក់ អ៊ីទូ មើណាងិស(ស) សឺម៉ាគិន គើរ៉ាស់(ស))*

**maklum** /ម៉ាក់លុម/ *v* យល់: *សូមយល់ផងចុះនេះគឺជាថ្ងៃដំបូងរបស់ខ្ញុំ mohon maklum, ini hari pertamaku (មូហុន ម៉ាក់លុម អ៊ីនី ហារី ពើរ(r)តាម៉ាគូ);*

**memaklumi** /មើម៉ាក់លូមី/ *v* យល់: *មិនមានអ្វីដែលត្រូវសោកស្តាយនោះឡើយខ្ញុំយល់ពីឧប្បត្តិហេតុនេះ*

*tidak ada yang perlu disesalkan, saya memaklumi kejadian itu (ទីដាក់ អាដា យ៉ាំង ពើរ(r)លូ ឌិសឺសាល់កាន់ សាយ៉ា មើម៉ាក់លូមី គើចា្យឌីយ៉ាន អ៊ីទូ)*

**makmur** /ម៉ាក់មួរ(r)/ *a* ចម្រុងចម្រើន: *ប្រទេសដែលចម្រុងចម្រើន negara makmur (នើហ្គារ៉ា ម៉ាក់មួរ(r))*

**makna** /ម៉ាក់ណា/ *n* អត្ថន័យ: *អត្ថន័យពីរ makna ganda (ម៉ាក់ណា ហ្គាន់ដា);*

**bermakna** /បឺរ(r)ម៉ាក់ណា/ *v មានអត្ថន័យ: អ្នកសុខចិត្តមកចូលរួមវាពិតជាមានអត្ថន័យខ្លាំងណាស់សម្រាប់ពួកយើង kesediaan Anda untuk hadir sangat bermakna bagi kami (គើសឺឌីយ៉ាអាន អានដា អ៊ុនទុក ហាឌីរ(r) សាង៉ាត់ បឺរ(r)ម៉ាក់ណា បាហ្គី កាមី)*

**maksud** /ម៉ាកស៊ូត/ *n* **1** គោលបំណង: *គោលបំណងនៃឃ្លារបស់គាត់ គឺច្បាស់លាស់ហើយ maksud kalimatnya sudah jelas (ម៉ាក់ស៊ូត កាលីម៉ាត់ញ៉ា ស៊ូដះ ចឿឡាស់ (s));* **2** ន័យ: *តើអ្នកចង់បានន័យថាម៉េច? apa maksudmu? (អាប៉ា ម៉ាក់ស៊ូតមូ?);*

**bermaksud** /បឺរ (r) ម៉ាក់ស៊ូត/ *v* ចេតនា: *ខ្ញុំមានចេតនាចង់ជួយគាត់ saya bermaksud menolongnya (សាយ៉ា បឺរ (r) ម៉ាក់ស៊ូត មើណូឡុងញ៉ា)*

**malah** /ម៉ាឡះ/ *adv* បែរជា: *គាត់បែរជាចាក់ចេញជៀសជាងនិយាយពីបញ្ហានោះ ia malah pergi daripada membicarakan masalah itu (អ៊ីយ៉ា ម៉ាឡះ ពើរ(r)ហ្គី ដារីប៉ាដា មើមប៊ីចារ៉ាកាន់ ម៉ាសាឡះ អ៊ីទូ);*

**malahan** /ម៉ាឡាហាន់/ *p* ថែមទាំង: *ឆ្កែរបស់ខ្ញុំចេះល្បិចច្រើនហើយវាថែមទាំងអាចប្រើឱ្យធ្វើចលនាកាយសម្ព័ន្ធទៀត anjing saya tahu banyak trik, malahan ia bisa diperintah untuk melakukan gerakan akrobatik (អាន់ជិង សាយ៉ា តាអ៊ូ បាញ៉ាក់ ទ្រិត ម៉ាឡាហាន់ អ៊ីយ៉ា ប៊ីសា ឌិពើរីនតះ អ៊ុនទុក មើឡាគូកាន់ ហ្គើរ៉ាកាន់ អាក្រូបាទីត)*

**malam** /ម៉ាឡាំ/ *n* យប់: *ព្រះច័ន្ទភ្លឺច្បាស់នៅពេលយប់ pada malam hari bulan bersinar terang (ប៉ាដា ម៉ាឡាំ ហារី ប៊ូឡាន ពើរ (r) ស៊ីណើរ (r) ទើរ៉ាំង);*

**bermalam** /ប៊ឺរ(r)ម៉ាឡាំ/ *v* សម្រាក; គេង; ស្នាក់នៅ:

*ដោយសារតែអាកាសធាតុមិនល្អទីបំផុតពួកយើងគេងនៅផ្ទះរបស់អ្នកស្រុក karena cuaca buruk, kami akhirnya bermalam di rumah seorang penduduk (ការ៉េណា ជូវ៉ាចា ប៊ូរុគ កាមី អាកហ៊ីរ(r)ញ៉ា ប៊ឺរ(r)ម៉ាឡាំ ឌិ រូម៉ះ សឺអូរ៉ាំង ពើនឌូឌុគ);*

**kemalaman** /គើម៉ាឡាម៉ាន់/ *a* ដែលងងឹត:

*ខ្ញុំត្រូវទៅឥឡូវនេះបើមិនដូច្នេះទេខ្ញុំនឹងត្រឡប់ទៅវិញយប់ហើយ saya harus pergi sekarang, jika tidak saya akan kemalaman pulang (សាយ៉ា ហារុស(ស) ពើរ(r)ហ្គី សឺការ៉ាំង ជីកា ទីដាក់ សាយ៉ា អាកាន់ គើម៉ាឡាម៉ាន់ ពូឡាំង);*

**malam-malam** /ម៉ាឡាំ–ម៉ាឡាំ/ *n* នៅពេលយប់:

*នៅពេលយប់បុរសម្នាក់នោះលបចូលទៅក្នុងអគារ malam-malam, orang itu menyelinap ke dalam gedung itu (ម៉ាឡាំ–ម៉ាឡាំ អូរ៉ាំង អ៊ីទូ មើញើលីណាប់ គើ ដាឡាំ ហ្គឺឌុង អ៊ីទូ);*

**semalaman** /សឺម៉ាឡាម៉ាន់/ *n* មួយយប់ពេញ:

*ខ្ញុំត្រូវធ្វើឯកសារសម្រាប់ធ្វើបទបង្ហាញនេះពេញមួយយប់ saya harus mengerjakan bahan presentasi ini semalaman (សាយ៉ា ហារុស(ស) មើងើរ(r)ចាកាន់ បាហាន់ ព្រេសិន–តាស៊ី អ៊ីនី សឺម៉ាឡាម៉ាន់);*

**malang** /ម៉ាឡាំង/ *a* ដែលអភ័ព; ដែលក្រីក្រ:

*ស្ត្រីអភ័ពម្នាក់នោះកាន់ទុក្ខការស្លាប់របស់ប្តីនាង wanita malang itu meratapi kematian suaminya (វ៉ានីតា ម៉ាឡាំង អ៊ីទូ មើរ៉ាតាពី គើម៉ាទីយ៉ាន់ ស៊ូវ៉ាមីញ៉ា);*

**-- melintang** /ម៉ាឡាំង មើលីនតាំង/ រសាត់អណ្តែត:

*ខ្ញុំបានរសាត់អណ្តែតអស់រយៈពេល២០ឆ្នាំនៅក្នុងប្រទេសនេះ saya sudah malang melintang selama 20 tahun di negara ini (សាយ៉ា ស៊ូដះ ម៉ាឡាំង មើលីនតាំង សឺឡាម៉ា ឌូវ៉ាពូលុះ តាហ៊ុន ឌិ នើហ្គារ៉ា អ៊ីនី);*

**kemalangan** /គើម៉ាឡាង៉ាន់/ *n* អភ័ព; ក្រីក្រ; ចង្រៃ:

*វាត្រូវបានគ្រួសារមិនអើពើដោយសារតែពួកគេគិតថាជាអ្នកនាំចង្រៃដល់គ្រួសារ ia diabaikan oleh keluarganya karena dianggap membawa kemalangan bagi mereka (យ៉ា*

*ខិអាបាអ៊ីកាន់ អូលេះ គើលូវ៉ារ(r)ហ្កាញ៉ា កាឃើណា ខិអាងហ្កាប់ មើមបាវ៉ា គើម៉ាឡាង៉ាន់ បាហ្គី មើឃកា)*

**malapetaka** /ម៉ាឡា ពើតាកា/ *n* មហន្តរាយ: *គ្រោះមហន្តរាយនោះបានកើតឡើងនៅពេលដែលព្យុះបានបំផ្លាញផ្ទះរបស់គាត់ malapetaka itu datang ketika badai menghancurkan rumahnya (ម៉ាឡា ពើតាកា អ៊ីទូ ដាតាំង គើទីកា បាដៃ មើងហាន់ជូរ(r)កាន់ រូម៉ះញ៉ា)*

**malas** /ម៉ាឡាស់ (s)/ *a* ខ្ជិល: *បើសិនជាចង់ឆ្លាត សូមកុំខ្ជិល jika ingin pandai, jangan malas belajar (ជីកា អ៊ីងីន ប៉ាន់ដៃ, ចាង៉ាន់ ម៉ាឡាស់(s) ប៊ើឡាចារ(r));*

**bermalas-malas(an)** /ប៊ើរ(r)ម៉ាឡាស់(s)- ម៉ាឡាសាន់/ *v* សម្រាកលេង: *ចុងសប្តាហ៍នេះយើងនឹងសម្រាកលេងនៅផ្ទះតែប៉ុណ្ណោះ akhir pekan ini kami hanya akan bermalas-malasan di rumah (អាក់ហ៊ីរ(r) ពើកាន់ អ៊ីនី កាមី ហាញ៉ា អាកាន់ ប៊ើរ(r)ម៉ាឡាស់(ស) -ម៉ាឡាសាន់ ឌិ រូម៉ះ);*

**pemalas** /ពើម៉ាឡាស់/ *n* មនុស្សខ្ជិល: *យ៉ាប់ណាស់មនុស្សខ្ជិលការងាររបស់នាក់គឺដេកតែមួយមុខតែប៉ុណ្ណោះ dasar pemalas, kerjamu hanya tidur saja! (ដាសារ(r) ពើម៉ាឡាស់(ស) គើរ(r)ចាមូ ហាញ៉ា ទីឌូរ(r) សាចា)*

**maling** /ម៉ាលីង/ *n* ចោរ: *ចោរនោះចូលតាមបង្អួច maling itu masuk lewat jendela (ម៉ាលីង អ៊ីទូ ម៉ាសូក ឡេវ៉ាត់ ជិនដេឡា)*

**malu** /ម៉ាលូ/ *a* ខ្មាសអៀន: *កុំខ្មាសអៀនអី jangan malu-malu kucing (ចាង៉ាន់ ម៉ាលូ-ម៉ាលូ គូជីង); អ្នកគួរតែមានអារម្មណ៍ថាខ្មាសអៀននឹងខ្លួនឯង kamu harusnya merasa malu pada dirimu sendiri (កាមូ ហារូស(s)ញ៉ា មើរ៉ាសា ម៉ាលូ ប៉ាដា ឌីរីមូ សិនឌីរី);*

**mempermalukan** /មើមពើរ(r)ម៉ាលូកាន់/ *v* ធ្វើឲ្យខ្មាស់គេ: *មនុស្សរាល់គ្នាដឹងថាវាគ្រាន់តែចង់ធ្វើឲ្យខ្ញុំខ្មាស់គេតែប៉ុណ្ណោះ semua orang tahu bahwa ia hanya bermaksud mempermalukanku di depan umum (សឹមូវ៉ា អូរ៉ាំង តាហ៊ូ បះវ៉ា អ៊ីយ៉ា ហាញ៉ា ប៊ើរ(r)ម៉ាស៊ុត មើមពើរ(r)ម៉ាលូកាន់គូ ឌិ ឌើប៉ាន់ អ៊ូមិម);*

**kemaluan** /គើម៉ាលូវ៉ាន់/ *n* ប្រដាប់ភេទ; ប្រដាប់បន្តពូជ

**malu-malu kucing** /ម៉ាលូ ម៉ាលូ គូជិង/ អឹមអៀន: *គាត់ញញឹមអឹមអៀនៗ dia tersenyum malu-malu kucing (ឌីយ៉ា តើរ(r) សើញូម ម៉ាលូ–ម៉ាលូ គូជិង)*

**mampir** /ម៉ាំពីរ(r)/ *v* ចូលលេង; ឈាងចូល: *ល្អវាអ្នកគួរតែចូលលែងផ្ទះរបស់ខ្ញុំ sebaiknya kamu mampir ke rumahku (សឺបាអ៊ីគញ៉ា កាមូ ម៉ាំពីរ(r) គើ រូម៉ះគូ);*

**mampu** /ម៉ាំពូ/ *a* លទ្ធភាព: *គាត់គ្មានលទ្ធភាពសងបំណុលគាត់បានទេ ia tidak mampu membayar utangnya (អ៊ីយ៉ា ទីដាក់ ម៉ាំពូ មឹមបាយើតរ (r) អ៊ូតាំងញ៉ា);*

**kemampuan** /គើម៉ាំពូវ៉ាន់/ *n* សមត្ថភាព: *គាត់មានសមត្ថភាពរាប់បានច្រើនជាងបងប្រុសគាត់ kemampuan berhitungnya melebihi kakaknya (គើម៉ាំពូវ៉ាន់ តើរ(r)ហ៊ីទុងញ៉ា មើលើពីហ៊ី កាកាកញ៉ា)*

**mana** /ម៉ាណា/ *pron* មួយណា: *ទើមួយណាដែលអ្នកស្រលាញ់? mana yang kau suka? (ម៉ាណា យ៉ាំង កោវ ស៊ូកា);*

**-- bisa** /ម៉ាណា ប៊ីសា/ ម្តេចនឹងអាច: *ខ្ញុំបានរៀបចំកម្មវិធីនេះអស់រយៈពេលរាប់ខែម្តេចនឹងអាចលុបចោលបាន saya telah menyiapkan acara ini selama berbulan-bulan, mana bisa dibatalkan (សាយ៉ា ទើឡះ មើញីយ៉ាបកាន់ អាចារ៉ា អ៊ីនី សឺឡាម៉ា បឺរ(r)ប៊ូឡាន់–ប៊ូឡាន់ ម៉ាណា ប៊ីសា ឌិបាតាល់កាន់);*

**-- lagi** /ម៉ាណាឡាហ្គី/ អ្វីទៀត: *អ្វីទៀតដែលយើងត្រូវធ្វើ? mana lagi yang harus kami kerjakan? (ម៉ាណា ឡាហ្គី យ៉ាំង ហារុស(ស) កាមី គើរ(r)ចាកាន់);*

**-- tahu** /ម៉ាណា តៅ/ អ្នកណាដឹង: *អ្នកណាដឹងប្រហែលជាគាត់ដ៏អាចថាបាន mungkin memang dia orangnya, siapa tahu (មូងគិន មែម៉ាំង ឌីយ៉ា អូរ៉ាំងញ៉ា, ស៊ីយ៉ាប៉ា តាហ៊ូ);*

**di mana** /ឌិ ម៉ាណា/ *pron* នៅកន្លែងណា: *ខ្ញុំមិនដឹងថាពួកគេឥឡូវនេះនៅកន្លែងណាទេ? saya tidak tahu di mana mereka sekarang (សាយ៉ា ទីដាក់ តាអ៊ូ ឌិម៉ាណា មើរេកា សឺការ៉ាំង);*

**ke mana** /គើ ម៉ាណា/ *pron* ទៅណា:

*ទើខ្ញុំត្រូវយកកញ្ចប់នេះទៅណា? kemana saya harus mengantarkan paket ini? (គើម៉ាណា សាយ៉ា ហារុស(ស) មើង៉ាន់តារ(r)កាន់ ប៉ាកិត អ៊ីនី)*

**manakala** /ម៉ាណាកាឡា/ *p* ពេលណា: *នៅពេលណាដែលអ្នកត្រូវការជំនួយអ្នកអាចទាក់ទងមកយើងបាន manakala kau membutuhkan bantuan, kau bisa menghubungi kami (ម៉ាណាកាឡា កោវ មើមប៊ូទុះកាន់ បានទូវ៉ាន់ កោវ ប៊ីសា មើងហ៊ូប៊ូងី កាមី)*

**manasuka** /ម៉ាណាស៊ូកា/ *a* តាមចិត្តចង់; ដែលអាចជ្រើសរើសបាន: *ការបន្ថែមធានារ៉ាប់រងសុខភាពទៅលើគណនីសន្សំរបស់អ្នកគឺអ្នកអាចជ្រើសរើសបាន penambahan asuransi kesehatan pada tabungan Anda bersifat manasuka (ពើណាំបាហាន់ អាស៊ូរ៉ាន់ស៊ី គើសីហាតាន់ ប៉ាដា តាប៊ូង៉ាន់ អាន់ដា បឺរ(r)ស៊ីហ្វាត់ ម៉ាណាស៊ូកា)*

**mancanegara** /ម៉ាន់ចានើហ្គើរ៉ា/ *n* បរទេស

**mancung** /ម៉ាន់ជុង/ *a* ស្រួច: *ច្រមុះនាងស្រួចដូចជាច្រមុះរបស់ឪពុកនាងអញ្ចឹង hidungnya mancung seperti ayahnya (ហ៊ីឌុងញ៉ា ម៉ាន់ជុង សឺពើរ(r)ទី អាយ៉ះញ៉ា)*

**mandi** /ម៉ាន់ឌី/ *v* ងូតទឹក: *ងូតទឹកដើម្បីឱ្យរាងកាយស្រស់ស្រាយ mandi supaya badan segar (ម៉ាន់ឌី ស៊ូប៉ាយ៉ា បាដាន់ សេគើរ (r))*

**mandiri** /ម៉ាន់ឌិរី/ *a* ដែលឯករាជ: *ស្ត្រីដែលឯករាជ wanita mandiri (វ៉ានីតា ម៉ាន់ឌិរី);*

**kemandirian**/គើម៉ាន់ឌិរីយ៉ាន់/ *n* ឯករាជភាព; ភាពម្ចាស់ការលើខ្លួនឯង: *ភាពម្ចាស់ការលើខ្លួនឯងអាចសម្រេចទៅបានដោយការខិតខំប្រឹងធ្វើការ kemandirian dapat diraih dengan kerja keras (គើម៉ាន់ឌិរីយ៉ាន ដាប៉ាត់ ឌិរ៉ាអ៊ិស(ស) ឌើង៉ាន់ គើរ(r)ចា្ឆ គើរ៉ាស់(ស))*

**manfaat** /ម៉ាន់ហ្វាអាត/ *n* អត្ថប្រយោជន៍: ជួយអ្នកដទៃ មានអត្ថយោជន៍ច្រើនណាស់ *membantu orang lain banyak manfaatnya (*មឹមបាន់ទូ អូរ៉ាង ឡៃន បាញ៉ាក់ ម៉ានហ្វាអាតញ៉ា*)*

**mangkuk** /ម៉ុំងកុក/ *n* ចាន: *ចានសម្ល mangkuk sup (ម៉ុំងកុកស៊ុប)*

**manis** /ម៉ានីស (s)/ *a* ផ្អែម: *ថែមស្ករដើម្បីឱ្យផ្អែម tambahkan gula supaya manis (តាំបាស់កាន់ គូឡា ស៊ូប៉ាយ៉ា ម៉ានីស (s))*

**manja** /ម៉ាន់ច្យា/ *a* បានចិត្ត; ថ្នាក់ថ្នម; ខ្និកខ្នក់: *ការបំពេញបំណងតាមការចង់បានរបស់កុមារនឹងធ្វើឱ្យពួកគេបានចិត្ត memenuhi semua keinginan anak dapat membuat anak menjadi manja (មើមើនូហ៊ី សឺមូវ៉ា គើអ៊ីងីណាន់ អាណាក់ ដាប៉ាត់ មើមប៊ូវ៉ាត់ អាណាក់ មើនច្យាឌិ ម៉ាន់ច្យា);*

**bermanja-manja** /ប៊ឺរ(r)ម៉ាន់ច្យា-ម៉ាន់ច្យា/ *v* ថ្នាក់ថ្នម; ខ្និកខ្នក់: *ខ្ញុំចូលចិត្តធ្វើខ្និកខ្នក់ជាមួយបងស្រីរបស់ខ្ញុំ saya suka bermanja-manja dengan kakak perempuan saya (សាយ៉ា ស៊ូកា ប៊ឺរ(r)ម៉ានច្យា ឌើង៉ាន់ កាកាក់ ពើរើមពូវ៉ាន់ សាយ៉ា);*

**memanjakan** /មើម៉ាន់ច្យាកាន់/ *v* ធ្វើឱ្យបានចិត្ត; ថ្នាក់ថ្នម; ខ្និកខ្នក់: *អ្នកមិនគួរធ្វើឱ្យកូនស្រីរបស់អ្នកបានចិត្តឡើយ sebaiknya Anda tidak memanjakan putri Anda (សឺបាអ៊ីគញ៉ា អាន់ដា ទីដាក់ មើម៉ាន់ច្យាកាន់ ពូទ្រី អាន់ដា)*

**mantan** /ម៉ាន់តាន់/ *n* អតីត: *អតីតប្រធានាធិបតី mantan presiden (ម៉ានតាន់ ប្រេស៊ីដិន)*

**mantap** /ម៉ានតាប់/ *a* គ្រប់គ្រាន់: *ខ្ញុំគ្រប់គ្រាន់អាចកំណត់ជម្រើសបានហើយ saya sudah mantap menentukan pilihan (សាយ៉ា ស៊ូដាស់ ម៉ានតាប់ មើនិនទូកាន់ ពីលីហាន់)*

**mantel** /ម៉ាន់ទែល/ *n* អាវធំ: *អាវធំនេះធ្វើពីស្បែកខ្លា mantel itu terbuat dari kulit macan (ម៉ាន់តែល អ៊ីទូ ទើរ(r)ប៊ូវ៉ាត់ ដារី គូលីត ម៉ាចាន់)*

**manusia** /ម៉ានូស៊ីយ៉ា/ *n* មនុស្ស: *ពិភពលោកនេះមិនអាចបំពេញតម្រូវការរបស់មនុស្សទៀតទេ alam ini sudah tidak mampu mencukupi kebutuhan manusia (អាឡាំ អ៊ីនី ស៊ូដះ ទីដាក់ ម៉ាំពូ មើនជូគូពី គើប៊ូទូហាន់ ម៉ានូស៊ីយ៉ា);*

**kemanusiaan** /គើម៉ានូស៊ីយ៉ាអាន/ *n* មនុស្សធម៌: *អង្គការមនុស្សធម៌ organisasi kemanusiaan (អូរ(r)ហ្គានីសាស៊ី គើម៉ានូស៊ីយ៉ាអាន)*

**manusiawi** /ម៉ានូស៊ីយ៉ាវី/ *a* សារជាតិមនុស្ស: *ការភ័យខ្លាចការបរាជ័យគឺជាសារជាតិរបស់មនុស្ស takut gagal adalah hal yang*

*manusiawi (តាគុត ហ្កាហ្កាល់ អាដាឡះ ហាល់ យ៉ាំង ម៉ានូស៊ីយ៉ាវី)*

**marah** /ម៉ារ៉ះ/ *a* ខឹង: *គាត់ខឹងដោយសារមិត្តគាត់កុហក់ ia marah karena temannya berbohong (អ៊ីយ៉ា ម៉ារ៉ាស់ ការ៉េណា ទើម៉ាន់ញ៉ា ពើរ (r) ពោហុ៊ង);*

**kemarahan** /កើម៉ារ៉ាហាន់/ *n* កំហឹង: *កំហឹងគាត់កាន់តែខ្លាំង kemarahannya memuncak (កើម៉ារ៉ាហាន់ញ៉ា មើមុនចាក់)*

**marak** /មារ៉ាក់/ *a* កើនឡើង: *ចំនួនឧក្រិដ្ឋកម្មតាមបណ្ដាញអ៊ិនធើណែតកាន់តែកើនឡើង angka kejahatan dunia maya semakin marak (អាំងកា គើឆ្យាហាតាន់ ឌូនីយ៉ា ម៉ាយ៉ា សឺម៉ាគិន មារ៉ាក់);*

**semarak** /សឺម៉ារ៉ាក់/ *a* ដែលត្រចះត្រចង់: *ការប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីដ៏ត្រចះត្រចង់ peringatan tahun baru yang semarak (ពើរីង៉ាតាន់ តាហ៊ុន បារូ យ៉ាំង សឺម៉ារ៉ាក់)*

**mari** /មារី/ *p តោះ: មក: តោះមកតាមខ្ញុំ mari ikuti saya! (មារី អ៊ីគូទី សាយ៉ា!)*

**markah** /ម៉ារ(r)កាស់/ *n* សញ្ញា: *សញ្ញាចរាចរណ៍ markah jalan (ម៉ារ(r)កាស់ ចាឡាន);*

**memarkahi** /មើម៉ារ(r)កាហ៊ី/ *v* ដាក់សញ្ញា: *ខ្ញុំដាក់សញ្ញាផ្កាយនៅទំព័រទី៥ saya memarkahi halaman 5 dengan tanda bintang (សាយ៉ា មើម៉ារ(r)កាហ៊ី ហាឡាម៉ាន់ លីម៉ា ទើង៉ាន់ តាន់ដា ពីនតាំង)*

**markas** /ម៉ារ(r)កាស់(s)/ *n* បន្ទាយ: *បន្ទាយទាហាន markas tentara (ម៉ារ(r)កាស់(ស) តិនតារ៉ា);*

**-- polisi** /ម៉ារ(r)កាស់ ប៉ូលីស៊ី/ ប៉ុស្ដិ៍ប៉ូលីស; ស្ថានីយ៍ប៉ូលីស: *មានការប៉ះទង្គិចគ្នារវាងប្រជាពលរដ្ឋនិងប៉ូលីសនៅមុខស្ថានីយ៍ប៉ូលីស terjadi bentrokan antara warga dengan aparat di depan markas polisi (ទើរ(r)ឆ្យាឌិ បិនត្រូកាន់ អាន់តារ៉ា វ៉ារ(r)ហ្កា ឌើង៉ាន់ អាប៉ារ៉ាត់ ឌិ ឌើប៉ាន់ ម៉ារ(r)កាស់(ស) ប៉ូលីស៊ី)*

**masa** /ម៉ាសា/ *n* ពេលវេលា: *គ្រប់យ៉ាងគឺមានពេលវេលារបស់វា; ពេលវេលាកន្លង; ពេលអនាគត semua ada masanya; masa lalu; masa depan (សើម័រ អាដា ម៉ាសាញ៉ា; ម៉ាសាឡាឡូ; ម៉ាសា ឌើប៉ាន់);*

**-- kini** /ម៉ាសា គីនី/ សព្វថ្ងៃនេះ; ឥឡូវនេះ: *សព្វថ្ងៃ*

*នេះស្ត្រីមេផ្ទះជាច្រើនបានពង្រឹងខ្លួនឯងតាមរយៈអាជីវកម្មអនឡាញ* di masa kini, *banyak ibu rumah tangga yang memberdayakan dirinya melalui bisnis daring (ឌិ ម៉ាសា គីនី បាញ៉ាក់ អ៊ីប៊ូ រូម៉ះ តាំងហ្គា យ៉ាំង មើមបឺរ(r)ដាយ៉ាកាន់ ឌិរីញ៉ា មើឡាលូអី ប៊ីស្នីស(ស) ដារិង);*

**semasa** /សឺម៉ាសា/ *n* កំឡុងពេល; ខណៈពេល; កាលពី: *កាលពីយុវវ័យខ្ញុំបានរស់នៅប៉ុន្មានឆ្នាំដែរនៅសូឡូជាមួយឪពុកមារបស់ខ្ញុំ* semasa remaja, *saya tinggal beberapa tahun di Solo bersama paman saya (សឺម៉ាសា រ៉េម៉ាចា សាយ៉ា ទីងហ្គាល់ បឺបឺរ៉ាប៉ា តាហ៊ុន ឌិ សូឡូ បឺរ(r)សាម៉ា ប៉ាម៉ាន់ សាយ៉ា)*

**masak** /ម៉ាសាក់/ *a* ទុំ: *ជ្រើសរើសតែផ្លែណាដែលទុំពិតប្រាកដដើម្បីធ្វើទឹកក្រឡុកដែលមានរស់ជាតិឆ្ងាញ់* pilihlah *hanya buah yang benar-benar masak agar rasa jus menjadi enak (ពីលិះឡះ ហាញ៉ា ប៊ូវ៉ាស់(ស) យ៉ាំង បឺណារ(r)-បឺណារ(r) ម៉ាសាក់ អាហ្គារ(r) រ៉ាសា ជុស(ស) មើនចាឌី អ៊ែណាក់);*

**masakan** /ម៉ាសាកាន់/ *n* ម្ហូបអាហារ: *masakan jepang (ម៉ាសាកាន់ ជើប៉ាំង);*

**memasak** /មើម៉ាសាក់/ *v* ចម្អិន; ធ្វើម្ហូប: *តើអ្នកអាចចម្អិនវាកុំឲ្យឆ្អិនពេកសម្រាប់ខ្ញុំបានទេ? bisakah Anda memasaknya tidak terlalu matang untuk saya? (ប៊ីសាកះ អាន់ដា មើម៉ាសាក់ញ៉ា ទីដាក់ ទើរ(r)ឡាលូ ម៉ាតាំង អ៊ុនទុក សាយ៉ា)*

**masalah** /ម៉ាសាឡាស់/ *n* បញ្ហា: *គ្រប់យ៉ាងទៅដោយរលូន គ្មានបញ្ហាទេ* semuanya *lancar, tidak ada masalah (សើម័រញ៉ា ឡាន់ចើរ(r) ទីដាក់ អាដា ម៉ាសាឡាស់)*

**masih** /ម៉ាសីស/ *adv* នៅតែ: *នៅតែរង់ចាំ masih menunggu (ម៉ាសីស មើនុងគូ)*

**masing-masing** /ម៉ាស៊ិង-ម៉ាស៊ិង/ *pron* រាល់ៗ

**masinis** /ម៉ាស៊ីនីស (s)/ *n* ក្បាលរថភ្លើង: *ក្បាលរថភ្លើងនោះធ្វើឲ្យរថភ្លើងដំណើរការបានល្អ masinis itu menjalankan keretanya dengan sangat baik (ម៉ាសីនីស(s) អ៊ីទូ មិនចាឡានកាន់ កើរេតាញ៉ា ទើងាន់ សាងាត់ បៃ)*

**masjid 1** /ម៉ាស(s)ជីត/ *n* វិហារ: *អ្នកម៉ូស្លីមថ្វាយបង្គំនៅវិហារ* muslim

*sembahyang di masjid (ម៉ូស្ទីម ស៊ីមពាស់យ៉ាំង ឌី ម៉ាស(s)ជីត)*;

**2** /មែស(s)ជ/ *n* ម៉ាស់ស្ថិទ; វិហារអ៊ីស្លាម: *នៅក្នុងខែរ៉ម៉ាទនសាសនិកអ៊ីស្លាមបានទៅវិហារអ៊ីស្លាមដើម្បីធ្វើការគោរពបូជា pada bulan Ramadan umat Islam memenuhi masjid-masjid untuk beribadah (ប៉ាដា ប៊ូឡាន់ រ៉ាម៉ាដាន អ៊ូម៉ាត់ អ៊ីស្លាម មើមើនូហ៊ី មើសជីត មើសជីត អ៊ុនទុក ប៊ើរីបាដះ)*

**masuk** /ម៉ាស៊ុក/ *v* ចូល: *ចូលក្នុងបន្ទប់ masuk ke ruangan (ម៉ាស៊ុក តើ រ្វ៉ាំងង៉ាន់)*; *ចូលសាលារៀន masuk sekolah (ម៉ាស៊ុក សើកូឡះ)*;

**-- akal** /ម៉ាស៊ុក អាកាល់/ សមហេតុផល: *ការពន្យល់សមហេតុផល alasan yang masuk akal (អាឡាសាន់ យ៉ាំង ម៉ាស៊ុក អាកាល់)*;

**-- angin** /ម៉ាស៊ុគ អាងិន/ ខ្យល់; គ្រុន: *ក្មេងនោះគ្រុនដោយសារតែវាហែលទឹកយូរពេក anak itu masuk angin karena terlalu lama berenang (អាណាក់ អ៊ីទូ ម៉ាស៊ុគ អាងិន ការរើណា ទើរ(r)ឡាលូ ឡាម៉ា ប៊ើរើណាំង)*;

**masukan** /ម៉ាស៊ូកាន់/ *n* ដាក់; បញ្ចូល: *សូមបញ្ចូលលេខរបស់លោកអ្នកដើម្បីធ្វើការចុះឈ្មោះ mohon masukkan nomor Anda untuk melakukan registrasi ini (ម៉ូហុន ម៉ាស៊ូកាន់ ណូម៉ូរ(r) អានដា អ៊ុនទុក មើឡាគូកាន់ រ៉េហ្គីស្ត្រាស៊ី អ៊ីនី)*;

**memasukkan** /មើម៉ាស៊ុកាន់/ *v* បញ្ចូល: *បញ្ចូលឡានក្នុងយានដ្ឋាន memasukkan mobil ke dalam garasi (មើម៉ាស៊ុកាន់ ម៉ូប៊ីល តើ ដាឡាំ ហ្គារ៉ាស៊ី)*; *បញ្ចូលទិន្នន័យ memasukkan data (មើម៉ាស៊ុកាន់ ដាតា)*;

**termasuk** /តើរ(r) ម៉ាស៊ុក/ *v* រួមបញ្ចូល: *មិនរួមបញ្ចូលពន្ធទេ tidak termasuk pajak (ទីដាក់ តើរ(r)ម៉ាស៊ុក ប៉ាចាក់)*

**masyarakat** /ម៉ាស្យ៉ារ៉ាកាត់/ *n* **1** សង្គម: *ពង្រឹងសង្គម pemberdayaan masyarakat (ពើមបឺរ(r)ដាយ៉ាអាន ម៉ាស្យារ៉ាកាត់)*; **2** សង្គម: *ពង្រឹងសង្គម pemberdayaan masyarakat (ពើមបឺរ(r)ដាយ៉ាអាន ម៉ាស្យារ៉ាកាត់)*;

**memasyarakatkan** /មើម៉ាស្យ៉ារ៉ាកាត់កាន់/

*v* ធ្វើឱ្យសង្គមមូបនីយកម្ម:

*រដ្ឋាភិបាលធ្វើសង្គមមូបនីយកម្មស្ដីពីអ៊ិនធើណេត ចាប់ពីទីក្រុងរហូតដល់តំបន់ដាច់ស្រយាល* *pemerintah memasyarakat-kan internet mulai dari kota hingga ke daerah terpencil (ពើមើរិនតះ មើម៉ាស្យារ៉ាកាត់កាន់ អ៊ិនទើរ(r)ណែត មូឡៃ ដារី កូតា ហ៊ីងហ្គា កឺ ដាអេរ៉ះ ទើរ(r)ពើនជីល);*

**pemasyarakatan** /ពើម៉ាស្យ៉ារ៉ាកាតាន់/ *n* សង្គមមូបនីយកម្ម:

*សង្គមមូបនីយកម្មនៃភាសាឥណ្ឌូនេស៊ី* *pemasyarakatan bahasa Indonesia (ពើម៉ាស្យារ៉ាកាតាន់ បាហាសា ឥណ្ឌូនេស៊ីយ៉ា)*

**masyhur** /ម៉ាស្ហូរ(r)/ *a* ល្បីល្បាញ:

*ស្នាដៃវិចិត្រករនេះល្បីល្បាញពេញពិភពលោក* *karya-karya pelukis itu masyhur di dunia (ការ(r)យ៉ា–ការ(r)យ៉ា ពើលូគិស(ស) អ៊ីទូ ម៉ាស្ហូរ(r) ឌិ ឌូនីយ៉ា);*

**termasyhur** /ទើរ(r)ម៉ាស្ហូរ(r)/

*a* ល្បីល្បាញ:

*ស្នាដៃវិចិត្រករនេះល្បីល្បាញបំផុតពេញពិភពលោក* *karya-karya pelukis itu termasyhur di dunia (ការ(r)យ៉ា ការ(r)យ៉ា ពើលូគិស(ស) អ៊ីទូ ទើរ(r)ម៉ាស្ហូរ(r) ឌិ ឌូនីយ៉ា)*

**mata** /ម៉ាតា/ *n* ភ្នែក: *បើកភ្នែក* *membuka mata (មឹមប៊ូកា ម៉ាតា); បិទភ្នែក memejamkan mata (មើមេចាំកាន់ ម៉ាតា); ភ្នែកងងុយគេង mata mengantuk (ម៉ាតា មើងាន់ទុក);*

**-- air** /ម៉ាតា អាយីរ(r)/ ក្បាលទឹក; ប្រភពទឹក:

*ទួលនោះមានប្រភពទឹកជាច្រើនដែលជាទឹកស្អាត* *bukit itu mempunyai banyak mata air yang cukup bersih (ប៊ូគិត អ៊ីទូ មើមពូញ៉ៃ បាញ៉ាក់ ម៉ាតា អាយីរ(r) យ៉ាំង ជូគុប បឺរ(r)ស៊ីះ);*

**-- angin** /ម៉ាតា អាងិន/ ទិសខ្យល់:

*ត្រីវិស័យត្រូវបានប្រើដោយអ្នកដំណើរដើម្បីកំណត់ទិសនៃ**ខ្យល់*** *kompas masih digunakan para pelancong untuk menentukan arah mata angin (កុមប៉ាស់(ស) ម៉ាស៊ិះ ឌិហ្គូណាកាន់ ប៉ារ៉ា ពើឡាន់ចុង អ៊ុនទុក មើនែនទូកាន់ អារ៉ះ ម៉ាតា អាងិន);*

**-- duitan** /ម៉ាតា ឌូវីតាន់/ មុខលុយ;

**-- gelap** /ម៉ាតា ហ្គើឡាប់/ ងងឹតមុខ; មោបាំង: *ដោយសារតែគេបានដឹងថាកំពុងធ្វើសកម្មភាពចោរ នោះមោបាំងក៏បានសម្លាប់ម្ចាស់ផ្ទះទៅ karena ketahuan sedang melancarkan aksinya, pencuri itu gelap mata dan membunuh pemilik rumah (ការេណា គើតាហ៊ូវ៉ាន់ សឺដាំង មើឡាន់ចារ(r)កាន់ អាក់ស៊ីញ៉ា ពើនជូរី អ៊ីទូ ហ្គើឡាប់ ម៉ាតា ដាន់ មើមប៊ូនុះ ពើមីលីគ រូម៉ះ);*

**-- hati** /ម៉ាតា ហាទី/ ទឹកចិត្ត;

**-- ikan** /ម៉ាតា អ៊ីកាន់/ ភ្នែកត្រី;

**-- kaki** /ម៉ាតា កាគី/ ភ្នែកគោល;

**-- pelajaran** /ម៉ាតា ពើឡាច្សារ៉ាន់/ មុខវិជ្ជា: *សាលារៀនមួយចំនួនបានបន្ថែមមុខវិជ្ជាដើម្បីបង្កើនការជាប់របស់សិស្ស beberapa sekolah menambah beberapa mata pelajaran untuk meningkatkan prestasi muridnya (បឺបឺរ៉ាប៉ា សឺកូឡះ មើណាំបះ បឺបឺរ៉ាប៉ា ម៉ាតា ពើឡាច្សារ៉ាន់ អ៊ុនទុក មើនិងកាត់កាន់ ព្រេស្តាស៊ី មូរីដញ៉ា);*

**-- pencarian** /ម៉ាតា ពើនចាហារីយ៉ាន់/ របរចិញ្ចឹមជីវិត;

**-- sapi (telur)** /ម៉ាតា សាពី ទើលូរ(r)/ ពងមាន់(ចៀនកំឡុងផ្អិនពេក);

**-- uang** /ម៉ាតា អ៊ូវាំង/ រូបិយប័ណ្ណ; រូបិយវត្ថុ: *រូបិយប័ណ្ណអន្តរជាតិ mata uang asing (ម៉ាតា អ៊ូវាំង អាស៊ីង);*

**semata wayang** /សឺម៉ាតា វ៉ាយ៉ាំង/ មួយគត់;

**semata-mata** /សឺម៉ាតា ម៉ាតា/ *adv* តែម្នាក់ឯង

**matahari** /ម៉ាតាហារី/ *n* ព្រះអាទិត្យ: *ព្រះអាទិត្យរះនៅពេលព្រឹក matahari terbit pada pagi hari (ម៉ាតាហារី តើរ(r)ប៊ីត ប៉ាដា ប៉ាហ្គី ហារី)*

**matang**/ម៉ាតាំង/ *a* ឆ្អិន: *ផ្លែបឺរនោះទុំល្អហើយ alpukat itu sudah cukup matang (អាល់ពូកាត់ អ៊ីទូ ស៊ូដះ ជូគុប ម៉ាតាំង)*

**mati** /ម៉ាទី/ *v* **1** ស្លាប់: *ឆ្កែនេះមិនដកដង្ហើមព្រោះវាបានស្លាប់ហើយ anjing ini tidak bernafas karena sudah mati*

*(អាន់ជឹង អ៊ីនី ទីដាក់ ពើរ(r)ណាហ្វាស់(s) កាម៉េណា ស៊ូដាស់ ម៉ាទី)*; **2** ខូច: *ម៉ាស៊ីននេះបានខូចហើយ mesin ini sudah mati (មើស៊ីន អ៊ីនី ស៊ូដាស់ ម៉ាទី);*

**-- kutu** /មាទី គូទូ/ ចប់;

**-- langkah** /ម៉ាទី ឡាំងកះ; បាក់ចង្កេះ;

**-- rasa** /ម៉ាទី រ៉ាសា/ ស្ពឹក; លែងដឹងអ្វីទាំងអស់;

**-- suri** /ម៉ាទី ស៊ូរី/ ស្លាប់ហើយរស់ឡើងវិញ; សន្លប់ធំ;

**kematian** /គើម៉ាទីយ៉ាន់/ *n* ស្លាប់; ងាប់;

**mati-matian** /ម៉ាទី ម៉ាទីយ៉ាន់/ *adv* ខ្លាំងខ្លា; ងាប់រស់;

**mematikan** /មើម៉ាទីកាន់/ *v* បិទ; ១: *បិទភ្លើង mematikan lampu ((សាំពូ) មើម៉ាទីកាន់ ឡាំពូ); បិទវិទ្យុ mematikan radio (មើម៉ាទីកាន់ រ៉ាឌីយ៉ូ); ២ បិទអាជីវកម្មអ្នកដទៃ mematikan usaha orang lain ((ឌូអា) មើម៉ាទីកាន់ អ៊ូសាហា អូរ៉ាង ឡែន)*

**mau** /ម៉ាវ/ *adv* ចង់:

*ខ្ញុំចង់ក្លាយជាអវកាសចរនៅថ្ងៃណាមួយ aku ingin menjadi astronot kelak (អាគូ អ៊ីងិន មើនចាឌី អាស្ត្រូណូត គើឡាក់);*

**mau tak mau** /ម៉ាវ តាក់ ម៉ាវ/ ចង់ឬមិនចង់;

**kemauan** /គើម៉ាវ៉ាន់/ *n* ចំណង់; ការចង់បាន;

**maupun** /ម៉ាវពុន/ *p* ឬ;

**semau-maunya** /សឺម៉ាវម៉ាវញ៉ា/ *adv* តាមតែវាចង់

**mayat** /ម៉ាយ៉ាត់/ *n* សាកសព/ខ្មោច:

**medali** /មេដាលី/ *n* មេដាយ: *មេដាយមាស medali emas (មេដាលី អេម៉ាស់(ស))*

**megah** /មេហ្គះ/ *a* ធំ: *អាគារនោះធំណាស់ gedung itu sangat megah (ហ្គើដ្លុង អ៊ីទូ សាងាត់ មេហ្គះ)*

**meja** /មេជែ/ *n* តុ: *តុរៀន meja belajar (មេជែ ពើឡាជើរ(r)); តុធ្វើការ meja kerja (មេជែ គើរ (r) ជែ); តុញ៉ាំបាយ meja makan (មេជែ ម៉ាកាន់);*

**-- hijau** /មេចា្យ ហុីចា្យវ/ តុលាការ: *ជនពុករលួយបានយំនៅពេលដែលប្រឈមមុខនៅតុលាការ koruptor itu menangis ketika dihadapkan ke meja hijau (ក្អរុបតូរ(r) អុីទូ មើណាងិស(ស) គើទីកា ឌិហាដាប់កាន់ គើ មេចា្យ ហុីចា្យវ)*

**mekar** /មើការ(r)/ *v* រីក: *ក្មេងស្រីនោះធំឡើងដូចជាផ្កាកំពុងរីក gadis itu tumbuh seperti bunga yang sedang mekar (ហ្គាឌិស(ស) អុីទូ ទុមប៊ុះ សឺពើរ(r)ទី ប៊ូង៉ា យ៉ាំង សឺដាំង មើការ(r));*

**bermekaran** /ប៊ឺរ(r)មើការ៉ាន់/ *v* រីក: *នៅក្នុងខែមេសាប្រទេសតួកគីនឹងមើលទៅអស្ចារ្យជាមួយនិងផ្កាតូលីបដែលរីកស្គុះស្គាយពេញទីក្រុង pada bulan April, Turki akan tampak luar biasa dengan bunga-bunga tulip yang bermekaran di seluruh kota (ប៉ាដា ប៊ូឡាន់ អាព្រីល ទួរ(r)គី អាកាន់ តាំប៉ាក់ លូអា(r) ប៊ីយ៉ាសា ឌើង៉ាន់ ប៊ូង៉ា–ប៊ូង៉ា ទូលីព យ៉ាំង ប៊ឺ(r)មើការ៉ាន់ ឌិ សឺលូរុះ កូតា)*

**melar** /មើឡារ(r)/ *a* យឺត: *អាវនេះយឺត kaus ini melar (កាអ៊ូស(ស) អុីនី មើឡារ(r))*

**melarat** /មើឡារ៉ាត់/ *a* ក្រីក្រ;

**memang** /មែមុាំង/ *adv* ពិតប្រាកដណាស់; ជាការពិត

**memar** /មើម៉ារ(r)/ *a* ដែលជាំ

**mempan** /មើមប៉ាន់/ *v* ដែលសក្តិសិទ្ធិ; ដែល

**mempelai** /មើមពើឡៃ/ *n* កូនក្រមុំ

**menang** /មើណាំង/ *v* ឈ្នះ;

**kemenangan** /គើមើណាង៉ាន់/ *n* ជ័យជម្នះ;

**memenangkan** /មើមើណាំងកាន់/ *v* យកឈ្នះ;

**pemenang** /ពើមើណាំង/ *n* អ្នកឈ្នះ

**menantu** /មើណាន់ទូ/ *n* កូនប្រសារប្រុស; កូនប្រសារស្រី

**menara** /មើណារ៉ា/ *n* ប៉ម: *ទេសភាពមើលពីលើប៉មពិតជាស្រស់ស្អាតណាស់ pemandangan dari atas menara ini sangat indah (ពើម៉ាន់ដាង៉ាន់ ដារី អាតាស់ មើណារ៉ា អុីនី សាង៉ាត់ អុិនដះ);*

**-- gading** /មើណារ៉ា ហ្គាឌិង/ កន្លែងស្រណុកស្រុកស្រួល:

*ការរិះគន់ចំពោះគោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋាភិបាលដែលបានមកពីពួកអ្នកជំនាញសេដ្ឋកិច្ចដែលរស់នៅតែកន្លែងស្រណុកស្រុកស្រួលតែប៉ុណ្ណោះ kritikan terhadap kebijakan ekonomi yang diambil pemerintah bersumber dari para ahli ekonomi yang hanya hidup di atas menara gading (គ្រីទីកាន់ ទើរ(r)ហាដាប់ គេប៊ីចាកាន់ អេកូណូមី យ៉ាំង ឌីអាំប៊ីល ពើមើរិនតះ ប៊ើ(r)ស៊ូមប៊ើ(r) ដារី ប៉ារ៉ា អះលី អេកូណូមី យ៉ាំង ហាញ៉ា ហ៊ីឌុត ឌិអាតាស់ មើណារ៉ាហ្គាឌីង);*

**-- suar** /មើណារ៉ា ស៊ូរ៉ា(r)/ ប៉មភ្លើង: *អ្នកការពារប៉មភ្លើង penjaga menara suar (ពើនចាហ្គា មើណារ៉ា ស៊ូរ៉ារ(r))*

**mendung** /មិនឌុង/ *a* អាប់អួ: *អាកាសធាតុថ្ងៃនេះអាប់អួណាស់ cuaca hari ini sangat mendung! (ច័រចា ហារី អ៊ីនី សាងាត់ មិនឌុង)*

**menit** /មើនីត/ *n* នាទី: *ខ្ញុំរង់ចាំគាត់អស់រយៈពេលម្ភៃនាទី aku menunggunya selama dua puluh menit (អាគូ មលនុងហ្គូញ៉ា សើឡាម៉ា ឌូអា ពូលូស មើនីត)*

**mentah** /មិនតះ/ *a* ខ្ចី: *តំណាប់ស្វាយជាចំណីពិសេសប្រទេសហ្វីលីពីន manisan mangga mentah adalah makanan khas Filipina (ម៉ានីសាន់ ម៉ាំងហ្គា អាដាឡាស់ ម៉ាកាណាន់ ខាស់(s) ហ្វីលីពីណា)*

**mental** /មេនតាល់/ *n* ផ្លូវចិត្ត: *ជំងឺផ្លូវចិត្ត gangguan mental (ហ្គាំងហ្គូវ៉ាន់ មើនតាល់)*

**mentang, mentang-mentang** /មើនតាំង មើនតាំង/ *adv* ដោយសារតែ: *នាងមើលងាយអ្នកដទៃដោយសារតែឪពុករបស់នាងជាម្ចាស់ភាគហ៊ុនមួយក្នុងចំណោមម្ចាស់ភាគហ៊ុនជាច្រើននៅក្នុងការិយាល័យ dia menganggap rendah yang lain mentang-mentang ayahnya salah seorang pemegang saham di kantor itu (ឌីយ៉ា មើង៉ាំងហ្គាប់ ផឹនដះ យ៉ាំង ឡាអ៊ីន មើនតាំង–មើនតាំង អាយ៉ះញ៉ា សាឡះ សើអូរ៉ាំង ពើមើហ្គាំង សាហាំ ឌិ កាន់តូរ(r) អ៊ីទូ)*

**mentega** /មិនតេហ្គា/ *n* ប៊ឺ: *តើមានជាតិប៊ឺដែរឬទេ? apakah mengandung mentega? (អាប៉ាកាស់ មើងាន់ដុង មិនតេហ្គា)*

**menteri** /មើនទើរី/ *n* រដ្ឋមន្ត្រី: *នាយករដ្ឋមន្ត្រី* *perdana menteri (ពើរ(r)ដាណា មើនទើរី);*

**kementerian** /គើមើនទើរីយ៉ាន់/ *n* ក្រសួង: *គណៈប្រតិភូក្រសួង* *utusan kementerian (អ៊ូទូសាន់ គើមើនទើរីយ៉ាន់)*

**menu** /មើនូ/ *n* បញ្ជី: តើពួកខ្ញុំអាចមើលបញ្ជីមុខម្ហូបបានទេ? *dapatkah kami melihat menu makan siangnya?* (ដាប៉ាត់កាស់ កាមី មើលីហាត់ មើនូ ម៉ាកាន់ ស៊ីយ៉ាំងញ៉ា?)

**merah** /មេរ៉ះ/ *a* ពណ៌ក្រហម: *ស្ត្រីម្នាក់នោះស្លៀកសម្លៀកបំពាក់ពណ៌ក្រហមពិតជាស្រស់ស្អាតណាស់* *wanita itu mengenakan gaun merah yang sangat indah (វ៉ានីតា អ៊ីទូ មើងើណាកាន់ ហ្គាអ៊ុង មេរ៉ះ យ៉ាំង សាង៉ាត់ អ៊ិនដះ);*

**-- hati** /មេរ៉ះ ហាទី/ ពណ៌ក្រហមឆ្អិន: *ពណ៌ក្រហមឆ្អិនគេតែងបកអត្ថន័យវាថាជានិមិត្តរូបនៃភាពក្លាហាន* *warna merah hati seringkali diartikan sebagai simbol keberanian (វ៉ារ(r)ណា មើរ៉ះ ហាទី សើរីងកាលី ឌីយ៉ារ(r)ទីកាន់ សើបាហ្គៃ ស៊ីមបុល គើបើរ៉ានីយ៉ាន់);*

**-- jambu** /មេរ៉ះ ចាំប៊ូ/ ពណ៌ស៊ីជំពូ: *ពណ៌ស៊ីជំពូគឺជាពណ៌ដែលបូកបញ្ចូលគ្នារវាងពណ៌ក្រហមនិងពណ៌ស* *merah jambu adalah corak warna yang merupakan perpaduan antara warna merah dan putih (មេរ៉ះ ចាំប៊ូ អាដាឡះ ចូរ៉ាក់ វ៉ារ(r)ណា យ៉ាំង មើរូប៉ាកាន់ ពើរ(r)ប៉ាឌូវ៉ាន់ អាន់តារ៉ា វ៉ារ(r)ណា មេរ៉ះ ដាន់ ពូទីះ);*

**-- muda** /មេរ៉ះ មូដា/ ពណ៌ក្រហមខ្ចី; ពណ៌ស៊ីជំពូ: *ពណ៌ក្រហមខ្ចីគឺជាពណ៌ដ៏ស្រស់ស្អាត* *merah muda merupakan warna yang cantik (មេរ៉ះ មូដា មើរូប៉ាកាន់ វ៉ារ(r)ណា យ៉ាំង ចាន់ទីគ);*

**-- telinga** /មេរ៉ះ ទើលីង៉ា/ ក្តៅត្រចៀក: *ឥរិយាបទរបស់ក្មេងនោះបានធ្វើឲ្យឪពុករបស់វាក្តៅត្រចៀក* *kelakuan anak itu membuat merah telinga bapaknya (គើឡាគូវ៉ាន់ អាណាក់ អ៊ីទូ មើមប៊ូវ៉ាត់ មេរ៉ះ ទើលីង៉ា បាប៉ាក់ញ៉ា);*

**pemerah bibir** /ពើមេរ៉ះ ប៊ីប៊ីរ(r)/ ក្រេម: *នារីនេះប្រើក្រេមលាបមាត់ពណ៌ក្រហម* *gadis itu mengenakan pemerah bibir berwarna*

*merah (ហ្គាឌិស(ស) អ៊ីទូ មើងើណាកាន់ ពើមេរ៉ះ ប៊ីប៊ីរ(r) ប៊ីរ(r)- រ៉ារ(r)ណា មេរ៉ះ);*

**pemerah pipi** /ពើមេរ៉ះ ពីពី/ ម៉ាកាយ៉េ: *ម៉ាកាយ៉េមានអត្ថប្រយោជន៍ជាច្រើននិងពីរក្នុងចំណោមវាគឺធ្វើឱ្យមើលទៅមុខស្រស់និងជួយកែទម្រង់មុខ pemerah pipi mempunyai banyak manfaat dan dua di antaranya adalah membuat wajah terlihat lebih segar dan mengoreksi bentuk wajah (ពើមេរ៉ះ ពីពី មើមពូញ៉ៃ បាញ៉ាក់ ម៉ាន់ហ្វាអាត់ ដាន់ ឌូវ៉ា ឌីអាន់តារ៉ាញ៉ា អាដាឡះ មើមប៊ូវាត់ វ៉ាច្យ៉ះ ទើរ(r)លីហាត់ លើប៊ិះ សឺហ្គារ(r) ដាន់ មើង៉ូរ៉េគស៊ី បិនទុក វ៉ាច្យ៉ះ)*

**merdeka** /មើរ(r)ដេកា/ *a* ដែលឯករាជ: *ប្រទេសដែលឯករាជ negara merdeka (នើហ្គារ៉ា មើរ(r)ដេកា);*

**kemerdekaan** /គើមើរ(r)ដេកាអាន/ *n* ការឯករាជ: *ថ្ងៃឯករាជ hari kemerdekaan (ហារី គើមើរ(r)ដេកាអាន)*

**merdu** /មើរ(r)ឌូ/ *a* ពិរោះ *សម្លេងរបស់តារាចម្រៀងរូបនេះគឺពិតជាពិរោះណាស់ suara penyanyi itu sangat merdu (ស៊្វារ៉ា ពើញ៉ាញី អ៊ីទូ សាង៉ាត់ មើរ(r)ឌូ)*

**merek** /មើរ៉េក/ *n* ម៉ាក: *ម៉ាកល្បី merek terkenal (មើរ៉េក តើរ(r)កើណាល់);*

**bermerek** /ពើរ(r) មើរ៉េក/ *v* មានម៉ាកល្បី: *កាបូបដែលមានម៉ាកល្បី tas bermerek (តាស់(s) ពើរ(r) មើរ៉េក)*

**mereka** /មើរេកា/ *pron* ពួកគេ: *ពួកគេរស់នៅផ្ទះតែមួយជាមួយឪពុកម្ដាយពួកគេ mereka tinggal serumah dengan orangtuanya (មើរេកា ទីងហ្គាល់ ស៊ើរូម៉ះ ទើងាន់ អូរ៉ាំងតួរញ៉ា)*

**meriah** /មើរីយ៉ះ/ *a* អ៊ឹកធឹក: *ពិធីជប់លៀងនោះពិតជាអ៊ឹកធឹកណាស់ pesta itu sangat meriah (ប៉េស្តា អ៊ីទូ សាង៉ាត់ មើរីយ៉ះ)*

**merica** /មើរីចា/ *n* ម្រេច: *មនុស្សជាច្រើនតែងតែនិយាយថាម្រេចគឺជាស្ដេចនៃគ្រឿងទេសសម្រាប់រាល់មុខម្ហូបទាំងអស់ banyak orang menyebutkan merica adalah rajanya dari segala bumbu dalam setiap masakan (បាញ៉ាក់ អូរ៉ាំង មើញើប៊ុតកាន់ មើរីចា អាដាឡះ រ៉ាច្យាញ៉ា ដារី សឺហ្គាឡា ប៊ុមប៊ូ ដាឡាំ សឺទីយ៉ាប ម៉ាសាកាន់)*

**merpati** /មើរ(r)ប៉ាទី/ *n* ព្រាប:

*សត្វព្រាបមិនត្រឹមតែជានិមិត្តរូបនៃសន្តិភាពនោះទេប៉ុន្តែក៏ជានិមិត្តរូបនៃស្នេហាអមតៈ burung merpati tidak hanya sebagai lambang perdamaian tetapi juga lambang kesetiaan cinta (ប៊ូរុង មើរ(r)ប៉ាទី ទីដាក់ ហាញ៉ា សឺបាហ្គៃ ឡាំបាំង ពើរ(r)ដាម៉ៃយ៉ាន ទើតាពី ជូហ្គា ឡាំបាំង គើសេទីយ៉ាអាន ជិនតា);*

**-- pos** /មើរ(r)ប៉ាទី ប៉ុស(s)/ ព្រាបនាំសារ:

*ព្រាបនាំសារបានក្លាយទៅជាវិធីផ្តល់ពត៌មានដ៏មានប្រយោជន៍នៅក្នុងសង្គ្រាម merpati pos telah menjadi cara mengantarkan informasi yang sangat berguna dalam perang (មើរ(r)ប៉ាទី ប៉ុស(ស) ទើឡះ មើនច្យាឌិ ចារ៉ា មើង៉ាន់តារ(r)កាន់ អ៊ីនហ្វូរ(r)ម៉ាស៊ី យ៉ាំង សាង៉ាត់ បឺរ(r)ហ្គូណា ដាឡាំ ពើរ៉ាំង)*

**mertua** /មើរ(r)ទូវ៉ា/ *n* ឪពុកម្តាយក្មេក:

*ខ្ញុំសូមណែនាំនេះគឺជាម្តាយក្មេករបស់ខ្ញុំ perkenalkan, ini ibu mertua saya (ពើរ(r)គើណាល់កាន់ អ៊ីនី អ៊ីប៊ូ មើរ(r)ទូវ៉ា សាយ៉ា)*

**mesin** /មើស៊ីន/ *n* ម៉ាស៊ីន:

*ម៉ាស៊ីនកត់អវត្តមានគឺជាឧបករណ៍មួយដែលចាំបាច់ត្រូវតែមាននៅក្នុងការិយាល័យ mesin absensi merupakan salah satu perangkat wajib di perkantoran (មើស៊ីន អាប់សេនស៊ី មើរូប៉ាកាន់ សាឡះ សាទូ ពើរ៉ាំងកាត់ វ៉ាជិប ឌិ ពើរ(r)កាន់តូរ៉ាន់);*

**-- cuci** /មើស៊ីន ជូជី/ ម៉ាស៊ីនបោកគក់:

*លោកឪពុកកំពុងតែជួសជុលម៉ាស៊ីនបោកគក់ដែលខូច ayah sedang membetulkan mesin cuci yang rusak (អាយ៉ះ សឺដាំង មើមប៊ឺទុលកាន់ មែស៊ីន ជូជី យ៉ាំង រូសាក់);*

**-- tik** /មើស៊ីន ទិក/ ម៉ាស៊ីនអង្គុលីលេខ:

*ហាងនេះមានលក់គ្រប់ម៉ាក់នូវម៉ាស៊ីនអង្គុលីលេខអេឡិចត្រូនិចនិងមិនមែនអេឡិចត្រូនិចដែលមានគុណភាពអាចធានាបាន toko itu menyediakan berbagai macam mesin tik manual maupun elektronik dengan kualitas yang terjamin (តូកូ អ៊ីទូ មើញ៉ើឌីយ៉ាកាន់ បឺរ(r)បាហ្គៃ ម៉ាចាំ មែស៊ីន តើទីគ ម៉ានូវ៉ាល់ ម៉ាវពុន អេឡិគត្រូនិគ ឌើង៉ាន់ គូវ៉ាលីតាស់(ស) យ៉ាំង ទើរ(r)ច្យាមីន)*

**meski** /មើស្គី/ *pron* សូម្បីតែ; ទោះបីតែ:

*ទោះបីជាខ្ញុំឈឺក៏ខ្ញុំនៅតែទៅធ្វើការ meski*

*sakit, saya tetap berangkat kerja (ម៉េស្គី សាគិត សាយ៉ា ទើតាប់ ប៊ឺរ៉ាំងកាត់ គើរ(r)ចា្យ)*

**meskipun** /មើស(s)គីពុន/ *p* ទោះបីជា: *ទោះបីជានឿយហត់ គាត់នៅតែស្វាហាប់ធ្វើការងារ meskipun lelah, dia masih tetap semangat untuk bekerja (មើស(s)គីពុន លើឡាស់, ឌីយ៉ា ម៉ាសីស ទើតាប់ សើម៉ាងាត់ អុនតុ ពើគើរ(r)ចា)*

**mesra** /ម៉េស្រា/ *a* ជិតស្និទ្ធ: *ទំនាក់ទំនងរបស់ពួកខ្ញុំលែងជិតស្និទ្ធទៀតហើយ hubungan kami sudah tidak mesra lagi (ហ៊ូប៊ូង៉ាន់ កាមី ស៊ូដះទីដាក់ ម៉េស្រា ឡាហ្គិ);*

**bermesraan** /ប៊ើរ(r)ម៉េស្រា/ *v* ស្និទ្ធស្នាល: *ពួកគេមិនស្និទ្ធស្នាលនៅមុខសាធារណៈជននោះទេ mereka tidak segan bermesraan di depan umum (មើរេកា ទីដាក់ សើហ្គាន់ ប៊ើរ(r)ម៉េស្រាអាន ឌិ ឌើប៉ាន់ អ៊ូមុម);*

**kemesraan** /គើម៉េស្រាអាន/ *n* ភាពស្និទ្ធស្នាល:

**mesti** /មើស្ទី/ *adv* ត្រូវតែ: *អ្នកត្រូវតែចូលរួមជប់លៀង kamu mesti datang ke pesta itu! (កាម៉ូ មើស្ទី ដាតាំង គើ ប៉េស្តា អ៊ីទូ!)*

**mewah** /មេវះ/ *a* អស្ចារ្យ: *ការរស់នៅបែបទាន់សម័យ gaya hidup mewah (ហ្គាយ៉ា ហ៊ីឌុព មើវះ);*

**kemewahan** /គើមេវាហាន់/ *n* ភាពអស្ចារ្យ: *ភាពស៊ីវិល័យមិនទាន់ប្រាកដថាមានសុភមង្គលនោះទេ kemewahan tidak menjamin kebahagiaan (គើមេវ៉ាហាន់ ទីដាក់មើនចា្យមីន គើបាហាគីយ៉ាអាន)*

**mi** /មី/ *n* មី: *ទោះជាយ៉ាងណាក៏ដោយ មីស្រស់មិនអាចជំនួសបាយបានទេ bagaimanapun mi instan tidak bisa menggantikan makan penuh (បាហ្គៃម៉ាណាពុន មីអ៊ិនស្តាន់ ទីដាក់ប៊ីសា មើងហ្គាន់ទីកាន់ មាកាន់ ពើនុះ)*

**miliar** /មីលីយ៉ារ(r)/ *num* កោដ: *រដ្ឋាភិបាលបានរៀបចំកញ្ចប់ថវិការាប់កោដរូពីយ៉ះ ដើម្បីផ្ដល់បន្ទប់ពិសោធន៍ដល់សាលារៀនតាមតំបន់ដាច់ស្រយាល pemerintah telah menganggarkan miliaran rupiah untuk pengadaan laboratorium di sekolah-sekolah terpencil (ពើមើរិនតះ ទើឡះម៉េ ម៉ាំងហ្គារ(r)កាន់ មីលីយ៉ារ៉ាន់ រូពីយ៉ះ អ៊ុនទុក ពើង៉ាដាអាន ឡាបូរ៉ាតូរីយូម ឌិ ស៊េកូឡះ–ស៊េកូឡះ ទើរប៉ិនជីល)*

**milik** /មីលីក/ *n* កម្មសិទ្ធ: *កម្មសិទ្ធផ្ទាល់ខ្លួន milik pribadi (មីលីក ព្រីបាឌី);*

**kepemilikan** /គើពើមីលីកាន់/ *n* ម្ចាស់: *ម្ចាស់ផ្ទះ kepemilikan rumah (គើពើមីលីកាន់);*

**memiliki** /មើមីលីគី/ *v* មាន: *គាត់មានបងស្រីស្អាតណាស់ dia memiliki kakak perempuan yang sangat cantik (ឌីយ៉ា មើមីលីគី កាកាក ពើរ៉ំពូវ៉ាន់ យ៉ាំង សាងាត់ ចាន់ទីក)*

**mimbar** /មិមប៉ារ(r)/ *n* វេទិកា: *វាគ្មិនកំពុងផ្ដល់នូវបទបង្ហាញរបស់គាត់នៅលើវេទិកា pembicara sedang memberikan presentasinya di mimbar (ពើមប៊ីចារ៉ា សើដាំង មើមបើរីកាន់ ប្រេសិនតាស៊ីញ៉ា ឌិ ម៉ិមបារ)*

**mimpi** /មិមពី/ *n* សុបិន្ត: *សុបិន្តដែលមិនដែលក្លាយជាការពិត mimpi yang tak pernah jadi nyata (មិមពី យ៉ាំង ទីដាក់ ពើរ(r)ណះ ចាឌិ ញ៉ាតា);*

**bermimpi** /បើរ(r)មិមពី/ *v* យល់សុបិន្ត: *ខ្ញុំយល់សប្តិឃើញពស់ចឹកខ្ញុំ saya bermimpi digigit ular (សាយ៉ា បើរ(r)មិមពី ឌិហ្គីហ្គិត អ៊ូឡារ(r))*

**minat** /មីណាត់/ *n* ចាប់អារម្មណ៍: *គាត់មានការចាប់អារម្មណ៍ខ្លាំងណាស់ក្នុងការគូររូប dia memiliki minat yang tinggi dalam karya seni (ឌីយ៉ា មើមីលិកគី មីណាត់ យ៉ាំង ទីងហ្គី ដាឡាម ការ(r)យ៉ា សើនី);*

**berminat** /បើរ(r)មីណាត់/ *v* មានចំណាប់អារម្មណ៍: *តើអ្នកចាប់អារម្មណ៍ពីកីឡាទេ? apakah Anda berminat di bidang olahraga? (អាប៉ាកះ អានដា បើរ(r)មីណាត់ ឌិប៊ីដាំង អូឡះរ៉ាហ្គា?)*

**peminat** /ពើមីណាត់/ *n* អ្នកចូលចិត្ត: *ចំនួនអ្នកដែលចូលចិត្តព្រឹត្តិការណ៍នោះខុសពីការរំពឹងទុក jumlah peminat acara*

*itu di luar perkiraan (ដូចឡុះ ពើមីណាត់អាចារ៉ា អ៊ីទូ ឌិ លូវ៉ារ(r) ពើរ(r)គីរ៉ាអាន)*

**minggu, mingguan** /មីងហ្គូវ៉ាន់/ *n* សប្ដាហ៍: *គាត់កំពុងដើរផ្សារពេលចុងសប្ដាហ៍ ibu sedang belanja mingguan (អ៊ីប៊ូ សើដាំង ពើឡាន់ចា មីងហ្គូវ៉ាន់)*

**minta, meminta** /មើមីនតា/ *v* សុំ: *សុំការភ័យទោស meminta maaf (មើមីនតា ម៉ាអាហ្វ);*

**permintaan** /ពើរ(r) មីនតាអាន់/ *n* សំណើរ: *ខ្ញុំមិនអាចផ្ដល់តាមសំណើររបស់គាត់ទេ aku tidak dapat mengabulkan permintaannya (អាគូ ទីដាក់ ដាប៉ាត់ មើង៉ាប៊ុលកាន់ ពើរ(r) មីនតាអាន់ញ៉ា)*

**minum** /មីនុម/ *v* ផឹក: *អ្នកត្រូវតែផឹកទឹកបរិសុទ្ធ kamu harus minum air mineral (កាមូ ហារូស(s) មីនុម អៃយើរ មីនើរ៉ាល់);*

**minuman** /មីនូម៉ាន់/ *n* ភេសជ្ជៈ: *ពួកខ្ញុំចង់កាម្មង់ភេសជ្ជៈ kami ingin memesan minuman (កាមី អ៊ីងីន មើមើសាន់ មីនូម៉ាន់)*

**minyak** /មីញ៉ាក់/ *n* ខ្លាញ់: *ខ្ញុំមិនអាចញុំាអាហារដែលមានជាតិខ្លាញ់ទេ saya tidak mengonsumsi minyak (សាយ៉ា ទីដាក់ មើងុនស៊ុមស៊ី មីញ៉ាក់);*

**-- wangi** /មីញ៉ាក់ វ៉ាំងី/ ទឹកអប់: *ទឹកអប់នេះក្លិនក្រអូបណាស់ minyak wangi ini baunya enak (មីញ៉ាក់ វ៉ាងី អ៊ីនី បាវអ៊ូញ៉ា អៃណាក់)*

**miring** /មីរិង/ *a* ផ្អៀង; ទ្រេត: *សូមប្រយ័ត្នកម្រាលនេះផ្អៀង hati-hati, lantai ini miring! (ហាទី–ហាទី ឡាន់តៃ អ៊ីនី មីរិង)*

**mirip** /មីរីប/ *a* ស្រដៀង: *គាត់ស្រដៀងនឹងប្អូនប្រុសគាត់ណាស់ dia sangat mirip dengan adik laki-lakinya (ឌីយ៉ា សាងាត់ មីរីប ទើងាន់ អាឌីក ឡាគី ឡាគីញ៉ា)*

**misa** /មីសា/ *n* ចំ: *ចំថ្ងៃអាទិត្យ misa minggu (មីសា មីងហ្គូ)*

**miskin** /មីស្គីន/ *a* ក្រីក្រ: *ប្រជាជនក្រីក្រ orang miskin (អូរ៉ាំង មីស្គីន)*

**mitra** /មិត្រា/ *n* ដៃគូ;

**-- bisnis** /មិត្រា ប៊ីស្នីស(s)/ ដៃគូពាណិជ្ជកម្ម:

*យើងឧស្សាហ៍ជួបដៃគូពាណិជ្ជកម្មនៅហាងកាហ្វេ kami sering bertemu dengan mitra bisnis di kedai kopi (កាមី សឺរីង បើរ(r)ទើមូ ឌើង៉ាន់ មីត្រា ប៊ីស្នីស(s) ឌិ គើដៃ កូពី);*

**-- kerja** /មិត្រា គើរ(r)ច្យា/ សហការី: *ហ្វើហាន ជាដៃគូការងារមួយរបស់ខ្ញុំនៅការិយាល័យ Farhan adalah salah satu mitra kerja saya di kantor (ហ្វារ(r)ហាន់ អាដាឡះ សាឡះ សាទូ មិត្រា គើរ(r)ច្យា សាយ៉ា ឌិ កាន់តូរ)*

**mobil** /មូប៊ីល/ *n* **1** ឡាន: *ឡានដឹកអូស mobil derek (មូប៊ីល ដេរ៉េក);* **2** រថយន្ត: *រថយន្តជួល mobil sewaan (មូប៊ីល សេវ៉ាអាន់)*

**modal** /ម៉ូដាល់/ *n* ដើមទុន: *ទុនវិនិយោគ modal investasi (ម៉ូដាល់ អ៊ិនវ៉េស្តាស៊ី);*

**-- asing** /ម៉ូដាល់ អាស៊ីង/ ភាគហ៊ុនបរទេស: *រដ្ឋាភិបាលជម្រុញអ្នកវិនិយោគក្រៅប្រទេសដើម្បីបង្កើនទុនបរទេស pemerintah mendorong investor luar negeri untuk menambah modal asing (ពើមើរិនតះ មើនដូរ៉ុង អ៊ិនវ៉េសតូរ(r) លូអារ(r)នើហ្គើរី អ៊ុនទុក មើណាំបះ ម៉ូដាល់ អាស៊ីង);*

**pemodal** /ពើម៉ូដាល/ *n* អ្នកវិនិយោគ: *អ្នកវិនិយោគបរទេស pemodal asing (ពើម៉ូដាល់ អាស៊ីង)*

**moga, semoga** /ស៊ើម៉ូហ្គា/ *adv* សង្ឃឹមថា: *ខ្ញុំសង្ឃឹមថាខ្ញុំនឹងប្រលងជាប់ semoga saya lulus ujian (ស៊ើម៉ូហ្គា សាយ៉ា លូលុស(s) អ៊ូជីយ៉ាន)*

**mogok** /ម៉ូហ្គុក/ *v* ឈប់ដំណើរការ: ម៉ាស៊ីនឡានរបស់ខ្ញុំឈប់ដំណើរការ mesin mobilku mogok (មើស៊ិន ម៉ូប៊ីលគូ ម៉ូហ្គុក);

**-- kerja** /ម៉ូហ្គុក គើរ(r)ច្យា/ ឈប់ធ្វើការ: *កម្មករនាំគ្នាធ្វើកូដកម្មថ្ងៃនេះ para buruh melakukan mogok kerja hari ini (ប៉ារ៉ា ប៊ូរុះ មើឡាគូកាន់ ម៉ូហ្គុក គើរ(r)ច្យា ហារី អ៊ីនី);*

**-- makan** /ម៉ូហ្គុក ម៉ាកាន់/ ធ្វើកូដកម្មអត់អាហារ: *គាត់មិនញ៉ាំបាយបីថ្ងៃហើយ ia sudah tiga hari mogok makan (យ៉ា ស៊ូដះ ទីហ្គា ហារី ម៉ូហ្គុក ម៉ាកាន)*

**mohon, mohon maaf** /ម៉ូហុន ម៉ាអាហ្វ/ សូមអភ័យទោស: *ខ្ញុំសុំទោសចំពោះការមកយឺត saya mohon maaf karena datang terlambat (សាយ៉ា ម៉ូហុន ម៉ាអាហ្វ ការ៉េណា ទើរ(r)ឡាំបាត់);*

**permohonan** /ពើរ (r) មូហូណាន់/ *n* **1** ស្នើរសុំ: *ស្នើរសុំវីសា permohonan visa (ពើរ (r) មូហូណាន់ ហ្វីសា);* **2** ការសុំ: *ការសុំអភ័យទោស permohonan maaf (ពើរ (r) មូហូណាន់ ម៉ាអាហ្វ)*

**mondar-mandir**/ម៉ុនដារ(r)-ម៉ាន់ឌិរ(r)/ *v* មើលឆ្វេងស្តាំ: *ចោរលួចនោះបានសំឡឹងមើលឆ្វេងស្តាំជុំវិញផ្ទះមុនពេលធ្វើសកម្មភាព pencuri itu sempat mondar-mandir di depan rumah itu sebelum melakukan aksinya (ពើនជូរី អ៊ីទូ សឹមប៉ាត់ ម៉ុនដារ(r)-ម៉ាន់ឌីរ(r) ឌិ ឌើប៉ាន់ រូម៉ះ សឺបឺលុម មើឡាគូកាន់អាក់ស៊ីញ៉ា។ )*

**motel** /មូតែល/ *n* សណ្ឋាគារ: *តើអ្នកអាចផ្តល់យោបល់ពីសណ្ឋាគារផ្សេងទៀតបានទេ? dapatkah Anda merekomendasikan motel lain? (ដាប៉ាត់កាស់ អាន់ដា មើរេកូមិនដាស៊ីកាន់ មូតែល ឡៃន?)*

**motor** /ម៉ូតូរ(r)/ *n* **1** ម៉ាស៊ីន: *ការត្រួតពិនិត្យម៉ាស៊ីនម៉ូតូត្រូវធ្វើឡើងរៀងរាល់ខែ perawatan mesin motor itu dilakukan setiap bulan (ពើរ៉ាវ៉ាតាន់ មើស៊ីនមូតូរ(r) អ៊ីទូ ឌិឡាគូកាន់ សឺទីយ៉ាប ប៊ូឡាន់);* **2** ម៉ូតូ: *ម៉ូតូនោះមិនឆេះទេ motor itu tidak dapat dinyalakan (មូតូរ(r) អ៊ីទូ ទីដាក់ ដាប៉ាត់ ឌីញ៉ាឡាកាន់);*

**-- balap** /ម៉ូតូរ(r) បាឡាប់/ ម៉ូតូប្រណាំង: *ក្មេងនោះសុំឪពុកម្តាយឲ្យទិញម៉ូប្រណាំងអោយគេ anak itu minta dibelikan motor balap kepada orang tuanya (អាណាក់អ៊ីទូ មិនតា ឌិបឺលីកាន់ ម៉ូតូរ(r) បាឡាប់ គើប៉ាដា អូរ៉ាំង ទូវ៉ាញ៉ា។);*

**-- bebek** /ម៉ូតូរ បេបិក/ ម៉ូតូ: *ចំនួនម៉ូតូកូនទាបានកើនឡើងយ៉ាងនៅឥណ្ឌូនេស៊ីជារៀងរាល់ឆ្នាំ jumlah motor bebek bertambah secara signifikan di Indonesia setiap tahunnya (ជូមឡះ ម៉ូតូរ(r) បែបិក បឺរ(r)តាំបះ សឺចារ៉ា ស៊ិកនីហ្វីកាន់ ឌិ ឥណ្ឌូនេស៊ីយ៉ា សឺទីយ៉ាប តាហ៊ុន។ )*

**muara** /មូរ៉ារ៉ា/ *n* មាត់; ជាយ

**muat, bermuatan** /ប៊ើរ(r)មូវ៉ាតាន់/ *v* ត្រូវបានផ្ទុកជាមួយ: *ឡាននោះអាចផ្ទុកបានខ្សាច់ និងថ្ម truk itu bermuatan pasir dan batu (ទ្រុក អ៊ីទូ ប៊ឺមូវ៉ាតាន់ ប៉ាស៊ីរ(r) ដាន់ បាទូ);*

**memuat** /មើមូវ៉ាត់/ *v* ផ្ទុក: *កម្មករបានប្រមូលរបស់របរដាក់ក្នុងឃ្លាំង para pekerja memuat barang-barang ke gudang (ប៉ារ៉ា ពើគើរ(r)ចា្យ មើមូវ៉ាត បារ៉ាំង–បារ៉ាំង គើ ហ្គូដាំង។);*

**muatan** /មូវ៉ាតាន់/ *n* ផ្ទុក: *ការដឹកជញ្ជូនទំនិញនាំចេញ muatan ekspor (មួតាន់ អែកស្ប័រ)*

**muda** /មូដា/ *a* **1** ក្មេង; យុវវ័យ: *អ្នកជំនួញវ័យក្មេង pengusaha muda (ពើងូសាហា មូដា);* **2** ខ្ចី: *ពណ៌បៃតងខ្ចី hijau muda (ហ៊ីចូ្យវ មូដា);*

**pemuda** /ពើមូដា/ *n* យុវជន: *ចលនាយុវជននៅឥណ្ឌូនេស៊ីចាប់ផ្ដើមក្នុងទស្សវត្សឆ្នាំ ១៩២០ gerakan pemuda di Indonesia dimulai sejak tahun 1920-an (ហ្គើរ៉ាកាន់ ពើមូដា ឌិ ឥណ្ឌូនេស៊ីយ៉ា ឌិមូឡាំ សឺចា្យក់ តាហ៊ុន ស៊ីរីប៊ូ សឹមប៊ីឡាន់ រ៉ាទូសាន់។)*

**mudah** /មូដះ/ *a* ងាយស្រួល: *សំណួរគណិតវិទ្យាពិតជាមហាស្រួលសម្រាប់ខ្ញុំ kuis matematika itu terlalu mudah bagiku (គូវិស(s) ម៉ាទើម៉ាទីកា អ៊ីទូ ទើរ(r)ឡាលូ មូដះ បាហ្គីគូ។);*

**mudah-mudahan** /មូដះ–មូដាហាន់/ *adv* សង្ឃឹមថា: *សង្ឃឹមថាគាត់នឹងមកដល់ទាន់ពេល mudah-mudahan dia datang tepat waktu (មូដះ–មូដាហាន់ ឌីយ៉ាដាតាំង ទើប៉ាត់ វ៉ាក់ទូ។)*

**mudi, kemudi** /គើមូឌិ/ *n* អ្នកបើកបរ: *ដោយសារតែងងុយគេង អ្នកបើកបរនោះមិនអាចគ្រប់គ្រងការបើកបរបាន karena mengantuk, pengemudi itu tidak mampu mengendalikan kemudinya (កាផើណា មើង៉ាន់ទុក ពើងើមូឌី អ៊ីទូ ទីដាក់មុាំងពូ មើងើនដាលីកាន់ គើមូឌីញ៉ា។)*

**mujarab** /មូចា្យរ៉ាប់/ *a* ប្រសិទ្ធិភាព: *ថ្នាំនោះមានប្រសិទ្ធិភាពណាស់ obat itu cukup mujarab (អូបាត់ អ៊ីទី ជូគុប មូចា្យរ៉ាប់។)*

**mujur** /មូជូរ/ *a* សំណាង: *គាត់ជាមនុស្សមានសំណាង ia orang yang sangat mujur (យ៉ា អូរ៉ាំង យ៉ាំង សាង៉ាត់ មូជូរ(r))*

**muka, bermuka dua** /បើរ(r)មូកា ឌូវ៉ា/ *v* លាក់ពុត: *សកម្មជនបរិស្ថានបានរិះគន់រដ្ឋាភិបាលក្នុងតំបន់ដែលមានចរិកលាក់ពុត kaum aktivis lingkungan mengkritisi pemimpin daerah yang bermuda dua (កាអ៊ុម អាក់ទីហ្វីស(s) លិងគូង៉ាន់ មើងគ្រីទិក ពើមិមពិន ដាអេរះ យ៉ាំង បឺរ(r)មូកាឌូវ៉ា។);*

**pemuka** /ពើមូកា/ *n* អ្នកដឹកនាំ: *អ្នកដឹកនាំសាសនា pemuka agama (ពើមូកា អាហ្កាម៉ា);*

**permukaan** /ពើរ(r) មូកាអាន់/ *n* ផ្ទៃ: *ផ្ទៃសមុទ្រ permukaan laut (ពើរ(r) មូកាអាន់ ឡាអ៊ូត)*

**mukim, bermukim** /បើរ(r)មូគីម/ *v* រស់នៅ: *អ្នកភូមិនោះជាទូទៅរស់នៅជុំវិញជម្រាលនៃភ្នំភ្លើងនេះ penduduk desa itu umumnya bermukim di sekitar lereng gunung api (ពើនឌូឌុក ដេសា អ៊ីទូ អ៊ូមុមញ៉ា បឺរ(r)មូគិម ឌិ សឺគីតារ(r) ឡេរ៉េង ហ្គូនុង អាពី);*

**permukiman** /ពើរ((r)មូគីម៉ាន់/ *n* តំបន់លំនៅដ្ឋាន

**mula, mula-mula** /មូឡា-មូឡា/ *adv* ដំបូង: *ដំបូងឡើយ យើងខ្ញុំជឿលើអ្នកនោះមុនពេលគាត់យកឡានក្រុមហ៊ុនរត់ mula-mula kami percaya saja dengan orang itu sebelum dia membawa lari mobil kantor (មូឡា-មូឡា កាមី ពើរ(r)ចាយ៉ា សាចា្យ ឌើង៉ាន់ អូរ៉ាំង អ៊ីទូ ស៊ើបើលុម ឌីយ៉ា មើមបាវ៉ា ឡារី ម៉ូប៊ីល កាន់តូរ។);*

**pemula** /ពើមូឡា/ *n* អ្នកដំបូង: *ដំណាក់កាលដំបូង tingkat pemula (ទិងកាត់ ពើមូឡា);*

**permulaan** /ពើរមូឡាអាន/ *n* ចាប់ផ្តើម: *ខ្ញុំមិនបានតាមដានស្តាប់ការបង្ហាត់បង្រៀននោះតាំងពីដំបូង saya tidak mengikuti ceramah itu dari permulaan (សាយ៉ា ទីដាក់ មើងីគូទី ជើរ៉ាម៉ះ អ៊ីទី ដារី ពើរ(r)មូឡាអាន។)*

**mulai** /ម៉ូឡៃ/ *v* ចាប់ផ្ដើម: *ថ្នាក់រៀននឹងចាប់ផ្ដើមឆាប់ៗ pelajaran akan segera dimulai (ពើឡាចារ៉ាន់ អាកាន់ ស៊ើហ្គើរ៉ា ឌីម៉ូឡៃ)*

**mulas** /មូឡាស់(s)/ *a* ឈឺក្រពះ: *ខ្ញុំឈឺក្រពះ perutku mulas (ពើរុតគូ មូឡាស់(s))*

**mulia** /មូលីយ៉ា/ *a* ល្អថ្លៃថ្នូ: *គាត់មានបេះដូងដ៏ល្អថ្លៃថ្នូ hati pria itu sungguh mulia (ហាទី ព្រីយ៉ា អ៊ីទូ ស៊ុងហ្គុះ មូលីយ៉ា។)*

**mulus** /មូលុស(s)/ *a* រលូន; រលោង: *នាងមានស្បែករលោង kulitnya mulus (គូលីតញ៉ា មូលុស(s))*

**mulut** /ម៉ូលុត/ *n* មាត់: *មាត់មានពិស mulut berbisa (ម៉ូលុត ពើរ(r) ពីសា)*

**muncul** /មុនជុល/ *v* លេចឡើង: *គ្រាប់មុនបានលេចឡើងនៅលើថ្ពាល់គាត់ muncul jerawat di pipinya (មុនជុល ចេរ៉ាវ៉ាត់ ឌី ពីពីញ៉ា)*

**mundur** /មុនឌួរ(r)/ *v* ថយក្រោយ: *ទៅមុខថយក្រោយ maju mundur (ម៉ាជូ មុនឌួរ(r))*

**mungil** /មូងីល/ *a* តូច: *កូនឆ្កែនោះតូចណាស់ anak anjing itu sangat mungil (អាណាក់ អាន់ជិង អ៊ីទូ សាង៉ាត់ មូងីល។)*

**mungkin** /មុងគីន/ *adv* ប្រហែលជា: *ប្រហែលជាគាត់នឹងមកទទួលអ្នក mungkin dia akan menjemputmu (មុងគីន ឌីយ៉ា អាកាន់ មិនជឹមពុតម៉ូ)*

**mungkir, memungkiri** /មើមុងគីរី/ *v* បដិសេធ: *សូមកុំបដិសេធទង្វើរបស់អ្នក jangan memungkiri perbuatanmu (ចាង៉ាន់ មើមុងគីរី ពើប៊ូវ៉ាតាន់មូ។)*

**muntah** /មុនតះ/ *v* ក្អួត

**murah** /ម៉ូរ៉ះ/ *a* ថោក: *សម្លៀកបំពាក់តម្លៃថោក baju murah (ប៉ៃជូ ម៉ូរ៉ះ);*

**-- hati** /មូរះ ហាទី/ ចិត្តល្អ; ចិត្តសប្បុរស: *ចូរធ្វើចិត្តឲ្យទូលាយសម្រាប់មនុស្សទូទៅ murah hatilah pada sesama (មូរះ ហាទីឡះ ប៉ាដា សឺសាម៉ា។);*

**-- meriah** /មូរះ មើរីយ៉ះ/ ថោក: *សំលៀកបំពាក់ដែលលក់នៅផ្សារតាមបែបប្រពៃណី ច្រើនតែមានតម្លៃថោក pakaian yang dijual di pasar tradisional biasanya murah meriah*

*(ប៉ាកែយ៉ាន យ៉ាំង ឌិជួវ៉ាល ឌិ ប៉ាសារ(r) ត្រាឌិស្សណាល់ ប៊ីយ៉ាសាញ៉ា មូរ៉ះ មើរិយ៉ះ។);*

**-- rezeki** /មូរ៉ះ រេហ្សិគី/ សំណាង: *អ្នកដែលតែងតែជួយដល់អ្នកដទៃ ច្រើនតែទទួលបានចំណូលជាហូរហែរវិញដែរ orang yang sering membantu sesama biasanya murah rezeki (អូរ៉ាំង យ៉ាំង សើរិង មើមបាន់ទូ សឹសាម៉ា ប៊ីយ៉ាសាញ៉ា មូរ៉ះ រេហ្សិគី);*

**-- senyum** /មូរ៉ះស៊ើញូម/ ញញឹមរួសរាយ: *ក្មេងដែលតែងតែញញឹមគឺមានមិត្តភក្តិច្រើន anak yang murah senyum banyak temannya (អាណាក់ យ៉ាំង មូរ៉ះ ស៊ើញូម បាញ៉ាក់ ទើម៉ាន់ញ៉ា។);*

**murahan** /មូរ៉ះ/ *a* ថោក: *អ្នកលក់ម្នាក់នោះឲ្យទំនិញមានតម្លៃថោកដល់ខ្ញុំ penjual itu memberikan barang murahan padaku (ពើនជួវ៉ាល អ៊ីទូ មើមប៊ើរីកាន់ បារ៉ាំង មូរ៉ាហាន់ ប៉ាដាគូ)*

**muram** /មូរ៉ាំ/ *a* ស្រពោន: *មុខគាត់មើលទៅស្រពោនណាស់ថ្ងៃនេះ wajahnya tampak muram hari ini (វ៉ាចាហ្វះញ៉ា តាំប៉ាក់ មូរ៉ាំ ហារី អ៊ីនី។)*

**murid** /ម៉ូរីត/ *n* សិស្ស: *សិស្សឆ្លាត murid pandai (ម៉ូរីត ប៉ាន់ដៃ)*

**murka, kemurkaan** /គើមូកាវ៉ាន់/ *n* កំហឹង: *គាត់មានការខឹងសម្បាយ៉ាងខ្លាំងដោយសារគោរបស់គាត់ត្រូវបានគេលួច dia murka mendapati sapinya dicuri orang (ឌីយ៉ា មូរ(r)កា មើនដាប៉ាទី សាពីញ៉ា ឌិជូរី អូរ៉ាំង។)*

**murni** /ម៉ុរ(r)នី/ *a* បរិសុទ្ធ; សុទ្ធ: *មាសសុទ្ធ emas murni (អេម៉ាស់(s) ម៉ុរ(r)នី)*

**murung** /មូរុង/ *a* មិនសប្បាយចិត្ត: *ដោយសារតែប្រលងមិនជាប់ កូនម្នាក់នោះមើលទៅមិនសប្បាយចិត្តសោះ karena tidak lulus ujian, anak itu tampak murung (ការរើណា ទីដាក់ លូលុស(ស) អ៊ូជីយ៉ាន អាណាក់ អ៊ីទូ តាំប៉ាក់ មូរុង។)*

**museum** /ម៉ូសេយូម/ *n* សារមន្ទីរ: *សារមន្ទីរប្រវត្តិសាស្ត្រ museum sejarah (ម៉ូសេយូម សើចារ៉ាស់)*

**musim** /មូស៊ីម/ *n* រដូវ: *តំបន់ត្រូពិចមានតែរដូវ២ប៉ុណ្ណោះ គឺរដូវក្តៅ និងរដូវភ្លៀង daerah tropis hanya memiliki dua musim, panas dan hujan (ដាអេរ៉ះ ត្រូពិស(s) ហាញ៉ា មើមីលីគី ឌូវ៉ា មូស៊ីម ប៉ាណាស់(ស) ដាន់*

*ហូច្យាន់។); រដូវភ្លៀង musim hujan (មូស៊ីម ហ៊ូច្យាន់); រដូវស្លឹកឈើជ្រុះ musim gugur (មូស៊ីម ហ្គូហ្គូរ(r));*

**-- kemarau** /មូស៊ិម គើម៉ារ៉ាវ/

រដូវរាំងស្ងួត: *រដូវក្តៅធ្វើឲ្យអណ្តូងខ្លះរីងស្ងួត musim kemarau membuat beberapa sumur kekeringan (មូស៊ីម គើម៉ាដ៉ៅ មើមប៊ូអ៉ាត បើបើរ៉ាប៉ា ស៊ូមបើរ(r) គើគើរីង៉ាន់។);*

**-- liburan** /មូស៊ិម លីប៊ូរ៉ាន់/

ពេលវិស្សមកាល: *សាលារៀនយើងខ្ញុំបានសម្រេចថាទៅលេងសួនសត្វនៅពេលវិស្សមកាល sekolah kami memutuskan untuk mengunjungi kebun binatang pada musim liburan (សើកូឡះ កាមី មើមូទុស្កាន់ អ៊ុនទុក មើង៉ុនជូងី គើប៊ុន ប៊ីណាតាំង ប៉ាដា មូស៊ីម លីប៊ូរ៉ាន់។);*

**-- pancaroba** /មុស៊ិម ប៉ាន់ចារ៉ូបា/

ប្តូរអាកាសធាតុ: *ប្រជាពលរដ្ឋជាច្រើនបានធ្លាក់ខ្លួនឈឺនៅពេលផ្លាស់ប្តូរអាកាសធាតុ banyak penduduk yg jatuh sakit ketika musim pancaroba (បាញ៉ាក់ ពើនឌូឌុក យ៉ាំង ច្យាទុះ សាគិត គើទីកា មូស៊ិម ប៉ាន់ចារ៉ូបា។)*

**musnah** /មូស្នះ/ *v* បំផ្លាញ: *ការតាំងទីលំនៅត្រូវបានបំផ្លាញដោយភ្លើងឆេះ permukiman itu musnah dilalap api (ពើរមូគីម៉ាន់អ៊ីទី មុស្នះ ឌិឡាឡាប់ អាពី។);*

**memusnahkan** /មើមូស្នះកាន់/ *v* បំផ្លាញ: *ក្រុមហ៊ុននោះមានគំនិតបំផ្លាញរាល់ឯកសារសំខាន់ៗរបស់ក្រុមហ៊ុន perusahaan itu berniat memusnakan semua dokumen penting perusahaan (ពើរូសាហាអាន អ៊ីទូ បើរ(r) នីយ៉ាត មើមូស្នះកាន់ ស៊ើមូវ៉ា ដុគូម៉េន់ ប៉ិនទិង ពើរូសាហាអាន។)*

**mustahil** /មូស្តាហីល/ *a* មិនអាច: *មិនអាចទេដែលធ្វើការងារនោះក្នុងរយៈពេល១យប់ប៉ុណ្ណោះ mustahil baginya mengerjakan tugas itu dalam satu malam (មូស្តាហីល បាហ្គីញ៉ា មើជើរ(r)ច្យាកាន់ ទូហ្គាស់(s) អ៊ីទូ ដាឡាម សាត់ទូ ម៉ាឡាម។)*

**musuh** /មូស៊ុះ/ *n* សត្រូវ: *ភាពភ័យខ្លាចជាសត្រូវចម្បងសម្រាប់យើង ketakutan adalah musuh utama kita (គើតាគូតាន់ អាដាឡះ មុស៊ុះ អ៊ូតាម៉ា គីតា។);*

**-- bebuyutan** /មូស៊ុះ បើប៊ូយូតាន់/ ដៃគូប្រឆាំង: *ក្លឹបបាល់ទាត់រៀលម៉ាទ្រីតជាដៃគូរប្រឆាំងស្លាប់រស់របស់បាសេឡូណា klub sepakbola Real Madrid merupakan musuh bebuyutan Barcelona (ក្លឹប សេប៉ាក់បូឡា Real Madrid មើរូប៉ាកាន់ មុសុះ គើប៊ូយូតាន់ បាសែឡូណា។);*

**bermusuhan** /បើរ(r)មូស៊ូហាន់/ *v* ឈ្លោះប្រកែកគ្នា: *គ្រូតែងតែហាមឃាត់កូនសិស្សមិនឲ្យឈ្លោះប្រកែកគ្នា guru selalu melarang muridnya untuk bermusuhan satu sama lain (ហ្គូរូ សើឡាលូ មើឡារ៉ាំង មូរីតញ៉ា អ៊ុនទុក បឺរ(r)មូស៊ូហាន់ សាទូ សាម៉ា ឡាអ៊ិន។);*

**memusuhi** /មើមូស៊ូហ៊ី/ *v* ប្រឆាំង: *យើងមិនត្រូវឈ្លោះប្រឆាំងគ្នាជាមួយគ្រួសារយើងខ្លួនឯងនោះទេ kita tidak boleh memusuhi keluarga kita sendiri (គីតា ទីដាក់ បូឡិះ មើមូស៊ូហ៊ី គើលូអ៉ារ(r)ហ្គា គីតា សឺនឌិរី។);*

**permusuhan** /ពើរ(r)មូស៊ូហាន់/ *n* ការប្រកួតប្រជែង: *ការប្រកួតប្រជែងរវាងកីឡាករប្រណាំងទាំងពីរនោះត្រូវបានបញ្ចប់ permusuhan antara kedua pembalap itu akhirnya dapat diselesaikan (ពើរ(r)មូសូហាន់អាន់តារ៉ា គើឌូវ៉ា ពើមបាឡាប់ អ៊ីទូ អាក់ហឺរ(r)ញ៉ា ដាប៉ាត់ ឌិសើលើសៃកាន់។)*

**mutakhir** /មូតាក់ហ៊ីរ(r)/ *a* ទំនើបចុងក្រោយ: *បច្ចេកវិទ្យាទំនើបចុងក្រោយ teknologi mutakhir (តិកណូឡូហ្គី មូតាក់ហ៊ីរ(r))*

**mutiara** /មូទីយ៉ារ៉ា/ *n* គុជខ្យង: *គុជខ្យងជាគ្រឿងលម្អរដ៏មានតម្លៃសម្រាប់នារីៗ mutiara merupakan perhiasan berharga yang digemari kaum wanita (មូទីយ៉ារ៉ា មើរូប៉ាកាន់ ពើរ(r)ហ៊ីយ៉ាសាន់ បើរ(r)ហារ(r)ហ្គា យ៉ាំង ឌិហ្គើម៉ារី កាអ៊ុម វ៉ានីតា។)*

**mutlak** /មូត្លាក់/ *a* ដាច់ខាត: *ច្បាប់ដាច់ខាត hukum mutlak (ហ៊ូគុម មុត្លាក់)*

**mutu** /មូទូ/ *n* គុណភាព: *ស្តង់ដារគុណភាព standar mutu (ស្តាន់ដារ(r) មូទូ)*

**nabati** /ណាបាទី/ *a* បន្លែ: *ខ្លាញ់ដែលចេញពីបន្លែ lemak nabati (លើម៉ាក់ ណាបាទី)*

**nada** /ណាដា/ *n* **1** សម្លេង: *សម្លេងរោទ៍ nada dering (ណាដា ដើរីង); សម្លេងរោទ៍ nada panggil (ណាដា ប៉ាង់ហ្គីល)*; **2** ខល: ហៅ: *សម្លេង ខល រង់ចាំ nada sela (ណាដា សេឡា);*

**-- dasar** /ណាដា ដាសារ(r)/ សុន្ទរកថា: *នៅក្នុងក្រុម G សន្ទរកថា គឺស្ដីពី G pada G mayor, nada dasarnya adalah G (ប៉ាដា G (ហ្គេ) ម៉ាយ៉ូរ(r) ណាដា ដាសារ(r) អាដាឡះ ហ្គេ (G));*

**senada** /ស៊ើណាដា/ *a* ស្រដៀង: *ពួកគេមានបញ្ហាស្រដៀងគ្នា mereka memiliki masalah yang senada (មើរេកា មើមីលិគី ម៉ាសាឡះ យ៉ាំង សើណាដា។)*

**nadi** /ណាឌិ/ *n* ជីពចរ: *វេជ្ជបណ្ឌិតកំពុងតែពីនិត្យជីបចរអ្នក ជម្ងឺ dokter sedang memeriksa denyut nadi pasiennya (ដុកតូរ(r) សើដាំង មើមើរិកសា ឌើញុត ណាឌី ប៉ាស៊ីយ៉ាន)*

**nafkah** /ណាហ្វ កះ/ *n* **1** ចំណូល: *ការចំណាយប្រចាំខែរបស់គាត់ច្រើនជាង ចំណូលប្រចាំខែ pengeluaran bulanannya melebihi nafkah yang dia terima (ពើងើលូវ៉ារ៉ាន់ ប៊ូឡាណាន់ញ៉ា មើលើប៊ីហី ណាហ្វកះ យ៉ាំង យ៉ា ទើរីម៉ា)*; **2** ការរស់នៅ: *គាត់ទៅបរទេស ដើម្បីចិញ្ចឹមជីវិតរស់នៅ dia pergi ke luar negeri untuk mencari nafkah (ឌីយ៉ា ពើរ(r)ហ្គី គើ លូវ៉ារ(r) នើហ្គើរី អ៊ុនទុក មើនចារី ណាហ្វកះ);*

**menafkahi** /មើណាហ្វកះហី/ *v* ផ្គត់ផ្គង់: *ក្មេងតូចនោះត្រូវផ្គត់ផ្គង់គ្រួសារវាទាំងមូល anak kecil itu harus menafkahi seluruh keluarganya (អាណាក់ គើជីល អ៊ីទូ ហារុស(s) មើណាហ្វកាហី ស៊ើលូរុះ គើលូវ៉ាហ្កា*

**nafsu** /ណាហ្វស៊ូ/ *n* ចំណង់: *អ្នកនោះមានចំណង់ខ្លាំងណាស់ ដើម្បីក្លាយទៅជាអ្នកដែលមានអំណាច នក្នុងភូមិ orang itu memiliki nafsu yang kuat untuk menjadi penguasa di kampungnya*

*(អូរ៉ាំង អ៊ីទូ មើមីលិគី ណាហ្វស៊ូ យ៉ាំង គូវ៉ាត់ អ៊ុនទុក មើនច្បាឌិ ពើង្ហសាហា ឌិ កាំពុងញ៉ា);*

**-- amarah** /ណាហ្វស៊ូ អាម៉ារះ/ កំហឹង: *កំហឹងរបស់គាត់បាន ផ្ទុះឡើង nafsu amarahnya meledak (ណាហ្វស៊ូ អាម៉ារះញ៉ា មើលើដាក់);*

**bernafsu** /ប៊ើរ(r)ណាហ្វស៊ូ/ *v* មានចំណង់: *ខ្ញុំគ្មានចំណង់ញ៉ាំការ៉េមទេ aku tidak bernafsu makan es krim (អាគូ ទីដាក់ ប៊ើរ(r)ណាហ្វស៊ូ ម៉ាកាន់ អ៊ែស្រ្គីម)*

**naga** /ណាហ្គា/ *n* នាគ: *នាគគឺជាសត្វទេវកថា naga adalah makhluk mitologi (ណាហ្គា អាដាឡះ ម៉ាក់លុក មីតូឡូហ្គី)*

**nahas** /ណាហាស់(s)/ *a* សំណាងមិនល្អ: *គាត់ពិតជាសំណាងមិនល្អមែនថ្ងៃនេះ sungguh nahas dia hari ini (ស៊ុងហ្គុះ ណាហះ ឌីយ៉ា ហារី អ៊ីនី)*

**naif** /ណាអ៊ីវ/ *a* ឆោតល្ងង់: *អាកប្បកិរិយាគាត់ដែលតែងតែការពារក្រុមកម្មករ ត្រូវបានបណ្ដាក្រុមនិយោជកមើលឃើញថាឆោតល្ងង់ sikapnya yang sering membela kaum buruh dianggap naif oleh para pengusaha (ស៊ីកាប់ញ៉ា យ៉ាំង សើរីង មើមបេឡា កាអ៊ុម ប៊ូរុះ ឌិអាំងកាប់ ណាអ៊ីហ្វ អូលេះ ប៉ារ៉ា ពើង្ហសាហា)*

[1]**naik** /ណៃ/ *v* កើនឡើង: *ចំណូលរបស់ គាត់ កើនឡើង ជារៀង រាល់ឆ្នាំ pendapatannya naik setiap tahun (ពិនដាប៉ាត់តាន់ញ៉ា ណៃ សេទីយ៉ាប តាហ៊ុន)*

[2]**naik** /ណាអ៊ីក/ *v* **1** ឡើង: *នាងឡើងដើមឈើ dia naik ke atas pohon (ឌីយ៉ា ណាអ៊ិក គើ អាតាស់(s) ប៉ូហុន។)*; **2** រះឡើង: *ព្រះអាទិត្យរះឡើងនាពេលព្រឹក matahari mulai naik di pagi hari (ម៉ាតា ហារី មូឡៃ ណាអ៊ិក ឌិប៉ាហ្គី ហារី។)*; **3** ឡើងជិះ: *តោះ ឡើងជិះឡាន ayo, naik ke mobil (អាយ៉ូ ណាអ៊ិក គើម៉ូប៊ីល។)*; **4** ជិះ: *នាងជិះកង់របស់នាងទៅសាលា រៀនរាល់ថ្ងៃ dia naik sepeda ke sekolah setiap hari (ឌីយ៉ា ណាអ៊ិក ស៊ើពេដា គើ ស៊ើកូឡះ ស៊ើទីយ៉ាប ហារី។;*

**-- kelas** /ណាអ៊ីក គើឡាស់(s)/ *v* ឡើងថ្នាក់: *ឪពុកម្ដាយខ្ញុំទិញហ្គីតាឱ្យខ្ញុំ ព្រោះខ្ញុំឡើងថ្នាក់ orang tuaku membelikanku gitar karena aku naik kelas*

*(អ្នុាំង ទូវ៉ាតូ មើមបើលីកាន់តូ ហ្គីតារ(r) កាមីណា អាគូ ណាអ៊ីក តើឡូះ);*

**-- turun** /ណាអ៊ីក ទូរុន/ *v* ឡើងចុះ: *គាត់រត់ឡើងចុះដំបូក* *dia berlari naik turun bukit (ឌីយ៉ា បើរ(r)ឡារី ណាអ៊ីក ទូរុន ប៊ូគិត។);*

**-- banding** /ណាអ៊ីក បាន់ឌិង/ បណ្ដឹងឧទ្ធរណ៍: *បុរសដែលគេកាត់ក្ដីខុសពីបទឧក្រិដ្ឋសម្លាប់មនុស្ស បានសម្រេចចិត្តបណ្ដឹងឧទ្ធរណ៍* *pria yang salah dituduh membunuh itu memutuskan untuk naik banding (ព្រីយ៉ា យ៉ាំង សាឡះ ឌិទូឌុះ មើមប៊ូនុះ អ៊ីទូ មើមូទុស្កាន់ អ៊ុនទុក ណាអ៊ីក បាន់ឌិង។);*

**-- cetak** /ណាអ៊ីក ជើតាក់/ តំឡើងពុម្ព: *សៀវភៅដែលអ្នកបានកម្ម៉ង់ មិនទាន់បានតំឡើងពុម្ពទេ* *buku yang kau pesan belum naik cetak (ប៊ូគូ យ៉ាំង កូវ ពើសាន់ បើលុម ណាអ៊ីក ជើតាក់។);*

**-- pitam** /ណាអ៊ីក ពីតាំ/ ខឹង: *បុរសនោះបានខឹង* *pria itu naik pitam (ព្រីយ៉ា អ៊ីទូ ណាអ៊ីក ពីតាំ);*

**-- takhta** /ណាអ៊ីក តះតា/ ឲ្យឡើងសោយរាជ: *ស៊ុលតាន់ ហាសានូឌិន បានឡើងសោយរាជ ជាស្ដេច ហ្គូវ៉ា ក្នុងឆ្នាំ ១៩៥៣ ជំនួស ស៊ុលតាន់ ម៉ូហាំម៉ាត់ សាអ៊ីត* *Sultan Hasanuddin naik takhta sebagai raja Gowa pada tahun 1653 menggantikan Sultan Muhammad Said (ស៊ុលតាន់ ហាសាន់ នូឌិន ណាអ៊ីក តាក់(ខ)តា ស៊ើបាហ្គៃ រ៉ាឡា ហ្គូវ៉ា ប៉ាដា តាហ៊ុន ស៊ើរីប៊ូ អឺណាម រ៉ាទុស(s) លីម៉ា ពូលូ ទីហ្គា មើងហ្គាន់ទីកាន់ ស៊ុលតាន់ ម៉ូហាម៉ាត់ សាអ៊ិដ);*

**kenaikan** /គើណាអ៊ីកាន់/ *n* ការបង្កើន: *ការបង្កើនព្យាការី* *kenaikan nabi (គើណាអ៊ីកាន់ ណាប៊ី);*

**menaiki** /មើណាអ៊ីគី/ *v* ឡើង: *អ្នកពន្លត់អគ្គីភ័យ បានឡើងលើជណ្ដើរ ដើម្បីជួយក្មេងស្រីតូចដែលក្នុងអគ្គីភ័យ* *pemadam kebakaran itu menaiki tangga untuk menolong gadis kecil yang terjebak di kebakaran (ពើម៉ាដាំម៉ាន់ គើបាកាវ៉ាន់ អ៊ីទូ មើណាអ៊ិគី*

*តាំងហ្កា អ៊ុនទុក មើណូឡុង ហ្កាឌិស(s) គើជីល យ៉ាំង ទើរជើបាក់ ឌិ គើបាកាវ៉ាន់);*

**menaikkan** /មើណៃកាន់/ *v* **1** ឡើង: *លើក ទង់*; **2** បង្កើន: *អ្នកគ្រប់គ្រង់គាត់បានបង្កើនឋានៈគាត់ក្នុងតួនាទីដែលមានឥទ្ធិពល atasannya menaikkan dia ke posisi yang berpengaruh (អាតាសាន់ញ៉ា មើណាអ៊ិកាន់ ឌីយ៉ា គើប៉ូស៊ីស៊ី យ៉ាំង បើរពើង៉ារុះ។)*; **3** លើកឡើង: *កូនៗនោះជួយឪពុកម្តាយពួកគេលើងឥវ៉ាន់ឡើងរថយន្ត anak-anak itu membantu orang tua mereka menaikkan barang-barang ke mobil (អាណាក់–អាណាក់ អ៊ីទី មើមបាន់ទូ អូរ៉ាំង ទូវ៉ា មើរេកា មើណាអ៊ីកាន់ បារ៉ាំង គើ ម៉ូប៊ីល។)*

**nakal** /ណាកាល់/ *a* ខូច; ច្រឡើម: *ក្មេងច្រឡើម anak nakal (អាណាក់ ណាកាល់);*

**kenakalan remaja** /គើណាកាឡាន់ ររ៉ាចា/ ក្មេងទំនើង; ក្មេងខូច: *គ្រួសារ និងបរិស្ថានជុំវិញជាឧទាហរណ៍២ដែលជាកត្តានាំឲ្យក្លាយជាក្មេងទំនើង keluarga dan lingkungan merupakan dua contoh faktor yang dapat menyebabkan kenakalan remaja (គើលូវ៉ារ(r)ហ្កា ដាន់ លិងហ្គូង៉ាន់ មើរូប៉ាកាន់ ឌូវ៉ា ចុនតុះ ហ្វាក់តូរ យ៉ាំង ដាប៉ាត់ មើញើបាប់កាន់ គើណាកាឡាន់ ររ៉ាចា)*

**nakhoda** /ណាខូដា/ *n* ប្រធានក្រុម: *គាត់ត្រូវបានគេតំឡើងជាប្រធានក្រុមកប៉ាល់ថ្មី dia diangkat sebagai nakhoda kapal yang baru (ឌីយ៉ា ឌិអាំងកាត់ សើបាហ្កៃ ណាខូតា កាប៉ាល់ យ៉ាំង បារូ);*

**menakhodai** /មើណាខូដៃ/ *v* រុករក: *ការរុករកនេះនឹងក្លាយជាបទពិសោធន៍ដំបូងរបស់គាត់ក្នុងការបើកបរកប៉ាល់ pelayaran ini akan menjadi pengalaman pertamanya menakhodai kapal (ពើឡាយ៉ារ៉ាន់ អ៊ីនី អាកាន់ មើនច្បាឌិ ពើង៉ាឡាម៉ាន់ ពើរ(r)តាម៉ាញ៉ា មើណាក់ខូដៃ កាប៉ាល់)*

**nalar** /ណាឡារ(r)/ *n* ហេតុផល: *ការគិតដែលមានហេតុផល berpikir dengan nalar (បើរ(r)ពីហ្គីរ(r) ឌើង៉ាន់ ណាឡារ(r)។);*

**bernalar** /បឺរ(r)ណាឡារ(r)/

*v* ហេតុផល:

*ការសរសេរជាដំណើរការដែលមានហេតុផល*

*menulis adalah proses bernalar (មើនូលិស(s) អាដាឡះ*

*ប្រូសែស(ស) បឺរ(r)ណាឡារ);*

**penalaran** /ពើណាឡារ៉ាន់/

*n* ផែកញែក: *ការផែកញែករបស់គាត់*

*មិនអាចទទួលយកបានដោយក្រុមការងារគាត់*

*penalarannya tidak diterima oleh rekan-rekannya (ពើណាឡារ(r)ញ៉ា ទីដាក់ ឌិទើរីម៉ា អូលេះ*

*រើកាន់–រើកាន់ញ៉ា)*

**naluri** /ណាលូរ(r)/ *n* វិញ្ញាណ; អារម្មណ៍:

*អារម្មណ៍ខ្ញុំ បានប្រាប់ខ្ញុំថានាងមិនកុហកទេ*

*naluriku mengatakan bahwa dia tidak berbohong (ណាលូរីគូ*

*មើង៉ាតាកាន់ បះវ៉ា ឌីយ៉ា ទីដាក់ បើរបូហុង)*

**naluriah** /ណាលូរីយ៉ះ/ *a* វិចារណៈញាណ:

*ការឆ្លើយតបដោយវិចារណៈញាណ respon*

*naluriah (រេស្ពោន ណាលូរីយ៉ះ)*

**nama** /ណាម៉ា/ *n* ឈ្មោះ *នាម; ឈ្មោះ*

*nama depan (ណាម៉ា ឌើប៉ាន់):*

*គោត្តនាម; ឈ្មោះឪពុក nama*

*keluarga (ណាម៉ា គើលូអាហ្គា);*

*ឈ្មោះពេញ nama lengkap (ណាម៉ា*

*ឡើងកាប់); ឈ្មោះហៅក្រៅ nama*

*panggilan (ណាម៉ា ប៉ាង់គីល);*

**-- dagang** /ណាម៉ា ដាហ្កាំង/

ឈ្មោះអាជីវកម្ម: *ឈ្មោះអាជីវកម្ម*

*យកល្អគួរតែចុះបញ្ជី nama dagang*

*sebaiknya didaftarkan (ណាម៉ា*

*ដាហ្កាំង សើបាលិកញ៉ា ឌិដាហ្វតារ(r)កាន់);*

**-- diri** /ណាម៉ា ឌិរី/ ឈ្មោះផ្ទាល់ខ្លួន:

*ឈ្មោះដែលល្អ អាចជាឈ្មោះមនុស្ស ឬ ស្ថាប័ន*

*nama diri dapat berupa nama orang atau organisasi (ណាម៉ា ឌិរី ដាប៉ាត់ បើរូប៉ា ណាម៉ា អូរ៉ាំង*

*អាតៅ អ៊ួរ(r)ហ្កានីសាស៊ី);*

**-- samaran** /ណាម៉ា សាម៉ារ៉ាន់/

ឈ្មោះក្លែងក្លាយ: *អ្នកនិពន្ធជាច្រើន*

*បានប្រើឈ្មោះក្លែងក្លាយ banyak*

*penulis menggunakan nama samaran (បាញ៉ាក់ ពើនូលិស(s)*

*មើងហ្គូណាកាន់ ណាម៉ា សាម៉ារ៉ាន់។);*

**kenamaan** /គើណាម៉ាអាន/

*a* ល្បីល្បាញ:

*នាងបានទិញសំលៀកបំពាក់ពីអ្នករចនាម៉ូតដ៏ល្បីល្បាញ* *dia membeli gaun karya seorang desainer kenamaan* (*ឌីយ៉ា មើមបើលី ហ្គាអ៊ុន ការ(r)យ៉ា សើអូរ៉ាំង ដេសាអ៊ីណើរ(r) គើណាម៉ាអាន*);

**ternama** /ទើរ(r)ណាម៉ា/

*v* ល្បីល្បាញ: *សិល្បៈករដ៏ល្បីល្បាញ* *aktor ternama* (*អាក់តូរ(r) ទើរ(r)ណាម៉ា*)

**nampan** /ណាំប៉ាន់/ *n* ថាស: *ថាសតែ* *nampan teh* (*ណាំប៉ាន់ តែះ*)

**namun** /ណាមុន/ *p* ប៉ុន្តែ; ទោះជាយ៉ាងណាក៏ដោយ:

*ខ្ញុំចង់ទៅមើលកុនជាមួយមិត្តភក្តិ ប៉ុន្តែខ្ញុំមិនទាន់បានរួចរាល់ការងារផ្ទះខ្ញុំ* *aku ingin pergi ke bioskop bersama teman-temanku, namun aku belum menyelesaikan pekerjaan rumahku* (*អាគូ អ៊ីងិន ពើរ(r)ហ្គី គើ ប៊ីយ៉ូស្កុប បើរ(r)សាម៉ា ទើម៉ាន់–ទើម៉ាន់គូ, អាគូ បើលុម មើញេលើសៃកាន់ ពើគើរ(r)ចាអាន រូមះគូ*)

**nanah** /ណាណះ/ *n* ខ្ទុះ

*របួសជង្គង់គាត់បានចេញឈាម និង ខ្ទុះ* *luka di lututnya mengeluarkan darah dan nanah* (*លូកា ឌិ ឡូទុតញ៉ា មើងើលូអារ(r)កាន់ ដារះ ដាន់ ណាណះ*)

**nanti** /ណាន់ទី/ *n* ពេលក្រោយ; ក្រោយមក:

*ប្រហែលជាគាត់មកដល់ពេលក្រោយ* *mungkin nanti dia akan datang* (*មុងគិន ណាន់ទី ឌីយ៉ា អាកាន់ ដាតាំង*);

**menanti** /មើណាន់ទី/ *v* រង់ចាំ:

*ខ្ញុំរង់ចាំអ្នករយៈពេល២ម៉ោងហើយ* *aku menantimu selama dua jam* (*អាគូ មើណាន់ទិមូ សើឡាម៉ា ឌូវ៉ា ចាំ*);

**nantinya** /ណាន់ទីញ៉ា/ *n* បន្ទាប់មក:

*បន្ទាប់មក គាត់នឹងប្រាប់ការពិតដល់យើង* *nantinya, dia pasti akan memberi tahu kita kebenarannya* (*ណាន់ទីញ៉ា ឌីយ៉ា ប៉ាស្ទី អាកាន់ មើមបើរីតាអ៊ូ គីតា គើបើរ(r)ណារ៉ាន់ញ៉ា*);

**penantian** /ពើណាន់ទីយ៉ាន់/

*n* ការរងចាំ:

*v* **1** ក្បែរ; ចំហៀង: *គាត់ដើរក្បែរមាត់ស្ទឹង dia berjalan menyamping sungai (ឌីយ៉ា បឺរ(r)ច្យាឡាន់ មើញ៉ាំពិង ស៊ូង៉ៃ);*

**2** ចំហៀង: *លោតទៅចំហៀង lompatan menyamping (ឡុមប៉ាតាន់ មើញ៉ាំពីង );*

**sampingan** /សាំពីង៉ាន់/ *n* បន្ទាប់បន្សំ: *ដើម្បីបំពេញតម្រូវការប្រចាំថ្ងៃ គាត់ក៏បានចាប់យកការងារបន្ទាប់បន្សំ untuk memenuhi kebutuhan sehari-hari dia juga mengambil pekerjaan sampingan (អ៊ុនទុក មើមើនូហ៊ី គើប៊ូទុះហាន់ សឺហារី-ហារី ឌីយ៉ា ជូហ្គាមើងម៉ាំប៊ីល ពើគើរ(r)ច្យាអាន់ សាំពីង៉ាន់)*

**sampul** /សាំពុល/ *n* គ្របដណ្ដប់; *គ្រប គ្របសៀវភៅ sampul buku (សាំពុល ប៊ូគូ);*

**-- buku** /សាំពុល ប៊ូគូ/ គ្របសៀវភៅ: *គ្របសៀវភៅនោះស្អាតណាស់ sampul buku itu indah (សាំពុល ប៊ូគូ អ៊ីទូ អ៊ីនដះ);*

**bersampul** /បឺរ(r)សាំពុល/

*v* មានគ្រប: *សៀវភៅប្អូនមានគ្របព័ណ៌ខៀវ buku adik bersampul biru (ប៊ូគូ អាឌិគ បឺរ(r)សាំពុល ប៊ីរូ);*

**menyampul** /មើញ៉ាំពុល/

*v* ដាក់គ្រប; ដាក់ស្រោម: *លេខាកំពុងតែដាក់ស្រោមសំបុត្រដែលនឹងត្រូវផ្ញើរ sekretaris sedang menyampul surat-surat yang akan dikirimnya (សេរ៉ើគ្រេតារីស(ស) សឺដាំង មើញ៉ាំពុល ស៊ូរ៉ាត់-ស៊ូរ៉ាត់ យ៉ាំង អាកាន់ ឌិគីរីមញ៉ា)*

**samudra** /សាមូដ្រា/ *n* **1** មហាសាគរ; មហាសមុទ្រ: *ប្រជុំកោះឥណ្ឌូនេស៊ីត្រូវបានហ៊ុំព័ទ្ធដោយមហាសមុទ្រប៉ាស៊ីហ្វិច និងមហាសមុទ្រឥណ្ឌា*

*kepulauan Indonesia diapit oleh samudra Pasifik dan samudra Hindia (គើពូឡៅវ៉ាន់ ឥណ្ឌូនេស៊ីយ៉ា ឌិអាពិត អូលេះ សាមូដ្រា ប៉ាស៊ីហ្វិត ដាន់ សាមូដ្រា ឥណ្ឌូនេស៊ីយ៉ា)*; **2** ធំ: *ទូលាយ ការប្រជុំធមតែងតែប្រារព្ធធ្វើឡើងនៅឯទីលានដ្ឋានធំ* rapat samudra sering *diselenggarakan di stadion utama (រ៉ាប៉ាត់ សាមូដ្រា សឺរិង ឌិសឺឡឹងហ្គារ៉ាកាន់ ឌិ ស្តាឌីយូន អ៊ូតាម៉ា)*

**sana** /សាណា/ *pron* ទីនោះ: *ពួកគេមានទីលំនៅនៅទីនោះ mereka bertempat tinggal di sana (មើរេកា ប៊ឺរ(r)តឹមប៉ាត់ ទីងហ្គាល់ ឌិ សាណា)*

**sanak, sanak saudara** /សាណាក់ សៅដារ៉ា/ *n* គ្រួសារ; សាច់ញាតិ

**sandal** /សាន់ដាល់/ *n* ស្បែកជើង: *ម៉ែប្រើស្បែកជើងថ្មី ibu memakai sandal baru (អ៊ីប៊ូ មើម៉ាកៃ សាន់ដាល់ បារូ)*

**sandar, bersandar** /ប៊ឺរ(r)សាន់ដាល់/ *v* **1** ពឹងផ្អែកលើ: *កុំពឹងផ្អែកនឹងជញ្ជាំងចាស់នោះពេកអី jangan bersandar pada dinding yang sudah tua itu (ចាំងង៉ាន់ ប៊ឺរ(r)សាន់ដាល់ ប៉ាដា ឌិនឌិង យ៉ាំង ស៊ូដះ ទូវ៉ា អ៊ីទូ )*; **2** ចង; រំពឹងលើ: *ចំណតកប៉ាល់ bersandar di dermaga (ប៊ឺរ(r)សាន់ដារ(r) ឌិ ឌើរ(r)ម៉ាហ្គា)*; រំពឹងលើ: *កុំរំពឹងលើជំនួយរដ្ឋាភិបាលពេក jangan terlalu banyak bersandar pada bantuan pemerintah (ចាំងង៉ាន់ ទើរ(r)ឡាលូ បាញ៉ាក់ ប៊ឺរ(r)សាន់ដារ(r) ប៉ាដា បានទូវ៉ាន)*;

**menyandarkan** /មើញ៉ាន់ដារ(r)កាន់/ *v* **1** ដាក់: *គាត់ដាក់កង់របស់គាត់នឹងរបង dia menyandarkan sepedanya ke pagar (ឌីយ៉ា មើញ៉ាន់ដារ(r)កាន់ សឺពេដាញ៉ា គើ ប៉ាហ្គារ(r))*; **2** រំពឹងលើ: *មនុស្សជាច្រើនរំពឹងអនាគតរបស់គេលើចំណេះដឹង banyak orang menyandarkan masa depannya pada pendidikan (បាញ៉ាក់ អូរ៉ាំង មើនញ៉ាន់ដារ(r)កាន់ ម៉ាសា ឌើប៉ាន់ញ៉ា ប៉ាដា ពើនឌិឌិកាន់)*

**sandera** /សាន់ឌើរ៉ា/ *n* ចំណាប់ខ្មាំង: *នៅប្រទេសហ្វីលីពីនក្នុងឆ្នាំ 2000 កុមារសិស្សសាលាមួយចំនួនត្រូវបានចាប់និងយកជាចំណាប់ខ្មាំង di Filipina tahun 2000 sejumlah anak sekolah*

*diculik dan dijadikan sandera (ឌិ ហ្គូលីពីនណា តាហ៊ុន ឌូវ៉ារីប៊ូ សឺជូមឡះ អាណាក់ សឺកូឡះ ឌិជូលិគ ដាន់ ឌិច្យាឌិកាន់ សានដេរ៉ា);*

**menyandera** /មើញ៉ាន់ឌើរ៉ា/ *v* ចំណាប់ខ្មាំង: *ពួកគេចាប់ក្មេងៗសិស្សសាលាជាចំណាប់ខ្មាំង mereka menyandera anak-anak sekolah (មើរេកា មើញ៉ាន់ដេរ៉ា អាណាក់-អាណាក់ សឺកូឡះ);*

**penyandera** /ពើញ៉ាន់ឌើរ៉ា/ *n* អ្នកចាប់ចំណាប់ខ្មាំង: *អ្នកចាប់ចំណាប់ខ្មាំងជាបុរសចំណាស់ penyanderanya seorang laki-laki tua (ពើញ៉ានដេរ៉ាញ៉ា សឺអូរ៉ាំង ឡាគី-ឡាគី ទូវ៉ា);*

**penyanderaan** /ពើញ៉ាន់ឌើរ៉ាអាន/ *n* ការដាក់ពន្ធនាគារដោយសារបំណុល: *ការចាប់ចំណាប់ខ្មាំងកើតឡើងនៅក្នុងអាការចាស់ penyanderaan terjadi di gedung tua (ពើញ៉ានដេរ៉ាអាន់ ទើរ(r)ច្យាឌិ ឌិ ហ្គើឌួង ទូវ៉ា)*

**sandiwara** /សាន់ឌិវ៉ារ៉ា/ *n* លេង: *យើងខ្ញុំចូលចិត្តទៅមើលភាពយន្ត kami suka pergi nonton sandiwara (កាមី ស៊ូកា ពើរ(r)ហ្គី ណុនតុន សានឌីវ៉ារ៉ា);*

**-- radio** /សាន់ឌិវ៉ារ៉ា រ៉ាឌិយ៉ូ/ កម្មវិធីវិទ្យុ: *រឿងនោះបានយកមកប្រើសម្រាប់កម្មវិធីវិទ្យុ cerita itu dijadikan sandiwara radio (ចឺរីតា អ៊ីទូ ឌិច្យាឌិកាន់ សាន់ឌិវ៉ារ៉ា រ៉ាឌិយ៉ូ);*

**bersandiwara** /ប៊ឺរ(r)សានឌិវ៉ារ៉ា/ *v* សំដែង: *គាត់សំដែងនៅឯរោងភាពយន្តដោយចំហរ ia bermain sandiwara di teater terbuka (អ៊ីយ៉ា ប៊ឺរ(r)ម៉ាអ៊ីន សាន់ឌិវ៉ារ៉ា ឌិ ទៀទើរ(r) ទើរ(r)ប៊ូកាក់);*

**menyandiwarakan** /មើញ៉ាន់ឌិវ៉ារ៉ាកាន់/ *v* **1** សំដែង: *គាត់កំពុងសំដែងរឿងសង្គម ia sedang menyandiwarakan sebuah cerita rakyat (អ៊ីយ៉ា សឺដាំង មើញ៉ាន់ឌិវ៉ារ៉ាកាន់ សឺប៊ូវ៉ះ ចឺរីតា រ៉ាក់យ៉ាត់)*; **2** វិនាដកម្ម: *អ្នកនិពន្ធនោះកំពុងរៀបចំសំដែងរឿងសង្គម pengarang itu sedang menyandiwarakan cerita rakyat (ពើង៉ារ៉ាំង អ៊ីទូ សឺដាំង មើញ៉ាន់ឌិវ៉ារ៉ាកាន់ ចឺរីតា រ៉ាក់យ៉ាត់)*

**sandung, sandungan** /សាន់ឌូង៉ាន់/ *n* ជំពប់ជើង: *ជំពប់ជើងដួល batu sandungan (បាទូ សាន់ឌូង៉ាន់*

**sangat** /សាង៉ាត់/ *adv* ណាស់: *ស្អាតណាស់ sangat cantik (សាង៉ាត់ ចាន់ទិក)*

**sanggup** /សាំងហ្គុប/ *v* អាច មានលទ្ធភាព: *គាត់មានលទ្ធភាពសងបំណុលគាត់ dia sanggup melunasi utangnya (ឌីយ៉ា សាំងហ្គុប មើលូណាស៊ី អ៊ូតាំងញ៉ា); ខ្ញុំអាចធ្វើកិច្ចការនោះបាន saya sanggup menunaikan tugas itu (សាយ៉ា សាំងហ្គុប មើនូណៃអ៊ីកាន់ ទូហ្គាស់ អ៊ីទូ);*

**kesanggupan** /គើសាំងហ្គូប៉ាន់/ *n* លទ្ធភាព: *លទ្ធភាពរបស់ខ្ញុំត្រឹមតែប៉ុណ្ណឹង kesanggupan saya hanya itu (គើសាំងហ្គូប៉ាន់ សាយ៉ា ហាញ៉ា អ៊ីទូ);*

**menyanggupi** /មើញ៉ាំងហ្គូពី/ *v* **1** កិច្ចការ: *គាត់អាចនឹងមក ia menyanggupi akan datang (អ៊ីយ៉ា មើញ៉ាំងហ្គូពី អាកាន់ ដាតាំង ); **2*** អាច: *ប្រសិនបើមិនអាច កុំសន្យាអី kalau tidak sanggup jangan berjanji (កាឡៅវ ទីដាក់ សាំងហ្គុប ចា្យង៉ាន់ បឺរ(r)ចា្យន់ជី)*

**sangka, menyangka** /មើញ៉ាំងកា/ *v* សង្ស័យ: *គាត់សង្ស័យថាខ្ញុំបានប្រព្រឹត្តិអ្វីខុស dia menyangka saya telah berbuat salah (ឌីយ៉ា មើញ៉ាំងកា សាយ៉ា ទើឡះ បឺរ(r)ប៊ូវ៉ាត់ សាឡះ); ប៉ូលីសសង្ស័យថាក្មេងម្នាក់នោះលួចម៉ូតូ polisi menyangka pemuda itu mencuri motor (ប៉ូលីស៊ី មើញ៉ាំងកា ពើម៉ូដា អ៊ីទូ មិនជូរី ម៉ូទរ(r))*

**sangka, tersangka** /ទើរ(r)សាំងកា/ *v* សង្ស័យ: *ជនសង្ស័យទាំងពីរនាក់បានសារភាពកំហុសរបស់ខ្លួន kedua tersangka sudah mengakui kesalahannya (គើឌូវ៉ា ទើរ(r)សាំងកា ស៊ូដះ មើង៉ាគូវី គើសាឡះហាន់ញ៉ា)*

**sangkal, menyangkal** /មើញ៉ាំងកាល់/ *v* បដិសេធ:s *គាត់បានបដិសេធការចោទប្រកាន់នោះ dia menyangkal tuduhan itu (ឌីយ៉ា មើញ៉ាំងកាល់ ទូឌូហាន់ អ៊ីទូ);*

**sangkalan** /សាំងកាឡាន់/ *n* ការបដិសេធ: *ការបដិសេធនោះសមហេតុផល sangkalan itu masuk akal (សាំងកាឡាន់ អ៊ីទូ ម៉ាស៊ុត អាកាល់)*

**sangkut, sangkut paut** /សាងគុត ប៉ាអ៊ុត/ *n* ទំនាក់ទំនង: *ខ្ញុំគ្មានទំនាក់ទំនងនៅក្នុងរឿងនេះ saya tidak ada sangkut*

*pautnya dengan perkara ini (សាយ៉ា ទីដាក់ អាដា សាំងគុត ប៉ាអ៊ុតញ៉ា ឌើង៉ាន់ ពើរ(r)កាវ៉ា អ៊ីនី);*

**bersangkutan** /ប៊ើរ(r)សាំងគូតាន់/ *v* មានទំនាក់ទំនង: *បញ្ហានោះមានទំនាក់ទំនងនឹងអតីតកាល perkara itu bersangkutan dengan masa lalunya (ពើរ(r)កាវ៉ា អ៊ីទូ ប៊ើរ(r)សាំងគូតាន់ ឌើង៉ាន់ ម៉ាសា ឡាលូញ៉ា);*

**menyangkut** /មើញ៉ាំងគុត/ *v* **1** ទំនាក់ទំនង: *ការពិភាក្សារបស់ពួកយើងគ្មានទំនាក់ទំនងនឹងរឿងហិរញ្ញវត្ថុទេ pembicaraan kami tidak menyangkut masalah uang (ពើមប៊ីចារ៉ាអាន កាមី ទីដាក់ មើញ៉ាំងគុត ម៉ាសាឡះ អ៊ួរ៉ាំង)*; **2** ទាក់; ទំពួក: *ខ្លែងរបស់ខ្ញុំបានទាក់នឹងបង្គោលភ្លើង layang-layangku menyangkut di tiang listrik (ឡាយ៉ាំង-ឡាយ៉ាំងគូ មើញ៉ាំងគុត ឌិ ទៀង លីស្ទ្រីក);*

**tersangkut** /ទើ(r)សាំងគុត/ *v* ចូលរួម: *គាត់បានចូលរួមក្នុងរឿងពុករលួយ dia tersangkut dalam skandal korupsi (ឌីយ៉ា ទើ(r)សាំងគុត ដាឡាំ ស្កានដាល់ ក្ករុពស៊ី)*

**sangsi** /សាងស៊ី/ *a* មិនច្បាស់: *ខ្ញុំមិនច្បាស់ថាគាត់អាចធ្វើការងារនោះ saya sangsi apakah dia bisa mengerjakan pekerjaan itu (សាយ៉ា សាំងស៊ី អាប៉ាកះ ឌីយ៉ា ប៊ីសា មើងើរ(r)ចាកាន់ ពើគើរ(r)ចាអាន់ អ៊ីទូ);*

**kesangsian** /គើសាំងស៊ីយ៉ាន់/ *n* មិនច្បាស់: *គ្មានអ្វីមិនច្បាស់ទៀតទេពីបញ្ហានោះ tidak ada kesangsian lagi tentang hal itu (ទីដាក់ អាដា គើសាំងស៊ីយ៉ាន ឡាហ្គី តិនតាំង ហាល់ អ៊ីទូ);*

**menyangsikan** /មើញ៉ាំងស៊ីកាន់/ *v* មិនជឿជាក់: *គាត់មិនជឿជាក់លើសមត្ថភាពខ្ញុំ dia menyangsikan kemampuan saya (ឌីយ៉ា មើញ៉ាំងស៊ីកាន់ គឹម៉ាំពូវ៉ាន សាយ៉ា)*

**santai** /សាន់តៃ/ *a* សម្រាកលំហែ: *សម្រាកលំហែមើលរឿង santai dan nikmati filmnya (សាន់តៃ ដាន់ និកម៉ាទី ហ្វីល៉្មញ៉ា)*

**sapa, menyapa** /មើញ៉ាប៉ា/ *v* ស្វាគមន៍: *គាត់ស្វាគមន៍គ្រប់ភាគីដែលបានជួប dia menyapa semua orang yang dijumpainya (ឌីយ៉ា មើញ៉ាប៉ា ស៊ឹមូវ៉ា អូរ៉ាំង យ៉ាំង ឌិជូមប៉ៃញ៉ា);*

**sapaan** /សាប៉ាអាន/ *n* **1** ស្វាគមន៍: *ភ្លាមៗលឺសម្លេងស្វាគមន៍ពីចង្ក្រាន tiba-tiba terdengar sapaan di dapur (ទីបា–ទីបា ទើរ(r)ឌើង៉ារ(r) សាប៉ាអាន់ ឌិ ដាពួរ(r))*; **2** ឈ្មោះក្រៅ: *ឈ្មោះក្រៅគាត់អ៊ីតា nama sapaannya Ita (ណាម៉ា សាប៉ាអានញ៉ា អ៊ីតា)*

**sapu** /សាពូ/ *n* អម្បោស: *ខ្ញុំបានទិញអម្បោស saya membeli sapu (សាយ៉ា ម៉ឹមបើលី សាប៉ូ);*

**menyapu** /សាពូ, មើញ៉ាពូ/ *v បោស: ម៉ាក់បោសម្អាតផ្ទះ ibu menyapu lantai (អ៊ីប៊ូ ម៉ឺញ៉ាពូ)*

**saraf** /សារ៉ាហ្វ/ *n* ប្រព័ន្ធប្រសាទ: *អ្នកជំនាញប្រព័ន្ធប្រសាទ ahli saraf (អះលី សារ៉ាហ្វ)*

**saran** /សារ៉ាន់/ *n អនុសាសន៍; យោបល់: អនុសាសន៍ដ៏ល្អ saran yang bagus (សារ៉ាន់ យ៉ាំង បាហ្គុស(s));*

**menyarankan** /សារ៉ាន់, មើញ៉ារ៉ាន់/ *v* ផ្តល់អនុសាសន៍; ផ្តល់យោបល់: *ពុកផ្តល់យោបល់ពីផែនការថ្មីមួយ ayah menyarankan sebuah rencana baru (អាយ៉ះ ម៉ឺញ៉ារ៉ាន់កាន់ សើប៊ូវ៉ះ រេនចេណា)*

**sarana** /សារ៉ាណា/ *n* មធ្យោបាយ: *រាល់គោលដៅទាំងអស់ត្រូវការមធ្យោបាយដើម្បីសម្រេចគោលដៅ setiap tujuan memerlukan sarana untuk mencapainya (សឺទីយ៉ាប ទូជូវ៉ាន មើមើរ(r)លូកាន់ សារ៉ាណា អ៊ុនទុក មើនចាប៉ៃញ៉ា);*

**-- dan prasarana** /សារ៉ាណា ដាន់ ប្រាសារ៉ាណា/ ហេដ្ឋារចនាសម្ព័ន្ធ: *ការកសាងចនាសម្ព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធមានសារៈសំខាន់សម្រាប់កំណើនសេដ្ឋកិច្ច pembangunan sarana dan prasarana penting untuk pertumbuhan ekonomi (ពើមបាង្ងូណាន់ សារ៉ាណា ដាន់ ប្រាសារ៉ាណា ប៉ិនទិង អ៊ុនទុក ពើរ(r)ទុមប៊ូហាន់ អេកូណូមី)*

**sarang** /សារាំង/ *n* **1** សំបុក: *សំបុកចាប sarang burung (សារាំង ប៊ួរ៉ុង);* **2** ទាញចេញ: *សំបុកចោរ sarang penyamun (សារាំង ពើញ៉ាមុន)*

**sarapan** /សារ៉ាប៉ាន់/ *n* អាហាពេលព្រឹក: *គាត់កំពុងចំអិនអាហារពេលព្រឹក*

*ibu sedang membuat sarapan (អ៊ីប៊ូ សើដាំង ម៉ឹមប៊ូវ៉ាត់ សារ៉ាប៉ាន់)*

**sari** /សារី/ *n* សំខាន់:

*នំនេះប្រើសារធាតុសំខាន់ទឹកក្រូច kue ini memakai sari buah jeruk (គូវ៉េ អ៊ីនី មើម៉ាកៃ សារី ប៊ូវ៉ះ ជើរ៉ុគ);*

**-- buah** /សារី ប៊ូវាស់(s)/ ផ្លែឈើ:

*រៀងរាល់ព្រឹកគាត់ផឹកទឹកផ្លែឈើ setiap pagi dia minum sari buah (សើទីយ៉ាប ប៉ាហ្គី ឌីយ៉ា មីនុម សារី ប៊ូវ៉ះ)*

**saring, menyaring** /មើញ៉ារិង/

*v* **1** សម្រាំង: *ពួកគេសម្រាំងខ្សាច់ជាមុនសិនមុននឹងលាយជាមួយស៊ីម៉ង់ mereka terlebih dahulu menyaring pasir sebelum mencampurnya dengan semen (មើរេកា ទើរ(r)លើបិះ ដាហ៊ូលូ មើញ៉ារិង ប៉ាសីរ(r) សឺបឺលុម មិនចាំពួរ(r)ញ៉ា ឌើង៉ាន់ សឺម៉ែន);*

**2** ជ្រើសរើស; សម្រាំង:

*ពួកគេជ្រើសរើសពីបេក្ខជនដាក់ការងារ mereka menyaring para pelamar kerja (មើរេកា មើញ៉ារិង ប៉ារ៉ា ពើឡាម៉ារ(r) គើរ(r)ចា្យ)*

**sarung** /សារុង/ *n* សារ៉ុង គាត់ស្លៀកសារ៉ុងថ្មី *dia memakai sarung baru (ឌីយ៉ា មើម៉ាកៃ សារុង បារូ);*

**menyarungkan** /មើញ៉ារុងកាន់/

*v* ស្រោម: *គាត់ដាក់ស្រោមដាវនោះ dia menyarungkan keris itu (ឌីយ៉ា មើញ៉ារុងកាន់ គីរីស(ស) អ៊ីទូ);*

**-- tangan** /សារុង តាង៉ាន់/ ស្រោមដៃ:

*មន្ត្រីពិធីប្រើស្រោមដៃ petugas upacara itu memakai sarung tangan (ពើទូហ្គាស់ អ៊ូប៉ាចារ៉ា អ៊ីទូ មើម៉ាកៃ សារុង តាង៉ាន់)*

**sasana** /សាសាណា/ *n* សាលប្រជុំ:

*សិក្ខាសាលានោះត្រូវរៀបចំឡើងនៅសាលប្រជុំ seminar itu dilaksanakan di sasana (សេមីណារ(r) អ៊ីទូ ឌិឡាក់សាណាកាន់ ឌិ សាសាណា)*

**sasar, menyasar** /មើញ៉ាសារ(r)/

*v* ទៅខុសគោលដៅ:

*គ្រាប់កាំភ្លើងនោះបានរសាត់ទៅជញ្ជាំង peluru itu menyasar ke dinding (ពើលូរូ អ៊ីទូ មើញ៉ាសារ(r) គើ ឌិនឌិង);*

**sasaran** /សាសារ៉ាន់/ *n* គោលដៅ:

*បណ្ដាញព័ត៌មាននោះគឺជាបណ្ដាលោកគ្រូអ្នកគ្រូ sasaran informasi itu adalah*

*para guru (សាសារ៉ាន់ អ៊ីនហ្គូរម៉ាស៊ី អ៊ីទូ អាដាឡះ ប៉ារ៉ា ហ្គូរ);*

**tersasar** /ទើរ(r)សាសារ(r)/ *v* វង្វេង: *ពេលទៅដល់ក្រុងបាលី ខ្ញុំបានវង្វេងប៉ុន្មានដងដែរ ketika tiba di Bali saya tersasar beberapa kali (តើទីកា ទីបា ឌិ បាលី សាយ៉ា ទើរ(r)សាសារ(r) ប៊ឺប៊ឺរ៉ាប៉ា កាលី)*

**satu** /សាទូ/ *num* មួយ: *មួយថ្ងៃ satu hari (សាទូ ហារី);*

**bersatu** /ប៊ឺរ(r)សាទូ/ *v* **1** ឯកភាព; រួបរួម: *សូមយើងឯកភាពគ្នាតែមួយ mari kita bersatu (ម៉ារី គីតា ប៊ឺរ(r)សាទូ);*

*2 តែមួយ ចិត្តតែមួយ bersatu hati (ប៊ឺរ(r)សាទូ ហាទី);*

**kesatu** /គើសាទូ/ *num* ដំបូង: *គាត់ជាកូនទី១ក្នុងចំណោមបងប្អូន៤នាក់ dia anak kesatu dari empat bersaudara (ឌីយ៉ា អាណាក់ គើសាទូ ដារី អឹមប៉ាត់ ប៊ឺរ(r)សាអ៊ូដារ៉ា);*

**kesatuan** /គើសាទូវ៉ាន់/ *n* **1** ឯកតា; **2** ភក្តីភាព; ឯកភាព: *ការរួបរួមដែលមិនអាចបំបែកបាន satu kesatuan yang tidak terpisahkan (សាទូ គើសាទូវ៉ាន់ យ៉ាំង ទីដាក់ ទើរ(r)ពីសះកាន់ )*; **3** សម្ព័ន្ធ: *សម្ព័ន្ធនិស្សិតឥណ្ឌូនេស៊ី kesatuan aksi mahasiswa Indonesia (គើសាទូវ៉ាន អាក់ស៊ី ម៉ាហាស៊ីស្វា ឥណ្ឌូនេស៊ីយ៉ា);*

**mempersatukan** /មើមពើរ(r)សាទូកាន់/ *v* ធ្វើឱ្យរួមតែមួយ: *ភាសាឥណ្ឌូនេស៊ីធ្វើការបញ្ចូលគ្នារវាងភាសាជនជាតិដើមរបស់ឥណ្ឌូនេស៊ី bahasa Indonesia mempersatukan suku-suku bangsa di Indonesia (បាហាសា ឥណ្ឌូនេស៊ីយ៉ា មើមពើរ(r)សាទូកាន់ ស៊ូគូ–ស៊ូគូ បAងសា ឌិ ឥណ្ឌូនេស៊ីយ៉ា);*

**menyatukan** /មើញ៉ាទូកាន់/ *v* **1** រួមបញ្ចូលគ្នា: *ភាសារួមបញ្ចូលជាតិសាសន៍ bahasa menyatukan bangsa (បាហាសា មើញ៉ាទូកាន់ បាំងសា)*; **2** ប្រមូល; ផ្តោតអារម្មណ៍: *គាត់ផ្តោតអារម្មណ៍តែលើការប្រកួតប្រជែង dia menyatukan perhatiannya hanya untuk pertandingan itu (ឌីយ៉ា មើញ៉ាទូកាន់ ពើរ(r)ហាទីយ៉ានញ៉ា ហាញ៉ា អ៊ុនទុក ពើរ(r)តាន់ឌីង៉ាន់ អ៊ីទូ);*

**persatuan** /ពើរ(r)សាទូវ៉ាន់/

*n* **1** សាមគ្គីភាព: *សាមគ្គីភាពនាំមកនូវការរីកចម្រើន persatuan membawa kemajuan (ពើរ(r)សាទូវ៉ាន មើមបាវ៉ា គើម៉ាជូវ៉ាន);*

**2** សមាគម; *អង្គការ: សមាគមនាំចេញឈើឥណ្ឌូនេស៊ី persatuan pengekspor kayu Indonesia (ពើរ(r)សាទូវ៉ាន ពើងអ៊ែកស្ពរ(r) កាយូ ឥណ្ឌូនេស៊ីយ៉ា);*

**satuan** /សាទូវ៉ាន់/ *n* ឯកតា: *សម្ព័ន្ធកងទ័ព satuan pasukan (សាទូវ៉ាន់ ប៉ាស៊ូកាន់);*

**satu-satu** /សាទូ-សាទូ/ *adv* ម្តងមួយ: *គាត់រាប់ផ្លែឈើនោះម្តងមួយៗ dia menghitung buah-buah itu satu-satu (ឌីយ៉ា មើងហ៊ីទុង ប៊ូវ៉ះ ប៊ូវ៉ះ អ៊ីទូ សាទូ-សាទូ);*

**satu-satunya** /សាទូ-សាទូញ៉ា/

*a* មួយគត់: *គាត់ជាកូនតែម្នាក់គត់ dia adalah anak satu-satunya (ឌីយ៉ា អាដាឡះ អាណាក់ សាទូ-សាទូញ៉ា)*

**saudara** /សៅដារ៉ា/ *n* បងប្អូន: *បងប្អូនសាច់ឆ្ងាយ saudara jauh (សៅដារ៉ា ចូវ)*

**-- laki-laki** /សៅដារ៉ា, សៅដារ៉ា ឡាគី-ឡាគី/ បងប្អូន; បងប្អូនប្រុស: *បងប្អូនប្រុសខ្លះៗ beberapa saudara laki-laki (ប៊ើរ៉ាប៉ា សៅដារ៉ា ឡាគី-ឡាគី);*

**-- perempuan** /សៅដារ៉ា, សៅដារ៉ា ពើរឹមពូវ៉ាន់/ បងប្អូន; បងប្អូនស្រី: *បងប្អូនស្រីពីរនាក់ dua saudara perempuan (ឌូវ៉ា សៅដារ៉ា ពើរ៉ឹមពូវ៉ាន់)*

**sawah** /សាវ៉ះ/ *n* វាលស្រែ: *ភ្ជួរស្រែ membajak sawah (មើមបាចាក់ សាវ៉ះ)*

**sawit** /សាវិត/ *n* ដូងប្រេង: *គាត់មានជំនួញដូងប្រេង dia mempunyai bisnis sawit (ឌីយ៉ា មើមពូញ៉ៃ ប៊ីស្នីស(ស) សាវីត)*

**saya** /សាយ៉ា/ *pron* ខ្ញុំ: *ខ្ញុំជាសិស្ស saya seorang pelajar (សាយ៉ា សើអូរ៉ាំង ប៉ើឡាចារ(r))*

**sayang** /សាយ៉ាំង/ **1** *v* ស្រឡាញ់; យកចិត្តទុកដាក់: *គ្រប់ម្តាយទាំងអស់ប្រាកដណាស់ស្រឡាញ់កូនៗ setiap ibu pasti sayang anaknya (ស៊ើទីយ៉ាប អ៊ីប៊ូ ប៉ាស្ទី សាយ៉ាំង អាណាក់ញ៉ា);*

**2** *a* ជាអកុសល: *ពិធីជប់លៀងនោះធំដុំណាស់ តែជាអកុសលមានភ្លៀង pesta itu meriah, sayang sekali hujan (ពែស្តា អ៊ីទូ មើរីយ៉ះ សាយ៉ាំង សឹកាលី ហ៊ូច្យាន់);*

**kesayangan** /គើសាយ៉ាង៉ាន់/ *n* ចំណូលចិត្ត;

**menyayangi** /មើញ៉ាយ៉ាងី/ *v* ស្រឡាញ់: *គាត់ស្រឡាញ់ម្តាយគាត់ dia menyayangi ibunya (ឌីយ៉ា មើញ៉ាយ៉ាងី អ៊ីប៊ូញ៉ា);*

**menyayangkan** /មើញ៉ាយ៉ាំងកាន់/ *v* សោកស្តាយ: *អ្នកដឹកនាំសោកស្តាយការបរាជ័យពីគម្រោងនោះ pimpinan menyayangkan kegagalan proyek itu (ពីមពីណាន់ មើញ៉ាយ៉ាំងកាន់ គើហ្គាហ្គាឡាន់ ប្រូយ៉ែក អ៊ីទូ);*

**penyayang** /ពើញ៉ាយ៉ាំង/ *n* ចិត្តមេត្តាករុណា: *គាត់មានចិត្តមេត្តាករុណា dia bersifat penyayang (ឌីយ៉ា បឺរ(r)ស៊ីហ្វាត់ ពើញ៉ាយ៉ាំង)*

**sayap** /សាយ៉ាប់/ *n* ស្លាប: *បាក់ស្លាប patah sayap (ប៉ាតះ សាយ៉ាប់)*

**sayembara** /សាយឹមបារ៉ា/ *n* ប្រកួតប្រជែង: *ការប្រកួតប្រជែងសរសេរចម្រៀង sayembara mengarang lagu (សាយឹមបារ៉ា មើង៉ារ៉ាំង ឡាហ្គូ)*

**sebab** /សឹបាប់/ *p* ពីព្រោះ: *ខ្ញុំអវត្តមាន ពីព្រោះខ្ញុំឈឺ saya tidak masuk sebab saya sakit (សាយ៉ា ទីដាក់ ម៉ាស៊ុក សើបាប់ សាយ៉ា សាគិត);*

**menyebabkan** /សើបាប់, មើញើបាប់កាន់/ *v* មូលហេតុ; បណ្តាលឲ្យ: *ភ្លៀងបណ្តាលឲ្យមានទឹកជំនន់ hujan menyebabkan banjir (ហ៊ូចាន់ ម៉ើញើបាប់កាន បាន់ជីរ(r));*

**penyebab** /សើបាប់, ពើញើបាប់/ *n* មូលហេតុ: *មូលហេតុនៃការស្លាប់ penyebab kematian (ពើញើបាប់ កឹម៉ាទីយ៉ាន);*

**-- akibat** /សឹបាប់ អាគីបាត់/ ហេតុនិងផល: *គ្រប់យ៉ាងដែលកើតមានប្រាកដណាស់ថាមានហេតុ និងផល semua*

*yang terjadi pasti ada sebab dan akibat (ស៊ីម្វ៉ា យ៉ាំង ទើរ(r)ចាឌិ ប៉ាស្ទិ អាដា សឺបាប់ ដាន់ អាគីបាត់)*

**sebagai** /សើបាហ្គៃ/ *p* ដូចជា: *ជាឧទាហរណ៍ sebagai contoh (សើបាហ្គៃ ចុនតុះ)*

**sebal** /សឺបាល់/ *a* **1** ក្តៅ; ឈឺចាប់: *ខ្ញុំឈឺចាប់ពេលស្តាប់លឺព័ត៌មាននោះម្តងទៀត saya sebal mendengar cerita itu lagi (សាយ៉ា សឺបាល់ មើនឌើង៉ារ(r) ចឺរីតា អ៊ីទូ ឡាហ្គី)*; **2** ធុញទ្រាន់: *បញ្ហារបស់គាត់ធ្វើឱ្យអ្នកផ្សេងក្តៅក្រហាយ keluhannya membuat orang lain sebal (គើលូហាន់ញ៉ា មើមប៊ូវ៉ាត់ អូរ៉ាំង ឡាអ៊ីន សឺបាល់)*

**sebar, menyebar** /សើបារ(r),មើញើបារ(r)/ *v* ផ្សព្វផ្សាយ: *គាត់ផ្សព្វផ្សាយព័ត៌មានមិនពិត dia menyebar berita yang salah (ឌីយ៉ា មើញើបារ(r) បើរីតា យ៉ាំង សាឡះ)*

**sebelah** /សើបឺឡះ/ *n* ក្បែរ; បន្ទាប់; ជាប់ ប៉ុស្តិ៍ប្រៃណីយ៍នៅជាប់ធនាគារ *kantor pos berada di sebelah bank (កាន់តូរ(r) បើរ៉ាដា ឌី សើបើឡះ បាំង)*;

**bersebelahan** /សើបឺឡះ, បឺរ(r)សឺបឺឡះហាន់/ *v* ក្បែរ; បន្ទាប់; ជាប់: *ប៉ុស្តិ៍ប្រៃណីយ៍នៅជាប់ធនាគារ kantor pos bersebelahan dengan bank (កាន់តូរ(r) បើរ(r)សើបើឡាហាន់ ដឺង៉ាន់ បាំង)*

**seberang** /សើបឺរ៉ាំង/ *n* **1** ឆ្លងកាត់; ម្ខាង: *សាលារៀននៅម្ខាងលានដ្ឋាន sekolah terletak di seberang lapangan (សើកូឡះ តើរ(r)ឡើតាក់ ឌិ សើបេរ៉ាំង ឡាប៉ាង៉ាន់)*; **2** ម្ខាងទៀត: *នៅម្ខាងទៀត di seberang (ឌិ សឺបឺរ៉ាំង)*; **3** ទល់មុខ: *ផ្ទះគាត់នៅទល់មុខផ្សារទំនើប rumahnya di seberang mal (រូម៉ះញ៉ា ឌិ សឺបឺរ៉ាំង ម៉ល)*;

**menyeberang** /សើបឺរ៉ាំង, ម៉ឺញ៉ើបឺរ៉ាំង/ *v* ឆ្លង: ក្មេងៗចង់ឆ្លងថ្នល់: *anak-anak ingin menyeberang jalan (អាណាក់-អាណាក់ អ៊ីង៉ិន ម៉ឺញ៉ើបើរ៉ាំង ចាឡាន់)*;

**penyeberangan** /សើបឺរាំង,ប៉ឺញ៉ើបឺរ៉ាំងង៉ាន់/ *n* **1** ឆ្លងកាត់; ខ្វែង: *ច្រកឆ្លើរជើង penyeberangan pejalan (ប៉ឺញ៉ើបើរ៉ាង៉ាន់ ប៉ឺចា្យឡាន់);* **2** ចម្លង: *ផ្លូវដើរឆ្លង jembatan penyeberangan (ចឹមបាតាន់ ប៉ឺញ៉ើបើរ៉ាង៉ាន់)*

**[1]sebut, menyebut** /សើប៊ុត, ម៉ឺញ៉ើប៊ុត/ *v* និយាយពី; រម្លឹកពី: *គាត់រម្លឹកពីឈ្មោះខ្ញុំ dia menyebut namaku (ឌីយ៉ា ម៉ឺញ៉ើប៊ុត ណាម៉ាគូ)*

**[2]sebut, menyebut** /មើញ៉ើប៊ុត/ *v* **1** ហៅ: *នៅក្នុងការបួងសួងនោះ គាត់ហៅឈ្មោះព្រះជាច្រើនដង dalam doa itu dia menyebut nama Tuhan berkali-kali (ដាឡាំ ដូអា អ៊ីទូ ឌីយ៉ា មើញ៉ើប៊ុត ណាម៉ា ទូហាន់ បឺរ(r)កាលី-កាលី); គាត់មិនអាចហៅឈ្មោះពេញប្អូនប្រុសគាត់ dia tidak bisa menyebut nama lengkap adiknya (ឌីយ៉ា ទីដាក់ ប៊ីសា មើញ៉ើប៊ុត ណាម៉ា លែងកាប់ អាឌិគញ៉ា);* **2** ប្រាប់: *ពួកគេហៅគ្រប់ភាគីដែលពាក់ព័ន្ធក្នុងរឿងនោះ mereka menyebut semua pihak terkait masalah itu (មើរេកា មើញ; ប៊ុត សឺមូវ៉ា ពីហាក់ ទើរ(r)កាអ៊ិត ម៉ាសាឡះ អ៊ីទូ )*

**[1]sedang** /សើដាំង/ *a* មធ្យម: *ទំហំមធ្យម ukuran sedang (អ៊ូគូរ៉ាន់ សើដាំង)*

**[2]sedang** /សឺដាំង/ **1** *adv* កំពុង: *ខ្ញុំកំពុងញ៉ាំពេលដែលអ្នកទូរស័ព្ទមកខ្ញុំ saya sedang makan ketika kamu menelepon saya (សាយ៉ា សឺដាំង ម៉ាកាន់ គើទីកា កាមូ មើណែលេប៉ុន សាយ៉ា);* **2** *a* មធ្យម: *លទ្ធផលប្រលងគាត់បានមធ្យម hasil ujiannya sedang saja (ហាស៊ីល អ៊ូជីយ៉ានញ៉ា សឺដាំង សាចា្យ);* **3** *a* គ្រប់គ្រាន់: *ចំនួនវាគ្រប់គ្រាន់ដើម្បីបំពេញតាមតម្រូវការ jumlahnya sedang untuk memenuhi syarat (ជូម្លះញ៉ា ជូគុប អ៊ុនទុក មើមើនូហ៊ី ស្យារ៉ាត់)*

**sedap** /សឺដាប់/ *a* **1** ផាសុកភាព: *ផ្ទះនេះមានសណ្ដាប់ធ្នាប់ ស្អាត និង មាន ផាសុកភាព rumah ini rapi, bersih, dan sedap (រូម៉ះ អ៊ីនី រ៉ាពី បឺរ(r)ស៊ីះ ដាន់ សឺដាប់);* **2** រីករាយ: *មើលទៅស្រស់ស្អាត sedap dipandang mata (សឺដាប់ ឌិប៉ាន់ដាំង ម៉ាតា);* **3**឵ឆ្ងាញ់: *នំនោះឆ្ងាញ់មែនទែន*

*kue itu sedap sekali (គូវ៉េ អ៊ីទូ សឺដាប់ សឺកាលី);*

**penyedap rasa** /ពើញឺដាប់ រ៉ាសា/ ប៊ីចេង: *ម្ហូបនោះដាក់ប៊ីចេង masakan itu diberi penyedap (ម៉ាសាកាន់ អ៊ីទូ ឌិប៊ីរី ពើញើដាប់)*

**sedekah** /សឺឌើកះ/ *n* វិភាគទាន: *ដាក់ទានដល់អ្នកក្រីក្រ memberi sedekah kepada fakir miskin (មើមប៊ីរី សឺឌើកះ គើប៉ាដា ហ្វាគីរ(r) មីស្គីន );*

**bersedekah** /ប៊ឺរ(r)សឺឌើកះ/ *v* ឧបត្ថម្ភ; វិភាគទាន: *ការដាក់ទានជាអំពើល្អ bersedekah adalah perbuatan baik (ប៊ឺរ(r)សឺឌើកះ អាដាឡះ ពើរ(r)ប៊ូវ៉ាតាន់ បាអ៊ិគ)*

**sederhana** /សើដឺរ(r) ហាណា/ *a* ធម្មតា; សាមញ្ញ: *ឃ្លាសាមញ្ញ kalimat sederhana (គាលីម៉ាត់ សើដើរ(r)ហាណា)*

**sedia, menyediakan** /សើឌីយ៉ា, មើញើឌីយ៉ាកាន់/ *v* ផ្តល់; មាន: *តូបនោះមានលក់អាហារត្រជាក់ toko itu menyediakan makanan beku (តូកូ អ៊ីទូ មើញើឌីយ៉ាកាន់ ម៉ាកាណាន់ បើគូ);*

**persediaan** /សើឌីយ៉ា, ប៉ើញើឌីយ៉ាអាន/ *n* ផ្គត់ផ្គង់; ផ្តល់: *ផ្គត់ផ្គង់ម្ហូបអាហារ persediaan makanan (ប៉ើរ(r)ញើឌីយ៉ាអាន ម៉ាកាណាន់);*

**tersedia** /សើឌីយ៉ា, តើរ(r)សើឌីយ៉ា/ *v* ផ្គត់ផ្គង់; ផ្តល់: *អាហារថ្ងៃត្រង់ត្រូវបានផ្តល់ឱ្យនៅម៉ោងដប់ពីរកន្លះ makan siang tersedia pukul 12.30 (ម៉ាកាន់ ស៊ីយ៉ាង តើរ(r)សើឌិយ៉ា ពូគុល ១២៣០)*

**sediakala** /សឺឌីយ៉ាកាឡា/ *n* ពីមុន: *ស្ថានភាពបានត្រឡប់ទៅរកភាពដើម keadaan kembali seperti sediakala (គើអាដាអាន គើមបាលី សឺពើរ(r)ទី សើឌីយ៉ាកាឡា)*

**sedih** /សើឌិះ/ *a* ទុក្ខព្រួយ; ពិបាកចិត្ត: *កូននោះពិបាកចិត្ត anak itu sedih (អាណាក់ អ៊ីទូ សើឌិះ)*

**sedikit** /សឺឌិគីត/ *a* **1** តិចតួច: *អំបិលតិចតួច sedikit garam (សឺឌិគិត ហ្គារ៉ាំ);* **2** តិចតួច: *ផ្អែមតិចតួចដែរ sedikit manis (សើឌីគិត ម៉ានិស(s))*

**segala** /សឺហ្គាឡា/ *n* **1** ទាំងអស់: *គ្រប់បញ្ហាទាំងអស់ត្រូវតែប្រឈមជាមួយដោយការអត់ធ្មត់ segala macam persoalan dihadapinya dengan sabar (សឺហ្គាឡា ម៉ាចាំ ពើរ(r)សូអាឡាន់ ឌិហាដាពីញ៉ា ឌើង៉ាន់ សាបារ(r));* **2** ស្អីទេ: *មិនចាំបាច់និយាយភាសាអង់គ្លេសស្អីទេ tidak usah pakai bahasa Inggris segala (ទីដាក់ អ៊ូសះ ប៉ាកៃ បាហាសា អ៊ិងហ្គ្រីស(ស) សឺហ្គាឡា);*

**segala-galanya** /សឺហ្គាឡាហ្គាឡាញ៉ា/ *adv* គ្រប់យ៉ាង: *គ្រួសារគឺជាអ្វីៗគ្រប់យ៉ាង keluarga adalah segala-galanya (គើលូវ៉ារ(r)ហ្គា អាដាឡះ សឺហ្គាឡាហ្គាឡាញ៉ា)*

**segan** /សឺហ្គាន់/ *a* **1** ខ្ជិល: *គាត់ខ្ជិលធ្វើកិច្ចការដែលស្មុគស្មាញ dia segan melakukan hal yang rumit (ឌីយ៉ា សឺហ្គាន់ មើឡាគូកាន់ ហាល់ យ៉ាំង រូមីត);* **2** ខ្មាស់អៀន: *នាងខ្មាស់អៀននឹងជួបមនុស្សម្នាជាច្រើន dia segan bertemu dengan banyak orang (ឌីយ៉ា សឺហ្គាន់ បឺរ(r)ទើមូ ឌើង៉ាន់ បាញ៉ាក់ អូរ៉ាំង);* **3** ញញើត: *គ្រប់គ្នាមានអារម្មណ៍ញញើតនឹងនាង semua merasa segan terhadapnya (សឺមូវ៉ា មើរ៉ាសា សឺហ្គាន់ ទើរ(r)ហាដាប់ញ៉ា)*

**segar** /សឺហ្គារ(r)/ *a* **1** ស្រស់ស្រាយ: *អាកាសធាតុខាងក្រៅស្រស់ស្រាយណាស់ udara di luar segar (អ៊ូដារ៉ា ឌិ លូវ៉ារ(r) សឺហ្គារ(r)) ខ្លួនប្រាណខ្ញុំមានអារម្មណ៍ថាស្រស់ស្រាយបន្ទាប់ពីហាត់ប្រាណរួច badan saya merasa segar setelah berolahraga (បាដាន់ សាយ៉ា មើរ៉ាសា សឺហ្គាររ(r) សឺទើឡះ បឺរ(r)អូឡះរ៉ាហ្គា);* **2** ស្រស់: *បន្លែនេះស្រស់ដោយសារតែទើបតែបេះពីចម្ការ sayuran ini segar karena baru saja dipetik dari kebun (សាយូរ៉ាន់ អ៊ីនី សឺហ្គារ(r) កាផើណា បារូ សាច្យា ឌិពើទីគ ដារី គើប៊ុន);*

**kesegaran** /គើសឺហ្គារ៉ាន់/ *n* ស្រស់ស្រាយ: *គំនិតស្រស់ស្រាយអាចទទួលបាននៅពេលព្រឹកព្រលឹម*

*kesegaran berpikir bisa didapat di pagi hari (តើសឺហ្គារ៉ាន ប៊ឺរ(r)ពីគីរ(r) ប៊ីសា ឌិដាប៉ាត់ ឌិ ប៉ាហ្គី ហារី);*

**menyegarkan** /មើញើហ្គារ(r)កាន់/ *v* ធ្វើឱ្យស្រស់ស្រាយ: *ផឹកភេសជ្ជៈធ្វើឱ្យខ្លួនប្រាណស្រស់ស្រាយ minum anggur menyegarkan badan (មីនុម អាំងហ្គូរ(r) មើញើហ្គារ(r)កាន់ បាដាន់);*

**-- bugar** /សឹហ្គារ(r) ប៊ូហ្គារ(r)/ សុខភាពល្អ: *ក្មេងដែលទើបនឹងកើតនោះមានសុខភាពល្អ bayi yang baru lahir itu segar bugar (បាយី យ៉ាំង បារូ ឡាហ៊ីរ(r) អ៊ីទូ សឹហ្គារ(r) ប៊ូហ្គារ(r))*

**segara** /សឹហ្គារ៉ា/ *n* មហាសមុទ្រ: *សណ្ឋាគារនោះត្រូវបានសាងសង់ឡើងនៅមាត់មហាសមុទ្រ hotel itu dibangun di tepi segara (ហូតែល អ៊ីទូ ឌិបាង៉ុន ឌិ ទើពី សឹហ្គារ៉ា)*

**segel** /សឹហ្គឹល/ *n* ត្រា: *លិខិតកិច្ចសន្យានោះមានសុពលភាពនៅពេលដែលចុះហត្ថលេខានៅខាងលើត្រា surat perjanjian itu sah bila ditandatangani di atas segel (ស៊ូរ៉ាត់ ពើរ(r)ចាន់ជីយ៉ាន អ៊ីទូ សះ ប៊ីឡាឌិតានដាតាំងង៉ានី ឌិ អាតាស់ សែហ្គឹល);*

**menyegel** /ញើហ្គឹល/ *v* ដាក់សញ្ញា: *ប៉ូលីសបានបិទទ្វាកន្លែងលេងល្បែង polisi menyegel tempat perjudian (ប៉ូលីស៊ី មើញើហ្គឹល ទើមប៉ាត់ ពើរ(r)ជូឌីយ៉ាន)*

**segenap** /សឹហ្គើណាប់/ *num* ទាំងអស់: *ថាមពលទាំងអស់ត្រូវបានបញ្ចេញដើម្បីបញ្ចប់គម្រោងនោះ segenap tenaga dikerahkan untuk menyelesaikan proyek itu (សេហ្គើណាប់ ទើណាហ្គា ឌិគើរ៉ះកាន់ អ៊ុនទុក មើញើឡឺសៃកាន់ ប្រូយ៉ែក អ៊ីទូ)*

**segera** /សើហ្គើរ៉ា/ *adv* ឆាប់ៗ: *ទៅឆាប់ៗ pergi segera (ពើរ(រ)ហ្គី សើហ្គើរ៉);*

**sesegera** /សើហ្គើរ៉ា, សើសើហ្គើរ៉ា, សើជើប៉ាត់/ *adv* ឆាប់ៗ: *ឆាប់ៗដែលអាចធ្វើទៅបាន sesegera mungkin (សឹហ្គើរ៉ា មុងគិន)*

**segi** /សឹហ្គី/ *n* **1** ជ្រុង: *អ្នកមើលបញ្ហានោះត្រឹមតែមួយជ្រុងប៉ុណ្ណោះ saudara melihat masalah itu*

*hanya dari satu segi saja (សៅដារ៉ា មើលីហាត់ ម៉ាសាឡះ អ៊ីទូ ហាញ៉ា ដារី សាទូ សឺហ្គី សាច្យា)*; **2** ទិដ្ឋភាព: *បញ្ហាមួយអាចមើលឃើញពីច្រើនទិដ្ឋភាព suatu masalah banyak seginya (ស៊ូវ៉ាទូ ម៉ាសាឡះ បាញ៉ាក់ សឺហ្គីញ៉ា)*; **3** ជ្រុង: *មានបណ្ដោយពីរ និងទទឹងមួយ ada dua segi panjang dan satu segi pendek (អាដា ឌូវ៉ា សឺហ្គី ប៉ាន់ច្យាំង ដាន់ សាទូ សេហ្គី ប៉េនដិត)*;

**persegi** /សើហ្គី, ប៉ើរ(r)សឺហ្គី/ *n* បួនជ្រុង; ចតុកោណ: *ថ្គាមរាងបួនជ្រុង dagu persegi (ដាគូ ប៉ើរ(r)សឺហ្គី) ម៉ែត្រការេ meter persegi (ម៉ែតើរ(r) ប៉ើរ(s)ហ្គី)*

**segitiga** /សឺហ្គីទីហ្គា/ *n* ត្រីកោណ: *គាត់ប្រើក្រណាត់រាងត្រីកោណ ដើម្បីគ្របក្បាលគាត់ ia memakai kain segitiga untuk menutup kepalanya (អ៊ីយ៉ា មើម៉ាកៃ កាអ៊ិន សឺហ្គីទីហ្គា អ៊ុនទុក មើនូទុប គើប៉ាឡាញ៉ា)*

**sehat** /សេហាត់/ *a* **1** សុខភាពល្អ: *អាហារដែលមានសុខភាពល្អ makanan sehat (ម៉ាកាណាន់ សេហាត់)*;

**2** សុខភាពល្អ; សុខសប្បាយ: *ខ្ញុំមានសុខភាពល្អ saya sehat (សាយ៉ា សេហាត់)*;

**3** ល្អប្រសើរ: *វិស័យធនាគារនៅប្រទេសនេះមានលក្ខណៈល្អប្រសើរណាស់ perbankan di negara ini sangat sehat (ពើរ(r)បាំងកាន់ ឌិ នើហ្គារ៉ា អ៊ីនី សាង៉ាត់ សេហាត់)*

**sehingga** /សឺហ៊ិងហ្គា/ *p* រហូតដល់: *គាត់ញ៉ាំច្រើនពេក ទើបកម្រើកលែងរួច dia makan terlalu banyak sehingga tak bisa bergerak (ឌីយ៉ា ម៉ាកាន់ ទើរ(r)ឡាលូ បាញ៉ាក់ សឺហ៊ិងហ្គា តាក់ ប៊ីសា ប៊ឺរ(r)ហ្គើរ៉ាក់)*

**sejahtera** /សឺច្យ៉ះទើរ៉ា/ *a* វិបុលភាព; ឧដុងឧត្ដម: *សង្គមមានយុត្តិធម៌ និង ឧដុងឧត្ដម masyarakat adil dan sejahtera (ម៉ាស្យារ៉ាកាត់ អាឌីល ដាន់ សឺច្យ៉ះទើរ៉ា)*;

**kesejahteraan** /គើសឺច្យ៉ះទើរ៉ាអាន/ *n* សុខុមាលភាព: *សង្គមមានសុខុមាលភាព negara berkesejahteraan rakyat*

*(នើហ្កាំ បឺរ(r)កឺសឺចាះទើរ៉ាអាន រ៉ាក់យ៉ាត់)* *ម្ដាយតែងតែយកចិត្តទុកដាក់ពីសុខុមាលភាពរបស់កូនៗ* *ibu selalu memperhatikan kesejahteraan anak-anaknya (អ៊ីប៊ូ សឺឡាលូ មើមពើរ(r)ហាទីកាន់ គើសឺចាះទើរ៉ាអាន អាណាក់-អាណាក់ញ៉ា)*

**sejak** /សឺច្យាក់/ *p* តាំងពី: *តាំងពីពីរសប្ដាហ៍មុន* *sejak dua minggu lalu (សឺច្យាក់ ឌូវ៉ា មិងហ្គូ ឡាលូ)*; *គាត់ឈឺតាំងពីម្សិលមិញ* *dia sakit sejak kemarin (ឌីយ៉ា សាគិត សើចាក់ កឺម៉ារិន)*

**sejarah** /សឺច្យារះ/ *n* ប្រវត្តិសាស្ត្រ: *ប្រវត្តិសាស្ត្រនៃការតស៊ូយកជ័យជំនះរបស់ឥណ្ឌូនេស៊ី* *sejarah perjuangan kemerdekaan Indonesia (សឺច្យារះ ពើរ(r)ជូវ៉ាង៉ាន់ គើមើរ(r)ដេកាអាន ឥណ្ឌូនេស៊ីយ៉ា)*;

**bersejarah** /ប៊ឺរ(r)សឺច្យារ៉ះ/ *v* ប្រវត្តិសាស្ត្រ: *វិមានឯករាជដែលនៅមុខទីស្ដីការជាវិមានប្រវត្តិសាស្ត្រ* *Monas yang ada di depan Istana Negara adalah tugu bersejarah (ម៉ូណាស់ យ៉ាំង អាដា ឌិ ឌើប៉ាន់ អ៊ីស្តាណា នើហ្គារ៉ា អាដាឡះ ទូហ្គូ ប៊ឺរ(r)សឺច្យារ៉ះ)*; *វត្ថុបុរាណជាច្រើនរបស់ឥណ្ឌូនេស៊ីត្រូវបានលក់ទៅក្រៅប្រទេស* *banyak benda bersejarah Indonesia yang dijual ke luar negeri (បាញ៉ាក់ បេនដា ប៊ឺរ(r)សឺច្យារ៉ះ ឥណ្ឌូនេស៊ីយ៉ា យ៉ាំង ឌិជូវ៉ល គើ លូវ៉ារ(r) ណើហ្គារី)*

**sejati** /សឺច្យាទី/ *a* ពិត: *ស្នេហាពិតមិនប្រកាន់រឿងទ្រព្យសម្បត្តិ និងឋានៈ* *cinta sejati tak mengenal harta dan kedudukan (ជិនតា សឺច្យាទី តាក់ មើងើណាល់ ហារ(r)តា ដាន់ គើឌូឌុគកាន់)*

**sejoli** /សឺច្យូលី/ *n* គូរ: *មួយគូរ* *dua sejoli (ឌូវ៉ា សឺច្យូលី)*

**sejuk** /សឺជុក/ *a* ត្រជាក់: *បរិយាកាសត្រជាក់* *suasana sejuk (ស៊ូវ៉ាសាណា សើជុក)*;

**kesejukan** /គើសឺជូកាន់/ *n* ស្ងប់: *ចិត្តស្ងប់* *kesejukan hatinya (គើសឺជូកាន់ ហាទីញ៉ា)*

**sekali** /សើកាលី/ **1** *adv* ណាស់: *រវល់ណាស់ sibuk sekali (សាង៉ាត់ ស៊ីប៊ុក);*

***2** n ម្តង ញុំាម្តង* makan sekali (*ម៉ាកាន់ សើកាលី)*

**sekarang** /សាំប៉ៃ សឺកាភ៉ុង/

*n* **1** រហូតដល់ឥឡូវ: *គាត់រស់នៅក្នុងផ្ទះចាស់រហូតដល់ឥឡូវ* dia *masih tinggal di rumah lama sampai sekarang (ឌីយ៉ា ម៉ាស៊ិះ ទិងហ្កាល់ ឌិ រូម៉ះ ឡាម៉ា សាំប៉ៃ សឺកាភ៉ុង)*;

**2** ឥឡូវ*: គាត់ទើបតែមកដល់* dia *sekarang sudah datang (ឌីយ៉ា សើកាភ៉ុង ស៊ូដះ ដាតាំង)*

**sekarat** /សឺការ៉ាត់/ *a* ឈឺចាប់: *អ្នកជម្ងឺនោះចាប់ផ្តើមឈឺចាប់* orang sakit *itu mulai sekarat (អូរ៉ាំង សាគិត អ៊ីទូ មូឡៃ សឺការ៉ាត់)*

**sekat, menyekat** /មើញើកាត់/ *v* បំបែក; ចែក: *គាត់ចែកបន្ទប់ខាងមុខជាពីរ* dia *menyekat ruang depan menjadi dua (ឌីយ៉ា មើញើកាត់ រ៉ូអាំង ឌើប៉ាន់ មិនចា្យឌិ ឌូវ៉ា)*;

**penyekat** /ពើញើកាត់/

*n* រណាំងខ័ណ្ឌចែក:

*ដើម្បីឱ្យបន្ទប់នេះមើលទៅធំទូលាយ ត្រូវយករណាំងខ័ណ្ឌចែកនោះចេញ* supaya *ruangan ini kelihatan luas, penyekatnya dilepaskan saja (ស៊ូប៉ាយ៉ា រ៉ូវ៉ាង៉ាន់ អ៊ីនី គើលីហាត់តាន់ លូវ៉ាស់(ស) ពើញើកាត់ញ៉ា ឌិលើប៉ាស្កាន់ សាចា្យ)*

**sekian** /សឺគីយ៉ាន់/ *n* **1** នោះ:

*ពីពលរដ្ឋជាច្រើននៅទីក្រុងចាកាតា មានតែមួយចំនួនតូចប៉ុណ្ណោះដែលជាអ្នកស្រុកដើមចាកាតា* dari sekian banyak *rakyat di Jakarta, hanya sebagian kecil yang keturunan Jakarta asli (ដារី សេគីយ៉ាន បាញ៉ាក់ រ៉ាក់យ៉ាត់ ឌិ ចា្យការ(r)តា ហាញ៉ា សឺបាហ្គីយ៉ាន គើជីល យ៉ាំង គើតូរុនណាន់ ចា្យការ(r)តា អាស្លី)*; **2** ប៉ុណ្ណេះសិនចុះ: *ប៉ុណ្ណេះសិនចុះ សូមអរគុណ* sekian dulu dan *terima kasih (សេគីយ៉ាន ឌូលូ ដាន់ ទើរីម៉ា កាស៊ិះ)*

**sekoci** /សឺកូជី/ *n* **1** ទូក:

*ពួកគេឆ្លងស្ទឹងនោះដោយទូក* mereka

*menyeberangi sungai itu dengan sebuah sekoci (មើញើរ៉ាងី ស៊ូង៉ៃ អ៊ីទូ ឌើង៉ាន់ សឺប៊ូវ៉ះ សេកូជី);*

**2** ស្ពូល: *ម៉ាស៊ីនដេរនោះមិនរាបរយល្អ ដោយសារតែស្ពូលវាអស់ខ្សែ jahitan mesin itu tidak rapi karena sekocinya kehabisan benang (ចាហ៊ីតាន់ ម៉ែស៊ីន អ៊ីទូ ទីដាក់ រ៉ាពី កាអើណា សេកូជីញ៉ា កឺហាប៊ីសាន់ ប៊ឺណាំង)*

**sekolah** /សើកូឡះ/ *n* សាលារៀន: *ថ្នាក់ដំបូង; ថ្នាក់បឋម sekolah dasar (សើកូឡះ ដាសារ(r));*

**bersekolah** /ប៊ឺរ(r)សឺកូឡះ/

*v* ចូលសាលា: *គាត់ចាប់ផ្ដើមចូលសាលាតាំងពីអាយុ៥ឆ្នាំ dia mulai bersekolah sejak usia 5 tahun (ឌីយ៉ា មូ៉ឡៃ ប៊ឺរ(r)សឺកូឡះ សឺចាក់ អ៊ូស៊ីយ៉ា លីម៉ា តាហ៊ុន);*

**-- dasar** /សឺកូឡះ ដាសារ(r)/

បឋមសិក្សា: *វាចាប់ផ្ដើមរៀនសាលាបឋមសិក្សានៅអាយុ៧ឆ្នាំ*

*dia mulai masuk sekolah dasar di usia 7 tahun (ឌីយ៉ា មូ៉ឡៃ ម៉ាស៊ុក សឺកូឡះ ដាសារ(r) ឌិ អ៊ូស៊ីយ៉ា ទូជុះ តាហ៊ុន);*

**-- menengah atas (SMA)** /សឺកូឡះ មើនែង៉ះ អាតាស់(s) (SMA)/

វិទ្យាល័យ: *បន្ទាប់ពីបញ្ចប់វិទ្យាល័យ គាត់នឹងបន្តទៅថ្នាក់ឧត្តមសិក្សា setelah lulus Sekolah Menengah Atas dia akan melanjutkan ke Perguruan Tinggi (សឺទើឡះ លូលុស(ស) សឺកូឡះ មើនែង៉ះ អាតាស់(ស) ឌីយ៉ា អាកាន់ មើឡាន់ជុតកាន់ គើ ពើរ(r)ហ្គូរ៉ាន ទិងហ្គី);*

**-- menengah pertama (SMP)** /សឺកូឡះ មើនែង៉ះ ពើរ(r)តាម៉ា (SMP)/ អនុវិទ្យាល័យ: *បច្ចុប្បន្ន គាត់បានចូលអនុវិទ្យាល័យហើយ sekarang dia sudah menduduki Sekolah Menengah Pertama (សឺការ៉ាំង ឌីយ៉ា ស៊ូដះ មើនឌូឌូគី សឺកូឡះ មើនែង៉ះ ពើរ(r)តាម៉ា);*

**-- negeri** /សឹកូឡះ ណឺហ្គើរី/ សាលារដ្ឋ: *សាលារដ្ឋមានអ្នកចាប់អារម្មណ៍ច្រើន sekolah negeri lebih banyak peminatnya (សឹកូឡះ ណឺហ្គើរី លើប៊ិះ បាញ៉ាក់ ពើមីណាត់ញ៉ា);*

**-- swasta** /សឹកូឡះ ស្វាស្តា/ សាលាឯកជន: *កូនគាត់ឱ្យចូលរៀននៅសាលាឯកជន anaknya disekolahkan di sekolah swasta (អាណាក់ញ៉ា ឌិសឹកូឡះកាន់ ឌិ សឹកូឡះ ស្វាស្តា)*

**sekop** /សឹកុប/ *n* ចបជីក*: ជាមួយនឹងចបជីក យើងអាចងាយស្រួលកាយដី និងយកវាទៅបន្លែងផ្សេង dengan sekop orang mudah menggali dan memindahkan tanah (ឌើង៉ាន់ សឹកុប អូរ៉ាំង មូដះ មើងហ្គាលី ដាន់ មើមិនដះកាន់ តាណះ)*

**sekutu** /សឹគូទូ/ *n* **1** សម្ព័ន្ធមិត្ត: *ទ័ពសម្ព័ន្ធមិត្ត pasukan sekutu (ប៉ាស៊ូកាន់ សឹគូទូ)*; **2** ដៃគូរ: *គាត់ជាដៃគូរជំនួញរបស់ខ្ញុំ dia sekutu usaha saya (ឌីយ៉ា សឹគូទូ អ៊ូសាហា សាយ៉ា);*

**bersekutu** /ប៊ឺរ(r)សឹគូទូ/ *v* ដៃគូរ: *នៅក្នុងសង្គ្រាមអ៊ីរ៉ាក់ ប្រទេសអង់គ្លេសចាប់ដៃគូរនឹងសហរដ្ឋអាមេរិក dalam perang Irak, Inggris bersekutu dengan Amerika (ដាឡាំ ពើរ៉ាំង អ៊ីរ៉ាក់ អ៊ីងគ្រីស(ស) ប៊ឺរ(r)សឹគូទូ ឌើង៉ាន់ អាមេរីកា)*

**selalu** /សើឡាលូ/ *adv* តែងតែ: *តែងតែចាំ selalu ingat (សើឡាលូ អ៊ីង៉ាត់)*

**selamat** /សើឡាម៉ាត/ *a* សុវត្ថិភាព: *គាត់រួចផុតពីគ្រោះថ្នាក់ dia selamat dari bahaya (ឌីយ៉ា សើឡាម៉ាត ដារី បាហាយ៉ា)*

**selat** /សឹឡាត់/ *n* ច្រកសមុទ្រ: *ច្រកសមុទ្រលំបុក (Lombok) selat Lombok (សេឡាត់ ឡូមបុក)*

**selatan** /សឹឡាតាន់/ *n* ខាងត្បូង: *ទិសខាងត្បូងជាទិសដៅមួយរបស់ខ្យល់ selatan adalah salah satu arah mata angin (សឹឡាតាន់ អាដាឡះ សាឡះ សាទូ អារះ ម៉ាតា អាង៉ិន)*; *ផ្នែកខាងត្បូង bagian selatan (បាហ្គីយ៉ាន); ឆ្នេរខាងត្បូង pantai selatan (សើឡាតាន់)*

**selenggara, menyelenggarakan** /មើញឹឡឹងហ្គារ៉ាកាន់/ *v* ប្រារព្ធ;

**penyelenggara** /ពើញើឡឹងហ្កា៉រ៉ា/ *n* អ្នករៀបចំ: *អ្នករៀបចំកញ្ចប់ធ្វើទេសចរណ៍ penyelenggara perjalanan wisata (ពើញើឡឹងហ្កា៉រ៉ា ពើរ(r)ចា្យឡាណាន់ វីសាតា);*

**penyelenggaraan** /ពើញើឡឹងហ្កា៉រ៉ាអាន/ *n* ការរៀបចំ: *រៀបចំសន្និបាត penyelenggaraan kongres (ពើញើឡឹងហ្កា៉រ៉ាអាន់ កុនហ្គ្រែស(ស));*

**terselenggara** /ទើរ(r)សឺឡឹងហ្កា៉រ៉ា/ *v* ដំណើរការ: *កម្មវិធីនោះដំណើរការទៅបានដោយការខិតខំប្រឹងប្រែងពីគ្រប់ភាគី acara itu terselenggara atas kerja keras semua pihak (អាចា៉រ៉ា អ៊ីទូ ទើរ(r)សឺឡឹងហ្កា៉រ៉ា អាតាស់(ស) គើរ(r)ចា្យ គើរ៉ាស់(ស) សឺមួ៉ា ពីហាក់)*

**selesai** /សើលើសៃ/ *v* ចប់; រួចរាល់: *ការងារបានរួចរាល់ហើយ pekerjaan itu selesai (ពើគើរ(r)ចា្យអាន អ៊ីទូ សើលើសៃ);*

**menyelesaikan** /សើលើសៃ, ម៉ើញើឡើសៃកាន់/ *v* ដោះស្រាយ; ចប់

**selidik, menyelidiki** /មើញើលីឌិគី/ *v* ស៊ើបអង្កេត: *ប៉ូលីសកំពុងតែស៊ើបអង្កេតពីករណីអំពើឃាតកម្មនោះ polisi sedang menyelidiki perkara pembunuhan itu (ប៉ូលីស៊ី សឺដាំង មើញើលីឌិគី ពើរ(r)កា៉រ៉ា ពើមប៊ូនូហាន់ អ៊ីទូ)*

**selimut** /សឺលីមុត/ *n* ភួយ: *ភួយនេះមានប្រហោងច្រើនណាស់ selimut ini banyak lubangnya (សឺលីមុត អ៊ីនី បាញ៉ាក់ លូបាំងញ៉ា)*

**seling** /សឺលិង/ *v* ប្តូរ: *ពួកសិករបានប្តូរដំណាំស្រូវជាមួយនឹងសណ្តែកនិងពោត petani seling tanaman padinya dengan kacang dan jagung (ប៉ាក់ តានី សឺលីង តាណាំម៉ាន់ ប៉ាឌីញ៉ា ឌើង៉ាន់ កាចាំង ដាន់ ចា្យហ្គុង)*

**selingan** /សឺលីង៉ាន់/ *n* **1** ជំនួស: *កុំញ៉ាំតែបាយរហូត ត្រូវញ៉ាំនំប៉័ងជំនួសវិញ* *jangan makan nasi terus, makanlah roti sebagai selingan (ច្យាង៉ាន់ ម៉ាកាន់ ណាស៊ី ទើរុស(ស) ម៉ាកាន់ឡះរ៉ូទី សឺបាហ្គៃ សឺលីង៉ាន់)*; **2** សម្រាក: *បន្ទាប់ពីនឿយហត់នឹងការងារ ខ្ញុំត្រូវការសម្រាក* *setelah lelah bekerja, saya perlu selingan (សឺទើឡះ លើឡះ បឺគើរ(r)ច្យា សាយ៉ា ពើរ(r)លូ សឺលីង៉ាន់)*

**selip, menyelipkan** /មើញើលីពកាន់/ *v* បញ្ចូល: *គាត់បញ្ចូលលិខិតនោះនៅចន្លោះទំព័រសៀវភៅ* *dia menyelipkan surat itu di antara halaman buku (ឌីយ៉ា មើញ៉ើលីបកាន់ ស៊ូរ៉ាត់ អ៊ីទូ ឌិ អាន់តារ៉ា ហាឡាម៉ាន់ ប៊ូគូ)*;

**terselip** /ទើរ(r)សឺលីព/ *v* **1** បានបញ្ចូល: *លិខិតដែលខ្ញុំខំស្វែងរកនោះត្រូវបានបញ្ចូលក្នុងចន្លោះទំព័រសៀវភៅ* *surat yang saya cari-cari itu terselip di antara tumpukan buku (ស៊ូរ៉ាត់ យ៉ាំង សាយ៉ា ចារី–ចារី អ៊ីទូ ទើរ(r)សឺលីប ឌិ អាន់តារ៉ា ទុមពូកាន់ ប៊ូគូ)*; **2** ងាក; ង (ចង្កូត): *ភ្លាមៗនោះឡានខ្ញុំងចង្កូត* *tiba-tiba mobil saya terselip (ទីបា–ទីបា ម៉ូប៊ីល សាយ៉ា ទើរ(r)សឺលីប)*

**selisih** /សឺលីស៊ីស(s)/ *n* **1** ភាពខុសគ្នា: *គាត់ជារឿយៗឈ្លោះប្រកែកគ្នាជាមួយប្អូនប្រុសគាត* *dia sering selisih dengan adiknya* *ភាពខុសគ្នាលើប្រាក់ចំណូលក្រុមហ៊ុននើបានធ្លាក់ចុះយ៉ាងខ្លាំងឆ្នាំនេះ (ឌីយ៉ា ស៊ើរីង សឺលីស៊ីះ ឌើង៉ាន់ អាឌិគញ៉ា)*; *selisih laba perusahaan itu turun drastis tahun ini (សឺលីស៊ីះ ឡាបា ពើរូសាហាអាន អ៊ីទូ ទូរូន ដ្រាស្ទីស(ស) តាហ៊ុន អ៊ីនី)*; **2** ខុសគ្នា: *ទើតម្លៃខុសគ្នាប៉ុន្មាន* *berapa selisih harganya? (ប៊ឺរ៉ាប៉ា សឺលីស៊ីះ ហារ(r)ហ្គាញ៉ា)*;

**perselisihan** /ពើរ(r)សឺលីស៊ីហាន់/ *n* ជម្លោះ: *ជម្លោះនោះបានដោះស្រាយរួចរាល់ហើយ* *perselisihan itu berhasil diselesaikan (ពើរ(r)សឺលីស៊ីហាន់ អ៊ីទូ ប៊ឺរ(r)ហាស៊ីល ឌិសឺលើសៃកាន់)*;

**-- jalan** /សឺលីស៊ីស(s) ច្យាឡាន់/ ជួសផ្លូវ: *ភ្ញៀវដែលនឹងមកដល់នោះជួសផ្លូវជាមួយខ្ញុំនៅមុខប្លុកគេហដ្ឋាន* *tamu yang akan datang itu selisih jalan*

*denganku di depan kompleks (តាមូ យ៉ាំង អាកាន់ ដាតាំង អ៊ីទូ ស៊ីលីស៊ីះ ច្បាឡាន់ ឌើង៉ាន់គូ ឌិ ឌើប៉ាន់ កុំភ្លិក);*

**-- pendapat** /ស៊ីលីស៊ីស(s) ប៉ិនដាប៉ាត់/ មិនយល់ស្រប: *និស្សិតនោះមិនយល់ស្របនឹងសាស្ត្រាចារ្យបង្រៀនអំពីទ្រឹស្តីថ្មី mahasiswa itu selisih pendapat dengan dosennya tentang teori yang baru (ម៉ាហាស៊ីស្វា អ៊ីទូ ស៊ីលីស៊ីះ ប៉ិនដាប៉ាត់ ឌើង៉ាន់ ដូសែនញ៉ា តិនតាំង តេអូរី យ៉ាំង បារូ)*

**selokan** /ស៊ឡូកាន់/ *n* លូទឹកស្អុយ: *លូទឹកស្អុយនោះពេញទៅដោយសម្រាមរហូតធ្វើឲ្យទឹកមិនអាចហូរបាន selokan itu penuh dengan sampah sehingga airnya tidak lancar mengalir (ស៊ឡូកាន់ អ៊ីទូ ពើនុះ ឌើង៉ាន់ សាំប៉ះ ស៊ីហ៊ិងហ្គា អាយីរ(r)ញ៉ា ទីដាក់ ឡាន់ចារ(r) មើង៉ាលីរ(r))*

**seluk-beluk** /ស៊ីលុគ ប៊ីលុគ/ *n* សម្អិត: *យើងត្រូវពន្យល់ឲ្យបានលម្អិតពីបញ្ហានេះ kita perlu menjelaskan seluk-beluk masalah ini (គីតា ពើរ(r)លូ មិនចាឡាស្កាន់ ស៊ីលុគ–ប៊ីលUគ ម៉ាសាឡះ អ៊ីនី)*

**selundup, menyelundupkan** /មើញ៉ើលុនឌុពកាន់/ *v* រត់ពន្ធ: *មានមធ្យោបាយច្រើនណាស់ដើម្បីនាំយកទំនិញខុសច្បាស់ចូលក្នុងប្រទេសនោះ banyak cara yang dilakukan untuk menyelundupkan barang-barang ilegal ke negeri itu (បាញ៉ាក់ ចារ៉ា យ៉ាំង ឌិឡាគូកាន់ អ៊ុនទុក មើញ៉ើលុនឌុពកាន់ បារ៉ាំង–បារ៉ាំង អ៊ីឡេហ្គាល់ គើ ណឺហ្គើរី អ៊ីទូ);*

**penyelundup** /ពើញ៉ើលុនឌុព/ *n* អ្នករត់ពន្ធ: អ្នករត់ពន្ធទំនិញមានតម្លៃនោះត្រូវបានចាប់នៅកំពង់ផែ *penyelundup barang berharga itu tertangkap di pelabuhan (ពើញ៉ើលូឌូប៉ាន់ បារ៉ាំង ប៊ឺរ(r)ហារ(r)ហ្គា អ៊ីទូ ទើរ(r)តាំងកាប់ ឌិ ពើឡាប៊ូហាន);*

**penyelundupan** /ពើញ៉ើលុនឌូប៉ាន់/ *n* ការរត់ពន្ធ: *នៅតំបន់ព្រំប្រទល់ចចច្រើនកើតមានការរត់ពន្ធខុសច្បាប់ di daerah perbatasan banyak terjadi penyelundupan warga ilegal (ឌិ ដាអេរះ ពើរ(r)បាតាសាន់ បាញ៉ាក់ ទើរ(r)ច្បាឌិ ពើញ៉ើលុនឌូប៉ាន់ វ៉ារ(r)ហ្គា អ៊ីលីហ្គាល់)*

**seluruh** /ស៊ើលូរុះ/ *num* ទាំងមូល; ទាំងអស់: *អ្នកចូលរួមទាំងអស*

*seluruh peserta (សើល្វរុះ ប៉ើសើរ(r)តា)*;
*ពលរដ្ឋគ្រប់លំដាប់ថ្នាក់បានចូលរួមក្នុងពិធីជប់លៀងនោះ seluruh lapisan masyarakat hadir di pesta rakyat itu (សឺល្វរុះ ឡាពីសាន់ ម៉ាស្យារ៉ាកាត់ ហាឌីរ(r) ឌិ ពែស្តា រ៉ាក់យ៉ាត អ៊ីទូ)*;
*ជីវិតខ្ញុំទាំងមូលបានផ្តល់ដល់នាងហើយ seluruh hidupku telah kucurahkan pada dirinya (សឺល្វរុះ ហ៊ីឌុពគូ ទើឡះ គូជូរះកាន់ ប៉ាដា ឌិរីញ៉ា)*;

**-- dunia** /សឺល្វរុះ ឌូនីយ៉ា/ ពិភពលោកទាំងមូល:
*Muhammad Ali ត្រូវបានគេស្គាល់ទូទាំងពិភពលោក Muhammad Ali dikenal di seluruh dunia (មូហាំម៉ាត់ អាលី ឌិគើណាល់ ឌិ សឺល្វរុះ ឌូនីយ៉ា)*;

**menyeluruh** /មើញឺល្វរុះ/ *v* ទាំងមូល:
*ពុករលួយបានរាលដាលក្នុងប្រទេសនេះទាំងមូល korupsi sudah menyeluruh melanda negeri ini (គូរ៉ុបស៊ី ស៊ូដះ មើឡានដា ណើហ្គើរី អ៊ីនី)*

**seluruhnya** /សឺល្វរុះញ៉ា/
*adv* សរុបទាំងអស់:
*ចំនួនសិស្សក្នុងថ្នាក់នោះសរុបទាំងអស់២០នាក់ jumlah murid kelas itu seluruhnya ada 20 orang (ជូមម្លះ មូរីត គើឡាស់(ស) អ៊ីទូ សឺល្វរុះញ៉ា អាដា ឌូវ៉ាពូលុះ អូរ៉ាំង)*

**semak** /សឺម៉ាក់/ *n* ព្រៃ:
*ខ្លាបានលាក់ខ្លួននៅក្នុងព្រៃរង់ចាំចំណី harimau bersembunyi di balik semak menunggu calon mangsanya (ហារីម៉ៅរ បឺរ(r)សឹមប៊ូញី ឌិ បាលិគ សឺម៉ាក់ មើនុងហ្គូ ចាឡុន មុាំងសាញ៉ា)*

**semangat** /សឺម៉ាង៉ាត់/ *n* **1** ស្មារតី:
*គាត់បានបាត់បង់ស្មារតី dia telah kehilangan semangat (ឌីយ៉ា ទើឡះ គើហ៊ីឡាង៉ាន់ សឺម៉ាង៉ាត់)*; **2** ស្វាហាប់: *ធ្វើការដោយស្វាហាប់ semangat bekerja (សើម៉ាង៉ាត់ ប៉ឺកើរ(r)ចា្យ)*;

**bersemangat** /បឺរ(r)សឺម៉ាង៉ាត់/ *v* លើកទឹកចិត្តយ៉ាងខ្លាំង:
*គាត់ឧស្សាហ៍ ហើយស្វាហាប់ខ្លាំងណាស់ dia rajin dan sangat bersemangat (ឌីយ៉ា រ៉ាជិន ដាន់ សាង៉ាត់ បឺរ(r)សឺម៉ាង៉ាត់)*

**semarak** /សឺម៉ារ៉ាក់/ *a* រស់រវើក; ស្រស់ស្អាត:

*បន្ទប់នោះបានក្លាយជាស្រស់ស្អាត បន្ទាប់ពីធ្វើការរចនាកែលម្អ ruangan itu menjadi semarak setelah didekorasi (រ៉ូវ៉ាងង៉ាន់ អ៊ីទូ ម៉ិនចាឌិ សឺម៉ារ៉ាក់ សឺតើឡះ ឌិដេកូរ៉ាស៊ី);*

**menyemarakkan** /មើញើម៉ារ៉ាក់កាន់/ *v* ស្រស់ស្រាយ:

*ពួកគេបានធ្វើឱ្យពិធីជប់លៀងនោះស្រស់ស្រាយ ដោយការច្រៀង និងរាំ mereka menyemarakkan pesta itu dengan tarian dan nyanyian (មើរេកា មើញើម៉ារ៉ាក់កាន់ ប៉េស្តា អ៊ីទូ ឌើង៉ាន់ តារីយ៉ាន ដាន់ ញ៉ាញីយ៉ាន)*

**sembah, mempersembahkan** /មើមពើរ(r)សឺមបះកាន់/ *v* នាំមកបង្ហាញ:

*ពួកគេនឹងនាំមកបង្ហាញពីការសម្តែងមួយ mereka akan mempersembahkan sebuah sandiwara (មើរេកា អាកាន់ មើមពើរ(r)ស៊ឺមបះកាន់ សឺប៊ូវ៉ះ សានឌីវ៉ារ៉ា);*

**menyembah** /មើញើមបះ/ *v* គោរពសក្ការ:

*ពួកគេគោរពសក្ការៈចំពោះដូនតាដែលបានស្លាប់ទៅ ហើយ mereka menyembah pada leluhurnya yang sudah tiada (មើរេកា មើញើមបះ ប៉ាដា ឡឺលូហ៊ូរ(r)ញ៉ា យ៉ាំង ស៊ូដះ ទីយ៉ាដា);*

**persembahan** /ពើរ(r)សឺមបាហាន់/ *n* បទបង្ហាញ:

*ការសម្តែងរាំបានបង្ហាញនៅចំពោះមុខភ្ញៀវអ្នកមុខអ្នកការ persembahan tarian ditujukan kepada tamu kehormatan (ពើរ(r)សឺមបាហាន់ តារីយ៉ាន ឌិទូជូកាន់ គើប៉ាដា តាមូ គើហូរ(r)ម៉ាតាន់)*

**sembahyang** /សឺមបះយ៉ាំង/ *n* ថ្វាយបង្គំ:

*បន្ទាប់ពីថ្វាយបង្គំ ពួកគេអង្គុយនៅផ្នែកខាងមុខនៃវិហារ setelah sembahyang mereka duduk di bagian depan masjid (សឺតើឡះ សឺមបះយ៉ាំង មើរេកា ឌូឌុគ ឌិ បាហ្គីយ៉ាន ដើប៉ាន់ ម៉ាស្ជិត);*

**bersembahyang** /ប៊ឺរ(r)សឺមបះយ៉ាំង/ *v* ថ្វាយបង្គំ:

*នាងថ្វាយបង្គំប្រាំដងក្នុងមួយថ្ងៃ dia bersembahyang lima kali sehari (ឌីយ៉ា ប៊ឺរ(r)សឺមបះយ៉ាំង លីម៉ា កាលី សឺហារី)*

**sembarang** /សឹមបារ៉ាំង/ *a* ស្អីក៏បាន; ចម្រុះ *ជ្រើសចុះសម្លៀកបំពាក់ណាក៏បានតែចិត្តចង់ pilihlah sembarang baju sesuai keinginanmu (ពីលិះឡះ សឹមបារ៉ាំង បាជូ សឺស៊ូអ៊ែ គើអ៊ីងីណាន់មូ)*

**sembilan** /សឹមប៊ីឡាន់/ *num* ប្រាំបួន (៩): *លំដាប់ទីប្រាំបួនទទួលបានរង្វាន់ប្រាំលានរូពីយ៉ាស់ peringkat sembilan mendapat hadiah lima juta rupiah (ពើរិងកាត់ សឹមប៊ីឡាន់ មិនដាប៉ាត់ ហាឌិយ៉ះ លីម៉ា ជូតា រូពីយ៉ះ);*

**-- belas** /សឹមប៊ីឡាន់ ប៊ឺឡាស់(s)/ ដប់ប្រាំបួន (១៩): *ផ្ទះគាត់លេខដប់ប្រាំបួន rumahnya nomor sembilan belas (រូម៉ះញ៉ា ណូម៉ូរ(r) សឹមប៊ីឡាន់ ប៊ឺឡាស់(ស));*

**-- puluh** /សឹមប៊ីឡាន់ ពូលុះ/ កៅសិប (៩០): *អ្នករាំកៅសិបអ្នកបានចូលរួមអបអរសាទរពិធីគម្រប់ខួបទីក្រុងនោះ sembilan puluh orang penari ikut meramaikan acara ulang tahun kota itu (សឹមប៊ីឡាន់ ពូលុះ អូរ៉ាំង ពើណារី អ៊ីគុត មើរ៉ាម៉ៃកាន់ អាចារ៉ា អ៊ូឡាំង តាហ៊ុន កូតា អ៊ីទូ);*

**-- puluhan** /សឹមប៊ីឡាន់ ពូលូហាន់/ កៅសិបជាង: *ចំនួនមាន់គាត់ប្រហែលជាជាងកៅសិបក្បាល jumlah ayamnya sekitar sembilan puluhan ekor (ជូមឡះ អាយ៉ាំញ៉ា សឺគីតារ(r) សឹមប៊ីឡាន់ ពូលូហាន់ អេកូរ(r));*

**-- ratus** /សឹមប៊ីឡាន់ រ៉ាទុស(s)/ ប្រាំបួនរយ (៩០០): *តម្លៃស្ករគ្រាប់នេះប្រាំបួនរយរូពីយ៉ាស់ harga permen ini sembilan ratus rupiah (ហារ(r)ហ្គា ពើរ(r)ម៉ែន អ៊ីនី សឹមប៊ីឡាន់ រ៉ាទុស(ស) រូពីយ៉ះ);*

**-- ribu** /សឹមប៊ីឡាន់ រីប៊ូ/ ប្រាំបួនពាន់ (៩០០០): *លុយក្នុងកាបូបគាត់ត្រឹមតែប្រាំបួនពាន់ uang di dompetnya hanya sembilan ribu (អ៊ូអាំង ឌិ ដិមប៉ិតញ៉ា ហាញ៉ា ស៊ឹមប៊ីឡាន់ រីប៊ូ)*

**sembuh** /សឹមប៊ុះ/ *v* ជាសះស្បើយ: *សូមឱ្យបានជាសះស្បើយ semoga lekas sembuh (សឺម៉ូហ្គា លើកាស់(ស) សឹមប៊ុះ); គាត់បានជាសះស្បើយហើយ dia sudah sembuh (ឌីយ៉ា ស៊ូដះ សឹមប៊ុះ);*

**menyembuhkan**
/មើញើមប៊ុះកាន់/ *v* ព្យាបាល:

*ដុកទ័រមិនទាន់អាចព្យាបាលជម្ងឺអេដស៍បានទេ*

*dokter belum dapat menyembuhkan penyakit AIDS (ដុកទើរ(r) ប៊ឺលុម ដាប៉ាត់ មើញើមប៊ុះកាន់ ពើញ៉ាគីត AIDS);*

**penyembuhan**
/ពើញើមប៊ូ/ *n* ព្យាបាល:

*ត្រូវការពេលវេលាយូរដើម្បីព្យាបាលជម្ងឺគាត់*

*perlu waktu lama untuk penyembuhan penyakitnya (ពើរ(r)លូ វ៉ាក់ទូ ឡាម៉ា អ៊ុនទុក ពើញើមប៊ូហាន់ ពើញ៉ាគីតញ៉ា)*

**sembunyi, bersembunyi**
/ប៊ឺរ(r)សឹមប៊ូញី/ *v* លាក់:

*គាត់បានលាក់ខ្លួននៅក្រោយឆាក dia bersembunyi di balik layar (ឌីយ៉ា ប៊ឺរ(r)សឹមប៊ូញី ឌិ បាលិគ ឡាយ៉ារ(r));*

**menyembunyikan**
/មើញើមប៊ូញីកាន់/ *v* លាក់ មនុស្សចាស់:

*តែងតែលាក់លុយពីក្រោមខ្នើយ orang tua itu menyembunyikan uang di balik bantal (អូរ៉ាំង ទូវ៉ា អ៊ីទូ មើញើមប៊ូញីកាន់ អ៊ូវ៉ាំង ឌិ បាលីគ បានតាល់);*

**persembunyian**
/ពើរ(r)សឹមប៊ូញីយ៉ាន់/ *n* លាក់ខ្លួន:

*កន្លែងលាក់ខ្លួនគាត់ត្រូវបានគេដឹងហើយ*

*tempat persembunyiannya sudah diketahui (ទើមប៉ាត់ ពើរ(r)សឹមប៊ូញីយ៉ានញ៉ា ស៊ូដះ ឌិគើតាហ៊ូវី);*

**tersembunyi**
/ទើរ(r)សឹមប៊ូញី/ *v* បង្កប់:

*ម្នាក់នោះមានបង្កប់ន័យ orang itu mempunyai maksud tersembunyi (អូរ៉ាំង អ៊ីទូ មើមពូញ៉ៃ ម៉ាក់ស៊ុត ទើរ(r)សឹមប៊ូញី);*

*កាំភ្លើងត្រូវបានបង្កប់នៅក្នុងអាវធំគាត់ pistol itu tersembunyi di balik jasnya (ពីស្តុល អ៊ីទូ ទើរ(r)សឹមប៊ូញី ឌិ បាលិគ ចាស់ញ៉ា)*

**sembur, menyembur**
/មើញឹមប៊ូរ(r)/ *v* ហូរ:

*ប្រេងនៅហូរចេញពីអណ្តូងប្រេងថ្មី minyak mentah menyembur dari sumur yang baru digali itu (មីញ៉ាក់ មើនតះ មើញើមប៊ូរ(r) ដារី ស៊ូមូរ(r) យ៉ាំង បារូ ឌិហ្គាលី អ៊ីទូ)*

**semen** /សឺម៉ិន/ *n* ស៊ីម៉ង់ត៍:

*នៅទីក្រុងគ្រេសិកមានរោងចក្រស៊ីម៉ងត៍*

*di kota Gresik ada pabrik semen (ឌិ កូតា ហ្គ្រេស៊ីត អាដា ប៉ាព្រិត សេម៉ែន)*

**semenanjung** /សឹមើណាន់ជុង/ *n* ឧបទ្វីប:

*ឧបទ្វីបម៉ាឡេស៊ី semenanjung Malaya (សឹមើណាន់ជុង ម៉ាលេស៊ីយ៉ា)*

**sementara** /សើមឹនតារ៉ា/ *n* បណ្ដោះអាសន្ន:

*ការងារបណ្ដោះអាសន្ន pekerjaan sementara (ប៉ឺកើរ(r)ចាអាន សើមឹនតារ៉ា);*

*ខ្ញុំរស់នៅក្នុងផ្ទះប្អូនខ្ញុំបណ្ដោះអាសន្នសិនប៉ុណ្ណោះ saya tinggal di rumah adik saya sementara saja (សាយ៉ា ទិហ្គាល់ ឌិ រូម៉ះ អាឌិក សាយ៉ា សើម៉ឹនតារ៉ា សាឡា);*

*ច្បាប់នេះមានលក្ខណៈបណ្ដោះអាសន្នប៉ុណ្ណោះ peraturan ini sifatnya hanya sementara (ពើរ៉ាទូរ៉ាន់ អ៊ីនី ស៊ីហ្វាត់ញ៉ា ហាញ៉ា សឹម៉ឹនតារ៉ា)*

**sementara itu** /សើមឹនតារ៉ា អ៊ីទូ/ ជាបណ្ដោះអាសន្ន: *ជាបណ្ដោះអាសន្ន, ខ្ញុំនៅតែធ្វើការ sementara itu, saya tetap bekerja (សើមឹនតារ៉ា អ៊ីទូ សាយ៉ា តើតាប់ បើកើរ(r)ចា)*

**semesta** /សឹមែស្តា/ *n* ទាំងមូល:

*ពិភពលោកទាំងមូល alam semesta (អាឡាំ សឹមែស្តា)*

**semir** /សឹមីរ(r)/ *n* ប្រដាប់ខាត់:

*គាត់ទិញប្រដាប់ខាត់នៅហាងនោះ ia membeli semir di toko itu (អ៊ីយ៉ា មើមប៊ឺលី សឹមីរ(r) ឌិ តូកូ អ៊ីទូ);*

**-- sepatu** /សឹមីរ(r)សឹប៉ាទូ/ ប្រដាប់ខាត់ស្បែកជើង:

*ប្រដាប់ខាត់ស្បែកជើងនេះមានពណ៌សូកូឡា semir sepatu ini berwarna cokelat (សឹមីរ(r) សឹប៉ាទូ អ៊ីនី បឺរ(r)វ៉ារ(r)ណា ចូកូឡិត);*

**menyemir** /មើញើមីរ(r)/ *v* ខាត់:

*គាត់ខាត់ស្បែកជើងដើម្បីឱ្យមើលទៅថ្មី ia menyemir sepatunya agar tampak baru (អ៊ីយ៉ា មើញើមីរ(r) សឹប៉ាទូញ៉ា អាហ្គារ(r) តាំប៉ាក់ បារូ)*

**sempat** /សឹមប៉ាត់/ *v* ឆ្លៀតពេល:

*ទោះជាមមាញឹកយ៉ាងណាក៏ដោយ ខ្ញុំនៅតែឆ្លៀតពេលសរសេរសំបុត្រ walaupun sibuk sekali, saya masih sempat menulis surat (វ៉ាឡោវពុន ស៊ីប៊ុក សឹកាលី សាយ៉ា ម៉ាស៊ីះ សឹមប៉ាត់ មើនូលីស(ស) ស៊ូរ៉ាត់);*

**kesempatan** /សឹមប៉ាត់, កឹសឹមប៉ាត់តាន់/ *n* ឱកាសៈ *ឱកាសល្អ kesempatan bagus (កឹសឹមប៉ាត់តាន់ បាហ្គុស(s))*

**sempit** /សឹមពិត/ *a* **1** ចង្អៀតៈ *ច្រកចង្អៀត gang sempit (ហ្កាំង សឹមពិត)*; **2** ខ្លី; មានកំណត់ៈ *ពេលវេលារបស់ខ្ញុំមានកំណត់ waktu saya sempit* (វ៉ាក់ទូ សាយ៉ា សឹមពិត); **3** តូច; ចង្អៀតៈ *សម្លៀកបំពាក់ដែលចង្អៀតនោះគាត់នៅតែប្រើ baju yang sempit itu masih dipakainya (បាជូ យ៉ាំង ស៊ឹមពិត អ៊ីទូ ម៉ាស៊ីះ ឌិប៉ាកៃញ៉ា)*

**semprot, menyemprot** /មើញ៉ឹមប្រុត/ *v* ស្រោច; បាញ់ៈ *ខ្ញុំបាញ់ដំណាំជាមួយថ្នាំសម្លាប់សត្វល្អិត saya menyemprot tanaman itu dengan pestisida (សាយ៉ា មើញើមប្រុត តាណាំម៉ាន់ អ៊ីទូ ឌើង៉ាន់ ប៉េស្ទីស៊ីដា)*;

**semprotan** /សឹមប្រោតាន់/ *n* ប្រដាប់ស្រោច; ប្រដាប់បាញ់ៈ *ប្រដាប់បាញ់បានខូច ចាំជួសជុលវា semprotannya rusak, nanti dibetulkan (សឹមប្រូតាន់ញ៉ា រូសាក់ ណាន់ទី ឌិប៊ឺទុលកាន់)*

**sempurna** /សឹមពូរ(r)ណា/ *a* **1** ល្អឥតខ្ចោះ; រួចរាល់ស្រួលបួលៈ *អ្នកដំណើរត្រូវបានស្នើរសុំឲ្យនៅអង្គុយរហូតដល់យន្តហោះបានចុះចតរួចរាល់ស្រួលបួលសិន para penumpang diminta untuk tetap duduk sampai pesawat berhenti dengan sempurna (ប៉ារ៉ា ពើនុមប៉ាំង ឌិមីនតា អ៊ុនទុក ទើតាប់ ឌូឌុក សាំប៉ៃ ពើសាវ៉ាត់ ប៊ឺរ(r)ហិនទី ឌើង៉ាន់ សឹមពូរ(r)ណា)*; **2** ឥតខ្ចោះៈ *ការងារល្អឥតខ្ចោះ pekerjaan sempurna (ប៉ើកើរ(r)ចាអាន សឹមពូរ(r)ណា)*

**semua** /សើមូវ៉ា/ *num* **1** ទាំងអស់ៈ *ក្មេងៗទាំងអស់ semua anak (សើមុវ៉ា អាណាក់)*; *សិស្សទាំងអស់ទើបតែតម្រង់ជួរនៅទីលានកម្មវិធី semua murid baru berbaris di lapangan upacara (សឺមូវ៉ា មូរីត បារូ ប៊ឺរ(r)បារីស(ស) ឌិ ឡាប៉ាង៉ាន់ អ៊ូប៉ាចារ៉ា)*; **2** រាល់; គ្រប់ៈ *រាល់ភ្ញៀវដែលបានអញ្ជើញបានមកចូលរួមពិធីជប់លៀងនោះ semua tamu undangan datang ke pesta itu (សឺមូវ៉ា តាមូ អ៊ុនដាង៉ាន់ ដាតាំង គើ ប៉េស្តា អ៊ីទូ)*

**semut** /សឺមុត/ *n* ស្រមោច: *សំបុកស្រមោច sarang semut (សារ៉ាំង សឺមុត)*;

**kesemutan** /គើសឺមូតាន់/ *n* ស្ពឹក: *ម្រាមដៃខ្ញុំស្ពឹក jari tangan saya kesemutan (ច្យារី តាង៉ាន់ សាយ៉ា គើសឺមូតាន់)*

**senam** /សឺណាម/ *n* កាយសម្ព័ន្ធ: *គាត់ចូលរួមប្រកួតកាយសម្ព័ន្ធ ia mengikuti lomba senam (អ៊ីយ៉ា មើងីគូទី ឡុមបា សឺណាំ)*

**senang** /សើណាំង/ *a* សប្បាយ: *ខ្ញុំសប្បាយចិត្ត saya senang (សាយ៉ា សើណាំង)*;

**kesenangan** /សើណាំង, គើសើណាង៉ាន់/ *n* ភាពរីករាយ: *ភាពរីករាយផ្ទាល់ខ្លួន kesenangan pribadi (គើសើណាង៉ាន់ ព្រីបាឌី)*;

**menyenangkan** /សើណាំង, ម៉ើញើណាំងកាន់/ *v* រីករាយ: *រីករាយដែលបានស្គាល់អ្នក menyenangkan berkenalan dengan Anda (ម៉ើញើណាំងកាន់ ប៊ើកើរ(r)ណា ដឹង៉ាន់ អានដា)*

**senapan** /សឺណាប៉ាន់/ *n* កាំភ្លើង: *កាំភ្លើងនោះជាកេរ្តិ៍ឪពុកគាត់ senapan itu warisan ayahandanya (សេណាប៉ាន់ អ៊ីទូ វ៉ារីសាន់ អាយ៉ាហាន់ដាញ៉ា)*;

**-- angin** /សឺណាប៉ាន់ អាងិន/ កាំភ្លើងខ្យល់: *គាត់បាញ់ចាបជាមួយកាំភ្លើងខ្យល់ ia menembak burung dengan senapan angin (អ៊ីយ៉ា មើណែមបាក់ ប៊ូរុង ឌើង៉ាន់ សេណាប៉ាន់ អាងិន)*

**senda, bersenda gurau** /ប៊ឺរ(r)សិនដា ហ្គូរ៉ៅ/ *v* និយាយលេង: *ពួកគេនិយាយលេងនៅឯសួនច្បារ mereka bersenda gurau di taman (មើរេកា ប៊ឺរ(r)សិនដា ហ្គូរ៉ៅ ឌិ តាណាំ)*

**sendat, tersendat** /ទើរ(r)សិនដាត់/ *v* ស្ទះ: *តាមផ្លូវស្ទះដោយសារតែមានការជួសជុលផ្លូវ jalanan tersendat karena ada perbaikan jalan (ច្យាឡាណាន់ ទើរ(r)សិនដាត់ ការើណា អាដា ពើរ(r)បាអ៊ីគកាន់ ច្យាឡាន់ )*

**sendi** /សែនឌី/ *n* **1** សន្លាក់: *សន្លាក់ជង្គង់*

*sendi lutut (សែនឌី លូទុត)*;

**2** មូលដ្ឋាន

**sendiri** /សិនឌីរី/ *a* ឯការ; ម្នាក់ឯង; ខ្លួនឯង:

*ទៅម្នាក់ឯង* pergi sendiri *(ប៉ឺរ(r)ហ្គី សិនឌីរី )*

**sendok** /សេនដុក/ *n* ស្លាបព្រា: *ស្លាបព្រាតែ*

*sendok teh (សេនដុក តែះ);*

**-- makan** /សិនដុក ម៉ាកាន់/

ស្លាបព្រាញុាំ: *ស្លាបព្រាញុាំនោះធ្វើពីមាស*

*sendok makan itu terbuat dari emas (សែនដុក ម៉ាកាន់ អ៊ីទូ ទើរ(r)ប៊ូវ៉ាត់ ដារី អេម៉ាស់(ស));*

**-- nasi** /សិនដុក ណាស៊ី/ ស្លាបព្រាបាយ:

*គាត់យកបាយដោយប្រើស្លាបព្រាបាយ dia mengambil nasi dengan sendok nasi itu (ឌីយ៉ា មើងាំប៊ីល ណាស៊ី ឌើង៉ាន់ សិនដុក អ៊ីទូ);*

**-- teh** /សិនដុកៈ តេះ/ ស្លាបព្រាតែ:

*គាត់ថែមស្ករមួយស្លាបព្រាតែចូលក្នុងទឹកផឹកគាត់ dia menambahkan gula satu sendok teh pada minumannya (ឌីយ៉ា មើណាំបះកាន់ ហ្គូឡា សាទូ សិនដុក តែស(ស) ប៉ាដា មីនូម៉ាន់ញ៉ា)*

**sengaja** /សឹង៉ាច្យា/ *v* ចេតនា: *ដោយចេតនា*

*dengan sengaja (ឌើង៉ាន់ សឹង៉ាច្យា);*

**kesengajaan** /គើសឹង៉ាច្យាអាន/

*n* ដោយចេតនា:

*ភ្លើងឆេះព្រៃនោះដូចជាកើតឡើងដោយចេតនា*

*kebakaran hutan itu merupakan kesengajaan (គើបាការ៉ាន់ ហ៊ូតាន់ អ៊ីទូ មើរូប៉ាកាន់ គើសឹង៉ាច្យាអាន)*

**senggang** /សឹងហ្គាង/ *a* **1** ទៅសល់:

*ខ្ញុំអត់មានពេលទៅសល់ទេ* saya tidak ada waktu senggang *(សាយ៉ា ទីដាក់ អាដា វ៉ាក់ទូ សឹងហ្គាំង)*; **2** ទំនេរ:

*ពេលណាក៏បានឲ្យតែអ្នកទំនេរ អ្នកអាចមកផ្ទះខ្ញុំ*

*kapan saja bila kamu senggang, datanglah ke rumah (កាប៉ាន់ សាច្យា ប៊ីឡា កាមូ សឹងហ្គាំង ដាតាំងឡះ គើ រូម៉ះ)*

**senggol, bersenggol-senggolan**

/បឺរ(r)សឹងហ្គុល សឹងហ្គូឡាន់/ *v* ច្រានគ្នា; រុញគ្នា: *នៅផ្សាររាត្រី ក្មេងៗរុញគ្នាលេងដើម្បីសប្បាយ di pasar malam anak-anak muda sering bersenggol-senggolan (ឌិប៉ាសារ(r) ម៉ាឡាំ អាណាក់–អាណាក់ មូដា សឺរិង បឺរ(r)សែងហ្គុល សែងហ្គូឡាន់);*

**menyenggol** /មើញ៉ឹងហ្គុល/ *v* រុញ: *នាងរុញខ្ញុំពេកខ្ញុំកំពុងងងុយគេង dia menyenggol saya waktu saya mengantuk (ឌីយ៉ា មើញ៉ែងហ្គុល សាយ៉ា វ៉ាក់ទូ សាយ៉ា មើង៉ាន់ទុក);*

**tersenggol** /ទើរ(r)សឹងហ្គុល/ *v* ច្រាន: *ខ្ញុំគ្រាន់តែច្រានបន្តិចសោះក៏ខឹងដែរ tersenggol sedikit saja kok terus marah (ទើរ(r)សែងហ្គុល សឺឌិគិត សាចា្យ កុក ទើរុស(ស) ម៉ារះ)*

**sengketa** /សឹងគេតា/ *n* ជម្លោះ *ជម្លោះរវាងប្រទេសប៉ាឡេស្ទីន និងអ៊ីស្រាអែល បានចាប់ផ្ដើមយូរលង់ណាស់មកហើយ sengketa antara Palestina dan Israel sudah lama berlangsung (សិងកេតា អានតារ៉ា ប៉ាលេស្ទីណា ដាន់ អ៊ីស្រាអែល ស៊ូដះ ឡាម៉ា បឺរ(r)ឡាំងស៊ុង)*

**sengketa, bersengketa** /បឺរ(r)សឹងគេតា/ *v* ឈ្លោះគ្នា, មានរឿង: *គាត់ជាក្មេងល្អ គាត់មិនដែលឈ្លោះគ្នានឹងមិត្តភក្ដិគាត់ទេ dia anak baik-baik, tidak pernah bersengketa dengan teman-temannya (ឌីយ៉ា អាណាក់ បាអ៊ីគ–បាអ៊ីគ ទីដាក់ពើរ(r)ណះ បឺរ(r)សិងកេតា ឌើង៉ាន់ ទើម៉ាន់–ទើម៉ាន់ញ៉ា)*

**sengsara** /សឹងសារ៉ា/ *a* វេទនា: *ជីវិតគាត់វេទនា hidupnya sengsara (ហ៊ីឌុពញ៉ា សឹសារ៉ា);*

**kesengsaraan** /គើសឹងសារ៉ាអាន/ *n* ទុក្ខវេទនា: *គ្រោះធម្មជាតិ និងសង្គ្រាមបងប្អូន បាននាំមកនាំទុក្ខវេទនាជាច្រើន bencana alam dan perang saudara membawa banyak kesengsaraan (បិនចាណា អាឡាំ ដាន់ ពើរ៉ាំង សៅដារ៉ា មើមបាវ៉ា បាញ៉ាក់ គើសឹងសារ៉ាអាន)*

**seni** /សឺនី/ *n* សិល្បៈ: *ស្នាដៃសិល្បៈ karya seni (ការ(r)យ៉ា សែនី);*

**kesenian** /គើសឺនីយ៉ាន/ *n* វិចិត្រសិល្ប: *រាត្រីវិចិត្រសិល្ប: malam kesenian (ម៉ាឡាំ គើសឺនីយ៉ាន);*

**seniman** /សឺនីម៉ាន់/ *n* សិល្បករ: *គាត់ជាសិល្បកររបាំ dia seorang seniman tari (ឌីយ៉ា សឺអូរ៉ាំង សឺនីម៉ាន តារី)*

**senja** /សឺនចា្យ/ *n* ព្រលប់: *ព្រលប់បានខិតជិតមកដល់ senja sudah menjelang (សិនចា្យ ស៊ូដះ មើនជើឡាំង)*

**senjata** /សិនចាតា/ *n* អាវុធ: *បុរសម្នាក់នោះបាននាំអាវុធ pria itu membawa senjata (ព្រីយ៉ា អ៊ីទូ មើមបាវ៉ា សិនចាតា);*

**-- api** /សឺនចា្យតា អាពី/ អាវុធ: *ប៉ូលិសត្រូវបានបំពាក់ដោយអាវុធ polisi berdinas dilengkapi dengan senjata api (ប៉ូលីស៊ី ប៊ឺរ(r)ឌីណាស់ ឌិឡឹកាពី ឌើង៉ាន់ សិនចា្យតា អាពី);*

**persenjataan** /ពើរ(r)សឺនចា្យតាអាន/ *n* អាវុធ: *អាវុធយុទ្ធភ័ណ្ឌធម្មតាសម្រាប់លើគោក, ក្នុងទឹក និងលើអាកាស persenjataan konvensional untuk darat, laut, dan udara (ពើរ(r)សិនចា្យតាអាន កុនវ៉ែនស្យូណាល់ អ៊ុនទុក ដារ៉ាត់ ឡាអ៊ុត ដាន់ អ៊ូដារ៉ា)*

**sentak, menyentak** /មើញ៉ិនតាក់/ *v* ប៉ះ;

**tersentak** /ទើរ(r)សឺនតាក់/ *v* កន្ត្រាក់; ភ្ញាក់: *គាត់បានភ្ញាក់ពីគេង dia tersentak dari tidurnya (ឌីយ៉ា ទើរ(r)សិនតាក់ ដារី ទីឌួរ(r)ញ៉ា)*

**senter** /សិនតើរ(r)/ *n* ភ្លើងពិល: *ភ្លើងពិលធម្មតាប្រើថ្ម lampu senter biasanya memakai baterai (ឡាំពូញ៉ា សិនតើរ(r) ប៊ីយ៉ាសាញ៉ា មើម៉ាកៃ បាទើរ៉ៃ)*

**sentuh** /សិនទុះ/ *v* ប៉ះ: *កុំប៉ះខ្ញុំ jangan sentuh aku! (ចា្យង៉ាន់ សិនទុះ អាគូ);*

**menyentuh** /មើញ៉ិនទុះ/ *v* **1** ប៉ះ: *កុំប៉ះម្ហូបអាហាររបស់អ្នកដទៃ jangan menyentuh makanan milik orang lain (ចា្យង៉ាន់ មើញ៉ិនទុះ ម៉ាកាណាន មីលិគ អូរ៉ាំង ឡាអ៊ិន); **2** ទង្គិច; ប៉ះ; ចុច ខ្ញុំបានប៉ះប៊ូតុងនោះដោយអចេតនា saya tidak sengaja menyentuh tombol itu*

*(សាយ៉ា ទីដាក់ សេង៉ាច្យា មើញ៉ិនទុះ តុមបុល អ៊ីទូ);*

**~ hati** /មើញ៉ិនទុះ ហាទី/ ប៉ះ: *រឿងនិទានដែលប៉ះពាល់ដល់អារម្មណ៍ kisah yang menyentuh hati (គីសះ យ៉ាំង មើញ៉ិនទុះ ហាទី);*

**sentuhan** /សិនទូហាន់/ *n* ប៉ះ: *បេះដូងរបស់ខ្ញុំញាប់ញ័រនៅពេលប៉ះដៃក្មេងស្រីដ៏ស្រស់ស្អាត sentuhan tangan gadis cantik itu mendebarkan hati saya (សិទូហាន តាង៉ាន ហ្កាឌិស(ស) ចាន់ទិគ អ៊ីទូ មើនឌើបារ(r)កាន់ ហាទី សាយ៉ា);*

**tersentuh** /ទើរ(r)សឺនទុះ/ *v* រន្ធត់: *ចិត្តខ្ញុំរន្ធត់យ៉ាងខ្លាំងដោយសារហេតុការណ៍នោះ hati saya tersentuh oleh kejadian itu (ហាទី សាយ៉ា ទើរ(r)សិនទុះ អូលេះ គើច្យាឌីយ៉ាន អ៊ីទូ)*

**senyum** /សើញូម/ *n* ញញឹម: *ទឹកមុខញញឹម senyum lebar (សើញូម ឡេបារ(r));*

**senyuman** /សឺញូម៉ាន់/ *n* ស្នាមញញើម: *ខ្ញុំឃើញស្នាមញញើមនៅលើមុខរបស់គាត់ saya melihat senyuman di wajahnya (សាយ៉ា មើលីហាត់ សឺញូម៉ាន ឌិ វ៉ាច្យ៉ះញ៉ា);*

**tersenyum** /ទើរ(r)សឺញូម/ *v* ញញើមដាក់: *នារីដ៏ស្រស់ស្អាតនោះញញើមដាក់អ្នក wanita cantik itu tersenyum padamu (វ៉ានីតា ចាន់ទិគ អ៊ីទូ ទើរ(r)សេញូម ប៉ាដាមូ)*

**sepak bola** /សើប៉ាក់ បូឡា/ *n* បាល់ទាត់: *ទីលានបាល់ទាត់ stadion sepak bola (សើតាឌីយ៉ូន សើប៉ាក់ បូឡា)*

**sepatu** /សើប៉ាទូ/ *n* ស្បែកជើង: *ស្បែកជើងបាល់ទាត់ sepatu sepak bola (សើប៉ាទូ សើប៉ាក់ បូឡា);*

**bersepatu** /បឺរ(r)សឺប៉ាទូ/ *v* ពាក់ស្បែកជើង: *អត់ពាក់ស្បែកជើង tidak bersepatu (ទីដាក់ បឺរ(r)សឺប៉ាទូ);*

**-- roda** /សឺប៉ាទូ រ៉ូដា/ ស្បែកជើងស្គី: *ដើរលើផ្លូវដែលរលោងជាមួយនឹងស្បែកជើងស្គី berjalan di atas permukaan halus dengan sepatu roda (បឺរ(r)ច្យាឡាន់ ឌិ អាតាស់(ស) ពើរ(r)មូកាអាន ហាលុស(ស) ឌើង៉ាន់ សឺប៉ាទូ រ៉ូដា)*

**sepeda** /សើប៉េដា/ *n* កង់: *កង់ដែលបានកង់បី* *sepeda roda tiga* (*សើប៉េដា រ៉ូដា ទីហ្កា*);

**-- motor** /សឺពេដា ម៉ូតូរ(r)/ ម៉ូតូ ការប្រណាំងម៉ូតូ *balapan sepeda motor* (*បាឡាប៉ាន់ សឺពេដា ម៉ូតូរ(r)*);

**bersepeda** /បឺរ(r)សឺពើដា/ *v* ជិះកង់: *គាត់ជិះកង់ទៅសាលារៀនរាល់ថ្ងៃ* *dia bersepeda ke sekolah setiap hari* (*ឌីយ៉ា បឺរ(r)សឺពេដា គើ សឺកូឡះ សឺទីយ៉ាប ហារី*)

**sepele, menyepelekan** /មើញើពេលេកាន់/ *v* មើលស្រាល: *កុំមើលស្រាលឪពុកម្ដាយរបស់អ្នក* *jangan menyepelekan orang tua* (*ចា្យង៉ាន់ មើញើពេលេកាន់ អូរ៉ាំង ទូវ៉ា*)

**seperti** /សើប៉ើរ(r)ទី/ *p* **1** ដូចជា: *ខ្ញុំញ៉ាំផ្លែឈើដូចជាផ្លែប៉ោម ផ្លែស្វាយ និងម្នាស់* *saya makan buah-buahan seperti apel, mangga, dan nanas* (*សាយ៉ា ម៉ាកាន់ ប៊ូវ៉ះ–ប៊ូវ៉ះហាន់ សើប៉ើរ(r)ទី អាប៉ែល, ម៉ាំង ហ្កា, ដាន់ ណាណាស់(s)*);

**2** ដូចធម្មតា; ដូចជា: *គាត់ត្រឡប់មកធ្វើការដូចធម្មតា* *dia kembali bekerja seperti biasa* (*ឌីយ៉ា គើមបាលី បឺគើរ(r)ចា្យ សឺពើរ(r)ទី ប៊ីយ៉ាសា*); **3** ដូច; ដូចគ្នានឹង: *អ្នកដូចគ្នានឹងប្អូនអ្នកចឹង* *kamu ini seperti adikmu* (*កាមូ អ៊ីនី សឺពើរ(r)ទី អាឌិគមូ*);

**-- biasa** /សឺពើរ(r) ទីប៊ីយ៉ាសា/ ដូចធម្មតា; ជាធម្មតា: *ជាធម្មតាម៉ាក់មកយឺតជាងគេរហូត* *seperti biasa ibu datang paling telat* (*សឺពើរ(r)ទី ប៊ីយ៉ាសា អ៊ីប៊ូ ដាតាំង ប៉ាលិង ទើឡាត់*)

**sepi** /សើពី/ *a* ស្ងាត់: *បរិយាកាសស្ងប់ស្ងាត់* *suasana sepi* (*ស៊ូវ៉ាសាណា សើពី*);

**kesepian** /គើសឺពីយ៉ាន់/ *n* ឯកា: *គាត់មានអារម្មណ៍ឯកា ខណៈគាត់នៅចំកណ្ដាលទីក្រុងដ៏អរអរនេះ* *dia merasa kesepian di tengah kota yang ramai ini* (*ឌីយ៉ា មើរ៉ាសា កេសឺពីយ៉ាន ឌិ ទើង៉ះ កូតា យ៉ាំង រ៉ាម៉ៃ អ៊ីនី*);

**menyepi** /មើញើពី/ *v* ធ្វើឲ្យស្ងាត់: *គាត់ចាកចេញធ្វើឲ្យស្ងាត់គុហានោះ* *dia pergi menyepi di gua itu* (*ឌីយ៉ា ពើរ(r)ហ្គី មើញើពី ឌិ ហ្គូវ៉ា អ៊ីទូ*)

**seragam** /ស៊ឺរ៉ាហ្គាំ/ *n* ឯកសណ្ឋាន:

*គាត់ពាក់ឯកសណ្ឋានពណ៌សរៀងរាល់ថ្ងៃច័ន្ទ dia memakai seragam putih setiap hari Senin (ឌីយ៉ា មើម៉ាកៃ ស៊ឺរ៉ាហ្គាំ ពូទិះ ស៊ីទីយ៉ាប ហារី ស៊ីនិន)*

**serah terima** /ស៊ឺរ៉ះ ទើរីម៉ា/ *n* ប្រគល់តំណែង:

*ការប្រគល់តំណែងដល់បុគ្គលិកថ្មីត្រូវប្រារព្ធធ្វើឡើងនៅថ្ងៃនេះ serah terima pegawai baru diadakan hari ini (ស៊ឺរ៉ះ ទើរីម៉ា ពើហ្គាវ៉ៃ បារូ ឌីអាដាកាន់ ហារី អ៊ីនី)*

**serah, menyerah** /មើញើរ៉ះ/ *v* ចុះចាញ់:

*សូមកុំចុះចាញ់ក្នុងការប្រឈមនឹងការលំបាក jangan menyerah dalam menghadapi kesulitan (ចាងង៉ាន់ មើញើរ៉ះ ដាឡាំ មើងហាដាពី គើស៊ូលីតាន់);*

**menyerahkan** /មើញើរ៉ះកាន់/ *v* ប្រគល់:

*គាត់ប្រគល់កិច្ចការស្រាវជ្រាវដល់សាស្ត្រាចារ្យគាត់ dia menyerahkan tugas pada dosennya (ឌីយ៉ា មើញើរ៉ះកាន់ ទូហ្គាស់(ស) ប៉ាដា ដូសែនញ៉ា);*

**terserah** /ទើរ(r)ស៊ឺរ៉ះ/ *v* ស្រេចតែ:

*ស្រេចតែអ្នកទេ! terserah kamu saja! (ទើរ(r)ស៊ឺរ៉ះ កាមូ សាចា)*

**serak** /ស៊ឺរ៉ាក់/ *a* ស្អក:

*សម្លេងគាត់ស្អកដោយសារតែស្រែកខ្លាំងៗ suaranya serak karena berteriak-teriak (ស៊ូអារ៉ាញ៉ា ស៊ឺរ៉ាក់ ការើណា ប៊ើ(r)ទើរាក–ទើរាក)*

**serakah** /ស៊ឺរ៉ាកះ/ *a* លោភលន់:

*គាត់ជាអ្នកដែលលោភលន់ dia adalah orang yang serakah (ឌីយ៉ា អាដាឡះ អូរ៉ាំង យ៉ាំង ស៊ឺរ៉ាកះ)*

**serang, menyerang** /មើញើរ៉ាំង/ *v* វាយប្រហារ; ខាំ:

*ខ្លានោះបានខាំអ្នកការពារសួនសត្វ harimau itu menyerang penjaga kebun binatang (ហារីម៉ៅ អ៊ីទូ មើញើរ៉ាំង ពើនចាហ្គា គើប៊ុន ប៊ីណាតាំង);*

**penyerangan** /ពើញើរ៉ាង៉ាន់/ *n* ការវាយប្រហារ; ការវាយលុកលុយ:

*ការវាយប្រហារត្រូវបានធ្វើឡើងដើម្បីតបតនឹងគុំនំ penyerangan dilakukan untuk membalas dendam (ពើញើរ៉ាង៉ាន់ ឌិឡាគូកាន់ អ៊ុនទុក មើមបាឡាស់ ដិនដាំ);*

**serangan** /ស៊ឺរ៉ាង៉ាន់/ *n* **1** មហារីក:

*គាត់មានជម្ងឺមហារីក dia mendapat*

*serangan jantung (ឌីយ៉ា មិនដាប៉ាត់ សឺរ៉ាង៉ាន់ ចង្វាន់ទុង)*; **2** វាយប្រហារ: *ប្រយុទ្ធ serangan balik (ស៊េរ៉ាំង បាលីក)*

**serasi** /សឺរ៉ាស៊ី/ *a* ការចុះសម្រុងគ្នា; ស៊ីគ្នា: *ការលាយបញ្ចូលពណ៌អាវស៊ីគ្នាខ្លាំងណាស់ paduan warna bajunya sangat serasi (ប៉ាឌួវ៉ាន់ វ៉ារ(r)ណា បាជូញ៉ា សាង៉ាត់ សឺរ៉ាស៊ី)*

**serat** /សឺរ៉ាត់/ *n* ជាតិសរសៃ: *អាហារដែលមានជាតិសរសៃជាតម្រូវការនៃរាងកាយ serat makanan banyak diperlukan oleh tubuh (សឺរ៉ាត់ ម៉ាកាណាន់ បាញ៉ាក់ ឌិពើរ(r)លូកាន់ អូលេះ ទូប៊ុះ)*

**serba ada** /សឺរ(r)បា អាដា/

*a* មានគ្រប់យ៉ាង: *ហាងនោះមានលក់ទំនិញគ្រប់បែបយ៉ាង toko serba ada menjual berbagai macam barang (តូកូ សឺរ(r)បា អាដា មិនជូវ៉ាល បឺរ(r)បាហ្គៃ ម៉ាចាំ បារ៉ាំង)*;

**-- bisa** /សឺរ(r)បា ប៊ីសា/ មានជំនាញ: *គាត់ជាក្មេងដែលមានជំនាញ ia anak yang serba bisa (អ៊ីយ៉ា អាណាក់ យ៉ាំង សឺរ(r)បា ប៊ីសា)*

**serbu, menyerbu** /មើញើរ(r)ប៊ូ/

*v* ឈ្លានពាន: *អ្នកលក់ឈ្លានពានទៅផ្សារដែលលក់ទំនិញថោកៗនោះ pembeli menyerbu pasar murah itu (ពើមបឺលី មើញើរ(r)ប៊ូ ប៉ាសារ(r) មូរ៉ះ អ៊ីទូ)*;

**serbuan** /សឺរ(r)ប៊ូវ៉ាន់/

*n* ការវាយប្រហារ: *ការលុកលុយ ការលុកលុយនៃសត្វល្អិតចំពោះដំណាំស្រូវបានបង្ករការខាតបង់ដល់កសិករ serbuan serangga pada tanaman padi itu merugikan petani (សឺរ(r)ប៊ូវ៉ាន សឺរ៉ុំងហ្កា ប៉ាដា តាណាំម៉ាន់ ប៉ាឌី អ៊ីទូ មើរូហ្គីកាន់ ពើតានី)*

**serbuk** /សឺរ(r)ប៊ុក/ *n* ម្សៅ: *ម្សៅ bedak serbuk (ប៊ឺដាក់ សឺរ(r)ប៊ុក)*

**serdadu** /សឺរ(r)ដាឌូ/ *n* ទាហ៊ាន: *ទាហ៊ានហាត់បាញ់កាំភ្លើង serdadu itu berlatih menembak (សឺរ(r)ដាឌូ អ៊ីទូ បឺរ(r)ឡាទិះ មើណែមបាក់)*

**serempak** /សឺរ៉េមប៉ាក់/ *a* ជាមួយគ្នា; ព្រមគ្នា:

*ការបោះឆ្នោតជ្រើសរើសមេឃុំត្រូវធ្វើឡើងព្រមគ្នានៅក្នុងខែមករា២០១៧ pemilihan kepala daerah diadakan secara serempak bulan Januari 2017 (ពើមីលីហាន់ គើប៉ាឡាដាអេរ៉ះ ឌីអាដាកាន់ សឺចារ៉ា សឺរ៉េមប៉ាក់ ប៊ូឡាន់ ច្បានូអារី ឌូវ៉ា រីប៊ូ ទូជូ បឺឡះ)*

**seret, menyeret** /មើញើរ៉េត/ *v* អូស:

*វាអូសរបស់លេងវា dia menyeret mainannya (ឌីយ៉ា មើញើរ៉េត ម៉ាអ៊ីណាន់ញ៉ា)*

**serikat** /សឺរីកាត់/ *n* សម្ព័ន្ធ; សហជីព:

*លោកបានដឹកនាំសហជីពនៅក្រុមហ៊ុននេះ dia mengepalai serikat pekerja di perusahaan itu (ឌីយ៉ា មើងើប៉ាឡៃ សឺរីកាត់ ពើគើរ(r)ចា ឌិ ពើរូសាហាអាន អ៊ីទូ);*

**-- dagang** /សឺរីកាត់ ដាហ្គាំង/ សមាគមពាណិជ្ជកម្ម:

*សមាជិកសមាគមពាណិជ្ជកម្មស្នើសុំបញ្ចុះតម្លៃពន្ធ anggota serikat dagang meminta penurunan pajak (អាងហ្គូតា សឺរីកាត់ ដាហ្គាំង មើមីនតា ពើនូរូណាន់ ប៉ាចាក់);*

**perserikatan** /ពើរ(r)សឺរីកាតាន់/ *n* សមាគម:

*សមាគមសញ្ជាតិ Perserikatan Bangsa-Bangsa (ពើរ(r)សឺរីកាតាន់ បាំងសា–បាំងសា)*

**sering** /សឺរិង/ *adv* ញឹកញាប់:

*ឪពុកទៅក្រៅក្រុងជាញឹកញាប់ ayah sering pergi ke luar kota (អាយ៉ះ សើរិង ប៉ើរ(r)ហ្គី កើលូវ៉ារ(r) កូតា )*

**serta** /សឺរ(r)តា/ *p* ក៏ដូចជា; ព្រមទាំង:

*សម្លៀកបំពាក់ ស្បែកជើង ព្រមទាំងកាបូបបានទិញរួចរាល់ហើយ baju, sepatu, serta tas sudah dibelinya (បាជូ សឺប៉ាទូ, សឺរ(r)តា តាស'(s) ស៊ូដះ ឌិបឺលីញ៉ា);*

**beserta** /បើសឺរ(r)តា/ *v* ជាមួយនឹង:

*ឪពុក ម្ដាយ ជាមួយនឹងកូនៗបានជួបជុំនៅផ្ទះលោកយាយគាត់ ayah, ibu, beserta anak-anak berkumpul di rumah neneknya (អាយ៉ះ អ៊ីប៊ូ បើសឺរ(r)តា អាណាក់–អាណាក់ បឺរ(r)គុមពុល ឌិ រូម៉ះ ណេណេកញ៉ា);*

**menyertai** /មើញើរ(r)តៃ/ *v* អមដំណើរ:

*គាត់អមដំណើរឪពុកគាត់ទៅក្រៅក្រុង*

*dia yang menyertai keberangkatan ayahnya ke luar kota (ឌីយ៉ា យ៉ាំង មើញើរ(r)តៃ គើប៊ីរ៉ាំងកាតាន់ អាយ៉ះញ៉ា គើ លួរ៉ា(r) កូតា);*

**menyertakan** /មើញើរ(r)តាកាន់/ *v* រួមបញ្ចូល; បញ្ចូល:

*គាត់បញ្ចូលរូបថតនៅក្នុងសំបុត្រដែលបានផ្ញើរ dia menyertakan foto-foto pada surat yang dikirimkan (ឌីយ៉ា មើញើរ(r)តាកាន់ ហ្វូតូ-ហ្វូតូ ប៉ាដា ស៊ូរ៉ាត់ យ៉ាំង ឌិគីរីមកាន់);*

**peserta** /ពើសឺរ(r)តា/ *n* អ្នកចូលរួម:

*អ្នកចូលរួមប្រកួតរត់ប្រណាំងមានចំនួន៥០នាក់ peserta lomba lari berjumlah 50 orang (ពើសឺរ(r)តា ឡុមបា ឡារី ប៊ឺរ(r)ជុមឡះ លីម៉ាពូលុះ អូរ៉ាំង)*

**serta-merta** /សឺរ(r)តា-មើរ(r)តា/

*adv* តែម្តង; សោះឡើយ:

*ភាពជោគជ័យរបស់គាត់មិនបានធ្វើឱ្យគាត់ខ្ជិលរៀនសោះឡើយ keberhasilannya tidak serta-merta membuatnya malas belajar (គើប៊ឺរ(r)ហាស៊ីឡានញ៉ា ទីដាក់ សឺរ(r)តា មើរ(r)តា មើមប៊ូអ៊ាតញ៉ា ម៉ាឡាស់(ស) ប៊ឺឡាច្បារ(r))*

**sertifikat** /សើរ(r)ទីហ្វិកាត់/

*n* វិញ្ញាប័ណ្ណប័ត្រ; លិខិតបញ្ជាក់: *លិខិតបញ្ជាក់កំណើត sertifikat kelahiran (សើរ(រ)ទីហ្វិកាត់ កើឡាហ៊ីរ៉ាន់)*

**seru, berseru** /ប៊ឺរ(r)ស៊ីរូ/ *v* ហៅ; ប្រកាស: ប្រធានាធិបតីប្រកាស

*ដើម្បីប្រឆាំងនឹងរបបកុម្មុយនីស presiden berseru melawan komunisme (ប៉េស៊ីដិន ប៊ឺរ(r)ស៊ីរូ មើឡាវ៉ាន់ កូមូនីស្មើ)*

**seruling** /ស៊ីរូលិង/ *n* ខ្លុយ:

*ខ្លុយនេះធ្វើឡើងពីដើមឬស្សី seruling ini terbuat dari bambu (ស៊ីរូលិង អ៊ីនី ទើរ(r)ប៊ូអ៊ាត ដារី បាំប៊ូ)*

**sesak** /សឺសាក់/ *a* តូចចង្អៀត; អួរអាប់:

*បន្ទប់នេះមានអារម្មណ៍អួរអាប់ដោយសារតែមានមនុស្សច្រើនពេក ruangan ini terasa sesak karena banyaknya orang (រ៉ាង៉ាន់ អ៊ីនី ទើរ៉ាសា សឺសាក់ កាផីណា បាញ៉ាក់ញ៉ា អូរ៉ាំង);*

**-- napas** /សឺសាក់ ណាប៉ាស់(s)/

ពិបាកដកដង្ហើម:

*បន្ទប់តូចចង្អៀតនេះធ្វើឱ្យគាត់ពិបាកដកដង្ហើម*

*ruangan sempit ini membuatnya sesak napas (រ៉ាង៉ាន់ ស៊ឹមពិត អ៊ីនី ម៉េមប៊ូអាតញ៉ា ស៊ឺសាក់ ណាប៉ាស់(ស))*

**sesal, menyesal** /ស៊ើសាល់, ម៉ឺញ៉ើសាល់/ *v* សោកស្ដាយ: *ខ្ញុំសោកស្ដាយណាស់ក្រោយពេលធ្វើឱ្យគាត់ឈឺចាប់ saya menyesal telah menyakiti perasaannya (សាយ៉ា ម៉ឺញ៉ើសាល់ តើឡះ ម៉ឺញ៉ាគីទី ប៉ើរ៉ាសាអានញ៉ា)*

**sesat, menyesatkan** /ម៉ើញ៉ើសាត់កាន់/ *v* បំភាន់; យល់ច្រលំ; វង្វេង; ដើរផ្លូវខុស: *ការបង្ហាត់បង្រៀនរបស់វាធ្វើឱ្យដើរផ្លូវខុស ajarannya sangat menyesatkan (អាច្យារ៉ាន់ញ៉ា សាង៉ាត់ ម៉ើញ៉ើសាត់កាន់);*

**tersesat** /ទើរ(r)ស៊ឺសាត់/ *v* វង្វេង: *គាត់វង្វេងនៅក្នុងព្រៃ dia tersesat di hutan (ឌីយ៉ា ទើរ(r)ស៊ឺសាត់ ឌិ ហ៊ូតាន់)*

**sesuatu** /*ស៊ើស៊ូអាទូ/ pron* របស់ម្យ៉ាង: *ខ្ញុំបានទិញរបស់ម្យ៉ាងនៅផ្សារ saya membeli sesuatu di pasar (សាយ៉ា ម៉ឹមបើលី ស៊ើស៊ូអាទូ ឌី ប៉ាសារ(r))*

**setelah** /ស៊ើតើឡះ/*adv* បន្ទាប់: *ម្ដាយបានត្រឡប់មកផ្ទះបន្ទាប់ពីទិញផ្លែឈើ ibu pulang setelah membeli buah (អ៊ីប៊ូ ពូឡាំង ស៊ើតើឡះ ម៉ឹមបើឡី ប៊ូវ៉ះ);*

**-- itu** /ស៊ើតើឡះ អ៊ីទូ/ បន្ទាប់ពី: *បន្ទាប់ពីនោះខ្ញុំក៏បានចាកចេញ saya pergi setelah itu (សាយ៉ា ប៉ើរ(រ)ហ្គី ស៊ើតើឡះ អ៊ីទូ)*

**setia** /ស៊ឺទីយ៉ា/ *a* ភក្ដីភាព: *គាត់ពិតជាមានភក្ដីភាពជាមួយក្រុមគ្រួសារគាត់ dia sangat setia dengan keluarganya (ឌីយ៉ា សាង៉ាត់ សេទីយ៉ា ឌើង៉ាន់ គើលូអារ(r)ហ្គាញ៉ា);*

**kesetiaan** /គើស៊ឺទីយ៉ាអាន/ *n* ភក្ដីភាព: *ភក្ដីភាពរបស់គាត់ចំពោះប្រទេសជាតិត្រូវបានសាកល្បងរួចហើយ kesetiaannya pada negara sudah teruji (គើស៊ឺទីយ៉ានញ៉ា ប៉ាដា នើហ្គារ៉ា ស៊ូដះ ទើរ(r)អ៊ូជី)*

**setir, menyetir** /ស៊ើទីរ(r), ម៉ឺញ៉ើទីរ(r)/ *v* បើកបរ:

**setor** /សើតូរ(r)/ *v* ដាក់ប្រាក់: *ដាក់ប្រាក់ setor uang (សើតូរ(r) អ៊ូអ៊ាំង)*

**setrika** /សឺទ្រីកា/ *n* ឆ្នាំងអ៊ុត: *គាត់អ៊ុតសម្លៀកបំពាក់ជាមួយឆ្នាំងអ៊ុត dia melicinkan baju dengan setrika (ឌីយ៉ា មើលីជិនកាន់ បាជូ ឌើង៉ាន់ សឺទ្រីកា)*

**setuju** /សើទូជូ/ *v* យល់ព្រម: *ខ្ញុំឯកភាព saya setuju (សាយ៉ា សើទូជូ);*

**menyetujui** /សឺទូជូ,មើញើទូជុយ/ *v* យល់ព្រម: *ប្រធានរបស់គាត់បានយល់ព្រមឱ្យគាត់ឈប់សម្រាកលំហែមាតុភាពរបស់នាង pimpinan telah menyetujui cuti hamilnya (ពិមពីណាន់ តើឡះ ម៉ើញើទូជុយ ជូទី ហាមីលញ៉ា);*

**persetujuan** /សើទូជូ, ប៉ើរ(r) សើទូជូវ៉ាន់/ *n* ព្រមព្រៀង; ការឯកភាព: *គាត់ទទួលបានការឯកភាពពីឪពុកម្ដាយគាត់ dia mendapatkan persetujuan orang tuanya (ឌីយ៉ា ម៉ើនដាប៉ាត់ ប៉ើរ(រ)សើទីជូវ៉ាន់ញ៉ា)*

**sewa** /សេវ៉ា/ *n* ជួល: *ជួលឡាន sewa mobil (សេវ៉ា ម៉ូប៊ីល);*

**menyewa** /សេវ៉ា,មើញេវ៉ា/ *v* ជួល: *ខ្ញុំចង់ជួលឡានសម្រាប់មួយអាទិត្យ saya ingin menyewa mobil untuk 1 minggu (សាយ៉ា អ៊ីងិន ម៉ើញេវ៉ា ម៉ូប៊ីល អ៊ុនទុក សាត់ទូ មិងហ្គូ)*

**sial** /ស៊ីយ៉ាល/ *a* ក្ដៅមែនទែន; សំណាងអាក្រក់មែន: *សំណាងអាក្រក់មែនទែនគាត់ព្រឹកនេះ sial benar dia pagi ini (ស៊ីយ៉ាល ប៊ឺណារ(r) ឌីយ៉ា ប៉ាហ្គី អ៊ីនី);*

**kesialan** /តើស៊ីយ៉ាឡាន់/ *n* សំណាងអាក្រក់: *សំណាងអាក្រក់តែងតែងតាមលងគាត់ជានិច្ច kesialan selalu menghampirinya (តើស៊ីយ៉ាឡាន់ សឺឡាលូ មើងហាំពីរីញ៉ា);*

**siang** /ស៊ីយ៉ាង/ *n* រសៀល: *ទិវាសួស្ដី selamat siang (សើឡាម៉ាត ស៊ីយ៉ាង);*

**kesiangan** /តេស៊ីយ៉ាង៉ាន់/ *n* ជ្រេ; ថ្ងៃ; ថ្ងៃរសៀល: *គាត់ក្រោកពីគេងដូចជាថ្ងៃបន្តិចហើយ dia bangun kesiangan (ឌីយ៉ា បាងុន តេស៊ីយ៉ាង៉ាន់)*

**siap** /ស៊ីយ៉ាប/ *v* រួចរាល់: *ខ្ញុំត្រៀមរួចរាល់សម្រាប់ចេញដំណើរ saya siap pergi (សាយ៉ា ស៊ីយ៉ាប ពើរ(r)ហ្គី);*

**-- cetak** /ស៊ីយ៉ាប ចឹតាក់/ រួចរាល់នឹងបោះពុម្ព: *សៀវភៅនេះរួចរាល់សម្រាប់ការបោះពុម្ព buku ini sudah siap cetak (ប៊ូគូ អ៊ីនី ស៊ូដះ ស៊ីយ៉ាប ចឹតាក់);*

**-- pakai** /ស៊ីយ៉ាប ប៉ាកៃ/ រួចរាល់នឹងប្រើប្រាស់: *ឡានថ្មីគាត់រួចរាល់សម្រាប់ជិះហើយ mobil barunya sudah siap pakai (ម៉ូប៊ិល បារូញ៉ា ស៊ូដះ ស៊ីយ៉ាប ប៉ាកៃ);*

**mempersiapkan** /ស៊ីយ៉ាប,មឹមពើរ(r)ស៊ីយ៉ាបកាន់/ *v* រៀបចំ: ខ្ញុំ *រៀបចំសំនួរ; saya mempersiapkan sebuah pertanyaan (សាយ៉ា មឹមពើរ(រ)ស៊ីយ៉ាបកាន់ សើប៊ូវ៉ះ ពើរ(រ)តាញ៉ាអាន);*

**menyiapkan** /ស៊ីយ៉ាប,មើញីយ៉ាបកាន់/ *v* រៀបចំ: *គាត់កំពុងរៀបចំអាហារពេលយប់ dia sedang menyiapkan makan malam (ឌីយ៉ា សើដាំង មើញីយ៉ាបកាន់ ម៉ាកាន់ ម៉ាឡាម);*

**persiapan** /ស៊ីយ៉ាប,ពើរ(r)ស៊ីយ៉ាបប៉ាន់/ *n* ការរៀបចំ: *ការរៀបចំដំបូង persiapan awal (ពើរ(r)ស៊ីយ៉ាបប៉ាន់ អាវ៉ាល់)*

**siapa** /*ស៊ីយ៉ាប៉ា*/ *pron* នរណា: *នាងជានរណា? siapa dia? (ប៉ា ឌីយ៉ា);*

**-- pun** /ស៊ីយ៉ាប៉ា ពុន/ អ្នកណាក៏បាន អ្នកណាក៏បាន អាចញ៉ាំនៅភោជនីយដ្ឋាននោះ *siapa pun boleh makan di restoran itu (ស៊ីយ៉ាប៉ា ពុន បូលេះ ម៉ាកាន់ ឌិ រ៉េស្តូរ៉ាន់ អ៊ីទូ)*

**siar, menyiarkan** /មើញីយ៉ារ(r)កាន់/ *v* ផ្សព្វផ្សាយ: គាត់ជាអ្នកផ្សព្វផ្សាយព័ត៌មាននោះ *dia yang menyiarkan berita itu (ឌីយ៉ា យ៉ាំង មើនញីយ៉ារ(r)កាន់ ប៊ើរីតា អ៊ីទូ);*

**siaran** /ស៊ីយ៉ារ៉ាន់/ *n* ការផ្សាយ ការផ្សាយវិទ្យុនោះនិយាយពីជ័យជំនះរបស់គាត់ *siaran radio itu berisi berita*

*kemenangannya (ស៊ីយ៉ាក៉ន់ ក៉ឥយ៉ូ អ៊ីទូ ប៊ីរស៊ី ប៊ីរតា គើមើណាង៉ាន់ញ៉ា)*

**siasat** /ស៊ីយ៉ាសាត់/ *n* ឧបាយកល; កលល្បិច កលល្បិចគាត់ខើម្បីកម្ចាត់សត្រូវ *siasatnya untuk mengelabui musuh (ស៊ីយ៉ាសាត់ញ៉ា អ៊ុនទុក មើងើឡាប៊ូវី មូស៊ុះ)*

**sia-sia** /ស៊ីយ៉ា ស៊ីយ៉ា/ *a* គ្មានយោជន៍ គ្មានប្រយោជន៍ទេ ណែនាំក្មេងដែលកំពុងតែខឹងចឹង *sia-sia saja menasihati anak yang sedang marah itu (ស៊ីយ៉ា–ស៊ីយ៉ា សាច្យា មើណាស៊ីហាទី អាណាក់ យ៉ាំង សឺដាំង ម៉ារ៉ះ អ៊ីទូ)*

**sibuk** /ស៊ីប៊ុក/ *a* រវល់; មមាញឹក ប្រព័ន្ធមមាញឹក *saluran sibuk (សាល្វ៉ាន់ ស៊ីប៊ុក);*

**kesibukan** /គើស៊ីប៊ូកាន់/

*n* ការរវល់; ភាពមមាញឹក: *ភាពមមាញឹកនោះមិនបានធ្វើឲ្យគាត់ភ្លេចញ៉ាំបាយនោះទេ kesibukan itu tidak membuatnya lupa makan (គើស៊ីប៊ូកាន់ អ៊ីទូ ទីដាក់ មើមប៊ូវ៉ាត់ញ៉ា លូប៉ា ម៉ាកាន់)*

**sidang** /ស៊ីដាំង/ *n* ការកាត់ក្តី; កិច្ចប្រជុំ គាត់ដឹកនាំការកាត់ក្តីនៅក្នុងតុលាការ *dia memimpin sidang di pengadilan (ឌីយ៉ា មើមិមពិន ស៊ីដាំង ឌិ ពើង៉ាឌីឡាន់);*

**bersidang** /បឺរ(r)ស៊ីដាំង/ *v* ប្រជុំ: *សមាជិកសភាចាប់ផ្តើមប្រជុំនៅក្នុងខែកុម្ភៈ anggota dewan mulai bersidang pada bulan Februari (អាំងហ្គូតា ដេវ៉ាន់ មូឡៃ បឺ(r)ស៊ីដាំង ប៉ាដា ប៊ូឡាន់ ហ្វេប្រ៊ូវ៉ារី)*

**sidik, penyidik** /ពើញីឌិគ/

*n* អ្នកស៊ើបអង្កេត: *អ្នកស៊ើបអង្កេតចាប់ផ្តើមប្រមូលវត្ថុតាំងផ្សេងៗ penyidik mulai mengumpulkan barang bukti (ពើញីឌិគ មូឡៃ មើងុមពុលកាន់ បារ៉ាំង ប៊ុគទី)*

**sidik jari** /ស៊ីឌិគ ច្យារី/ ស្នាមម្រាមដៃ: *ស្នាមម្រាមដៃមនុស្សម្នាក់ៗមិនដូចគ្នាទេ sidik jari setiap orang tidak sama (ស៊ីឌិគ ច្យារី សឺទីយ៉ាប អូរ៉ាំង ទីដាក់ សាម៉ា)*

**sifat** /ស៊ីហ្វាត់/ *n* អត្តចរិក: *អត្តចរិកល្អនោះហើយដែលធ្វើឲ្យគាត់មានមិត្តភក្តិច្រើន sifat baik itu yang membuatnya banyak teman (ស៊ីហ្វាត់ បាអ៊ីគ អ៊ីទូ យ៉ាំង មើមប៊ូវ៉ាតញ៉ា បាញ៉ាក់ ទើម៉ាន់)*

**sigap** /ស៊ីហ្គាប់/ a ឆ្លាត: *ក្មេងឧស្សាហ៍ និង ឆ្លាតអាចធ្វើលំហាត់បានល្អ ហើយឆាប់រហ័ស anak yang rajin dan sigap dapat menyelesaikan tugas dengan baik dan cepat (អាណាក់ យ៉ាំង រ៉ាជិន ដាន់ ស៊ីហ្គាប់ ដាប៉ាត់ មើញ៉េឡេសៃកាន់ ទូហ្គាស់ ឌើង៉ាន់ បាអ៊ិក ដាន់ ចឺប៉ាត់)*

**sihir** /ស៊ីហ៊ីរ(r)/ *n* វេទមន្ត: *គាត់រៀនវេទមន្ត dia belajar sihir (ឌីយ៉ា ប៊ឺឡាច្សារ(r) ស៊ីហ៊ីរ(r));*

**penyihir** /ពើញីហ៊ីរ(r)/ *n* អ្នកវេទមន្ត: *អ្នកវេទមន្តបានធ្វើឱ្យផ្កាក្លាយជាសត្វ penyihir telah menyihir bunga menjadi burung (ពើញីហ៊ីរ(r) ទើឡះ មើញីហ៊ីរ(r) ប៊ូង៉ា មិនច្យាឌី ប៊ូរ៉ុង);*

**tersihir** /ទើរ(r)ស៊ីហ៊ីរ(r)/ *v* ត្រូវបានពង្វក់ស្មារតី: *គាត់ត្រូវបានពង្វក់ស្មារតីដោយសារតែភាពរួសរាយរាក់ទាក់របស់មនុស្សម្នាក់នោះ dia tersihir oleh keramahan orang itu (ឌីយ៉ា ទើរ(r)ស៊ីហ៊ីរ(r) អូលេះ គើរ៉ាម៉ាហាន់ អូរ៉ាំង អ៊ីទូ)*

**sikap** /ស៊ីកាប់/ *n* អាកប្បកិរិយា: *អាកប្បកិរិយាសុភាព sikap sopan (ស៊ីកាប់ សូប៉ាន់)*

**sikat** /ស៊ីកាត់/ *n* ដុស: ដុសធ្មេញ *sikat gigi (ស៊ីកាត់ ហ្គីហ្គី)*

**siksa** /ស៊ិគសា/ *n* ដាក់ទោស; ដាក់ទណ្ឌកម្ម; ធ្វើបាប: *គាត់ធ្វើបានខ្លួនឯងគាត់ dia siksa dirinya sendiri (ឌីយ៉ា ស៊ិគសា ឌិរីញ៉ា ស៊ិនឌិរី);*

**menyiksa** /មើញិគសា/ *v* ធ្វើទណ្ឌកម្ម: *កុំធ្វើទណ្ឌកម្មសត្វអី jangan menyiksa binatang (ច្យាង៉ាន់ មើញិគសា ប៊ីណាតាំង);*

**siksaan** /ស៊ិគសាអាន/ *n* ការធ្វើទារុណកម្ម: *ការធ្វើទុរុណកម្មផ្លូវចិត្តបានធ្វើឱ្យគាត់កាន់តែស្គមរីងរៃ siksaan batin membuatnya semakin kurus (ស៊ិគសាអាន បាទិន មើមប៊ូវ៉ាតញ៉ា សឺម៉ាគិន គូរុស(ស));*

**tersiksa** /ទើរ(r)ស៊ិគសា/ *v* ពិបាក: *គាត់មានអារម្មណ៍ថាពិបាកអង្គុយលើកៅអីតូចនោះ dia merasa tersiksa duduk di kursi yang kecil itu (ឌីយ៉ា មើរ៉ាសា ទើរ(r)ស៊ីគសា ឌូឌុគ ឌិ គួរ(r)ស៊ី យ៉ាំង គើជីល អ៊ីទូ)*

**siku** /ស៊ីគូ/ *n* កែង: *កែងខាងស្ដាំ siku kanan (ស៊ីគូ កាណាន់)*

**sila, mempersilakan** /មើមពើរ(r)ស៊ីឡាកាន់/ *v* អញ្ជើញ: *គាត់អញ្ជើញភ្ញៀវដើម្បីអង្គុយ dia mempersilakan tamunya untuk duduk (ឌីយ៉ា មើមពើរ(r)ស៊ីឡាកាន់ តាមូញ៉ា អ៊ុនទុក ឌូឌុក)*;

**menyilakan** /ស៊ីឡា,មើញីឡាកាន់/ *v* អញ្ជើញ: *គាត់អញ្ជើញភ្ញៀវឲ្យអង្គុយ dia menyilakan tamu untuk duduk (ឌីយ៉ាកាន់ តាមូ អ៊ុនទុក ឌូឌុក)*

**silau** /ស៊ីឡៅ/ *a* ពន្លឺ: *ពន្លឺនៃអំណាច silau kekuasaan (ស៊ីឡោវ គើគូវ៉ាសាអាន)*;

**menyilaukan** /មើញីឡៅកាន់/ *v* ចាំង: *ពន្លឺនោះចាំងភ្នែកគាត់ cahaya itu menyilaukan pandangan matanya (ចាហាយ៉ា អ៊ីទូ មើញីឡោវកាន់ ប៉ាន់ដាង៉ាន់ ម៉ាតាញ៉ា)*

**silih, silih berganti** /ស៊ីលិះ ប៊ឺរ(r)ហ្កាន់ទី/ ផ្លាស់ប្ដូរ; ទៅមក: *អ្នកទេសចរណ៍ទៅមក pelawat datang silih berganti (ពើឡាវ៉ាត់ ដាតាំង ស៊ីលីស ប៊ឺរ(r)ហ្កាន់ទី)*

**SIM** /ស៊ីម/ *n* ប័ណ្ណបើកបរ: *អ្នកបើកបរនោះមិនទាន់ទទួលបានប័ណ្ណបើកបរទេ sopir itu belum memiliki SIM (សូពីរ(r) បើលុម មើមិលីគី ស៊ីម)*

**simak, menyimak** /មើញីម៉ាក់/ *v* ស្ដាប់យ៉ាងយកចិត្តទុកដាក់: *គាត់ស្ដាប់ការពន្យល់របស់គ្រូគាត់យ៉ាងយកចិត្តទុកដាក់ dia menyimak penjelasan gurunya (ឌីយ៉ា មើញីម៉ាក់ ពើនជើឡាសាន់ ហ្គូរូញ៉ា)*

**simpan, menyimpan** /ស៊ីមប៉ាំន់, មើញិមប៉ាន់/ *v* រក្សាទុក: *រក្សាទុកឯកសារ menyimpan data (មើញិមប៉ាន់ ដាតា)*

**simpang, persimpangan** /ស៊ិមប៉ាំង,ពើរ(r) ស៊ិមប៉ាង៉ាន់/ *n* ប្រសព្វ; ចំណុចប្រសព្វ: *ចំណុចប្រសព្វបីជ្រុង simpang tiga (ស៊ិមប៉ាំង ទីហ្កា)*

**simpati** /ស៊ីមប៉ាទី/ *n* អាណិតអាសូរ: *អារម្មណ៍អាណិតអាសូរកើតឡើងពេលឃើញទុក្ខលំបាកគាត់ rasa simpati timbul melihat kesedihannya (រ៉ាសា ស៊ិមប៉ាទី ទិមប៊ុល មើលីហាត់ គើសឺឌីហាន់ញ៉ា)*

**sinar** /ស៊ីណារ(r)/ *n* ពន្លឺ: ពន្លឺព្រះអាទិត្យ

*sinar matahari (ស៊ីណារ(r) ម៉ាតា ហារី);*

**bersinar** /ស៊ីណារ(r)/ *v* ចេញពន្លឺ: *ព្រះអាទិត្យចេញពន្លឺច្បាស់ matahari bersinar terang (ម៉ាតា ហារី បើរ(r)ស៊ីណារ(r) )*

**sindir, menyindir** /មើញិនឌិរ(r)/

*v* និយាយបញ្ឆិតបញ្ឆៀង: *ពួកគេចូលចិត្តនិយាយបញ្ឆិតបញ្ឆៀងអ្នកដែលមកដល់យឺត mereka suka menyindir orang yang datang terlambat (មើរេកា ស៊ូកា មើញិនឌីរ(r) អូរ៉ាំង យ៉ាំង ដាតាំង ទើរ(r)ឡាំបាត់);*

**sindiran** /ស៊ីនឌិរ៉ាន់/ *n* ការតិះដៀល

**singgah** /ស៊ិងហ្គះ/ *v* ឈប់សម្រាក: *ក្នុងដំណើរត្រឡប់មកវិញ កាត់បានឈប់សម្រាកនៅផ្ទះខ្ញុំ dalam perjalan pulang, dia singgah di rumahku (ដាឡាំ ពើរ(r)ចា្យឡាន់ ពូឡាំង ឌីយ៉ា ស៊ីងហ្គអះ ឌិ រូម៉ះគូ);*

**persinggahan** /ពើរ(r)ស៊ិងហ្គាហាន់/ *n* ចុះចត; ឈប់សម្រាក; ឈប់សម្រាកមុននឹងបន្តដំណើរ: *កន្លែងនេះបានក្លាយជាកន្លែងឈប់សម្រាកសម្រាប់អ្នកថ្មើរជើង tempat ini menjadi persinggahan bagi pejalan kaki (ទើមប៉ាត់ អ៊ីនី មិនច្យាឌិ ពើរ(r)ស៊ិងហ្គាហាន់ បាហ្គី ពើច្យាឡាន់ កាគី)*

**singkat** /ស៊ិងកាត់/ *a* សង្ខេប: *ព័ត៌មានសង្ខេប berita singkat (បើរីតា ស៊ិងកាត៊)*

**singkir, menyingkir** /មើញិងគីរ(r)/

*v* ជៀសចេញ: *មើសាកជៀសចេញពីទ្រូងផ្លូវ coba menyingkir dari tengah jalan (ចូបា មើញិងគីរ(r) ដារី ទើង៉ះ ច្យាឡាន់);*

**menyingkirkan** /មើញិងគីរ(r)កាន់/ *v* យកចេញ: *គាត់យកបន្លាចេញពីទ្រូងផ្លូវ dia menyingkirkan duri di tengah jalan (ឌីយ៉ា មើនញិងគីរ(r)កាន់ ឌូរី ឌិ ទើង៉ះ ច្យាឡាន់);*

**tersingkir** /ទើរ(r)ស៊ិងគៀរ(r)/ *v* បានលុបចេញ; ដកចេញ:

*គាត់ត្រូវបានលុបចេញពីពានរង្វាន់រត់ប្រណាំង dia sudah tersingkir dari kejuaraan lomba lari (ឌីយ៉ា ស៊ូដះ ទើរ(r)ស៊ិងគីរ(r) ដារី គើជូវ៉ារ៉អាន ឡុមបាឡារី)*

**sini** /ស៊ីនី/ *pron* មកនេះ: *អ្នកមកនេះ sini kamu (ស៊ីនី កាមូ)*

**sipit** /ស៊ីពិត/ *a* សម្លក់សំឡឹង: *ភ្នែកគាត់សម្លក់សំឡឹង matanya sipit (ម៉ាតាញ៉ា ស៊ីពិត)*

**sipu, tersipu-sipu** /ទើរ(r)ស៊ីពូ-ស៊ីពូ/ *v* អៀន; ខ្មាស់អៀន: *គាត់ឡើងអៀនដោយសារតែសរសើគាត់ dia tersipu-sipu malu karena dipuji (ឌីយ៉ា ទើរ(r)ស៊ីពូ-ស៊ីពូ ម៉ាលូ ការរ៉េណា ឌិពូជី)*

**siram, menyiram** /មើញីរ៉ាំ/ *v* ស្រោចទឹក: *គាត់ស្រោចទឹកផ្កានៅទីធ្លាផ្ទះ dia menyiram tanaman bunga di halaman rumah (ឌីយ៉ា មើញីរ៉ាំ តាណាម៉ាន់ ប៊ូង៉ា ឌិ ហាឡាម៉ាន់ រូម៉ះ);*

**tersiram** /ទើរ(r)ស៊ីរ៉ាំ/ *v* រលាក: *ដៃគាត់ពិការដោយសារតែរលាកទឹកក្តៅ tanganya luka tersiram air panas (តាង៉ាន់ញ៉ា លូកា ទើរ(r)ស៊ីរ៉ាំ អាយីរ(r) ប៉ាណាស់)*

**sirat, tersirat** /ទើរ(r)ស៊ីរ៉ាត់/ *v* បាំង; នៅពីក្រោយ

**sirik** /ស៊ីរិក/ *n* ច្រណែនឈ្នានីស: *បំបាត់នូវអារម្មណ៍ច្រណែនឈ្នានីសចេញពីចិត្តរបស់អ្នក hilangkan rasa sirik dari dalam hatimu (ហ៊ីឡាំងកាន់ រ៉ាសា ស៊ីរីគ ដារី ដាឡាំ ហាទីមូ)*

**sirip** /ស៊ីរិប/ *n* ព្រុយ

**sirna** /ស៊ីរ(r)ណា/ *a* បាត់:

*ក្ដីសង្ឃឹមគាត់ត្រូវបានបាត់បង់ហើយ sirna sudah harapannya (ស៊ីរ(r)ណា ស៊ូដះ ហារ៉ាប៉ាន់ញ៉ា)*

**sisa** /ស៊ីសា/ *a* នៅសល់; សំណល់:

*សំណល់អាគារ sisa bangunan (ស៊ីសា បាងូណាន់)*

**sisi** /ស៊ីស៊ី/ *n* ផ្នែក; ជ្រុង:

*ជ្រុងម្ខាងនៃផ្ទះគាត់បែរទៅរកទិសខាងកើត sisi rumahnya menghadap ke timur (ស៊ីស៊ី រូម៉ះញ៉ា មើងហាដាប់ គើ ទីមួរ(r))*

**sisih, penyisihan** /ពើញ៉ីស៊ីហាន់/

*n* ជម្រុស; លុបបំបាត់:

*វគ្គជម្រុសត្រូវបានឆ្លងកាត់ជាមួយនឹងលទ្ធផលដ៏ល្អ babak penyisihan dilalui dengan hasil yang baik (បាបាក់ ពើញ៉ីស៊ីហាន់ ឌិឡាលូវី ឌើង៉ាន់ ហាស៊ីល យ៉ាំង បាអ៊ីគ);*

**menyisihkan** /មើញ៉ីស៊ីកាន់/ *v* ផ្ទេរ; ផ្លាស់:

*គាត់បានផ្ទេរទ្រព្យសម្បត្តិគាត់សម្រាប់កិច្ចមនុស្សធម៌ dia menyisihkan hartanya untuk beramal (ឌីយ៉ា មើញ៉ីស៊ីកាន់ ហារ(r)តាញ៉ា អ៊ុនទុក បឺរ៉ាម៉ាល់);*

**tersisih** /ទើរ(r)ស៊ីស៊ិះ/ *v* ត្រូវបានជម្រុស:

*ទាំងដប់មួយក្រុមត្រូវបានជម្រុសនៅក្នុងវគ្គពាក់កណ្ដាលផ្ដាច់ព្រ័ត្រ kesebelasnnya tersisih pada bapak semifinal (គើសឺបឺឡាសាន់ញ៉ា ទើរ(r)ស៊ីស៊ិះ ប៉ាដា បាបាក់ សឺមី- ហ្វីណាល)*

**sisik** /ស៊ីស៊ិក/ *n* ស្រកា:

*ស្រកាត្រីនោះមានពណ៌លឿង sisik ikan itu berwarna kuning (ស៊ីស៊ិក អ៊ីកាន់ អ៊ីទូ បឺរ(r)វ៉ារ(r)ណា គូនិង)*

**sisip, menyisipkan** /មើញ៉ីស៊ិបកាន់/

*v* បញ្ចូល:

*គាត់បញ្ចូលក្រដាសនៅក្នុងទំព័រសៀវភៅដែលបានងានរួច dia menyisipkan kertas di antara halaman buku yang dibacanya (ឌីយ៉ា មើញ៉ីស៊ីបកាន់ គើរ(r)តាស់(ស) ឌិ អាន់តារ៉ា ហាឡាម៉ាន់ ប៊ូគូ យ៉ាំង ឌិបាចាញ៉ា);*

**sisipan** /ស៊ីស៊ីប៉ាន់/ *n* ការបញ្ចូល: *របៀបនៃការបញ្ចូលនៅក្នុងភាសាឥណ្ឌូនេស៊ី ដូចជា -el- និង -em- bentuk sisipan dalam bahasa Indonesia, antara lain -el- dan -em- (ប៊ិនទុត ស៊ីស៊ីប៉ាន់ ដាឡាំ បាហាសា ឥណ្ឌូនេស៊ីយ៉ា អាន់តារ៉ា ឡាអ៊ិន អែល ដាន់ អែម)*

**sisir** /ស៊ីស៊ីរ(r)/ *n* លាប: *លាបក្រាស់ sisir tebal (ស៊ីស៊ីរ(r) តើបើរ(r));*

**menyisir** /មើញីស៊ីរ(r)/ *v* សិត: *ម្ដាយសិតសក់ឱ្យកូនគាត់ ibu menyisir rambut (អ៊ីប៊ូ មើញីស៊ីរ(r) រ៉ាំបុត)*

**siswa** /ស៊ិស្វា/ *n* សិស្ស: *សិស្សថ្នាក់ទីប្រាំមានចំនួន៤០នាក់ siswa kelas lima berjumlah 40 anak (ស៊ីស្វា គើឡាស់(ស) លីម៉ា ប៊ើ(r)ជុម្លះ អ៉ឹមប៉ាត់ពូលុះ អាណាក់)*

**sita, menyita** /មើញីតា/ *v* រឹបអូស: *ប៉ូលិសរឹបអូសទំនិញគេចពន្ធ polisi menyita barang selundupan (ប៉ូលីស៊ី មើញីតា បារ៉ាំង សេលុនឌូប៉ាន់);*

**sitaan** /ស៊ីតាអាន/ *n* រឹបអូស: *ទំនិញរឹបអូសត្រូវបានរក្សាទុកក្នុងឃ្លាំង barang-barang sitaan tersimpan di gudang (បារ៉ាំង–បារ៉ាំង ស៊ីតាអាន ទើរ(r)ស៊ីមប៉ាន់ ឌិ ហ្គូឌុង)*

**siul, bersiul** /ប៊ើរ(r)ស៊ីយ៉ូល/ *v* ហួច: *ក្មេងតូចពូកែហួច anak kecil yang pandai bersiul (អាណាក់ គើជីល យ៉ាំង ប៉ាន់ដៃ ប៊ើរ(r)ស៊ីយុល);*

**siulan** /ស៊ីយូឡាន់/ *n* សម្លេងហួច: *សម្លេងហួចក្មេងនោះជាសញ្ញាថាវាបានមកដល់ហើយ siulan anak itu sebagai pertanda dia sudah datang (ស៊ីយូឡាន់ អាណាក់ អ៊ីទូ សឺបាហ្គៃ ពើរ(r)តានដា ឌីយ៉ា ស៊ូដះ ដាតាំង)*

**soal** /សូអាល់/ *n* បញ្ហា; រឿងរ៉ាវ: *នេះជាបញ្ហាដែលពិបាក ini adalah soal yang sulit (អ៊ីនី អាដាឡះ សូអាល់ យ៉ាំង ស៊ូលីត);*

**persoalan** /សូអាល់, ពើរ(r) សូអាឡាន់/ *n* បញ្ហា; រឿងរ៉ាវ: *បញ្ហាធំ persoalan besar (ប៉ើរ(r)សូអាឡាន់ ប៊ែសារ(r))*

**sobek** /សូបិក/ *a* រហែក: *អាវខ្ញុំរហែក baju saya sobek (បាជូ សាយ៉ា សូបិក)*

**sodor, menyodorkan** /មើញដូរ(r)កាន់/ *v* សម្រុក; ជម្រុញ:

*គាត់ជម្រុញលទ្ធផលការងារគាត់ dia menyodorkan hasil pekerjaannya (ឌីយ៉ា មើញដូរ(r)កាន់ ហាស៊ីល ពើគើរ(r)ចា្យអានញ៉ា)*

**sogok, menyogok** /មើញ៉ូហ្គុក/ *v* សំណូក; សូកប៉ាន់:

*គាត់ព្យាយាមសូកប៉ាន់មន្ត្រីរដ្ឋាភិបាល dia berusaha menyogok pejabat (ឌីយ៉ា ប៊ឺសាហា មើញ៉ូហ្គុក ពើចា្យបាត់);*

**sogok-menyogok** /សូហ្គុក មើញ៉ូហ្គុក/ សំណូកសូកប៉ាន់:

*សំណូកសូកប៉ាន់ជាទង្វើរដែលត្រូវបានហាមឃាត់ដោយរដ្ឋ sogok-menyogok merupakan perbuatan yang dilarang negara (សូហ្គុក–មើញ៉ូហ្គុក មើរូប៉ាកាន ពើរ(r)ប៊ូវ៉ាតាន់ យ៉ាំង ឌិឡារ៉ាំង នើហ្គារ៉ា)*

**sombong** /សុំបុង/ *a* ក្រអើតក្រទម:

*ក្មេងក្រអើតក្រទមនឹងមិនមានមិត្តភក្តិទេ anak sombong tidak akan berteman (អាណាក់ សុំបុង ទីដាក់ អាកាន់ ប៊ឺរ(r)ទើម៉ាន់);*

**kesombongan** /គើសុមបូង៉ាន់/ *n* ភាពក្រអើតក្រទម:

*ភាពក្រអើតក្រទមដែលធ្វើឲ្យវាធ្លាក់ខ្លួន kesombongan itu yang membuat dia jatuh (គើសុមបូង៉ាន់ អ៊ីទូ យ៉ាំង មើមប៊ូវ៉ាត ឌីយ៉ា ចា្យទុះ);*

**menyombongkan diri** /គើសុមបូង៉ាន់ឌីរី/

មានអំនួតលើខ្លួនឯង; តាំងខ្លួន:

*គាត់តែងតែមានអំនួតលើខ្លួនឯងដោយសារតែទ្រព្យសម្បត្តិដែលគាត់មាន dia selalu menyombongkan diri dengan kekayaan yang dimiliknya (ឌីយ៉ា សឺឡាលូ មើញុំបុងកាន់ ឌីរី ឌើង៉ាន់ កឺកាយ៉ាអាន យ៉ាំង ឌិមីលិគីញ៉ា)*

**sopan** /សូប៉ាន់/ *a* សុភាពរាបសារ:

*បុគ្គលិកសណ្ឋាគារនោះរួសរាយ និងសុភាពរាបសារ staf hotel itu ramah dan sopan (សើតាវ ហូតែល អ៊ីទូ រ៉ាមះ ដាន់ សូប៉ាន់)*

**sopir** /សូពីរ(r)/ *n* អ្នកបើកបរ:

*អ្នកបើកបរឡានតាក់ស៊ី sopir taksi (សូពីរ(រ) តាក់ស៊ី );*

**menyopir** /មើញ៉ូពីរ/ *v* បើកបរ:

*តើអ្នកអាចបើករហូតដល់យានដ្ឋានដ៏ជិតបំផុតបានទេ? apakah Anda*

*dapat menyopir sampai bengkel terdekat? (អាប៉ាកះ អានដា ដាប៉ាត់ មើញ៉ូពីរ(រ) សាំប៉ៃ បែងកែល តើរ(រ)ដើកាត់)*

**sorak** /សូរ៉ាក់/ *n* សម្លេងហូកញ្ជៀវ:
*សម្លេងហូកញ្ជៀវរបស់ទស្សនិកជនបានលឺដល់ខាងក្រៅអាគារ sorak penonton terdengar sampai luar gedung (សូរ៉ាក់ ពើណុនតុន ទើរ(r)ដឹង៉ារ(r) សាំប៉ៃ លូវ៉ារ(r) ហ្គើឌុង);*

**bersorak** /បឺរ(r)សូរាក់/ *v* ហូអបអរ:
ពួកគេហូអបអរដល់ជ័យជំនះក្រុមពួកគេ *mereka bersorak menyambut kemenangan timnya (មើរេកា បឺរ(r)សូរាក់ មើញាំប៊ុត គើមើណាង៉ាន់ ទីមញ៉ា)*

**sorak-sorai** /សូរ៉ាក់-សូរ៉ៃ/
*n* សម្លេងហូកញ្ជៀវ:
*សម្លេងហូកញ្ជៀវអបអរសាទរជ័យជំនះទាំងដប់មួយក្រុមនោះ sorak-sorai bergemuruh menyambut kemenangan kesebelasan itu (សូរ៉ាក់ សូរ៉ៃ បឺរ(r)ហ្គើមូរុះ មើញាំប៊ុត គើមើណាង៉ាន់ គើសឺបឺឡាសាន់ អ៊ីទូ)*

**sore** /សូរេ/ *n* រសៀល: *ម្ដាយផឹកតែពេលរសៀល ibu minum teh sore hari (អ៊ីប៊ូ មីនុម តែះ សូរេ ហារី)*

**sorot** /សូរ៉ុត/ *n* ពន្លឺ:
ពន្លឺភ្លើងអំពូលនោះបានទម្លុះវាំងននោះ *sorot lampu menembus tirai itu (សូរ៉ុត ឡាំពូ មើនើមប៊ុស(s) ទីរ៉ៃ អ៊ីទូ);*

**menyorot(i)** /មើញ៉ូរ៉ូទី/ *v* ពន្យល់:
គាត់បានពន្យល់បញ្ហានោះដោយផ្អែកលើផ្នែកចិត្តសាស្ត្រ *dia menyoroti masalah itu dari segi psikologi (ឌីយ៉ា មើញ៉ូរ៉ូទី ម៉ាសាឡះ អ៊ីទូ ដារី សឹហ្គី ពើស៊ីកូលូហ្គី);*

**tersorot** /ទើរ(r)សូរ៉ុត/ *v* ចាំងពន្លឺ:
*ចោរនោះបានចាំងពន្លឺកាមេរ៉ាសុវត្ថិភាពនៅក្នុងផ្ទះ pencuri itu tersorot CCTV di rumahnya (ពើនជូរី អ៊ីទូ ទើរ(r)សូរ៉ុត CCTV ឌិ រូម៉ះញ៉ា)*

**stasiun** /ស្តាស៊ីយូន/ *n* ស្ថានីយ៍: *ស្ថានីយ៍រថភ្លើង stasiun kereta api (ស្តាស៊ីយូន គើរ៉េតា អាពី)*

**stop** /ស្តប/ *v* ឈប់:
*ឡានោះឈប់នៅចំហៀងផ្លូវ mobil itu stop di pinggir jalan (ម៉ូប៊ីល អ៊ីទូ ស្តប ឌី ពិងហ្គីរ(រ) ចាឡាន់)*

**suai, menyesuaikan** /ស៊ូអ៊ី, មើញ៉ើស៊ូអ៊ីកាន់/ *v* កែតម្រូវ: *កែតម្រូវខ្លួន menyesuaikan diri (មើញ៉ើស៊ូអ៊ីកាន់ ឌីរី)*

**suaka, suaka alam** /ស៊ូវ៉ាកា អាឡាម/ ធនធានធម្មជាតិ: *ព្រៃឈើជាធនធានធម្មជាតិ hutan merupakan suaka alam (ហ៊ូតាន់ មើរូប៉ាកាន់ ស៊ូវ៉ាកា អាឡាម);*

**-- margasatwa** /ស៊ូវ៉ាកា ម៉ារ((r) ហ្គាសាត្វា/ កន្លែងអភិរក្សសត្វព្រៃ: *ដំរីត្រូវបានការពារនៅកន្លែងអភិរក្សសត្វព្រៃ gajah dilindungi di suaka margasatwa di Lampung (ហ្គាឆ្យ៉ះ ឌិលិនឌូងី ឌិ ស៊ូវ៉ាកា ម៉ារ((r)ហ្គាសត្វា ឌិ ឡាំពុង);*

**-- politik** /ស៊ូវ៉ាកា ប៉ូលីទីគ/ សិទ្ធិជ្រកកោននយោបាយ: *ពួកគេស្នើរសុំសិទ្ធជ្រកកោននយោបាយនៅប្រទេសផ្សេង mereka meminta suaka politik di negara lain (មើរេកា មើមិនតា ស៊ូវ៉ាកា ប៉ូលីទីគ ឌិ នើហ្គារ៉ា ឡាអ៊ិន)*

**suami** /ស៊ូវ៉ាមី/ *n* ប្តី; ស្វាមី: *នេះជាប្តីរបស់ខ្ញុំ ini suami saya (អ៊ីនី ស៊ូវ៉ាមី សាយ៉ា)*

**suap** /ស៊ូវ៉ាប់/ *n* សំណូក: *គាត់ត្រូវបានគេដឹងថាផ្តល់សំណូកដល់មន្ត្រី dia ketahuan memberi suap pada petugas (ឌីយ៉ា គើតាហ៊ូវ៉ាន់ មើមប៊ើរី ស៊ូវ៉ាប់ ប៉ាដា ពើទូហ្គាស់(s));*

**menyuap(kan)** /មើញូវ៉ាប់កាន់/ *v* បញ្ចុក: *ម្តាយបញ្ចុកបបរដល់កូន ibu menyuapkan bubur pada adik (អ៊ីប៊ូ មើញូវ៉ាប់កាន់ ប៊ូប៊ូរ(r) ប៉ាដា អាឌិគ);*

**sesuap** /សឺស៊ូវ៉ាប់/ *n* មួយម៉ាត់: *គាត់ញ៉ាំបាយតែមួយម៉ាត់ dia hanya memakan sesuap nasi (ឌីយ៉ា ហាញ៉ា មើម៉ាកាន់ សឺស៊ូវ៉ាប់ ណាស៊ី)*

**suara** /ស៊ូវ៉ារ៉ា/ *n* សម្លេង; រំខាន: *សម្លេងឡាន suara mobil (ស៊ូវ៉ារ៉ា ម៉ូប៊ីល);*

**-- bulat** /ស៊ូវ៉ារ៉ា ប៊ូឡាត់/ ឯកភាព: *គាត់ត្រូវបានជ្រើសរើសជាប្រធានដោយមតិឯកភាព dia terpilih sebagai ketua dengan suara bulat (ឌីយ៉ា ទើរ(r)ពីលិះ សឺបាហ្គៃ គើទូវ៉ា ឌើង៉ាន់ ស៊ូវ៉ារ៉ា ប៊ូឡាត់);*

**-- hati** /ស៊ូរ៉ា ហាទី/ មនសិការ: *មនសិការតែតែស្មោះត្រង់ suara hati selalu jujur (ស៊ូរ៉ា ហាទី សឺឡាលូ ជូជូរ(r))*

**suasana** /ស៊ូវ៉ាសាណា/ *n* ស្ថានភាព; បរិយាកាស: *បរិយាកាសដែលគួរឲ្យរីករាយ suasana yang menyenangkan (ស៊ូវ៉ាសាណា យ៉ាំង មើញ៉ើណាំងកាន់)*

**suatu, sesuatu** /ស៊ូវ៉ាទូ,ស៊ូវ៉ាទូ/ *pron* ស៊ូវ៉ាទូ; ស៊ូវ៉ាទូ: *រឿងអាក្រក់មួយបាន កើតឡើង sesuatu yang buruk terjadi (សើស៊ូវ៉ាទូ យ៉ាំង ប៊ូរុក តើរ(r)ចាឌី)*

**subur** /ស៊ូប៊ូរ(r)/ *a* ផ្លែផ្កា; ផលិតភាព; ជីជាតិ: *ដីដែលមានជីជាតិផ្តល់នូវផលិតផលជាច្រើន tanah yang subur memberi hasil berlimpah (តាណះ យ៉ាំង ស៊ូប៊ូរ(r) មើមបឺរី ហាស៊ីល បឺរ(r)លីមប៉ះ);*

**menyuburkan** /មើញូប៊ូរ(r)កាន់/ *v* ជំរុញការលូតលាស់: *ជីអាចជម្រុញការលូតលាស់របស់ដំណាំ pupuk dapat menyuburkan tanaman (ពូពុត ដាប៉ាត់ មើញូប៊ូរ(r)កាន់ តាណាម៉ាន់);*

**penyubur** /ពើញូប៊ូរ(r)/ *n* ជី: *ដំណាំសណ្តែកអាចធ្វើឲ្យដីមានជីជាតិ tanaman kacang-kacangan dapat dijadikan penyubur tanah (តាណាម៉ាន់ កាចាំង–កាចាង៉ាន់ ដាប៉ាត់ ឌិច្បាឌិកាន់ ពើញូប៊ូរ(r) តាណះ)*

**suci** /ស៊ូជី/ *a* ស្អាត; បរិសុទ្ធ: *ទឹកបរិសុទ្ធ air suci (អាយីរ(r) ស៊ូជី);*

**kesucian** /គើស៊ូជីយ៉ាន/ *n* បរិសុទ្ធ; ស្អាតស្អំ: *ទឹកចិត្តបរិសុទ្ធស្តែងចេញពីអំពើ kesucian hatinya tampak dari perbutannya (គើស៊ូជីយ៉ាន ហាទីញ៉ា តាំប៉ាក់ ដារី ពើរ(r)ប៊ូតាន់ញ៉ា)*

**sudah** /ស៊ូដះ/ *adv* រួចរាល់; ហើយ: *ស្អាតហើយ sudah bersih (ស៊ូដះ បើរ(r)ស៊ីះ);*

**berkesudahan** /បើរ(r)គើស៊ូដាហាន់/ *v* ចប់; រួចរាល់; បញ្ចប់: *រឿងបានបញ្ចប់ដោយសប្បាយរីករាយ cerita yang berkesudahan dengan bahagia (ចឺរីតា យ៉ាំង បឺរ(r)គើស៊ូដាហាន់ ឌើង៉ាន់ បាហាហ្គីយ៉ា);*

**kesudahan** /គើស៊ូដាហាន់/ *n* ចុងបញ្ចប់: *ចុងបញ្ចប់នៃសាច់រឿងនោះពិតជាមានក្តីសុខមែន kesudahan cerita itu sangat*

*membahagiakan (សឹស្ញ៉ូដះហាន់ ចឺរីតា អ៊ីទូ សាង៉ាត់ មើមបាហាហ្គីយ៉ាកាន់);*

**menyudahi** /មើញូដាហ៊ី/ *v* បញ្ចប់: *គាត់បានបញ្ចប់ការថ្លែងសន្ទរកថាស្តីពីផ្ទះដែលមានផាសុខភាព* dia menyudahi *pembicaraan tentang rumah sehat (ឌីយ៉ា មើញូដាហ៊ី ពើមប៊ីចារ៉ាអាន តិនតាំង រូម៉ះ សេហាត់)*

**sudut** /ស៊ូឌុត/ *n* ជ្រុង: *ជ្រុងបន្ទប់* sudut *ruangan (ស៊ូឌុត រូវ៉ាំង៉ាន់);*

**menyudut** /មើញូឌុត/ *v* ជ្រុង: *គាត់ទាត់បានចំជ្រុង* tendangannya *menyudut (តិនដាង៉ាន់ញ៉ា មើញូឌុត);*

**-- lancip** /ស៊ូឌុត ឡាន់ជិប/ មុំស្រួច: *ទំហំមុំស្រួចគឺ៣០ដឺក្រេ* besar sudut *lancip ialah 30° (បែសារ(r) ស៊ូឌុត ឡាន់ជិព អ៊ីយ៉ាឡះ ទីហ្គាពូលុះ);*

**-- tumpul** /ស៊ូឌុត ទុមពុល/ មុំទាល: *ទំហំមុំទាលគឺ៦០ដឺក្រេ* besar sudut *tumpul  ialah 60° (បែសារ(r) ស៊ូឌុត ទុមពុល អ៊ីយ៉ាឡះ អឹណាំពូលុះ);*

**tersudut** /ទើរ(r)ស៊ូឌុត/ *v* ជ្រុង; ចំហៀង: *គាត់បាននិទានប្រាប់បន្ទាប់ពីគាត់ខិតទៅចំហៀង* *dia pun bercerita setelah posisinya tersudut (ឌីយ៉ា ពុន ប៊ើរ(r)ចឺរីតា សឺទើឡះ ប៉ូស៊ីស៊ីញ៉ា ទើរ(r)ស៊ូឌុត)*

**suguh, menyuguhkan** /មើញូហ្គុះកាន់/ *v* **1** បម្រើ; យក: *ម៉ែយកនំទៅឲ្យភ្ញៀវ* ibu menyuguhkan *kue pada tamu (សាទូ អ៊ីប៊ូ មើញូហ្គុះកាន់ គូវេ ប៉ាដា តាមូ ខ្ញុំ);* **2** ផ្តល់: *គាត់បានផ្តល់ការបង្ហាញពីរបាំបុរាណ* dia *menyuguhkan pertunjukan tari tradisonal (យ៉ា មើញូហ្គុះកាន់ ពើរ(r)ទុនជូកាន់ តារី ត្រាឌិស្យូណាល់);*

**suguhan** /ស៊ុហ្គូហាន់/  *n* ការទទួលកាហ្វេ: *ការទទួលកាហ្វេត្រូវបានផ្តល់ជូននៅពេលយប់* *suguhan kopi diberikan pada malam hari (ស៊ូហ្គូហាន់ កូពី ឌិប៊ឺរីកាន់ ប៉ាដា ម៉ាឡាំ ហារី)*

**suhu** /ស៊ូហ៊ូ/ *n* សីតុណ្ហភាព: *សីតុណ្ហភាពបន្ទប់* *suhu kamar (ស៊ូហ៊ូ កាម៉ារ(r))*

**suka** /ស៊ូកា/ *a* ចូលចិត្ត: *គាត់ចូលចិត្តធ្វើដំណើរទៅទីក្រុង* dia suka *pergi ke kota (ឌីយ៉ា ស៊ូកា ពើរ(r)ហ្គី គើ កូតា)*

**kesukaan** /គើស៊ូកាអាន/

*n* ចំណង់ចំណូលចិត្ត:

*បាយឆាហ្នឹងហើយដែលជាចំណង់ចំណូលចិត្តក្មេងនោះ nasi gorenglah kesukaan anak itu (ណាស៊ី ហ្គូរ៉េងឡះ គើស៊ូកាអាន់ អាណាក់ អ៊ីទូ);*

**menyukai** /មើញូកៃ/ *v* ចូលចិត្ត:

*គាត់ចូលចិត្តម្ហូបដែលហឹរខ្លាំងណាស់ dia sangat menyukai masakan yang pedas (ឌីយ៉ា សាង៉ាត់ មើញូកៃ ម៉ាសាកាន់ យ៉ាំង ពើដាស់(ស));*

**sesuka** /សឺស៊ូកា/ *a* តាមចំណូលចិត្ត:

*ពួកគេញ៉ាំអីក៏បានតាមចំណូលចិត្តពួកគេ mereka makan apa saja sesuka hatinya (មើរេកា ម៉ាកាន់ អាប៉ា សាច្យា សឺស៊ូកា ហាទីញ៉ា)*

**sukar** /ស៊ូការ(r)/ *a* ពិបាក; ស្មុគស្មាញ:

*ផ្លូវមានភក់ពិតជាពិបាកឆ្លងកាត់ jalan berlumpur sangat sukar dilalui (ច្យាឡាន់ បឺរ(r)លុមពួរ(r) សាង៉ាត់ ស៊ូការ(r) ឌិឡាលូអ៊ី)*

**sukarela** /ស៊ូកាឝឡា/ *a* ស្ម័គ្រចិត្ត:

*គាត់ជួយជនរងគ្រោះទឹកជំនន់ដោយស្ម័គ្រចិត្ត dia membantu korban banjir dengan sukarela (ឌីយ៉ា មើមបាន់ទូ កូរ(r)បាន់ បានជីរ(r) ស៊ូការ៉េឡា)*

**sukarelawan** /ស៊ូកាឝឡាវ៉ាន់/

*n* អ្នកស្ម័គ្រចិត្ត: *គាត់បានក្លាយជាអ្នកស្ម័គ្រចិត្តដើម្បីបង្រៀននៅតំបន់ដាច់ស្រយាល dia menjadi sukarelawan untuk mengajar di daerah terpencil (ឌីយ៉ា មើនច្យាឌិ ស៊ូការ៉េឡាវ៉ាន់ អ៊ុនទុក មើង៉ាច្យារ(r) ឌិ ដាឞរះ ទើរ(r)ពើនជីល)*

**sukses** /ស៊ុកសែស/ *a* ដែលជោគជ័យ:

*គាត់ជាអ្នកជំនួញដែលជោគជ័យ dia seorang pengusaha sukses (ឌីយ៉ា សើអូរ៉ាំង ប៉ឹងូសាហា ស៊ុកសែស);*

**kesuksesan** /ស៊ុកសែស, គឹស៊ិកសែសាន់/ *n* ជោគជ័យ: *គន្លឹះជោគជ័យ kunci kesuksesan (គុនជី គើស៊ុកសែសាន់)*

**suku** /ស៊ូគូ/ *n* កុលសម្ព័ន្ធ

**sulam** /ស៊ូឡាំ/ *n* ប៉ាក់:

*គាត់បានប៉ាក់បូនៅលើអាវគាត់ dia*

*memberi sulam pita pada bajunya (ឌីយ៉ា មើមបឺរី ស៊ូឡាំ ពីតា ប៉ាដា បាជូញ៉ា);*

**menyulam** /មើញូឡាំ/ *v* ប៉ាក់:

*គាត់កំពុងប៉ាក់អាវ dia sedang menyulam bajunya (ឌីយ៉ា សឺដាំង មើញូឡាំ បាជូញ៉ា)*

**sulang, bersulang** /បើរ(r)ស៊ូឡាំង/

*v* លើកកែវអបអរសាទរ:

*គាត់លើកកែវអបអរជ័យជំនះគាត់ dia bersulang untuk merayakan kemenangannya (ឌីយ៉ា បឺរ(r)ស៊ូឡាំង អ៊ុនទុក មើរ៉ាយ៉ាកាន់ គើមើណាង៉ាន់ញ៉ា)*

**sulap** /ស៊ូឡាប់/ *n* បំលែង; ប្រើវេទមន្ត:

*សូមបំលែងលុយទៅជាក្រដាស sulaplah uang ini menjadi kertas (ស៊ូឡាប់ឡះ អ៊ួាំង អ៊ីនី មិនចា្យឌិ គើរ(r)តាស(s));*

**menyulap** /មើញូឡាប់/ *v* ប្រើវេទមន្ត:

*គាត់ប្រើវេទមន្តធ្វើឱ្យពងក្លាយជាសត្វ dia menyulap telur menjadi burung (ឌីយ៉ា មើញូឡាប់ ទើលួរ(r) មិនចា្យឌិ ប៊ូរ៉ុង);*

**pesulap** /ពើស៊ូឡាប៉ាន់/

*n* អ្នកលេងសៀក:

*គាត់ជាអ្នកលេងសៀកដ៏ល្បីនៅក្នុងទីក្រុង dia adalah pesulap yang terkenal di kotanya (ឌីយ៉ា អាដាឡះ ពើស៊ូឡាប់ យ៉ាំង ទើរ(r)គើណាល់ ឌិ កូតាញ៉ា)*

**sulih, sulih suara** /ស៊ូលិះ ស៊ូវ៉ារ៉ា/

ការបោះពុម្ព:

*ការបោះពុម្ពមគ្គទេសប៍នោះត្រឹមត្រូវខ្លាំងណាស់ sulih suara dalam pertunjukan itu sangat tepat (ស៊ូលិះ ស៊ូវ៉ារ៉ា ដាឡាំ ពើរ(r)ទុនជូកាន់ អ៊ីទូ សាង៉ាត់ ទើប៉ាត់)*

**suling** /ស៊ូលិង/ *n* ចម្រាញ់:

*គាត់ចម្រាញ់ផ្កាកុលាបនេះក្លាយជាទឹកអប់ dia suling bunga mawar ini menjadi parfum (ឌីយ៉ា ស៊ូលិង ប៊ូង៉ា ម៉ាវ៉ារ(r) អ៊ីនី មិនចា្យឌិ ប៉ារ(r)ហ្វូម)*

**sulit** /ស៊ូលីត/ *a* ពិបាក: *ពិបាកយល់បញ្ហានេះ sulit memahami soal ini (ស៊ូលីត មើម៉ាហាមី សូអាល់ អ៊ីនី);*

**kesulitan** /គើស៊ូលីតាន់/

*n* បញ្ហា; ការលំបាក:

*គាត់ជួបប្រទះការលំបាកទាក់ទងនឹងថវិកា dia*

*mengalami kesulitan dengan keuangannya (ឌីយ៉ា មើង៉ាឡាមី គើស៊ូលីតាន់ ឌើង៉ាន់ គើអ៊ូវ៉ាង៉ាន់ញ៉ា);*

**mempersulit** /មើមពើរ(r)ស៊ូលីត/ *v* ធ្វើឱ្យកាន់តែស្មុគស្មាញ: *សូមកុំធ្វើឱ្យស្ថានភាពកាន់តែស្មុគស្មាញ jangan mempersulit keadaan (ចង៉ាន់ មើមពើរ(r)ស៊ូលីត គើអាដាអាន);*

**menyulitkan** /មើញូលីតកាន់/ *v* ធ្វើឱ្យពិបាក: *កង្វះខាតសម្ភារៈនេះធ្វើឱ្យពិបាកធ្វើការឱ្យរួចរាល់ kekurangan alat ini menyulitkan penyelesaian pekerjaan (គើគូរ៉ាង៉ាន់ អាឡាត់ អ៊ីនី មើញ៉ូលីតកាន់ ពើញេលេសៃយ៉ាន ពើគើរ(r)ចាអាន់)*

**sumbang, sumbang saran** /ស៊ុមបាំង សារ៉ាន់/ *n* ផ្ដល់អនុសាសន៍; ផ្ដល់មតិ: *គាត់បានផ្ដល់អនុសាសន៍ក្នុងសកម្មភាពនេះ dia memberikan sumbang saran dalam kegiatan ini (ឌីយ៉ា មើមប៊ើរីកាន់ ស៊ុមបាំង សារ៉ាន់ ដាឡាំ គើហ្គីយ៉ាតាន់ អ៊ីនី);*

**menyumbang** /មើញុមបាំង/ *v* ផ្ដល់ជំនួយ; ចែករំលែក: *គាត់ផ្ដល់ជំនួយឡានថ្មីមួយ dia menyumbang satu mobil baru (ឌីយ៉ា មើញុមបាំង សាទូ ម៉ូប៊ីល បារូ);*

**penyumbang** /ពើញុមបាំង/ *n* អ្នកផ្ដល់ជំនួយ: *អ្នកផ្ដល់ជំនួយថវិកា penyumbang dana (ពើញុមបាំង ដាណា);*

**sumbangan** /ស៊ុមបាង៉ាន់/ *n* វិភាគទាន: *គាត់បានចូលវិភាគទានថវិកានៅក្នុងកម្មវិធីនេះ dia memberikan sumbangan dana dalam acara ini (ឌីយ៉ា មើមប៊ើរីកាន់ ស៊ុមបាង៉ាន់ ដាណា ដាឡាំ អាចារ៉ា អ៊ីនី)*

**sumber** /ស៊ុមប៊ើរ(r)/ *n* ប្រភព: *ប្រភពទឹក sumber air (ស៊ុមប៊ើរ(r) អាយីរ(r));*

**-- daya** /ស៊ុមប៊ើរ(r)ដាយ៉ា/ ធនធាន: *ធនធានធម្មជាតិ sumber daya alam (ស៊ុមប៊ើរ(r) ដាយ៉ា អាឡាម);*

**bersumber** /ប៊ើរ(r)ស៊ុមប៊ើរ(r)/ *v* ប្រភព: *ធ្យូងថ្មប្រភពពីផូស៊ីលរុក្ខជាតិ batu bara bersumber dari fosil tumbuhan (បាទូ បារ៉ា ប៊ើរ(r)ស៊ុមប៊ើរ(r) ដារី ហ្វូស៊ីល ទុមប៊ូហាន់)*

**sumpah** /ស៊ុមប៉ះ/ *n* សម្បថ: *បុរសនោះនិយាយពាក្យសម្បថ pria itu mengucapkan sumpah (ព្រីយ៉ា អ៊ីទូ មើងូចាប់កាន់ ស៊ុមប៉ះ);*

**bersumpah** /ប៊ឺរ(r)ស៊ុមប៉ះ/ *v* ស្បថ: *គាត់ស្បថថានឹងមិនកុហកឡើយ dia bersumpah tidak akan berbohong (ឌីយ៉ា ប៊ឺរ(r)ស៊ុមប៉ះ ទីដាក់ អាកាន់ ប៊ឺរ(r)បូហុង)*

**sumpit** /ស៊ុមពិត/ *n* ចង្កឹះ: *ក្មេងនោះញ៉ាំជាមួយចង្កឹះ anak itu makan menggunakan sumpit (អាណាក់ អ៊ីទូ ម៉ាកាន់ មើងហ្គូណាកាន់ ស៊ុមពិត)*

**sumsum** /ស៊ុមស៊ុម/ *n* ខួរ: *ឈឺរហូតដល់ខួរឆ្អឹង sakitnya sampai ke tulang sumsum (សាគិតញ៉ា សាំប៉ៃ គើ ទូឡាំង ស៊ុមស៊ុម)*

**sumur** /ស៊ូមូរ(r)/ *n* អណ្តូង: *ពុកយកទឹកពីអណ្តូង ayah mengambil air dari sumur (អាយ៉ះ មើងាំបឹល អាយីរ(r) ដារី ស៊ូមូរ(r))*

**sungai** /ស៊ូង៉ៃ/ *n* ស្ទឹង: *ទឹកស្ទឹងជ្រៅ sungai dalam (ស៊ូង៉ៃ ដាឡាម)*

**sungguh**/ស៊ុងហ្គុះ/ *adv* ពិតជា: *គាត់ពិតជាពូកែមែន dia sungguh pintar (ឌីយ៉ា ស៊ុងហ្គុះ ពិនតារ(r));*

**sesungguhnya** /សឺស៊ុងហ្គុះញ៉ា/ *adv* ប្រាកដប្រជា; មើងម៉ាតច្បាស់លាស់: *ពន្យល់ឲ្យមើងម៉ាត់ច្បាស់លាស់ menerangkan dengan sesungguhnya (មើនើរ៉ាំងកាន់ ឌើង៉ាន់ សឺស៊ុងហ្គុះញ៉ា);*

**sungguhpun** /ស៊ុងហ្គុះពុន/ *p* ទោះជាអញ្ចឹងក៏ដោយ: *ទោះជាចឹងក៏ដោយ ខ្ញុំមិនចង់ទិញទំនិញនោះទេ sungguhpun bagus, saya tidak ingin membeli barang itu (ស៊ុងហ្គុះពុន បាហ្គុស(ស) សាយ៉ា ទីដាក់ អ៊ីង៉ិន មើមប៊ឺលី បារ៉ាំង អ៊ីទូ)*

**suntik, menyuntik** /ស៊ុនទិក,មើញ៉ុនទិក/ *v* ចាក់: *ចាក់អ្នកជម្ងឺ menyuntik pasien (មើញ៉ូទឹក ប៉ាស៊ីយែន)*

**sunting, menyunting** /មើញុនទិង/

*v* កែ; កែសម្រួល:

*គាត់ត្រូវបានចាត់តាំងឲ្យកែសម្រួលប្រលោមលោក* *dia ditugaskan menyunting naskah drama (ឌីយ៉ា ឌិទូហ្គាស់កាន់ មើញុនទិង ណាស្កះ ដ្រាម៉ា);*

**penyunting** /ពើញុនទិង/

*n* អ្នកកែសម្រួល:

*ម៉ាក់ធ្វើការជាអ្នកកែសម្រួលភាសា* *ibu bekerja sebagai penyunting bahasa (ឌីយ៉ា បឺគើរ(r)ចា្យ សឺបាហ្គៃ ពើញុនទិង បាហាសា);*

**suntingan** /ស៊ុនទីង៉ាន់/ *n* កំណែ:

*កំណែស្រ្គីបនោះបានផ្ញើរតាមប្រៃសណីយ៍រួចហើយ* *suntingan naskah itu telah dikirim melalui pos (ស៊ុនទីង៉ាន់ ណាស្កះ អ៊ីទូ ទើឡះ ឌិគីរិម មើឡាលូវី ប៉ុស(ស)*

**suntuk** /ស៊ុនទុក/ *adv* យឺតពេល:

*បងធ្វើកិច្ចការកាលពីយប់មិញយឺតបេល* *kakak mengerjakan tugas semalam suntuk (កាកាក់ មើងើរ(r)ចា្យកាន់ ទូហ្គាស់ សឺម៉ាឡាំ ស៊ុនទុក)*

**sunyi** /ស៊ូញី/ *a* ស្ងាត់: *បរិយាកាសស្ងាត់* *suasana sunyi (ស៊្វាសាណា ស៊ូញី)*

**supaya** /ស៊ូប៉ាយ៉ា/ *p* ដើម្បី: *ខ្ញុំរៀនដើម្បីឲ្យពូកែ* *saya belajar supaya pintar (សាយ៉ា បើឡាចា្យរ(r) ស៊ូប៉ាយ៉ា ពិនតារ(r))*

**suram** /ស៊ូរ៉ាំ/ *a* អាប់អួរ: *ថ្ងៃដែលអាប់អួរ* *hari yang suram (ហារី យ៉ាំង ស៊ូរ៉ាំ)*

**surat** /ស៊ូរ៉ាត់/ *n* សំបុត្រ: *សំបុត្រស្នេហា* *surat cinta (ស៊ូរ៉ាត់ ជិនតា);*

**-- kabar** /ស៊ូរ៉ាត់ កាបារ(r)/

*n* ការសែត: *ឪពុកកំពុងអានកាសែត* *ayah sedang membaca surat kabar (អាយ៉ះ សើដាំង មើមបាចា ស៊ូរ៉ាត់ កាបារ(r));*

**-- berharga** /ស៊ូរ៉ាត់ បើរ(r)ហារ(r)ហ្គា/ មូលបត្រ:

*ម្តាយរក្សាមូលបត្រក្នុងទូសុវត្ថិភាព* *ibu menyimpan surat berharga di dalam brankas (អ៊ីប៊ូ មើញិមប៉ាន់ ស៊ូរ៉ាត់ បឺរ(r)ហារ(r)ហ្គា ឌិ ដាឡាំ ប្រាំងកាស់(ស));*

**-- elektronik** /ស៊ូរ៉ាត់ អេឡិកត្រូនិក/ អ៊ីម៉ែល:

*ខ្ញុំបានផ្ញើរអ៊ីម៉ែលទៅមិត្តភក្តិ* *saya mengirimkan surat elektronik kepada teman (សាយ៉ា មើងីរិមកាន់ ស៊ូរ៉ាត់ អេឡិគត្រូនិគ គើប៉ាដា ទើម៉ាន់);*

-- **kaleng** /ស៊ូរ៉ាត់ កាឡឹង/ លិខិតអនាមិក: *លោកពូបានទទួលលិខិតអនាមិកកាលពីរសៀលមិញនេះ paman mendapatkan surat kaleng siang tadi (ប៉ាម៉ាន់ មិនដាប៉ាត់កាន់ ស៊ូរ៉ាត់ កាឡែង ស៊ីយ៉ាង តាឌិ);*

**menyurati** /ស៊ូរ៉ាត់, មើញ៉ូរ៉ាតិ/ *v* សរសេរទៅកាន់: *សរសេរទៅកាន់ម្តាយគាត់ menyurati ibunya (មើញ៉ូរ៉ាទី អ៊ីប៊ូញ៉ា);*

**tersurat** /ទើរ(r)ស៊ូរ៉ាត់/ *v* បានកត់ត្រា: *រឿងទាំងអស់នោះបានកត់ត្រារួចរាល់តាំងពីមុន hal itu sudah tersurat sejak dahulu (ហាល់ អ៊ីទូ ស៊ូដះ ទើរ(r)ស៊ូរ៉ាត់ សឺចាក់ ដាហ៊ូលូ)*

**suruh** /ស្វូរុះ/ *n* បញ្ជា: *ខ្ញុំបញ្ជាវាឲ្យទិញទឹកផឹក saya suruh dia membeli air minum (សាយ៉ា ស៊ូរុះ ឌីយ៉ា មើមបឺលី អាយីរ(r) មីនុម);*

**menyuruh** /មើញ៉ូរុះ/ *v* បញ្ជា: *ពុកបញ្ជាឲ្យប្អូនទិញសៀវភៅ ayah menyuruh adik membeli buku (អាយ៉ះ មើញ៉ូរុះ អាឌិក មើមបឺលី ប៊ូគូ)*

**surut** /ស៊ូរុត/ *a* ស្រកចុះ; ថយក្រោយ: *ជំហានដែលដើររួចហើយ មិនអាចថយក្រោយបានទេ langkah sudah terlangkahkan tidak dapat surut lagi (ឡាំងកះ ស៊ូដះ ទើរ(r)ឡាំងកះកាន់ ទីដាក់ ដាប៉ាត់ ស៊ូរុត ឡាហ្គី)*

**susah** /ស៊ូសះ/ *a* លំបាក; ពិបាក; ទុក្ខវេទនា: *គាត់បានស៊ាំទៅហើយជាមួយនឹងជីវិតដែលលំបាក dia sudah terbiasa hidup susah (ឌីយ៉ា ស៊ូដះ ទើរ(r)ប៊ីយ៉ាសា ហ៊ីឌុព ស៊ូសះ);*

-- **hati** /ស៊ូសះ ហាទី/ *a* ពិបាកចិត្ត: *គាត់ធ្វើកិច្ចការងារដោយពិបាកចិត្ត dia mengerjakan pekerjaannya dengan susah hati (ឌីយ៉ា មើងើរ(r)ចាកាន់ ពើគើរ(r)ចាអានញ៉ា ឌើង៉ាន់ ស៊ូសះ ហាទី);*

-- **payah** /ស៊ូសះ ប៉ាយ៉ះ/ *a* ទាំងលំបាក: *ក្មេងនោះធ្វើលំហាត់រួចទាំងលំបាក anak itu menyelesaikan tugasnya dengan susah payah (អាណាក់ អ៊ីទូ មើញើឡឺសៃកាន់ ទូហ្គាស់ញ៉ា ឌើង៉ាន់ ស៊ូសះ ប៉ាយ៉ះ);*

**kesusahan** /គើស៊ូសះហាន់/ *n* រឿងរ៉ាវស្មុគស្មាញ; ការលំបាក: *គ្រួសារគាត់កំពុងតែជួបប្រទះរឿងរ៉ាវស្មុគស្មាញ keluarganya sedang*

*mengalami kesusahan (តើល្ងាំ(r)ហ្កាញ៉ា សឹដាំង មើង៉ាឡាមី តើស៊ូសះហាន់);*

**menyusahkan** /មើញូសះកាន់/ *v* ធ្វើឱ្យពិបាកដល់: *កាយវិការវាជាញឹកញាប់បានធ្វើឱ្យពិបាកដល់អ្នកដទៃ* *sikapnya seringkali menyusahkan orang lain (ស៊ីកាប់ញ៉ា សឺរឹងកាលី មើញូសះកាន់ អូរ៉ាំង ឡាអ៊ិន)*

**susu** /ស៊ូស៊ូ/ *n* ទឹកដោះ: *ទឹកដោះសូកូឡា* *susu cokelat (ស៊ូស៊ូ ចូក្លាត់);*

**menyusui** /មើញូស៊ុយ/ *v* បំបៅដោះ: *ម៉ាក់កំពុងបំបៅដោះប្អូន* *ibu sedang menyusui adik (អ៊ីប៊ូ សឹដាំង មើញូស៊ូអី អាឌិគ)*

**susul, menyusul** /មើញូស៊ុល/ *v* តាមក្រោយ: *ទៅឥឡូវចុះ ខ្ញុំនឹងទៅតាមក្រោយ* *pergilah sekarang saya akan menyusul (ពើរ(r)ហ្គីឡះ សឺការ៉ាំង សាយ៉ា អាកាន់ មើញូស៊ុល);*

**susulan** /ស៊ូស៊ូឡាន់/ *n* បន្តបន្ទាប់: *ព័ត៌មានជាបន្តបន្ទាប់* *berita susulan (បឺរីតា ស៊ូស៊ូឡាន់)*

**susun** /ស៊ូស៊ុន/ *n* ជួរ; គំនរ: *មួយគំនរសៀវភៅ* *satu susun buku (សាទូ ស៊ូស៊ុន ប៊ូគូ);*

**menyusun** /មើញូស៊ុន/ *v* តំរៀប: *ប្អូនតំរៀបធ្វើផ្ទះពីដុំអុស* *adik menyusun rumah-rumahan dari balok kayu (អាឌិគ មើញូស៊ុន រូម៉ះ–រូម៉ាហាន់ ដារី បាឡុក កាយូ);*

**susunan** /ស៊ូស៊ូណាន់/ *n* កម្រង: *កម្រងឃ្លាដែលគាត់ធ្វើបានត្រឹមត្រូវហើយ* *susunan kalimat yang dia buat sudah benar (ស៊ូស៊ូណាន់ កាលីម៉ាត់ យ៉ាំង ឌីយ៉ា ប៊ូវាត់ ស៊ូដះ បឺណារ(r));*

**tersusun** /ទើរ(r)ស៊ូស៊ុន/ *v* បានតំរៀប: *ដុំអុសនោះបានតំរៀបឱ្យមានរបៀបហើយ* *kotak kayu itu telah tersusun dengan rapi (កូតាក់ កាយូ អ៊ីទូ ទើឡះ ទើរ(r)ស៊ូស៊ុន ដើង៉ាន់ រ៉ាពី)*

**susup, menyusup** /មើញូស៊ុប/ *v* ជ្រៀតចូល: *គាត់បានជ្រៀតចូលយ៉ាងលឿនទៅក្រោមដើម្បីជៀសវាងការវាយប្រហារ* *dengan cepat ia menyusup ke bawah untuk mengelak pukulan itu (ដើង៉ាន់ ចឺប៉ាត់ អ៊ីយ៉ា មើញូស៊ុប គើ បាវះ អ៊ុនទុក មើង៉ើឡាក់ ពូគូឡាន់ អ៊ីទូ);*

**penyusup** /ពើញូស៊ុប/ *n* អ្នកឈ្លានពាន: *អ្នកឈ្លានពានប្រកដដោយអាវុធនោះត្រូវបានប៉ូលីសចាប់ហើយ penyusup bersenjata itu sudah ditangkap polisi (ពើញូស៊ុព បឺរ(r)សិនច្យាតា អ៊ីទូ ស៊ូដះ ឌិតាំងកាប់ ប៉ូលីស៊ី)*

**susut** /ស៊ូស៊ុត/ *a* បន្ថយ; ធ្លាក់ចុះ: *ដើមទុនវាធ្លាក់ចុះដោយសារតែបំណុល modalnya susut karena banyak utang (ម៉ូដាលញ៉ា ស៊ូស៊ុត ការើណា បាញ៉ាក់ ហ៊ូតាំង);*

**menyusut** /មើញូស៊ុត/ *v* កាន់តែតូចជាងមុន: *ខ្លួនគាត់កាន់តែតូចជាងមុនដោយសារតែឈឺ badannya menyusut karena sakit (បាដាន់ញ៉ា មើញូស៊ុត ការើណា សាគិត)*

**sutra** /ស៊ូទើរ៉ា/ *n* សូត្រ: *សម្លៀកបំពាក់គាត់ធ្វើឡើងដោយក្រណាត់សូត្រសុទ្ធ pakaiannya terbuat dari kain sutra asli (ប៉ាកៃយ៉ានញ៉ា ទើរ(r)ប៊ូវាត់ ដារី កាអ៊ិន ស៊ូទើរ៉ា អាស្លី)*

**swasta** /ស្វាសើតា/ *a* ឯកជន: *ក្រុមហ៊ុនឯកជន perusahaan swasta (ពើរូសាហាអាន ស្វាសើតា)*

**syahbandar** /ស្យះបាន់ដារ(r)/ *n* មេកំពង់ផែ: *ឪពុកវាធ្វើការជាមេកំពុងផែនៅកំពង់ផែនោះ ayahnya bekerja sebagai syahbandar di pelabuhan itu (អាយ៉ះញ៉ា បឺគើរ(r)ច្យា សឺបាហ្គៃ ស្យ៉ះបានដារ(r) ឌិ ពើឡាប៊ូហាន់ អ៊ីទូ)*

**syair** /ស្យៃយីរ(r)/ *n* កំណាព្យ: *គាត់ធ្វើកំណាព្យចម្រៀងពិរោះខ្លាំងណាស់ dia membuat syair lagu yang sangat indah (ឌីយ៉ា មើមប៊ូវាត់ ស្យៃយីរ(r) ឡាហ្គូ យ៉ាំង សាង៉ាត់ អ៊ីនដះ)*

**syarat** /ស្យារ៉ាត់/ *n* លក្ខ័ណ្ឌ: *ជាមួយនឹងលក្ខ័ណ្ឌដូចខាងក្រោម dengan syarat sebagai berikut (ដើង៉ាន់ ស្យារ៉ាត់ សឺបាហ្គៃ បឺរីគុត)*

**traktir, mentraktir**
/មើនត្រាក់ទីរ(r)/ *v* ប៉ាវ; ចេញលុយឱ្យ:
*គាត់ចេញលុយឱ្យពួកយើងញ៉ាំឆ្ងាញ់ៗ dia mentraktir kami makan enak (ឌីយ៉ា មើនត្រាក់ទីរ(r) កាមី ម៉ាកាន់ អ៊ែណាក់)*

**taat** /តាអាត់/ *a* គោរព; ធ្វើតាមបង្គាប់:
*អ្នកគោរពប្រតិបត្តិ hamba yang taat (ហាំបា យ៉ាំង តាអាត់);*

**ketaatan** /គើតាអាតាន់/
*n* ការគោរពប្រតិបត្តិ:
*ការគោរពប្រតិបត្តិរបស់កូនចំពោះឪពុកម្ដាយ ketaatan anak pada orang tua (គើតាអាតាន់ អាណាក់ ប៉ាដា អូរ៉ាំងទូវ៉ា);*

**menaati** /មើណាអាត់ទី/ *v* គោរព:
*គាត់តែងតែគោរពតាមច្បាប់ dia selalu menaati aturan (ឌីយ៉ា សឺឡាលូ មើណាអាត់ទី អាទូរ៉ាន់)*

**tabah** /តាបះ/ *a* រឹងមាំ:
*ម៉ែតែងតែរឹងមាំក្នុងការប្រឈមនឹងការសាកល្បងនានាក្នុងជីវិត ibu selalu tabah menjalani cobaan hidup (អ៊ីប៊ូ សឺឡាលូ តាំបះ មិនច្បាឡានី ចូបាអាន ហ៊ីឌុព);*

**ketabahan** /គើតាបាហាន់/
*n* ភាពរឹងមាំ:
*ភាពរឹងមាំរបស់ម្ដាយមិនអាចកាត់ថ្លៃបាន ketabahan seorang ibu tidak ada bandingannya (គេតាបាហាន់ សឺអូរ៉ាំង អ៊ីប៊ូ ទីដាក់ អាដា បាន់ឌីង៉ាន់ញ៉ា)*

**tabrak** /តាប្រាក់/ *v* បុកៈ *បុក ហើយរត់ tabrak lari (តាប្រាក់ ឡារី);*

**-- lari** /តាប្រាក់ ឡារី/ បុកហើយរត់:
*អ្នកដែលបុកហើយរត់នោះចុងក្រោយត្រូវបានប៉ូលីសចាប់ pelaku tabrak lari itu akhirnya tertangkap polisi (ពើឡាគូ តាប្រាក់ ឡារី អ៊ីទូ អាក់ហ៊ីរ(r)ញ៉ា ទើរ(r)តាំងកាប់ ប៉ូលីស៊ី);*

**bertabrakan**
/បើរ(r)តាប្រាកាន់/ *v* បុកគ្នា:
*យានយន្តបួនបានបុកគ្នា empat kendaraan bertabrakan (អឹមប៉ាត់ កេនដារ៉ាអាន់ បឺរ(r)តាប្រាកាន់);*

**menabrak** /មើណាប្រាក់/ *v* បុក:
*ឡាននោះបុកដើមឈើ mobil itu menabrak pohon (ម៉ូប៊ីល អ៊ីទូ មើណាប្រាក់ ប៉ូហុន);*

**penabrak** /ពើណាប្រាក់/ *n* អ្នកបុក:
*អ្នកបុកនោះបានរត់គេចភ្លាមៗ penabrak*

*itu langsung kabur (តើណាប្រាក់ អ៊ីទូ ឡាំងស៊ុង កាប៊ូរ(r));*

**tabrakan** /តាប្រាកាន់/ *n* បុកគ្នា; ការប៉ះទង្គិចគ្នា: *ការប៉ះទង្គិចគ្នាបានកើតឡើងនៅលើផ្លូវធំ sebuah tabrakan terjadi di jalan tol (សើប៊ូវ៉ះ តាប្រាកាន់ តើរចាឌី ឌី ចាឡាន់ តុល);*

**tertabrak** /ទើរតាប្រាក់/ *v* បានបុក: *ឡានក្រុងមួយបានបុករទេះភ្លើង sebuah bus tertabrak kereta api (សឺប៊ូវ៉ះ ប៊ឺស(ស) ទើរ(r)តាប្រាក់ គើរ៉េតា អាពី)*

**tabu** /តាប៊ូ/ *n* បម្រាម: *ប្រធានបទនោះបានក្លាយទៅជារឿងដែលត្រូវបានដក់បម្រាមមិនឲ្យអាន tema itu menjadi hal yang tabu dibicarakan (តេម៉ា អ៊ីទូ មិនចា្យឌិ ហាល់ យ៉ាំង តាប៊ូ ឌិប៊ីចារ៉ាកាន់)*

**tabuh** /តាប៊ុះ/ *n* គោះ: *គោះស្គរជាមួយនឹងសូត្រ memukul tabuh sambil bertakbir (មើមូគុល តាប៊ុះ សាំប៊ីល ប៊ឺរ(r)តាក់ប៊ីរ(r));*

**menabuh** /មើណាំប៊ុះ/ *v* គោះ: *គាត់តែងតែគោះស្គរនៅពេលយប់ dia selalu menabuh kendang di malam hari (ឌីយ៉ា សឺឡាលូ មើណាប៊ុះ កិនដាំង ឌិ ម៉ាឡាំ ហារី)*

**tabung, tabung oksigen** /តាប៊ុង, តាប៊ុង អុកស៊ីហ្គេន/ បំពង់អុកស៊ីសែន: *ខ្ញុំបានទិញបំពង់អុកស៊ីសែន aku membeli tabung oksigen (អាគូ ម៉ើមបើលី តាប៊ុង អុកស៊ីហ្គេន);*

**menabung** /មើណាប៊ុង/ *v* សន្សំ: *ខ្ញុំសន្សំប្រាក់នៅធនាគារនោះ aku menabung di bank itu (អាគូ ម៉ើណាប៊ុង ឌិបាំង អ៊ីទូ);*

**tabungan** /តាប៊ុង,តាប៊ូង៉ាន់/ *n* ការសន្សំ: *ការប្រាក់សន្សំ bunga tabungan (ប៊ូង៉ា តាប៊ូង៉ាន់)*

**tabur** /តាប៊ូរ(r)/ *v* សាបព្រួស: *សាបព្រួស tabur bunga (តាប៊ូរ(r) ប៊ូង៉ា);*

**bertaburan** /បើរ(r)តាប៊ូរ៉ាន់/ *v* ខ្ចាត់ខ្ចាយ: *បាវស៊ីម៉ងត៍បានរហែក ហើយស៊ីម៉ងត៍បានខ្ចាត់ខ្ចាយពាសពេញលើកម្រាលក្នុងឃ្លាំង sak semennya pecah dan isinya bertaburan di lantai gudang (សាក់ សឺម៉ែនញ៉ា ពើចះ ដាន់ អ៊ីស៊ីញ៉ា ពើរ(r)តាប៊ូរ៉ាន ឌិ ឡាន់តៃ ហ្គូដាំង)*

**tadi** /តាឌិ/ *n* អម្បាលមិញ:

*ទើអ្នកណាទើបមកដល់អម្បាលមិញ siapa yang datang tadi? (ស៊ីយ៉ាប៉ា យ៉ាំង ដាតាំង តាឌិ)*

**tafsir** /តាហ្វស៊ីរ(r)/ *n* ការបកប្រែ:

*ការបកប្រែយល់សប្តិ tafsir mimpi (តាហ្វសីរ(r) មីមពី);*

**menafsirkan** /មើណាហ្វស៊ីរ(r)កាន់/ *v* បកប្រែ:
